# មាតិកា


អារម្ភកថារបស់រដ្ឋមន្ត្រីក្រសួងកិច្ចការនារី .......... គ
អង្គការដែលឧបត្ថម្ភដល់ការសិក្សាស្រាវជ្រាវ .......... ង
សេចក្តីថ្លែងអំណរគុណ .......... ឆ
ដែនកំណត់នៃការសិក្សាស្រាវជ្រាវ .......... ជ
អក្សរកាត់ .......... ឈ
បញ្ជីឈ្មោះតារាង .......... ញ
គោលបំណងនៃការសិក្សាស្រាវជ្រាវ .......... ណ

## សេចក្តីសង្ខេប .......... ១

## ជំពូកទី១ សេចក្តីផ្តើម .......... ៧

១.១ រូបភាពគំរូនៅកម្ពុជា .......... ៧
១.២ អំពើហិង្សាប្រឆាំងនឹងស្ត្រីនៅកម្ពុជា .......... ១០
១.៣ និយមន័យ : អំពើហិង្សាប្រឆាំងនឹងស្ត្រី និងអំពើរំលោភសេពសន្ថវៈ .......... ១០
១.៤ អំពើហិង្សាក្នុងគ្រួសារនៅកម្ពុជា .......... ១១
១.៥ អំពើរំលោភសេពសន្ថវៈនៅកម្ពុជា .......... ១៣
១.៦ មធ្យោបាយដោះស្រាយតាមបែបប្រពៃណីចំពោះអំពើហិង្សាក្នុងគ្រួសារៈ ការផ្សះផ្សា និងការលែងលះគ្នា .......... ១៤
១.៧ ក្របខ័ណ្ឌច្បាប់បច្ចុប្បន្ន សំរាប់អំពើហិង្សាក្នុងគ្រួសារ នៅកម្ពុជា .......... ១៧
១.៨ ក្របខ័ណ្ឌគោលនយោបាយបច្ចុប្បន្ន សំរាប់អំពើហិង្សាក្នុងគ្រួសារ នៅកម្ពុជា .......... ២១

## ជំពូកទី២ លទ្ធផលនៃការសិក្សាស្រាវជ្រាវ .......... ២៥

### ២.១ អំពើហិង្សាលើរាងកាយ .......... ២៦

២.១.១ ឥរិយាបថ ចំពោះអំពើហិង្សាក្នុងគ្រួសារ .......... ២៦
២.១.២ បទពិសោធន៍ទទួលរងគ្រោះដោយសារអំពើហិង្សាក្នុងគ្រួសារ .......... ៣៧
២.១.៣ ផលប៉ះពាល់នៃអំពើហិង្សាផ្លូវកាយដែលប្រព្រឹត្តិដោយសហព័ទ្ធ .......... ៤៨
២.១.៤ ការប្រើគ្រឿងស្រវឹង ដែលបណ្តាលឱ្យមានអំពើហិង្សាក្នុងគ្រួសារ .......... ៥៤

### ២.២ ការបំពានផ្លូវចិត្ត .......... ៥៩

២.២.១ ការខឹងរបស់បុរស .......... ៥៩
២.២.២ ឥរិយាបថត្រួតត្រា .......... ៦២

**២.៣ អំពើរំលោភសេពសន្ថវៈ និងអំពើរំលោភសេពសន្ថវៈ ក្នុងចំណោងអាពាហ៍ពិពាហ៍ ....................................៧១**
២.៣.១ អំពើរំលោភសេពសន្ថវៈ ជាទូទៅ....................................................................៧១
២.៣.២ អំពើរំលោភសេពសន្ថវៈ ក្នុងចំណងអាពាហ៍ពិពាហ៍..............................................៧៤
**២.៤ ការស្វែងរកជំនួយ..................................................៨១**
២.៤.១ ជំរើសដែលមានក្នុងការស្វែងរកជំនួយ ...........................................................៨១
២.៤.២ ការស្វែងរកជំនួយសំរាប់អំពើរំលោភសេពសន្ថវៈ ..............................................៨២
២.៤.៣ ការស្វែងរកជំនួយសំរាប់ករណីបំពានផ្សេងៗទៀត .............................................៨៥
២.៤.៤ បទពិសោធន៍ផ្ទាល់ខ្លួនរបស់អ្នកផ្តល់ចំលើយ ក្នុងការស្វែងរកជំនួយ.........................៨៧
២.៤.៥ បទពិសោធន៍ ក្នុងការលែងលះ.......................................................................៨៩
**២.៥ អាជ្ញាធរមូលដ្ឋាន និងប៉ូលីស ................................ ៩៣**
២.៥.១ ឥរិយាបថរបស់អាជ្ញាធរមូលដ្ឋាន និងប៉ូលីសអំពីអំពើហិង្សាក្នុងគ្រួសារ.................៩៣
២.៥.២ ទស្សនៈរបស់អាជ្ញាធរមូលដ្ឋាន និងប៉ូលីសចំពោះការស្វែងរកជំនួយ.....................៩៧
២.៥.៣ ទស្សនៈរបស់អាជ្ញាធរមូលដ្ឋាន និងប៉ូលីសចំពោះស្ថានភាពផ្លូវច្បាប់នៃ អំពើហិង្សាក្នុងគ្រួសារ ....................................................................................៩៧
២.៥.៤ ឥរិយាបថរបស់អាជ្ញាធរមូលដ្ឋាន និងប៉ូលីសចំពោះការខឹងរបស់បុរស ................. ៩៨
២.៥.៥ ទស្សនៈរបស់អាជ្ញាធរមូលដ្ឋាន និងប៉ូលីសចំពោះឥទ្ធិពលនៃវប្បធម៌ទៅលើបុរស .. ៩៨
២.៥.៦ បទពិសោធន៍របស់អាជ្ញាធរមូលដ្ឋាន និងប៉ូលីសចំពោះអំពើហិង្សាក្នុងគ្រួសារ.........៩៩
**២.៦ ប្រជាពលរដ្ឋកម្ពុជា និងសិទ្ធិរបស់ពួកគេ .....................១០៧**
២.៦.១ សិទ្ធិមួយចំនួនដែលត្រូវបានចាត់ទុកថាជាសិទ្ធិសំខាន់ចំពោះប្រជាពលរដ្ឋកម្ពុជា .. ១០៧
២.៦.២ ទស្សនៈវិស័យស្តីអំពីវិសមភាព ............................................................... ១០៨
២.៦.៣ ការស្វែងរកជំនួយ ដើម្បីការពារសិទ្ធិ.........................................................១១០
២.៦.៤ សិទ្ធិកាន់កាប់ដីធ្លី.......................................................................................១១១
២.៦.៥ ទស្សនៈរបស់អាជ្ញាធរមូលដ្ឋាន និងប៉ូលីសចំពោះសិទ្ធិរបស់បុគ្គលម្នាក់ៗ ..........១១១

**ជំពូកទី ៣ សេចក្តីសន្និដ្ឋាន.................................. ១១៣**
**ឧបសម្ព័ន្ធA: តារាង ............................................. ១១៩**
**ឧបសម្ព័ន្ធB: វិធីសាស្ត្រ ......................................... ១៥១**
**ឧបសម្ព័ន្ធC: កំរងសំណួរនៃការអង្កេត ............................១៥៧**

បញ្ជីឈ្មោះ និងឯកសារយោង...........................................................................១៩៧

# អារម្ភកថា

*របស់លោកជំទាវ រដ្ឋមន្ត្រី ក្រសួងកិច្ចការនារី នៃព្រះរាជាណាចក្រកម្ពុជា*

អំពើហិង្សាក្នុងគ្រួសារ កើតឡើងយ៉ាងខ្លាំងក្លានៅទូទាំងប្រទេសកម្ពុជា។ អំពើហិង្សាក្នុងគ្រួសារមានការប៉ះទង្គិចយ៉ាងធ្ងន់ធ្ងរដល់ការរស់នៅ និងការអភិវឌ្ឍន៍នៃស្ត្រីរាប់ពាន់នាក់នៅកម្ពុជា។ ស្ត្រីទាំងនេះបានរងរបួសយ៉ាងធ្ងន់ធ្ងរខាងរាងកាយ ការឈឺចាប់យ៉ាងខ្លាំង បាត់បង់ចំណូល និងមានការលំបាកយ៉ាងខ្លាំងផ្នែកសុខភាព និងសុខុមាលភាព។ ទាំងនេះគឺមានការប៉ះពាល់ដល់សមត្ថភាពធ្វើការរបស់ពួកគេ និងប៉ះពាល់ដល់ការរកចំណូលសំរាប់ផ្គត់ផ្គង់គ្រួសារ។ ហើយនៅទីបញ្ចប់ គឺប៉ះពាល់ដល់គ្រួសារពួកគេទាំងមូល។

ជាអកុសល អំពើហិង្សាក្នុងគ្រួសារត្រូវបានគេចាត់ទុកថាជាបញ្ហាក្នុងគ្រួសារ មិនមែនជាបញ្ហាសង្គម ឬបញ្ហាសាធារណៈទេ។ ស្ត្រីជាច្រើនទ្រាំនឹងបញ្ហានេះដោយចាត់ទុកថាជារឿងធម្មតាមួយក្នុងជីវិតរបស់ពួកគេ។ ជនរងគ្រោះជាច្រើនមិនចង់និយាយប្រាប់ពីរឿងអសោចរបស់ពួកគេប្រាប់អ្នកក្រៅឡើយ ហើយជំនួយសំរាប់ជនរងគ្រោះគឺមិនគ្រប់គ្រាន់ដោយសារខ្វះសេវាផ្គត់ផ្គង់ និងដោយសារអ្នកក្រៅពុំចង់ជួយជនរងគ្រោះ។ ករណីជាច្រើនពុំត្រូវបានគេរាយការណ៍ ហើយជនរងគ្រោះជាច្រើនមិនស្នើសុំជំនួយ ឬប្តឹងជនល្មើស។

ប្រទេសកម្ពុជាមានបញ្ហាប្រឈមមុខជាច្រើន។ ដោយសារថាជាងពាក់កណ្តាលនៃប្រជាពលរដ្ឋគឺជាស្ត្រី ទើបប្រទេសជាតិទាំងមូលត្រូវការការចូលរួមរបស់ពួកគេនៅគ្រប់វិស័យ។ ស្ត្រីត្រូវការចាំបាច់នូវការបង្កើនភាពអង់អាចនៅគ្រប់ទិដ្ឋភាពនៃជីវិត ដើម្បីឈោងចាប់នូវអ្វីដែលស្ត្រីត្រូវការ និងដើម្បីឱ្យប្រទេសកម្ពុជាឈានទៅដល់ប្រទេសមួយដែលមានសក្តានុពលពេញលេញ។

អំពើហិង្សាក្នុងគ្រួសារ គឺជាឧបសគ្គមួយក្នុងចំណោមឧបសគ្គជាច្រើននៅក្នុងសង្គមកម្ពុជា។ ដើម្បីដោះស្រាយបញ្ហានេះ យើងចាំបាច់ត្រូវយល់អោយបានច្បាស់ជាងមុនអំពីឥរិយាបថរបស់ប្រជាពលរដ្ឋខ្មែរ ក៏ដូចជាកាលៈទេសៈទាំងឡាយដែលទាក់ទងនឹងអំពើហិង្សាក្នុងគ្រួសារ។ ការសិក្សានេះពិនិត្យលើកត្តាជាច្រើន ដូចជាការយល់ដឹងពីអំពើហិង្សាក្នុងគ្រួសារ និងអត្ថប្រយោជន៍នៃការជួយជនរងគ្រោះ ដោយសារអំពើហិង្សាក្នុងគ្រួសារ។ ការសិក្សានេះផ្តល់នូវព័ត៌មានជាបន្ទាន់ និងទាន់ពេលដល់អ្នករៀបចំគោលនយោបាយ មន្ត្រីកម្មវិធី អ្នកដឹកនាំសហគមន៍ និងអ្នកផ្សេងៗទៀត។ ការសិក្សានឹងជួយផ្តល់នូវទិសដៅសំរាប់ការរៀបចំកម្មវិធី និងអន្តរាគមន៍ឱ្យមានប្រសិទ្ធភាព និងចុងក្រោយគឺផ្តល់នូវដំណោះស្រាយដែលផ្តល់ផលប្រយោជន៍ដល់សង្គមកម្ពុជាទាំងមូល។

ការអង្កេតនេះ នឹងមិនអាចធ្វើទៅបានទេ បើគ្មានការជួយគាំទ្រពីរាជរដ្ឋាភិបាលកម្ពុជា និងអ្នកផ្តល់ជំនួយផ្សេងទៀតនៅកម្ពុជា ក៏ដូចជាសហគមន៍អន្តរជាតិ។ តាងនាមឱ្យរាជរដ្ឋាភិបាលកម្ពុជា ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់បណ្តាអង្គការនានា ដែលបានជួយផ្តល់ថវិកា និងដំណើរការការសិក្សាស្រាវជ្រាវនេះ។ ក្រសួងសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់អង្គការ GTZ[១] កម្មវិធីអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រី (អនុសញ្ញាស៊ីដ) របស់អង្គការមូលនិធិអភិវឌ្ឍន៍សហប្រជាជាតិដើម្បីស្ត្រី (យូនីហ្វេម) យូនីហ្វេមនៅអាស៊ីអាគ្នេយ៍[២] គំរោងលើកស្ទួយសិទ្ធិមនុស្សនៃវិទ្យាស្ថានគ្រប់គ្រងខាងកើត ខាងលិច[៣] និងក្រុមហ៊ុនស្រាវជ្រាវតណ្ហចិន ដែលបានចូលរួមយ៉ាងសំខាន់ជាមួយយើងខ្ញុំក្នុងកិច្ចខិតខំប្រឹងប្រែង ដើម្បីបញ្ចប់អំពើហិង្សាក្នុងគ្រួសារនៅកម្ពុជា។

**លោកជំទាវ វេជ្ជ. អ៊ឹង កន្ថាផាវី**
**រដ្ឋមន្ត្រី**



១ ជំនួយថវិកាដោយក្រសួងអភិវឌ្ឍន៍ និងកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចអាល្លឺម៉ង់

២ ជំនួយថវិកាដោយទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិកាណាដា

៣ ជំនួយថវិកាដោយ USAID

# អង្គការដែលបានឧបត្ថម្ភដល់ការសិក្សាស្រាវជ្រាវ

*ជំនួយថវិកាសំរាប់ការសិក្សាស្រាវជ្រាវនេះ គឺផ្តល់ដោយអង្គការអន្តរជាតិដូចខាងក្រោមៈ*

## អង្គការកិច្ចសហប្រតិបត្តិការបច្ចេកទេសអាល្លឺម៉ង់ (GTZ)
## គំរោងលើកកំពស់សិទ្ធិស្ត្រី

គំរោងលើកកំពស់សិទ្ធិស្ត្រី គឺជាគំរោងទ្វេភាគីដែលអនុវត្តដោយក្រសួងកិច្ចការនារី និងអង្គការ GTZ ។ គោលបំណងនៃគំរោងនេះ គឺកសាងសមត្ថភាពក្របខ័ណ្ឌក្រសួងកិច្ចការនារី ដើម្បីឱ្យក្រសួងអាចអនុវត្តច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ហើយគោលបំណងនៃគំរោងនេះផងដែរ គឺដើម្បីកំណត់រកអង្គការនានា ដើម្បីអនុវត្តផែនការសកម្មភាពជាតិប្រឆាំងអំពើហិង្សាក្នុងគ្រួសារ នៅក្នុងផ្នែកសេវាសង្គមកិច្ច និងយុទ្ធនាការផ្សព្វផ្សាយ ។ គំរោងនេះផងដែរ គឺដើម្បីបញ្ជ្រាបយេនឌ័រទៅក្នុងប្រព័ន្ធច្បាប់តាមរយៈការផ្តល់អនុសាសន៍ នៅក្នុងដំណើរការធ្វើសេចក្តីព្រាងច្បាប់ ។ គំរោងនេះទទួលជំនួយថវិកាពីក្រសួងអភិវឌ្ឍន៍ និងសហប្រតិបត្តិការសេដ្ឋកិច្ចអាល្លឺម៉ង់ ។

## គំរោងលើកស្ទួយសិទ្ធិមនុស្សនៅកម្ពុជានៃវិទ្យាស្ថានគ្រប់គ្រងខាងកើត ខាងលិច (HRCP EWMI)

គំរោងលើកស្ទួយសិទ្ធិមនុស្សនៅកម្ពុជា (HRCP) ផ្តោតលើវិធាននៃច្បាប់ ការគ្រប់គ្រង និងជាគំរោងសិទ្ធិមនុស្សដែលភ្នាក់ងារអាមេរិកដើម្បីការអភិវឌ្ឍន៍អន្តរជាតិ ផ្តល់ឱ្យទៅវិទ្យាស្ថានគ្រប់គ្រងខាងកើត ខាងលិច ។ គោលដៅនៃគំរោងលើកស្ទួយសិទ្ធិមនុស្សនៅកម្ពុជា (HRCP) គឺដើម្បីលើកកំពស់ និងពង្រឹងចលនាសិទ្ធិមនុស្សនៅកម្ពុជាឱ្យមានប្រសិទ្ធភាពជាងមុនសំរាប់ការលើកស្ទួយ និងការការពារសិទ្ធិមនុស្ស ។ គំរោងលើកស្ទួយសិទ្ធិមនុស្សនៅកម្ពុជា (HRCP) ព្យាយាមធ្វើឱ្យប្រសើរឡើងនូវលទ្ធភាពរបស់អង្គការសិទ្ធិមនុស្សដែលជាអង្គការក្រៅរដ្ឋាភិបាល និងក្រុមពាក់ព័ន្ធនានា ធ្វើយ៉ាងណាឱ្យសកម្មភាពតស៊ូមតិមាននិរន្តរ៍ភាព ធ្វើឱ្យប្រសើរឡើងនូវការទទួលបានយុត្តិធម៌ និងកសាងសមត្ថភាពក្នុងការពង្រឹងសិទ្ធិមនុស្សនៅក្នុងផ្នែក ច្បាប់ និងចលនាសិទ្ធិមនុស្ស ។ គំរោងក៏ជួយផងដែរនូវជំនួយផ្នែកច្បាប់ដល់ជនក្រីក្រ ក្រុមងាយទទួលរងគ្រោះ និងប្រជាពលរដ្ឋដែលរស់នៅជនបទ ។

## កម្មវិធីអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រី (ស៊ី ដ) របស់អង្គការ មូលនិធិអភិវឌ្ឍន៍សហប្រជាជាតិដើម្បីស្ត្រី (យូនីហ្វេម) ប្រចាំអាស៊ីអាគ្នេយ៍

ការងាររបស់អង្គការយូនីហ្វេម គឺលើកកំពស់សមភាពយេនឌ័ររវាងស្ត្រី និងបុរស និងលើកកំពស់ស្ថានភាពរបស់ស្ត្រី។ ជាពិសេសអង្គការយូនីហ្វេម ផ្តោតលើការអនុវត្តន៍ផែនការសកម្មភាពនៅទីក្រុងប៉េកាំង និងការប្តេជ្ញាចិត្តជាសកលរបស់អង្គការសហប្រជាជាតិ តាមរយៈការបង្កើនភាពអង់អាចដល់ស្ត្រីក្នុងផ្នែកសេដ្ឋកិច្ច និងនយោបាយ និងតាមរយៈការបង្កើនឱ្យមានការទទួលស្គាល់យ៉ាងពេញលេញអំពីសិទ្ធិស្ត្រី។ គោលបំណងនៃកម្មវិធី ស៊ី ដ នៅអាស៊ីអាគ្នេយ៍ គឺដើម្បីបង្កើនការយល់ដឹងអំពីសិទ្ធិស្ត្រីជាសិទ្ធិមនុស្ស និងបង្កើនការយល់ដឹងអោយកាន់តែជ្រាលជ្រៅអំពីអនុសញ្ញា ស៊ី ដ។ ការងាររបស់កម្មវិធី គឺបង្កើនការយល់ដឹងអំពីតម្រូវការចាំបាច់នូវសកម្មភាព ដើម្បីធានាឱ្យបាននូវសិទ្ធិរបស់ស្ត្រីដែលមានចែងនៅក្នុងអនុសញ្ញា និងកសាងសមត្ថភាព និងការប្តេជ្ញាចិត្តផ្នែកនយោបាយក្នុងការអនុវត្តន៍ និងត្រួតពិនិត្យអនុសញ្ញា ស៊ី ដ។ គំរោងនេះទទួលបានថវិកាឧបត្ថម្ភពីជំនួយអភិវឌ្ឍអន្តរជាតិរបស់ប្រទេសកាណាដា (CIDA)។

អង្គការកិច្ចសហប្រតិបត្តិការបច្ចេកទេសអាល្លឺម៉ង់ (GTZ) វិទ្យាស្ថានគ្រប់គ្រងខាងកើត ខាងលិច (EWMI) និងអង្គការយូនីហ្វេម បានសហការជាមួយក្រសួងកិច្ចការនារី ដែលក្រសួងត្រូវបានបង្កើតឡើងដើម្បីដឹកនាំ និងគ្រប់គ្រងកិច្ចការស្ត្រី និងលើកកំពស់ស្ថានភាពស្ត្រី។ ក្រសួងគឺជាអ្នកជំរុញ និងជាអ្នកស្វែងរកការគាំទ្រមតិ ដើម្បីជំរុញឱ្យស្ថាប័នសាធារណៈ សង្គមស៊ីវិល និងផ្នែកឯកជន បញ្ចូលសមភាពយេនឌ័រ ទៅក្នុងគោលនយោបាយ និងកម្មវិធីរបស់ពួកគេ ហើយក្រសួងគឺជាអ្នកសំរបសំរួលផងដែរ។ តំណាងឱ្យស្ត្រីកម្ពុជា ក្រសួងក៏ទទួលខុសត្រូវផងដែរក្នុងការត្រួតពិនិត្យ និងវាយតំលៃគោលនយោបាយ និងកម្មវិធីដើម្បីប៉ាន់ប្រមាណអំពីការចូលរួមចំណែករបស់គោលនយោបាយ និងកម្មវិធីទាំងនេះ ក្នុងការសំរេចឱ្យបាននូវគោលដៅរបស់រាជរដ្ឋាភិបាលស្តីពីសមភាពយេនឌ័រ។

# សេចក្តីថ្លែងអំណរគុណ

ការសិក្សាស្រាវជ្រាវនេះបានរៀបចំឡើង ដោយផ្អែកលើការងាររបស់អង្គការនានានៅក្នុងប្រទេសកម្ពុជា ក៏ដូចជាបណ្តាអង្គការនៅក្រៅប្រទេស។ ការសិក្សា និងរបាយការណ៍នានាដែលអង្គការទាំងនេះមាន គឺមានសារៈសំខាន់ក្នុងការរៀបចំការសិក្សាស្រាវជ្រាវនេះ: ដូចជាការសិក្សាស្រាវជ្រាវរបស់អង្គការប្រឆាំងអំពើហិង្សាក្នុងគ្រួសារ (PADV) ក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា (CDP) អង្គការការពារសិទ្ធិមនុស្សលីកាដូ (LICADHO) អង្គការកម្ពុជាដើម្បីជួយស្ត្រីមានវិបត្តិ (CWCC) អង្គការយេនឌ័រ និងអភិវឌ្ឍន៍ដើម្បីកម្ពុជា (GAD) សេវាសង្គមកិច្ចកម្ពុជា (SSC) និងអង្គការយូនីហ្វេម កម្មវិធីស្តីពីការលុបបំបាត់អំពើហិង្សាប្រឆាំង និងស្ត្រី (UNIFEM EVAW)។

របាយការណ៍នេះគឺជាលទ្ធផលមួយដែលបានមកពីការជួយពីស្ថាប័ន និងអង្គការជាច្រើន។ ការស្រាវជ្រាវត្រូវបានគ្រោង និងអនុវត្តដោយក្រុមហ៊ុនស្រាវជ្រាវឥណ្ឌូចិន (IRL) ដែលជាក្រុមហ៊ុនស្រាវជ្រាវឯកជនមួយផ្តល់សេវាស្រាវជ្រាវនៅកម្ពុជាតាំងពីឆ្នាំ១៩៩៧។ ក្រុមហ៊ុននេះបានរៀបចំឧបករណ៍ស្រាវជ្រាវនានា ដោយមានការពិគ្រោះយោបល់ជាមួយអ្នកផ្តល់ជំនួយ រៀបចំអ្នកដែលត្រូវសម្ភាស ដំណើការសម្ភាស និងធ្វើរបាយការណ៍អំពីលទ្ធផលនៃការសិក្សាស្រាវជ្រាវនេះ។ របាយការណ៍នេះត្រូវបានចងក្រង និងសរសេរដោយ Catherine Cecil។ តារាងសំណួរ និងការរចនាសៀវភៅរៀបចំដោយ Christine Schmutzler។ បកប្រែជាភាសាខ្មែរដោយ សាយ សំភា ជា ហ៊ីង កក់ កណ្ណិកា សុត្រី ហួណេ ឃុន រតនា និង ញ៉ែម រស្មី។ គំរោងទាំងមូលនឹងមិនអាចដំណើរការទៅបានទេ បើគ្មានការណែនាំ និងគាំទ្រយ៉ាងពេញទំហឹងពី Susanne Muller។

សូមថ្លែងអំណរគុណជាពិសេសដល់ Mariolein Coren និង ញ៉ែម រស្មី ដែលបានផ្តល់ការបណ្តុះបណ្តាលអំពីអំពើហិង្សាក្នុងគ្រួសារដល់អ្នកធ្វើសម្ភាស និងជួយពិនិត្យការបកប្រែ និងការប្រើពាក្យនៅក្នុងតារាងសំណួរ ហើយក៏សូមថ្លែងអំណរគុណផងដែរដល់ Ellen Minotti ដែលបានជួយបង្កើនការយល់ដឹងអំពីអំពើហិង្សាប្រឆាំងនិងស្ត្រីដល់អ្នកធ្វើសម្ភាស។ អង្គការយេនឌ័រ និងអភិវឌ្ឍន៍ដើម្បីកម្ពុជា បានផ្តល់ការបណ្តុះបណ្តាលអំពីយេនឌ័រដល់អ្នកធ្វើសម្ភាស។ អង្គការផ្តល់ជំនួយក៏សូមថ្លែងអំណរគុណផងដែរដល់ Ingrid FitzGerald និង Stefano Magistretti ដែលបានជួយណែនាំពីវិធីសាស្ត្រ និងការបកស្រាយអំពីលទ្ធផលដែលទទួលបាន។ អ្នករៀបចំ និងអង្គការផ្តល់ជំនួយក៏សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់ Elaine McKay, Kate Frieson, Mehrak Mehrvar, Stefanie Lux, Helen Keane និង Ellen Minotti ដែលបានផ្តល់នូវគំនិតល្អៗដល់ការសិក្សាស្រាវជ្រាវនេះ។

អង្គការអ្នកផ្តល់ជំនួយសូមផ្ញើជូនរបាយការណ៍នេះដល់ស្ត្រី បុរស និងក្មេងៗដែលទទួលរងនូវការបំពាន ដោយសង្ឃឹមថារបាយការណ៍នេះនឹងជួយក្នុងការកាត់បន្ថយការប្រព្រឹត្តអំពើហិង្សានាពេលអនាគត។

## ដែនកំណត់នៃការសិក្សាស្រាវជ្រាវ

អំពើហិង្សាក្នុងគ្រួសារ គឺជាបញ្ហាដែលតែងតែបន្សល់នូវស្លាកស្នាមនៅក្នុងជីវិត ហើយអ្នកដែលជួបរឿងរ៉ាវបែបនេះមានការលំបាកក្នុងការលើកយករឿងនេះមកពិភាក្សាណាស់ ជាពិសេសគឺយកមកពិភាក្សាជាមួយអ្នកសម្ភាសដែលពួកគាត់ពុំស្គាល់។ ហេតុដូច្នេះហើយ អ្នកស្រាវជ្រាវធ្វើការប៉ាន់ប្រមាណថាប្រជាជន អាចនឹងពុំផ្តល់ព័ត៌មានអោយបានអស់អំពីបទពិសោធន៍របស់ពួកគាត់ឡើយ ហើយការផ្តល់ព័ត៌មានបែបនេះ អាចប៉ះពាល់ដល់លទ្ធផលនៃការស្រាវជ្រាវនេះផងដែរ។ លើសពីនេះទៅទៀត ទោះបីជាមានសំណួរជាច្រើនត្រូវបានសួរទៅប្រជាពលរដ្ឋនៅក្នុងក្រុមធំ ប៉ុន្តែក៏មានសំណួរមួយចំនួនត្រូវបានសួរទៅលើក្រុមតូច ឧទាហរណ៏ដូចជា ក្រុមដែលធ្លាប់មានបទពិសោធន៏ក្នុងអំពើហិង្សា។ ក្រុមតូចនេះពុំអាចតំណាងឱ្យប្រជាជនកម្ពុជាទាំងមូលនោះទេ។ ទោះបីជាអ្នកធ្វើសម្ភាសត្រូវបានគេបណ្តុះបណ្តាលអំពីអំពើហិង្សាក្នុងគ្រួសារ និងយេនឌ័រ ប៉ុន្តែការបណ្តុះបណ្តាលនៅមានកំរិត។ ចំណុចចុងក្រោយបង្អស់មួយទៀត គឺថាអាចមានកំហុសឆ្គង ក្នុងការកត់ត្រាចំលើយ ហេតុដូច្នេះហើយសូមប្រិយមិត្តអ្នកអានទាំងអស់ សូមមេត្តាជ្រាបអំពីដែនកំណត់និង កំហុសឆ្គងដែលអាចកើតមាននៅក្នុងការសិក្សាស្រាវជ្រាវនេះ។

# អក្សរកាត់

CDP ក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា

CEDAW អនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារី

CIDA ទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិរបស់ប្រទេសកាណាដា

CMDG គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា

CWCC អង្គការកម្ពុជាដើម្បីជួយស្ត្រីមានវិបត្តិ

DV អំពើហិង្សាក្នុងគ្រួសារ

ERM សាលាភូមិន្ទចៅក្រម និងព្រះរាជអាជ្ញា

EWMI វិទ្យាស្ថានគ្រប់គ្រងខាងកើត និងខាងលិច

GAD អង្គការយេនឌ័រ និងអភិវឌ្ឍន៍ដើម្បីកម្ពុជា

GTZ អង្គការកិច្ចសហប្រតិបត្តិការបច្ចេកទេសអាល្លឺម៉ង់

IOM អង្គការអន្តរជាតិដើម្បីជនអន្តោប្រវេសន៍

IRL ក្រុមហ៊ុនស្រាវជ្រាវឥណ្ឌូចិន

JICA ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន

J4P ភាពយុត្តិធម៌សំរាប់ជនក្រីក្រ

LICADHO អង្គការការពារសិទ្ធិមនុស្ស លីកាដូ

LPWGP កម្មវិធីការពារផ្លូវច្បាប់ដល់ស្ត្រី និងកុមារី

MoI ក្រសួងមហាផ្ទៃ

MoJ ក្រសួងយុត្តិធម៌

MoSVYR ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

MoWA ក្រសួងកិច្ចការនារី

NAP ផែនការសកម្មភាពជាតិសំរាប់ការអនុវត្តន៍ច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ

NGO អង្គការក្រៅរដ្ឋាភិបាល

PADV អង្គការប្រឆាំងអំពើហិង្សាក្នុងគ្រួសារ

PWR គំរោងលើកកំពស់សិទ្ធិស្ត្រី

RGC រាជរដ្ឋាភិបាលកម្ពុជា

SSC អង្គការសេវាសង្គមកិច្ចកម្ពុជា

TAF មូលនិធិអាស៊ី

ToR លក្ខខណ្ឌការងារ

UNDP កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ

UNFPA មូលនិធិប្រជាជនសហប្រជាជាតិ

UNICEF មូលនិធិសហប្រជាជាតិដើម្បីកុមារ

UNIFEM មូលនិធិអភិវឌ្ឍន៍សហប្រជាជាតិដើម្បីស្ត្រី

USAID ទីភ្នាក់ងារអាមេរិកដើម្បីអភិវឌ្ឍន៍អន្តរជាតិ

# បញ្ជីឈ្មោះតារាង

តារាងទាំងនេះ បង្ហាញនូវចំលើយចំពោះសំណួរនៅក្នុងការអង្កេត។ រាល់សំណួរទាំងអស់ត្រូវបានសួរទៅប្រជាពលរដ្ឋក្នុងក្រុមទូទៅ លើកលែងតែករណីមួយចំនួន។


**តារាងទី១:** សំណួរទី ៨ a – *តើទទួលយកបានឬទេ ចំពោះប្តីប្រព្រឹត្តអំពើនេះទៅលើប្រពន្ធ? ទំព័រទី ២៧*

តារាងទី២: សំណួរទី ៨ b – *តើស្ថិតក្រោមកាលៈទេសៈណាខ្លះ ដែលប្តីសមហេតុសមផលក្នុងការប្រព្រឹត្ត អំពើនេះ ចំពោះប្រពន្ធ? ទំព័រទី ២៩*

តារាងទី៣: សំណួរទី ១១, ៨ a – *តាមគំនិតរបស់អ្នក តើអំពើទាំងនេះណាមួយដែលជាអំពើឧក្រិដ្ឋ? ថាតើទទួលយកបានឬទេចំពោះ ប្តីប្រព្រឹត្តអំពើនេះទៅលើប្រពន្ធ? ទំព័រទី ៣២*

តារាងទី៤: សំណួរទី ១១, ៨ a (បែងចែកតាមយេនឌ័រ) – *ទំព័រទី ៣៣*

តារាងទី៥: សំណួរទី ៣៣ a – *តើ (កត្តា) អ្វីខ្លះខាងក្រោមនេះជាឥទ្ធិពលលើការប្រព្រឹត្តរបស់បុរសទាំង អស់នោះ? ទំព័រទី ៣៤*

តារាងទី៦: សំណួរទី ៣៣ b – *តើ (កត្តា) អ្វីខ្លះខាងក្រោមនេះជាឥទ្ធិពលនៃការប្រព្រឹត្តរបស់ស្ត្រី? ទំព័រទី ៣៥*

តារាងទី៧: សំណួរទី ១១, ៨ a, ១២ a, ១៦ a – *តើទទួលយកបានឬទេចំពោះ ប្តីប្រព្រឹត្តអំពើនេះទៅ លើប្រពន្ធ? តើអំពើទាំងនេះណាមួយ ដែលជាអំពើឧក្រិដ្ឋ? តើខ្លួនអ្នកផ្ទាល់ដឹង/ស្គាល់ថា មាន ស្ត្រីណាខ្លះដែល ប្តីបានប្រព្រឹត្តអំពើដូចខាងក្រោមនេះទៅលើប្រពន្ធរបស់គាត់ដែរឺទេ? ហើយចុះប្តី ឬប្រពន្ធរបស់អ្នក ធ្លាប់បានប្រព្រឹត្តអំពើទាំងនេះទៅលើខ្លួនអ្នកដែរឬទេ? ទំព័រទី ៣៨*

តារាងទី៨: សំណួរទី ១២ b – *តើកាលៈទេសៈខាងក្រោមនេះណាខ្លះដែលប្តីប្រព្រឹត្តអំពើទាំងនោះទៅលើប្រពន្ធរបស់គាត់? ទំព័រទី ៤០*

តារាងទី៩: សំណួរទី ១៦ a , ៣៤ a, b – *ហើយចុះប្តីឬប្រពន្ធរបស់អ្នកធ្លាប់បានប្រព្រឹត្តអំពើទាំងនេះទៅលើខ្លួនអ្នកដែរឬទេ? តើអ្នកធ្លាប់បានឃើញឪពុករបស់អ្នកវាយដំម្តាយរបស់អ្នកទេ? ហើយ តើអ្នកធ្លាប់បានឃើញម្តាយរបស់អ្នកវាយដំឪពុករបស់អ្នកទេ? ទំព័រទី ៤២*

តារាងទី១០: សំណួរទី ១៧ b – *តើនរណាដែលបានធ្វើដូចនោះ? ទំព័រទី ៤៤*

តារាងទី១១: សំណួរទី ១៥ a , ៣៤ a, b – *តើអ្នក, ខ្លួនអ្នកផ្ទាល់ ធ្លាប់បានប្រព្រឹត្តអំពើទាំងនេះទៅលើ ប្តី ឬប្រពន្ធ របស់អ្នកដែរទេ? តើអ្នកធ្លាប់បានឃើញឪពុករបស់អ្នកវាយដំម្តាយរបស់អ្នកទេ? ហើយ តើអ្នកធ្លាប់បានឃើញម្តាយរបស់អ្នកវាយដំឪពុករបស់អ្នកទេ? ទំព័រទី ៤៧*

តារាងទី១២: សំណួរទី ១៩ a - *តើអ្វីខាងក្រោមនេះណាខ្លះ ធ្លាប់បានកើតឡើងចំពោះអ្នក? ទំព័រទី ៤៩*

តារាងទី១៣: សំណួរទី ២០ a - *តើអ្នកធ្លាប់មានទទួលរងគ្រោះថ្នាក់អ្វីខ្លះ ដូចខាងក្រោមនេះ? ទំព័រទី ៥២*

តារាងទី១៤: សំណួរទី ២០ b -*តើអ្នកធ្លាប់មានទទួលរងគ្រោះថ្នាក់អ្វីខ្លះ ដូចខាងក្រោមនេះ? ទំព័រទី ៥៣*

តារាងទី១៥: សំណួរទី ១៧ a - *តើអ្នកធ្លាប់ផឹកស្រា ឬ ស្រាបៀរដែរឬទេ?*

តារាងទី១៦: សំណួរទី ១៧ b -*តើប្តី ឬប្រពន្ធរបស់អ្នកធ្លាប់ផឹកស្រា ឬ ស្រាបៀរដែរឬទេ? ទំព័រទី ៥៤*

តារាងទី១៧: សំណួរទី ១៦ a បន្តពី ៧ b -*ហើយចុះប្តីឬប្រពន្ធអ្នកធ្លាប់បាន ប្រព្រឹត្តអំពើទាំងនេះទៅលើខ្លួនអ្នកដែរឬទេ? តើប្តី ឬប្រពន្ធរបស់អ្នកធ្លាប់ផឹកស្រា ឬ ស្រាបៀរដែរឬទេ? ទំព័រទី ៥៥*

តារាងទី១៨: សំណួរទី ១៥ a បន្តពី ៧ a - *តើអ្នក, ខ្លួនអ្នកផ្ទាល់ ធ្លាប់បានប្រព្រឹត្តអំពើទាំងនេះទៅលើប្តី ឬប្រពន្ធរបស់អ្នកដែរទេ? តើអ្នកធ្លាប់ផឹកស្រា ឬស្រាបៀរដែរឬទេ? ទំព័រទី ៥៦*

តារាងទី១៩: សំណួរទី ២១ a - តើប្តីមានភាពសមហេតុផលក្នុងការខឹងក្នុងកាលៈទេសៈដូចខាងក្រោមដែរឬទេ? *ទំព័រទី ៦១*

តារាងទី២០: សំណួរទី ២១ b - *តើអ្នកគិតថាប្តីត្រូវមានភាពសមហេតុផលត្រឹមត្រូវក្នុងការប្រព្រឹត្តអំពើដាក់ប្រពន្ធដូចខាងក្រោមដែរឬទេ? ទំព័រទី ៦៣*

តារាងទី២១: សំណួរទី ៣១ a - *ប្រសិនបើការរំលោភសេពសន្ថវៈត្រូវបានប្រព្រឹត្តឡើងដោយមនុស្សខាងក្រោមនេះ, តើអ្នកគិតថាវានឹងត្រូវផ្តន្ទាទោសយ៉ាងណាដែរ? ទំព័រទី ៧៣*

តារាងទី២២: សំណួរទី ២៧ c -*តើក្នុងកាលៈទេសៈណាដែលប្រពន្ធមានភាពសមហេតុផលត្រឹមត្រូវក្នុងការបដិសេធការរួមភេទជាមួយប្តីរបស់គាត់? ទំព័រទី ៧៦*

តារាងទី២៣: សំណួរទី ៣៥ a - *នៅក្នុងឃុំ ឬ ភូមិរបស់អ្នក, សេវាដែលអាចមានខាងក្រោមនេះណាខ្លះដែលអាចជួយដោះស្រាយបញ្ហាដែលយើង កំពុងតែពិភាក្សាគ្នានេះ? ទំព័រទី ៨២*

តារាងទី២៤: សំណួរទី ៣២ c - *តើស្ត្រីនោះមានបានធ្វើអ្វីទេ បន្ទាប់ពីបានកើតរឿងនេះឡើង? ទំព័រទី ៨៣*

តារាងទី២៥: សំណួរទី ១៦ c - *តើអ្នកបានធ្វើអ្វីខ្លះដើម្បីបញ្ឈប់អំពីខាងលើ? ទំព័រទី ៨៦*

តារាងទី២៦: សំណួរទី ៣៨ a - *តើខ្លួនអ្នកផ្ទាល់ធ្លាប់ស្វែងរកជំនួយពីភ្នាក់ងារខាងក្រោមនេះចំពោះបញ្ហាទាំងនេះដែរឬទេ? ទំព័រទី ៨៨*

តារាងទី២៧: សំណួរទី ៣៨ a - *តើខ្លួនអ្នកផ្ទាល់ធ្លាប់ស្វែងរកជំនួយពីភ្នាក់ងារខាងក្រោមនេះចំពោះបញ្ហាទាំងនេះដែរឬទេ? ទំព័រទី ៨៩*

តារាងទី២៨: សំណួរទី ៨ b (សំណួរសំរាប់អាជ្ញាធរមូលដ្ឋាន និងប៉ូលីស) - *តើស្ថិតក្រោមកាលៈទេសៈខាងក្រោមនេះណាខ្លះដែលប្តីសមហេតុសមផលក្នុងការប្រព្រឹត្តអំពើនេះចំពោះប្រពន្ធ? ទំព័រទី ៩៦*

តារាងទី២៩: សំណួរទី ១៨ a,c (សំណួរសំរាប់អាជ្ញាធរមូលដ្ឋាន និងប៉ូលីស) - *តើអ្វីខ្លះខាងក្រោមនេះជាឥទ្ធិពលនៃការប្រព្រឹត្តរបស់បុរសទាំងអស់នោះ? ទំព័រទី ៩៩*

តារាងទី៣០: សំណួរទី ២៤ (សំណួរសំរាប់អាជ្ញាធរមូលដ្ឋាន និងប៉ូលីស) - *នៅក្នុង១២ខែកន្លងទៅនេះ តើករណីចំនួនប៉ុន្មានដែលបានកើតមាននៅក្នុង ឃុំ/សង្កាត់/ស្រុករបស់អ្នកនៅពេលដែលស្ត្រីបានប្តឹងទៅប៉ូលិស/អាជ្ញាធរ?ទំព័រទី ១០០*

តារាងទី៣១: សំណួរទី ២៧ a,b (សំណួរសំរាប់អាជ្ញាធរមូលដ្ឋាន និងប៉ូលីស) - *តើករណីមួយណាខ្លះក្នុងចំណោមករណីខាងក្រោមទាំងនេះកើតឡើងញឹកញាប់កំរិតណាដែរ? ទំព័រទី ១០១*

តារាងទី៣២: សំណួរទី ៣២ a (សំណួរសំរាប់អាជ្ញាធរមូលដ្ឋាន និងប៉ូលីស) - *ការដាក់ចំណាត់ថ្នាក់ចំពោះស្ថានភាពអំពើហិង្សាចាប់ពី "មិនពេញចិត្តទាល់តែសោះ" ដល់ "ពេញចិត្តខ្លាំងណាស" ទំព័រទី ១០២*

តារាងទី៣៣: សំណួរទី ២២ (សំណួរសំរាប់អាជ្ញាធរមូលដ្ឋាន និងប៉ូលីស) - *ការដាក់ចំណាត់ថ្នក់ចំពោះបញ្ហាច្បាប់ និងសណ្តាប់ធ្នាប់ចាប់ពី "មិនសំខាន់ទាល់តែសោះ" ដល់ "សំខាន់ខ្លាំងណាស់" ទំព័រទី ១០៣*

តារាងទី៣៤: សំណួរទី ៤០ a - *តាមគំនិតរបស់អ្នក តើអ្វីខ្លះជាសិទ្ធិដ៏សំខាន់បំផុតដែលពលរដ្ឋមាន? ទំព័រទី ១០៧*

តារាងទី៣៥: សំណួរទី ៤០ e - *តើបុរសមានសិទ្ធិផ្សេងពីស្ត្រីដែលឬទេ? ទំព័រទី ១០៩*

តារាងទី៣៦: សំណួរទី ៤០ f - *តើមានសិទ្ធិទាំងនោះមានអ្វីខ្លះ? ទំព័រទី ១០៩*

តារាងទី៣៧: សំណួរទី ៤១ b - *តើមាននរណាម្នាក់នៅក្នុងសហគមន៍របស់អ្នកអាចជួយអ្នកអោយទទួលបានសិទ្ធិរបស់អ្នកដែរឬទេ? ទំព័រទី ១១០*

តារាងទី៣៨: សំណួរទី ៩ a - *តើវាជាការដែលទទួលយកបានដែរឬទេ នៅពេលដែលប្រពន្ធប្រព្រឹត្តអំពើនេះទៅលើប្តី? ទំព័រទី ១១៩*

តារាងទី៣៩: សំណួរទី ១១ - *តើអំពើទាំងនេះណាមួយ ដែលជាអំពើឧក្រិដ្ឋ? ទំព័រទី ១២០*

តារាងទី៤០: សំណួរទី ១២ a(ចំណាត់ថ្នាក់) - *តើខ្លួនអ្នកផ្ទាល់ដឹង/ស្គាល់ថាមាន ស្ត្រីណាខ្លះដែលប្តីបានប្រព្រឹត្តអំពើដូចខាងក្រោមនេះទៅលើប្រពន្ធរបស់គាត់ដែររឺទេ? ទំព័រទី ១២១*

តារាងទី៤១: សំណួរទី ១២ a(ភាគរយ) - *តើខ្លួនអ្នកផ្ទាល់ដឹង/ស្គាល់ថាមាន ស្ត្រីណាខ្លះដែលប្តីបានប្រព្រឹត្តអំពើដូចខាងក្រោមនេះទៅលើប្រពន្ធរបស់គាត់ដែររឺទេ? ទំព័រទី ១២២*

តារាងទី៤២: សំណួរទី ១៤ c – តើមនុស្សដែលប្រព្រឹត្តអំពើទាំងនោះ អាចធ្វើអ្វីដើម្បីបញ្ឈប់ការប្រព្រឹត្តអំពើរបស់ខ្លួន? តើពួកគេបានធ្វើអ្វីដែរ? ទំព័រទី ១២៣

តារាងទី៤៣: សំណួរទី ១៥ b – តើរយៈពេល ១២ ខែចុងក្រោយមកនេះអ្នកធ្លាប់បានប្រព្រឹត្តអំពើទាំងនេះចំនួនប៉ុន្មានដង? ទំព័រទី ១២៤

តារាងទី៤៤: សំណួរទី ១៥ c – តើមានអ្វីដែលអាចបញ្ឈប់អ្នកបាន ពីការប្រព្រឹត្តនូវអំពើទាំងនេះ? ទំព័រទី ១២៥

តារាងទី៤៥: សំណួរទី ១៦ a – ហើយចុះប្តី ឬប្រពន្ធរបស់អ្នកធ្លាប់បានប្រព្រឹត្តអំពើទាំងនេះទៅលើខ្លួនអ្នកដែរឬទេ? ទំព័រទី ១២៦

តារាងទី៤៦: សំណួរទី ១៦ b – តើរយៈពេល ១២ ខែចុងក្រោយមកនេះ ប្តី ឬប្រពន្ធអ្នកធ្លាប់បានប្រព្រឹត្តអំពើទាំងនេះចំនួនប៉ុន្មានដង? ទំព័រទី ១២៧

តារាងទី៤៧: សំណួរទី ១៨ a – តើអ្នកបានធ្វើអ្វីខ្លះដើម្បីបញ្ឈប់អំពើខាងលើ? ទំព័រទី ១២៨

តារាងទី៤៨: សំណួរទី ២២ a – តើប្រពន្ធអាចធ្វើអ្វី ប្រសិនបើប្តីរបស់គាត់ប្រព្រឹត្តដូចនេះ? ទំព័រទី ១២៩

តារាងទី៤៩: សំណួរទី ២៣ b – ហើយតើខ្លួនអ្នកផ្ទាល់ដឹង/ជួបប្រទះនឹងករណីដែលប្តីបានប្រព្រឹត្តដូចខាងក្រោមទៅកាន់ប្រពន្ធដែរឬទេ? ទំព័រទី ១៣០

តារាងទី៥០: សំណួរទី ២៥ a – តើខ្លួនអ្នកផ្ទាល់ដែលធ្លាប់មិនសប្បាយចិត្តឬខឹងខ្លាំងជាមួយប្រពន្ធរបស់អ្នកនៅកាលៈទេសៈខាងក្រោមនេះណាខ្លះដែរឬទេ? ទំព័រទី ១៣១

តារាងទី៥១: សំណួរទី ២៥ b – តើអ្នកធ្លាប់ធ្វើអ្វីខ្លះខាងក្រោមនេះដែរឬទេ? ទំព័រទី ១៣២

តារាងទី៥២: សំណួរទី ២៥ c – តាមគំនិតរបស់អ្នក, តើមានអ្វីអាចបញ្ឈប់អ្នកពីការធ្វើដូច្នេះ? ទំព័រទី ១៣៣

តារាងទី៥៣: សំណួរទី ២៦ a – តើប្តីរបស់អ្នកដែលធ្លាប់មិនសប្បាយចិត្ត ឬខឹងខ្លាំងជាមួយអ្នកនៅកាលៈទេសៈខាងក្រោមនេះណាខ្លះដែរឬទេ? ទំព័រទី ១៣៤

តារាងទី៥៤: សំណួរទី ២៦ b – តើប្តីរបស់អ្នកធ្លាប់ធ្វើអ្វីខ្លះខាងក្រោមនេះដែរឬទេ? ទំព័រទី ១៣៥

តារាងទី៥៥: សំណួរទី ២៦ c – ប្រសិនបើប្តីរបស់អ្នកប្រព្រឹត្តដូចនេះ តើអ្នកធ្វើអ្វីខ្លះដែរ? ទំព័រទី ១៣៦

តារាងទី៥៦: សំណួរទី ២៧ d – តើស្ត្រីម្នាក់អាចធ្វើអ្វីបាន ប្រសិនបើនាងត្រូវបានប្តីបង្ខំអោយរួមភេទដែលផ្ទុយនឹងឆន្ទៈរបស់នាង? ទំព័រទី ១៣៧

តារាងទី៥៧: សំណួរទី ២៩ b – តើនាងបានធ្វើអ្វី? ទំព័រទី ១៣៨

តារាងទី៥៨: សំណួរទី ៣២ b – តើអ្នកចាប់រំលោភសេពសន្ថវៈនោះជានរណាដែរ? ទំព័រទី ១៣៩

តារាងទី៥៩: សំណួរទី ៣២ d – ហើយតើបានជាលទ្ធផលអ្វីខ្លះ? ទំព័រទី ១៤០

តារាងទី៦០: សំណួរទី ៣៦ a-b – ហើយប្រសិនបើមានស្ត្រីនៅក្នុងភូមិឃុំរបស់អ្នកធ្លាប់ទទួលរងគ្រោះថ្នាក់ដោយសារបញ្ហាទាំងនេះ, តើនាងទំនងជាមកជួបភ្នាក់ងារទាំងនេះដើម្បី ស្វែងរកជំនួយនិងការគាំទ្រដែរឬទេ? ទំព័រទី ១៤១

តារាងទី៦១: សំណួរទី ៣៧ b –តើស្ត្រីស្វែងរកការលែងលះនៅឯណា? ទំព័រទី ១៤២

តារាងទី៦២: សំណួរទី ៣៩ a - *ហើយក្នុងករណីមានរឿងខាងក្រោមនេះកើតឡើង,តើអ្នកធ្លាប់ស្វែងរកការលែងលះគ្នាដែរទេ? ទំព័រទី ១៤៣*
តារាងទី៦៣: សំណួរទី ៤០ c - *ក្នុងសហគមន៍របស់អ្នក,តើមានមនុស្សខ្លះមានសិទ្ធិច្រើនជាងមនុស្សដទៃទៀតដែរឬទេ? ទំព័រទី ១៤៤*
តារាងទី៦៤: សំណួរទី ៤០ d - *តើពួកគេជានរណា? ទំព័រទី ១៤៤*
តារាងទី៦៥: សំណួរទី ៨ a (សំណួរសំរាប់អាជ្ញាធរមូលដ្ឋាន និងប៉ូលីស) -*តើអាចទទួលយកបានឬទេចំពោះ ប្តីប្រព្រឹត្តអំពើនេះទៅលើប្រពន្ធ? ទំព័រទី ១៤៥*
តារាងទី៦៦: សំណួរទី ៩ a (សំណួរសំរាប់អាជ្ញាធរមូលដ្ឋាន និងប៉ូលីស) - *តើវាទទួលយកបានឬទេចំពោះប្រពន្ធប្រព្រឹត្តអំពើនេះទៅលើប្តីប្រពន្ធ? ទំព័រទី ១៤៦*
តារាងទី៦៧: សំណួរទី ១០ a (សំណួរសំរាប់អាជ្ញាធរមូលដ្ឋាន និងប៉ូលីស) - *តើមនុស្សម្នាក់អាចធ្វើអ្វីបានខ្លះ ប្រសិនបើប្តី ឬ ប្រពន្ធរបស់ពួកគេប្រព្រឹត្តអំពើដូច្នេះ? ទំព័រទី ១៤៧*
តារាងទី៦៨: សំណួរទី ១១ c (សំណួរសំរាប់អាជ្ញាធរមូលដ្ឋាន និងប៉ូលីស) - *តាមគំនិតរបស់អ្នកតើអំពើ ទាំងនេះណាមួយ ដែលជាអំពើឧក្រិដ្ឋ? ទំព័រទី ១៤៨*
តារាងទី៦៩: សំណួរទី ៣០ a (សំណួរសំរាប់អាជ្ញាធរមូលដ្ឋាន និងប៉ូលីស) - *តាមគំនិតរបស់អ្នកតើមានមនុស្សខ្លះក្នុងសហគមន៍របស់អ្នកមានសិទ្ធិច្រើនជាងមនុស្សដទៃទៀតដែរឬទេ? ទំព័រទី ១៤៩*

## គោលបំណង

ការអង្កេតនេះធ្វើឡើងដើម្បីផ្តល់ព័ត៌មានសំរាប់ការពិភាក្សា និងការធ្វើសេចក្តីសំរេចស្តីពីអំពើហិង្សាក្នុងគ្រួសារ និងសំរាប់កម្មវិធីសង្គមផ្សេងទៀតរបស់អ្នកពាក់ព័ន្ធសំខាន់ៗ មានដូចជារាជរដ្ឋាភិបាលកម្ពុជា អ្នកផ្តល់ជំនួយ តុលាការ និងប៉ូលីស អ្នកជំនាញការផ្នែកច្បាប់ វិទ្យាស្ថានផ្សេងៗ អ្នកស្រាវជ្រាវ និងសង្គមស៊ីវិលទាំងមូល ។

វិធីសាស្ត្រ និងរចនាសម្ព័ន្ធទូទៅនៃការអង្កេតនេះគឺត្រូវបានរៀបចំឡើងសំរាប់យកទៅប្រើបន្តទៀតនៅក្នុងការអង្កេតតាមដែលអាចធ្វើទៅបាន បន្តពីការអង្កេតរបស់អង្គការ PADV ដែលធ្វើនៅឆ្នាំ ១៩៩៦[៤] ដើម្បីធ្វើការប្រៀបធៀបលទ្ធផល ។ ជាពិសេសការអង្កេតនេះវាស់វែងទៅលើប្រភេទនៃអំពើហិង្សា គឺដូចគ្នាអំពើហិង្សាផ្លូវកាយ និងដោយពាក្យសំដី ( ប្រភេទនៃឥរិយាបថមានដូចជា ការជះទឹកអាស៊ីត ការចាក់ និងបាញ់ ការចោលអ្វីមួយទៅលើនរណាម្នាក់ ការស្រែកជេរបណ្តាសា) ដូចគ្នាទៅនិងប្រភេទដែលអង្គការ PADV[៥] បានប្រើ ។

ទោះជាយ៉ាងណាក៏ដោយ ការអង្កេតនេះធ្វើឡើងដោយមានការខុសប្លែកខ្លះ ។ ការអង្កេតនេះធ្វើទៅលើក្រុមមនុស្សតំណាង១ក្រុម នៅក្នុងខេត្តចំនួន១៣ ។ ក្នុងការអង្កេតនេះមានអ្នកតំណាងពីរក្រុមគឺ ក្រុមដែលមានចំនួន៣០០០នាក់ ដែលបានជ្រើសរើសសំរាប់តំណាងឱ្យប្រជាពលរដ្ឋទូទៅ និង ៣០០នាក់ សំរាប់តំណាងឱ្យអាជ្ញាធរដែនដី ដោយធ្វើការជ្រើសរើសក្នុងខេត្តនិមួយៗ និងដោយចៃដន្យ[៦] ។ របៀបនៃការជ្រើសរើសអ្នកតំណាង គឺមានច្រើនដំណាក់កាល ហើយចែកជាក្រុម ។ ពិស្តាលំអិតនៃវិធីសាស្ត្រនៃការសិក្សានេះ មាននៅក្នុងឧបសម្ព័ន្ធ B ។ ការស្រាវជ្រាវរបស់អង្គការ PADV ក្នុងឆ្នាំ១៩៩៦ គឺធ្វើនៅក្នុងតែរាជធានី និង៦ខេត្ត-ក្រុងតែប៉ុណ្ណោះ (ប្រហែល ៥៩% នៃអត្រាប្រជាជនកម្ពុជាទូទៅនាពេលនោះ) ។ លើសពីនេះការសិក្សានេះ រាប់បញ្ចូលទាំងការរំលោភសេពសន្ថវៈ និងការរំលោភសេពសន្ថវៈក្នុងចំណោងអាពាហ៍ពិពាហ៍ ដែលខុសគ្នាពីការអង្កេតរបស់អង្គការ PADV ។

---

[៤] Nelson, Erin and Zimmerman, Cathy (១៩៩៦) ការអង្កេតគ្រួសារស្តីពីអំពើហិង្សាក្នុងគ្រួសារនៅកម្ពុជា ភ្នំពេញ: អង្គការប្រឆាំងអំពើហិង្សាក្នុងគ្រួសារ "PADV" និងក្រសួងកិច្ចការនារី) ។

[៥] ការសិក្សា PADV និងការសិក្សាថ្មីៗនេះបានផ្តោតទៅលើឥរិយាបថ ដូចខាងក្រោម: ការពិភាក្សាដោយ សៀមសាត់ ការស្រែក ការជេរប្រមាថ ការគប់វត្ថុអ្វីៗទៅលើអ្នកដទៃ ការរុញច្រាន ការកព
ការទាត់ ការខាំ ការទាញគ្រវី ការបោចសក់ ឬដាល់ ការប៉ុនប៉ងវាយធ្វើបាប ការព្យាយាមវាយនឹងវត្ថុអ្វីមួយ ការវាយហើយវាយទៀត (ទាត់ធាក់គ្មានត្រាប្រណី) គំរាមកំហែង នឹងកាំបិត ឬកាំភ្លើង ពូថៅ ឬកាំបិតវែង) ការដុត ឬខ្ទប់មាត់ឱ្យថប់ ជះទឹកអាស៊ីត ការចាក់ ឬបាញ់ ។

[៦] ប្រភពអ្នកតំណាង គឺអ្នកឆ្លើយតបសម្ភាស ៣០០០នាក់ តំណាងឱ្យប្រជាជនទូទៅ និង៣០០នាក់ ជាអាជ្ញាធរដែនដី និងប៉ូលីស ។
ទោះជាយ៉ាងណាក៏ដោយ ធាតុពិតក្រុមស្រាវជ្រាវបានសម្ភាស ៣០៣០នា
និងប៉ូលីស ដើម្បីធ្វើឱ្យប្រាកដថា ពួកគេបានបំពេញតាមចំនួនកំណត់នៃការធ្វើសម្ភាសន៍ពិតប្រាកដមែន ។ ចំនួននៃការធ្វើសម្ភាសន៍ដែលធ្វើទៅតាមសំណួរនីមួយៗ គឺមាននៅក្នុងតារាងចំលើយ ។

ការអង្កេតនេះធ្វើឡើងដើម្បីជាមូលដ្ឋានក្នុងការតាមដានការវិវឌ្ឍន៍នាពេលខាងមុខ។ ដូច្នេះហើយ ការអង្កេតនេះប្រមូលផ្តុំទិន្នន័យយ៉ាងទូលំទូលាយពីការសម្ភាសន៍ក្រុមធំ តំណាងឱ្យប្រជាពលរដ្ឋទាំងអស់ និងក្រុមតូចតំណាងឱ្យអាជ្ញាធរដែនដី និងប៉ូលីស។ អំពើហិង្សាមានការទាក់ទងយ៉ាងស្មុគស្មាញជាមួយនឹងកត្តាមួយចំនួន ដូចជាកត្តាវប្បធម៌ សង្គម និងសេដ្ឋកិច្ច ហើយប្រទេសដែលមានប្រពៃណីទំនៀមទំលាប់ និងប្រវត្តិសាស្ត្រអំពីឋានានុក្រមយេនឌ័រដូចប្រទេសកម្ពុជា គឺអាចមានការលំបាកក្នុងការស្វែងយល់ និងដោះស្រាយកត្តាទាំងនេះ។ ដូច្នេះហើយការអង្កេតនេះ បានប្រើវិធីសាស្ត្រផ្សេងៗដើម្បីខិតទៅជិតបញ្ហា និងដើម្បីសំរេចឱ្យបាននូវគោលបំណងដូចខាងក្រោមៈ

- បង្កើតទិន្នន័យមូលដ្ឋានដើម្បីវាស់វែងការយល់ដឹង ឥរិយាបថ និងការអនុវត្តន៍ពាក់ព័ន្ធនឹងអំពើហិង្សាប្រឆាំងនិងស្ត្រី។ ឧបករណ៍ និងដែនកំណត់នៃការសិក្សាស្រាវជ្រាវនេះអាចយកទៅប្រើនៅក្នុងការសិក្សាស្រាវជ្រាវក្រោយទៀត ដើម្បីត្រួតពិនិត្យនិន្នាការនៃអំពើហិង្សាក្នុងគ្រួសារ និងវាយតំលៃលើការឆ្លើយតបរបស់រដ្ឋាភិបាល និងទីភ្នាក់ងារផ្សេងទៀត។
- បង្កើតនូវមូលដ្ឋានចំណេះដឹងថ្មីៗ ស្តីពីបរិបទនៃអំពើហិង្សា ដែលទីភ្នាក់ងារអ្នកផ្តល់ជំនួយ និងរដ្ឋាភិបាលអាចយកទៅប្រើ ដើម្បីប៉ាន់ប្រមាណអំពីស្ថានភាពបច្ចុប្បន្ន ក្នុងទស្សនវិស័យនៃការសំរេចបាននូវគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជ (គ.អ.ស.ក)។
- ផ្តល់នូវការយល់ដឹងអំពីវប្បធម៌ និងទស្សនៈរបស់សង្គមកម្ពុជា និងយុទ្ធសាស្ត្រកែប្រែទំនៀមទំលាប់ និងឥរិយាបថតឹងរឹងមួយចំនួន ដែលជាឧបសគ្គក្នុងការអភិវឌ្ឍន៍របស់ស្ត្រីកម្ពុជា។ ជាក់ស្តែង ការសិក្សាស្រាវជ្រាវនេះធ្វើឡើងដើម្បីស្វែងរករូបភាពគ្រប់ជ្រុងជ្រោយលើកត្តាដូចខាងក្រោមៈ
- ទិន្នន័យជាតួលេខច្បាស់លាស់ ដែលទាក់ទងទៅនឹងការយល់ដឹង និងបទពិសោធន៍ដោយផ្ទាល់ ឬ ដោយប្រយោលរបស់អ្នកផ្តល់ចំលើយ និងអំពើហិង្សាប្រឆាំងនឹងស្ត្រី។
- ទិន្នន័យអំពីអំពើហិង្សា ដែលកើតឡើងនៅក្រៅក្រុមគ្រួសារ ដូចជាអំពើហិង្សា ដែលប្រព្រឹត្តដោយមិត្តភក្តិ មនុស្សខាងក្រៅ ប៉ូលីស និងទាហាន។
- ការយល់ដឹងពិស្តារអំពីគំនិតនិងឥរិយាបថរបស់ក្រុមមនុស្សតំណាងដែលរួមបញ្ចូលទាំងតារាងឥរិយាបថលើរាងកាយ និងដោយពាក្យសំដី ហើយមានទាំងអំពើរំលោភសេពសន្ថវៈ និងការរំលោភក្នុងចំណងអាពាហ៍ពិពាហ៍ រួមទាំងឥរិយាបថថាតើការប្រើអំពើហិង្សា ត្រូវចាត់ទុកថាជាអំពើពុំអាចទទួលយកបាននៅក្នុងសង្គម ឬជាបទឧក្រិដ្ឋ និងឥរិយាបថចំពោះបុព្វហេតុផលនៃអំពើហិង្សា។
- ឥទ្ធិពលនៃអំពើហិង្សាទៅលើសង្គម ជាពិសេសការខាតបង់ដោយប្រយោល (ខាតពេលវេលា បាត់បង់ប្រាក់ចំណូល បាត់បង់ឱកាស ។ល។) និងការខាតបង់ដោយផ្ទាល់ ថ្លៃថ្នាំ ថ្លៃប៉ូលីស ថ្លៃតុលាការ ។ល។)
- ការប៉ាន់ប្រមាណសេវាកម្មដែលមានស្រាប់សំរាប់ជនរងគ្រោះដោយសារអំពើហិង្សា គុណភាពនៃសេវាកម្ម និងការយល់ដឹងរបស់សាធារណជនអំពីសេវាកម្មទាំងនោះ។
- ទម្រង់ច្បាស់លាស់នៃប្រវត្តិរបស់អ្នកផ្តល់ចំលើយ។ ទម្រង់បែបនេះនឹងជួយក្នុងការបែងចែកឥរិយាបថចំពោះអំពើហិង្សា។

# ១. សេចក្តីសង្ខេប

អំពើហិង្សាប្រឆាំងនឹងស្ត្រី មិនត្រឹមតែប៉ះពាល់យ៉ាងធ្ងន់ធ្ងរលើស្ត្រីដែលទទួលរងគ្រោះនោះទេ គឺថែមទាំងប៉ះពាល់ដល់សង្គមជាតិ និងសេដ្ឋកិច្ចផងដែរ ។ ដើម្បីដោះស្រាយបញ្ហាអំពើហិង្សាក្នុងគ្រួសារនៅកម្ពុជា រាជរដ្ឋាភិបាលបានកំណត់យកការកាត់បន្ថយអំពើហិង្សាក្នុងគ្រួសារ ជាការងារអាទិភាព ។ គោលដៅ ទី ៣ នៃគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា គឺ "ការលើកកំពស់សមភាពយេនឌ័រ និងការបង្កើនភាពអង់អាចដល់ស្ត្រី" ។ ចំណុចដៅទី ៨ នៅក្នុងគោលដៅនេះគឺ "កាត់បន្ថយរាល់ទម្រង់នៃអំពើហិង្សាលើស្ត្រី និងកុមារ" វិទ្យាស្ថានគ្រប់គ្រងខាងកើត និង ខាងលិច អង្គការយូនីហ្វេមគំរោងលើកកំពស់សិទ្ធិស្ត្រីនៃអង្គការជីធីហ្សិត (GTZ) រួមសហការជាមួយក្រសួងកិច្ចការនារី បានផ្តួចផ្តើមរៀបចំការសិក្សាស្រាវជ្រាវនេះដើម្បីប្រមូលព័ត៌មានសំរាប់ធ្វើការប៉ាន់ប្រមាណអំពីស្ថានភាព និងរៀបចំដំណោះស្រាយឱ្យមានប្រសិទ្ធភាព ។ អំពើហិង្សាប្រឆាំងនឹងស្ត្រីនៅកម្ពុជាគឺជាប្រធានបទនៃការសិក្សាអស់រយៈពេល ១០ឆ្នាំ មកហើយ ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយការសិក្សាស្រាវជ្រាវនេះគឺជាអង្កេតថ្នាក់ជាតិទីមួយ ដែលផ្តោតលើឥរិយាបថចំពោះអំពើហិង្សាក្នុងគ្រួសារ ។

ការសិក្សាស្រាវជ្រាវនេះផ្តល់នូវទិន្នន័យជាមូលដ្ឋានស្តីពីឥរិយាបថ និង ប្រេវ៉ាឡង់នៃអំពើហិង្សាក្នុងគ្រួសារ ដើម្បីជួយក្នុងការត្រួតពិនិត្យការងាររីកចំរើនរបស់រដ្ឋាភិបាលក្នុងការអនុវត្តន៍ គ.អ.ស.ក ។ ការសិក្សាស្រាវជ្រាវបានពិនិត្យលើបរិបទ និងឥរិយាបថចំពោះអំពើហិង្សាក្នុងគ្រួសារ ។ ហេតុដូច្នេះហើយ ការសិក្សាស្រាវជ្រាវបានផ្តោតលើកត្តាជាច្រើន ដែលពាក់ព័ន្ធយ៉ាងខ្លាំងក្នុងការរៀបចំកម្មវិធី និងអន្តរាគមន៍ផ្សេងៗ ។ ការសិក្សាស្រាវជ្រាវនេះនឹងជួយរដ្ឋាភិបាលក្នុងការរៀបចំគោលនយោបាយ និងយុទ្ធសាស្ត្រក្នុងការលើកកំពស់សមភាពយេនឌ័រ ។

អំពើហិង្សាក្នុងគ្រួសារនៅកម្ពុជាកើតឡើងនៅក្នុងរង្វង់នៃបរិបទស្មុគស្មាញនៃឥរិយាបថ និងការឱ្យតំលៃអំពីតួនាទីយេនឌ័រ ទំនាក់ទំនងសង្គម និងអំពើហិង្សាទូទៅ ។ ជាទូទៅទោះបីជាអ្នកផ្តល់ជំនួយ រដ្ឋាភិបាល និងអង្គការក្រៅរដ្ឋាភិបាលបានធ្វើការងារច្រើនក្នុងការកាត់បន្ថយអំពើហិង្សាក្នុងគ្រួសារចាប់តាំងពីអង្គការ PADV ចេញផ្សាយរបាយការណ៍ឆ្នាំ ១៩៩៦ ក៏ដោយក៏ស្ថានភាពអំពើហិង្សាក្នុងគ្រួសារ ពុំមានលក្ខណៈល្អប្រសើរនៅឡើយ ។ ការសិក្សាស្រាវជ្រាវបានពិនិត្យលើកំរិតនៃអំពើហិង្សាក្នុងគ្រួសារ ក៏ដូចជាឥរិយាបថ និងផលប៉ះពាល់ដែលពាក់ព័ន្ធនឹងបញ្ហានេះដែរ ។ ការសិក្សាស្រាវជ្រាវនេះក៏បង្ហាញផងដែរនូវចំណុចស៊ីជំរៅនៃស្ថានភាពអំពើហិង្សាក្នុងគ្រួសាររាប់ទាំងចំណុចស្តីពីការទទួលយករបស់ស្ត្រីចំពោះអំពើហិង្សា ទស្សនៈដែលយល់ឃើញថា អំពើហិង្សាក្នុងគ្រួសារជាបញ្ហាឯកជន បញ្ហាគ្រួសារ និងផលប៉ះពាល់នៃអំពើហិង្សាទៅលើប្រជាពលរដ្ឋក្រីក្រ ។ លទ្ធផលសំខាន់ៗនៃការពិភាក្សាស្រាវជ្រាវនេះ មានដូចខាងក្រោម ។

## ឥរិយាបថ

- ការសិក្សាស្រាវជ្រាវបានបង្ហាញឱ្យឃើញ នូវការទទួលយកយ៉ាងខ្លាំងក្លាចំពោះអំពើហិង្សាក្នុងគ្រួសារ ក្នុងករណីមួយចំនួន ជាពិសេសករណីអំពើហិង្សាក្នុងគ្រួសារ ដែលកើតឡើងដោយប្តីធ្វើលើប្រពន្ធ និងការជឿជាក់ យ៉ាងខ្លាំងថាបុរសមានសិទ្ធិជាងស្ត្រី ។
- មានការយល់ឃើញជាទូទៅថា ការតវ៉ារបស់ប្រពន្ធអំពីការគ្រប់គ្រងរបស់ប្តី ឬសិទ្ធិរបស់ប្តីក្នុងការធ្វើអ្វីតាមចិត្តចង់ គឺជាហេតុផលដែលបណ្តាលឱ្យមានអំពើហិង្សាក្នុងគ្រួសារកាន់តែខ្លាំងឡើង ។ ជាងពាក់កណ្តាលនៃអ្នកផ្តល់ចំលើយបាននិយាយថា ឥរិយាបថរបស់ប្រពន្ធបែបនេះ គឺជាហេតុផលដែលបណ្តាលឱ្យមានអំពើហិង្សាកាន់តែធ្ងន់ធ្ងរអាចរហូតដល់ស្លាប់ ។
- ស្ត្រីច្រើនទទួលយកនូវអំពើហិង្សាជាងបុរស ។
- ឥរិយាបថទាំងនេះ គឺមិនកែប្រែ មិនមានការផ្លាស់ប្តូរទេ សូម្បីតែក្នុងចំណោមមនុស្សវ័យក្មេងក៏ដោយ ។
- ចំនុចខ្វះខាតនៃការអនុវត្តន៍ច្បាប់ គឺជាចំណុចដែលមានឥទ្ធិពលយ៉ាងខ្លាំងទៅលើឥរិយាបថរបស់បុរសចំពោះស្ត្រី ។ ចំណុចដែលមានឥទ្ធិពលសំខាន់ផ្សេងទៀតគឺគៀបសង្កត់ពីក្រុមមិត្តភ័ក្រ្ត ។

## បទពិសោធន៍

- ប្រហែល ៦៤% នៃអ្នកផ្តល់ចំលើយបានស្គាល់ប្តីជាអ្នកដែលប្រើអំពើហិង្សាលើប្រពន្ធ ហើយ ២២.៥% នៃអ្នកផ្តល់ចំលើយជាស្ត្រីបានទទួលអំពើហិង្សាពីប្តី ។ នេះគឺមានន័យថា ប្រេវ៉ាឡង់នៃអំពើហិង្សាប្រឆាំងនឹងស្ត្រី គឺមិនប្រែប្រួលទេ ចាប់តាំងពីអង្កេតរបស់អង្គការ PADV ឆ្នាំ ១៩៩៦ និង អង្កេតប្រជាសាស្រ្ត និងសុខភាពនៅកម្ពុជា CDHS ឆ្នាំ២000 ។
- ថ្វីបើមានភាពលំអៀងទៅលើស្ត្រីចំពោះការប្រើអំពើហិង្សាក៏ដោយ ក៏មានបុរស១២% បាននិយាយថា ប្រពន្ធរបស់ពួកគេបានប្រើអំពើហិង្សាលើពួកគេ ។
- ការអង្កេតបានបង្ហាញថា អំពើហិង្សាមានការពាក់ព័ន្ធយ៉ាងខ្លាំងជាមួយការប្រើគ្រឿងស្រវឹង និងទាក់ទងទៅនឹងការប្រើអំពើហិង្សាតគ្នាមកពីឪពុកម្តាយ ។

## ផលប៉ះពាល់នៃអំពើហិង្សាផ្លូវកាយ

- អំពើហិង្សាក្នុងគ្រួសារប៉ះពាល់យ៉ាងខ្លាំងដល់ផ្នែកសេដ្ឋកិច្ច ផ្លូវកាយ និង ផ្លូវចិត្តរបស់ជនរងគ្រោះ ។
- ជិតមួយភាគប្រាំនៃអ្នកផ្តល់ចំ [illegible] និយាយថា អំពើហ ពួកគេខកខានពុំបានធ្វើការ ។ អំពើហិង្សាបានបណ្តាលឱ្យ ១៦%នៃអ្នកផ្តល់ចំលើយ បាត់បង់ចំណូលប្រហែល ១ខែ ក្នុង ១ឆ្នាំ ។ អំពើហិង្សាក្នុងគ្រួសារកាន់តែមានការប៉ះពាល់យ៉ាងធ្ងន់ធ្ងរចំពោះគ្រួសារក្រីក្រ គឺពួកគេនិយាយថា ពួកគេបាត់បង់ប្រាក់ចំណូលចំនួនជិត ២ខែ កាលពីឆ្នាំមុន ។

- ជិតមួយភាគប្រាំ នៃអ្នកផ្តល់ចំលើយដែលទទួលរងអំពើហិង្សាពីសហព័ន្ធរបស់ខ្លួនបាននិយាយថា កូនរបស់ពួកគេមិនបានទៅរៀនពី ៥ ទៅ ២០ ដង ក្នុង ១២ខែចុងក្រោយនេះ។ ជាងនេះទៅទៀត ៧% នៃអ្នកផ្តល់ចំលើយដែលទទួលរងអំពើហិង្សាពីសហព័ទ្ធរបស់ខ្លួនបាននិយាយថា កូនរបស់ពួកគេមិនបានទៅរៀន ២០ដង ឬច្រើនជាងនេះ ក្នុងកំឡុងពេលមានអំពើហិង្សាក្នុងគ្រួសារ ។
- អ្នកផ្តល់ចំលើយទាំងនេះ ក៏បាននិយាយផងដែរអំពីការប៉ះពាល់លើសុខភាព និងសុខុមាលភាពរបស់ពួកគេ គឺរួមមានចាប់ពីការខឹងសម្បារ និងបញ្ហាផ្លូវកាយរហូតដល់ការភ័យខ្លាចធ្ងន់ធ្ងរ ។

## ការរំលោភបំពានផ្លូវចិត្ត

- អ្នកផ្តល់ចំលើយជាច្រើនបានដឹងថា ប្តីចាប់ខឹងនៅពេលដែលប្រពន្ធពុំបានបំពេញតួនាទីយេនឌ័រ[៧] របស់ពួកគេ ដូចជាពេលប្រពន្ធមិនមើលកូន ឬមិនធ្វើការផ្ទះ ឬចាយលុយដោយមិនបានប្រាប់ប្តី ។
- ស្រដៀងគ្នានេះដែរ ចំនួនភាគច្រើននៃអ្នកផ្តល់ចំលើយបានដឹងថា ប្តីព្យាយាមត្រួតត្រាប្រពន្ធតាមរយៈការត្រួតត្រាលើការស្លៀកពាក់ កន្លែងដែលប្រពន្ធទៅ និងមនុស្សដែលប្រពន្ធជួប ។
- ជាងពាក់កណ្តាលនៃអ្នកផ្តល់ចំលើយជាបុរស បាននិយាយថាឥរិយាបថទាំងនេះ គឺសមហេតុផល ។

## អំពើរំលោភសេពសន្ថវៈ

- អំពើរំលោភសេពសន្ថវៈត្រូវអរំ ធ ពនិឱ [illegible] ជាង
- ជាងមួយភាគបួន នៃអ្នកផ្តល់ចំលើយបានស្គាល់អ្នកដែលត្រូវគេរំលោភសេពសន្ថវៈ ហើយតួលេខក្នុងចំណោមអ្នកក្រីក្រគឺខ្ពស់ជាងនេះ ៤២% ។
- ភាគច្រើននៃជនល្មើសត្រូវបានអ្នកផ្តល់ចំលើយឆ្លើយថាជាសមាជិកគ្រួសារ ។
- អំពើរំលោភសេពសន្ថវៈ គឺជាករណីតែមួយគត់ដែលស្ត្រីស្វែងរកជំនួយ និងការផ្តន្ទាទោសជនល្មើស ។
- មានការគាំទ្រយ៉ាងខ្លាំងឱ្យមានការដាក់ទោសជាប់ពន្ធនាគាចំពោះអ្នកប្រព្រឹត្តបទរំលោភសេពសន្ថវៈនេះ ប៉ុន្តែមានការគាំទ្រតិចជាងនេះចំពោះការដាក់ទោសជាប់ពន្ធនាគារពីបទរំលោភសេពសន្ថវៈនៅពេលដែលជនល្មើសជាមិត្តប្រុស ឬសង្សារ[៨] ។
- លទ្ធផលជាទូទៅបំផុតនៃ [illegible] ជនល្មើស ។
- ទោះបីជាយ៉ាងណាក៏ដោយ ៣០% នៃករណីទាំងនេះត្រូវបានដោះស្រាយដោយការព្រមាន ឬគ្មានលទ្ធផលជាផ្លូវការនោះទេ ។

[៧] តួនាទីយេនឌ័រ រួមមានការថែទាំកូន និងផ្ទះសម្បែង ទុកឱ្យប្តីរបស់គាត់ធ្វើការសំរេចគ្រប់បែបយ៉ាង ហើយប្រពន្ធ គឺនៅផ្ទះ ។

[៨] នៅប្រទេសកម្ពុជា ពាក្យ "មិត្តប្រុស" ត្រូវបានគេប្រើដើម្បីនិយាយអំពីទំនាក់ទំនងមួយដែលកើតឡើងមុន រៀបការ និងពាក្យ "សង្សារ" ត្រូវបានគេ ប្រើដើម្បីនិយាយអំពីប្រភេទទំនាក់ទំនងមួយ ក្រោយរៀបការរួច (ឧទាហរណ៍: "ការរៀបការលើកទីពីរ") ដែលមិនមែនជាការរៀបការទីមួយ និងជា ប្រភេទទំនាក់ទំនងមួយ ជាមួយអ្នករកស៊ីផ្លូវភេទ ។

## អំពើរំលោភសេពសន្ថវៈក្នុងចំណងអាពាហ៍ពិពាហ៍

- ទោះបីជាមនុស្សភាគច្រើនយល់ឃើញថាប្តីពុំមានសិទ្ធិបង្ខំឱ្យប្រពន្ធរួមភេទក៏ដោយ ប៉ុន្តែការរំលោភសេពសន្ថវៈក្នុងចំណងអាពាហ៍ពិពាហ៍ ពុំត្រូវបានគេចាត់ទុកដូចជាអំពើរំលោភសេពសន្ថវៈដោយជនល្មើសផ្សេងទៀតឡើយ ។
- ប្រហែលជា ១៤% នៃអ្នកផ្តល់ចំលើយបានស្គាល់ប្រពន្ធមួយនាក់ដែលត្រូវប្តីបង្ខំឱ្យរួមភេទ ហើយតួលេខនេះបានឡើងរហូតដល់ ២៣%ក្នុងចំណោមប្រជាពលរដ្ឋក្រីក្រ ។
- មានការយល់ស្របក្នុងចំណោមអ្នកផ្តល់ចំលើយជាច្រើន ចំពោះមូលហេតុសំរាប់ប្រពន្ធក្នុង ការបដិសេធចំពោះប្តីរបស់ខ្លួន ។ជាង៣ភាគ៤នៃអ្នកផ្តល់ចំលើយបាននិយាយថា ស្ត្រីមានហេតុផលក្នុងការបដិសេធនឹងប្តី នៅពេលដែលនាងទើបតែឆ្លងទន្លេរួច ។ ប៉ុន្តែប្រហែលជាពាក់កណ្តាលប៉ុណ្ណោះដែលនិយាយថា ការខ្លាចឆ្លងជម្ងឺអេដស៍ពីប្តី គឺជាហេតុផលមួយដែរ ។
- អំពើរំលោភសេពសន្ថវៈក្នុងចំណងអាពាហ៍ពិពាហ៍គឺជាប្រធានបទដែលការអង្កេតនេះ បានយកចិត្តទុកដាក់បំផុត ហើយអង្កេតនេះបង្ហាញឱ្យឃើញថា អ្នកដែលបានស្វែងរកជំនួយមានចំនួនតិចតួច ។ ក្នុងចំណោមអ្នកដែលបានរាយការណ៍ថា បានស្គាល់ស្ត្រីដែលទទួលការរំលោភសេពសន្ថវៈនោះជាងពាក់កណ្តាលបានឆ្លើយថាស្ត្រីនោះនៅស្ងៀម និងមិនធ្វើអ្វីសោះ ។

## ការចូលរួមចំណែកនៃការប្រើគ្រឿងស្រវឹង ដែលបណ្តាលឱ្យមានអំពើហិង្សាក្នុងគ្រួសារ

- អង្កេតនេះបានបង្ហាញនូវទំនាក់ទំនងយ៉ាងជិតស្និទ្ធរវាងគ្រឿងស្រវឹង និងអំពើហិង្សា ។ នៅពេលដែលការប្រើគ្រឿងស្រវឹងមានការកើនឡើង ដូច្នេះកំរិតនៃអំពើហិង្សាក៏កើនឡើងផងដែរ ។
- យោងទៅលើចំលើយស្តីពីការប្រើប្រាស់គ្រឿងស្រវឹងរបស់អ្នកដទៃទៀត អង្កេតនេះបានបង្ហាញឱ្យឃើញថា៨០%នៃបុរសយ៉ាងហោចណាស់ក៏បានផឹកក្នុងឱកាសម្តងម្កាលដែរ ។
- ចំលើយរបស់អ្នកផ្តល់ចំលើយអំពីទំលាប់នៃការផឹកជាតិស្រវឹងរបស់ពួកគេ និងចំលើយរបស់សហព័ទ្ធរបស់ពួកគេ គឺខុសគ្នា ។ ករណីនេះបានបង្កើតនូវសំណួរពីរ គឺអំពីប្រេវ៉ាឡង់នៃការប្រើគ្រឿងស្រវឹង និងភាពពិតនៃការនិយាយប្រាប់អំពីទំលាប់នៃការផឹកគ្រឿងស្រវឹង ព្រោះថាសង្គមមិនឱ្យតំលៃចំពោះការផឹកគ្រឿងស្រវឹង ។ ដូច្នេះករណីនេះអាចប៉ះពាល់ដល់លទ្ធផលនៃការស្រាវជ្រាវអំពីទំនាក់ទំនងរវាងគ្រឿងស្រវឹង និងអំពើហិង្សា ។

## ការស្វែងរកជំនួយ

- ក្នុងចំណោមអ្នកតំណាងទាំងអស់ មានតែ១១%ទេ បាននិយាយថា ពួកគេបានស្វែងរកជំនួយចំពោះអំពើហិង្សាក្នុងគ្រួសារ ឬការរំលោភសេពសន្ថវៈ ។
- ស្ត្រីភាគច្រើនបាននិយាយថាអ្វីដែលនាងអាចធ្វើទៅបាននោះគឺនៅស្ងៀម និងមិនធ្វើអ្វីទាំងអស់ ។

- អ្នកផ្តល់ចំលើយជាច្រើន (៥៤%នៃបុរសទាំងអស់ និង៦២%នៃស្ត្រីទាំងអស់)ក៏បាននិយាយថា អាជ្ញាធរភូមិ ឃុំ គឺជាកន្លែងដែលពួកគេទៅរកជំនួយ។ អាជ្ញាធរទាំងអស់នោះ គឺជាអ្នកដែលនៅជិតប្រជាពលរដ្ឋបំផុត។
- ភាគច្រើននៃករណីទាំងអស់នេះ លទ្ធផល គឺការផ្សះផ្សាគ្នា។
- ក្នុងចំណោមអ្នកស្វែងរកការលែងលះ មានតែមួយភាគ៤ប៉ុណ្ណោះ ដែលទទួលបានជោគជ័យទទួលបានជោគជ័យ។
- មានតែប្រជាជនមួយចំនួនតូចប៉ុណ្ណោះបាននិយាយថា ពួកគេបានទៅរកតុលាការ មេធាវី ឬអង្គការក្រៅរដ្ឋាភិបាល។

## អាជ្ញាធរមូលដ្ឋាន និងប៉ូលីស

- ក្រុមនេះបានបង្ហាញនូវឥរិយាបថភាគច្រើនដូចក្រុមផ្សេងៗទៀតដែរ អំពីហេតុផលនៃអំពើហិង្សា។
- អាជ្ញាធរមូលដ្ឋានបានឆ្លើយថា "ពេលខ្លះមិនសប្បាយចិត្ត" ចំពោះការកើតមាននូវអំពើហិង្សាក្នុងគ្រួសារ និងការរំលោភសេពសន្ថវៈដែលក្នុងនោះចំលើយជ្រើសរើសមានចាប់ពី "មិនពេញចិត្តខ្លាំង" រហូតដល់ពេញចិត្តខ្លាំង។ ប៉ុន្តែអំពើហិង្សាក្នុងគ្រួសារ និងការរំលោភសេពសន្ថវៈគឺពុំមែនជាបញ្ហាអាទិភាពដូចបញ្ហាគ្រឿងញៀន ឧក្រិដ្ឋកម្ម អំពើពុករលួយ និងការរំលោភរបស់បងធំ ដែលបញ្ហានេះជាអាទិភាពរបស់ច្បាប់ និងសណ្តាប់ធ្នាប់សង្គម។

# ១.សេចក្តីផ្តើម

ជំពូកនេះ គឺស្តីអំពីស្ថានភាពទូទៅរបស់ស្ត្រីនៅក្នុងប្រទេសកម្ពុជារួមមាន អត្រាប្រេវ៉ាឡង់នៃអំពើហិង្សាប្រឆាំងនឹងស្ត្រី អតុល្យភាពយេនឌ័រ និងក្របខ័ណ្ឌច្បាប់ និងគោលនយោបាយ ។ ជំពូកនេះនឹងពិពណ៌នា អំពីប្រវត្តិរហូតដល់លទ្ធផលនៃការសិក្សាស្រាវជ្រាវនេះដែលនឹងមានចែងនៅក្នុងជំពូកទី ២ ។

## ១.១ រូបភាពតំរូវនៅកម្ពុជា

ទោះជារដ្ឋធម្មនុញ្ញបានផ្តល់សិទ្ធិស្មើគ្នារវាងបុរស និងនារីក៏ដោយ ជាក់ស្តែងស្ថានភាពតួនាទីទាំងនោះនៅតែមានវិសមភាព ។ កម្ពុជា ជាសង្គមដែលប្រកាន់ឋានានុក្រមខ្លាំង និងឱ្យតំលៃខ្ពស់លើបុគ្គលដែលប្រតិបត្តិទៅតាមតួនាទីដែលសង្គមផ្តល់ឱ្យបានល្អ ។ តួនាទីយេនឌ័រ គឺជាផ្នែកមួយយ៉ាងសំខាន់នៃទំរង់ឋានានុក្រមនេះ ។ វប្បធម៌ខ្មែរបានដាក់ចេញនូវក្រិតក្រមយ៉ាងច្បាស់លាស់ សំរាប់បុរស និងនារី ។

ប្រវត្តិសាស្ត្រប្រទេសកម្ពុជា បានបង្ហាញនូវឧទាហរណ៍យ៉ាងច្រើន អំពីកំលាំង និងអំណាចរបស់នារី និងមានរឿងនិទានស្តីពីមាតាធិបតេយ្យ[៩] ដូចជារឿងនិទានជាច្រើននាសម័យអង្គរ និងសម័យក្រោយអង្គរ បានបង្ហាញអំពីវីរភាព និងតំលៃរបស់នារី ដែលបានចូលរួមយ៉ាងសកម្មនៅក្នុងជីវិតសាធារណៈ ។

កម្ពុជាសព្វថ្ងៃនេះ នារីទទួលខុសត្រូវលើការធ្វើការងារផ្ទះ និងថែរក្សាគ្រួសារជាចំបង ។ នារីវ័យក្មេង ចាប់ផ្តើមត្រៀមខ្លួនធ្វើជាប្រពន្ធដ៏ល្អ និងក្លាយជាម្តាយគេនៅក្នុងវ័យក្មេង ជាពិសេសនារីនៅតាមទីជនបទដែលមានប្រជាជនរស់នៅប្រមាណ ៨៥%[១០] ។នារីវ័យក្មេងៗទាំងនេះត្រូវបានទូន្មានឱ្យគោរពប្រតិបត្តិ និងស្តាប់បង្គាប់ឪពុកម្តាយ និងណែនាំអំពីការ "ចូលក្នុងសង្គម"[១១] ។ មាននារីវ័យក្មេងជាច្រើន ដែលត្រូវបានគេរំពឹងថា នឹងបានជួយថែរក្សាបងប្អូន ផ្ទះសម្បែង និងជួយនៅក្នុងមុខរបររបស់គ្រួសារ មិនថាវាជាការងារកសិកម្ម ឬការជួញដូរនោះទេ ។ មានទំនៀមទំលាប់ផ្សេងទៀតបានជំរុញឱ្យស្ត្រីនៅតែក្នុងផ្ទះ ជាពិសេសនៅពេលដែលនារីពេញវ័យក្រមុំ[១២] ។

---

[៩] Sokmeng, (Thea 2004)តួនាទីរបស់ស្ត្រី នៅក្នុងសង្គមកម្ពុជា នៅក្នុងប្រវត្តិសាស្ត្រ និងវប្បធម៌ (ភ្នំពេញ) ទំព័រទី ៤

[១០] វិទ្យាស្ថានជាតិស្ថិតិ (១៩៩៨) ជំរឿនប្រជាពលរដ្ឋទូទៅ ១៩៩៨ (ភ្នំពេញ) និងរបាយការណ៍គោលដៅអភិវឌ្ឍន៍សហសវត្សរ៍របស់រាជរដ្ឋាភិបាល ឆ្នាំ២០០៣ ភ្នំពេញ) ទំព័រទី ៥

[១១] ឯកសាររបស់បណ្ឌិត Frieson, Kate ចំណងជើងថា: *In the Shadow: Women, Power and Politics in Cambodia (Victoria, BC, Canada: Center for Asia-Paci c Initiative)* ទំព័រទី ៥

[១២] Sokmeng, Thea ទំព័រទី ៩

នៅប្រទេសកម្ពុជាស្ត្រីពុំមែនគ្មានអំណាចនោះទេ។ ស្ត្រីអាចទទួលបានទ្រព្យសម្បត្តិកេរ្តិ៍មរតកដូចជាបុរសដែរ។ ជាញឹកញាប់ស្ត្រីដើរតួយ៉ាងសំខាន់ក្នុងការគ្រប់គ្រងហិរញ្ញវត្ថុគ្រួសារ ធ្វើការសំរេចចិត្តលើការចំណាយនិងការដាក់ទុនរកស៊ីផ្សេងៗ[១៣] ។ ប៉ុន្តែផ្លូវដើរពិតប្រាកដរបស់ស្ត្រីទៅរកអំណាចនៅក្នុងឋានានុក្រមសង្គម គឺត្រូវដើរតាមគន្លងក្រមនៃ (ច្បាប់ស្រី) ដែលតំរូវឱ្យស្ត្រីត្រូវបំរើ និងគោរពប្តី និងគោរពប្រណិប័តន៍ឪពុកម្តាយ ថែរក្សាកូនចៅ និងត្រូវមានឥរិយាបថសុភាពរាបសារ សំដីទន់ភ្លន់គ្រប់ពេលវេលា។ មានមតិមួយចំនួនយល់ថា តួនាទីដ៏សំខាន់របស់ស្ត្រីនៅក្នុងគ្រួសារ គឺត្រូវបានគេមើលឃើញថា ជាផ្នែកមួយនៃវប្បធម៌របស់មនុស្សជំនាន់ក្រោយហើយដែលមានការព្រួយបារម្ភនៅក្នុងសង្គមថាអាចមានការបាត់បង់នូវវប្បធម៌នេះ[១៤] ។

គំរូដ៏មានអំណាចរបស់នារីខ្មែរ ត្រូវបានរៀបរាប់នៅក្នុងព្រេងនិទានស្តីពីស្ត្រីគ្រប់ល័ក្ខណ៍[១៥]។ នៅក្នុងរឿងព្រេងនិទាន ស្ត្រីគ្រប់ល័ក្ខណ៍ គឺជាគន្លឹះសំរាប់សំរេចរាល់ជោគជ័យរបស់ប្តី។ តួនាទីរបស់ស្ត្រីត្រូវបានគេចាត់ទុកជាអ្នកគាំទ្រ ដូចដែលចែងនៅក្នុងពាក្យស្លោកខ្មែរថា "សំណាបយោងដី ស្ត្រីយោងបុរស"[១៦] ។ ស្ត្រី ត្រូវបានគេសង្ឃឹមថានឹងគោរព និងជួយជ្រោមជ្រែងប្តីក្នុងគ្រប់កាលៈទេសៈ ដោយមិនគិតពីកំហុស និងភាពខ្វះខាតរបស់ប្តី ឬការប្រតិបត្តិរបស់ប្តីមកលើប្រពន្ធរបស់ខ្លួននោះឡើយ។ ពាក្យស្លោកមួយទៀតបានពោលថា ប្តីជា "ម្ចាស់" និងណែនាំនារីឱ្យចេះ "គាំទ្រ និងខ្លបខ្លាចប្តីព្រោះនាងជាស្ត្រី " នឹងត្រូវប្រុងប្រយ័ត្ន "រាល់ការនិយាយស្តី ដោយជៀសវាងការចង់បានស្មើជាមួយប្តី"[១៧] ។

ឥរិយាបថចំពោះរឿងភេទសំរាប់ស្ត្រី មានលក្ខណៈខុសគ្នាខ្លាំងពីឥរិយាបថចំពោះរឿងភេទរបស់បុរស។ ប្រជាពលរដ្ឋខ្មែរ បានឱ្យតំលៃខ្ពស់លើភាពបរិសុទ្ធ ដែលជាល័ក្ខខ័ណ្ឌពិសេសសំរាប់អាពាហ៍ពិពាហ៍។ នារីដែលបាត់បង់ភាពបរិសុទ្ធមុនពេលរៀបការនឹងនាំមកនូវការអាម៉ាស់ដល់កិត្តិយសនិងស្ថានភាពគ្រួសារ[១៨]។ ដូចដែលមានពាក្យចាស់ពោលថា "បុរសគឺជាមាស ឯនារីគឺជាក្រណាត់ស"។ ពាក្យចាស់នេះមានន័យផ្សេងទៀតថា មាសគឺមិនខ្លាចភ្លើង និងមិនបាត់បង់តំលៃ ប៉ុន្តែក្រណាត់នឹងគ្មានតំលៃនៅពេលរហែក ឬប្រឡាក់ភក់។ ពាក្យចាស់នេះបានបង្ហាញឱ្យឃើញកាន់តែច្បាស់ថា នារីខ្មែរត្រូវតែប្រុងប្រយ័ត្នក្នុងការរក្សានូវភាពបរិសុទ្ធ និងត្រូវប្រតិបត្តិតាមច្បាប់ទូន្មាន (ច្បាប់ស្រី)។

ស្ត្រីក៏ត្រូវបានប្រៀនប្រដៅមិនឱ្យនិយាយរឿងក្នុងគ្រួសារទៅខាងក្រៅផ្ទះ ពីព្រោះអាចបណ្តាលឱ្យមានជម្លោះ។ ពាក្យស្លោកជាច្រើនបានទូន្មានស្ត្រី ឱ្យប្រយ័ត្នក្នុងការនិយាយស្តីទៅអ្នកខាងក្រៅ។

---

[១៣] Ebihara (1968) and Martin (1994) cited in Derks, Annuska (2005), Khmer Women on the Move: Migration and Urban Experiences in Cambodia (Amsterdam: Dutch University Press) សូមអានផងដែរ ឯកសាររបស់បណ្ឌិត Frieson, Kate ទំព័រទី ២

[១៤] ឯកសាររបស់បណ្ឌិត Frieson, ទំព័រទី ៤

[១៥] Sokmeng, ទំព័រទី ៦

[១៦] Ibid

[១៧] Luco, Fabienne (2002), Between a Tiger and a Lion (Phnom Penh: UNESCO) TMB½rTI 21 footnote 47

[១៨] CARE International Cambodia (2001) ប្រពន្ធល្អ : ការពិភាក្សាជាមួយនារីបានរៀបការអំពីជីវិត សុខភាព អាពាហ៍ពិពាហ៍ និងភេទ (ភ្នំពេញ)

"កុំឱ្យនាំភ្លើងខាងក្រៅចូលផ្ទះ ហើយនិងកុំនាំភ្លើងក្នុងផ្ទះចេញក្រៅ[១៩] "។ ស្ត្រីត្រូវបានប្រៀនប្រដៅថា ការជជែកលេងជាមួយអ្នកដទៃ នាំឱ្យកើតមានជម្លោះ។ "អ្នកនឹងយកបញ្ហាជម្លោះខាងក្នុងគ្រួសារទៅរាលដាលដល់អ្នកខាងក្រៅ ប្រសិនបើមិនមានការប្រុងប្រយ័ត្ន (ក្នុងករណីនេះ) យើងនឹងកក្កូរកកាយធ្វើឱ្យមានការចងកំហឹងដល់អ្នកទាំងពួង រួមទាំងកូនចៅ ហើយនេះជាការមិនល្អមួយ និងគួរឱ្យស្អប់[២០] ។

បុរសមានតួនាទីខ្ពស់ជាងស្ត្រី ទាំងនៅក្នុងគ្រួសារ និងក្នុងសង្គម។ បុរសគឺជាមេគ្រួសារ។ បុរសត្រូវបានគេចាត់ទុកថា ជាអ្នកធ្វើសេចក្តីសំរេចចុងក្រោយបង្អស់ក្នុងគ្រួសារ ហើយសមាជិកផ្សេងទៀតត្រូវផ្តល់ឱ្យបុរសនូវសេចក្តីគោរពប្រតិបត្តិតាម និងស្តាប់បង្គាប់[២១]។ ពាក្យស្លោកខ្មែរបានពោលថា បុរសមិនគួរជា "អ្នកដែលនៅក្រោមសំពត់របស់ស្ត្រី " បើមិនដូចនេះ បុរសនឹងក្លាយជាអ្នកនៅក្រោមបង្គាប់របស់ស្ត្រី។ ចរិកលក្ខណៈបែបនេះគឺជាការប្រមាថយ៉ាងធ្ងន់ធ្ងរបំផុតទៅលើបុរសខ្មែរ[២២] ។

ច្បាប់ទូន្មានសំរាប់បុរសមានឈ្មោះថាច្បាប់ប្រុស "ច្បាប់ក្រិតក្រមរបស់បុរស " ប្រុសគ្រប់លក្ខណ៏ និងការទូន្មានផ្សេងៗទៀតពីសាសនា។ ប៉ុន្តែច្បាប់ទូន្មានទាំងនេះពុំបានរៀបរាប់អំពីការអនុវត្តន៏ប្រចាំថ្ងៃរបស់បុរសឡើយ។ ឧទាហរណ៏ បុរសនៅក្នុងក្រុមគោលដៅមួយ ដែលរៀបចំឡើងដោយអង្គការ PADV នៅឆ្នាំ២០០៣ បានបង្ហាញឱ្យឃើញថា ទោះបីបុរសឱ្យតំលៃខ្ពស់លើក្បួនច្បាប់ទាំងនេះ ប៉ុន្តែបុរសនៅតែមានទស្សនះថា ការខកខានពុំបានអនុវត្តតាមច្បាប់ទាំងនេះ គឺជារឿងធម្មតា[២៣] ។

បុរសខ្មែរមានទស្សនះខុសៗគ្នាអំពីសមភាពរបស់នារី។ នៅក្នុងក្រុមគោលដៅរបស់អង្គការ PADV មានបុរសជាច្រើននិយាថានារីដែលមានចំណេះដឹងស្មើនឹងបុរសគួរតែទទួលនូវឱកាសស្មើគ្នា[២៤]។ ប៉ុន្តែបុរសទាំងនោះបានកត់សំគាល់ឃើញថាបុរស និងនារីមានតួនាទីខុសគ្នា ហើយបាននិយាយថា ការងាររបស់បុរសសំខាន់ជាងការងាររបស់នារី[២៥] ។

សង្គមខ្មែរទទួលយកនូវករណីបុរសទៅរួមភេទជាមួយដៃគូផ្សេងទៀតក្រៅពីភរិយារបស់គេ។ មានមនុស្សជាច្រើនជឿថាបុរសមិនអាចគ្រប់គ្រងខ្លួនឯងនិងជឿថាបុរសមានសិទ្ធិទៅរកការសប្បាយផ្លូវភេទនៅខាងក្រៅ។ ជាការពិតណាស់ មានពេលខ្លះបុរសបានប្រាប់ឱ្យដឹងថាក្រុមមិត្តភ័ក្រ្តវ័យស្រករគ្នារបស់ពួកគេជាអ្នកនាំឱ្យគេទៅរកការសប្បាយផ្លូវភេទ។ ការមានដៃគូជាច្រើនត្រូវបានគេមើលឃើញថាលក្ខណៈល្អរបស់មនុស្សប្រុស ក៏ដូចជាលក្ខណៈខ្លាំងផ្នែករាងកាយ និងសុខភាពផ្លូវចិត្ត[២៦] ។ លទ្ធផលនៃចំណុចនេះ គឺការបណ្តាលឱ្យមានការធ្វើអាជីវកម្មផ្លូវភេទគួរឱ្យកត់សំគាល់នៅកម្ពុជា។

---

១៩ Luco ទំព័រទី ២២ footnote 50

២០ Ibid

២១ Derks ទំព័រទី ៦០

២២ Giles, Liz (2004), Men Against Violence Against Women Pilot Project Evaluation: Phase One (Phnom Penh: PADV) ទំព័រទី ២៨

២៣ Giles, ទំព័រ២៦ ផ្ទុយទៅវិញ បុរសនៅក្នុងក្រុមគោលដៅបានយល់ថា ពួកគេសង្ឃឹមថានារីធ្វើតាមក្បួនដែលនិយាយពីភេទ

២៤ Ibid ទំព័រ២៩

២៥ Ibid

២៦ CARE International Cambodia

## ១.២ អំពើហិង្សាប្រឆាំងនឹងស្ត្រីនៅកម្ពុជា

ការបង្ហាញពីវិសមភាពយេនឌ័រក្នុងប្រទេសកម្ពុជា គឺតាមរយៈអំពើហិង្សាក្នុងគ្រួសារ។ អំពើហិង្សាក្នុងគ្រួសារ គឺជាបញ្ហាដ៏ធ្ងន់ធ្ងរដែលកំពុងរាលដាលក្នុងសង្គមកម្ពុជា។ យោងទៅតាមការអង្កេតអំពីប្រជាសាស្ត្រ និងសុខភាពនៅកម្ពុជាក្នុងឆ្នាំ២០០០បានឱ្យដឹងថា មាន ២៣% នៃស្ត្រីដែលមានអាយុពី ១៥ ដល់ ៤៩ ឆ្នាំ ដែលធ្លាប់រៀបការរួចហើយ គឺធ្លាប់ជួបប្រទះបទពិសោធន៍អំពើហិង្សាក្នុងគ្រួសារ។

ប្រទេសកម្ពុជាមិនមែនជាប្រទេសតែមួយដែលជួបប្រទះនឹងបញ្ហាដ៏ធ្ងន់ធ្ងរនេះទេ។ អង្គការសុខភាពពិភពលោក(WHO) បាននិយាយអំពើហិង្សាក្នុងគ្រួសារគឺជា "បញ្ហាប្រឈមមុខជាសកល"។ របាយការណ៍របស់អង្គការសុខភាពពិភពលោកបានរាយការណ៍ថា ២៧% នៃស្ត្រីនៅសហរដ្ឋអាមេរិក បានទទួលរងការរំលោភបំពានផ្លូវកាយពីសំណាក់ដៃគូជិតស្និទ្ធរបស់គេ ហើយមាន ៣៧% នៃស្ត្រីក្នុងប្រទេស Nicaragua ជួបប្រទះនឹងអំពើហិង្សាក្នុងគ្រួសាររបស់ពួកគេ។ យោងតាមរបាយការណ៍បានបង្ហាញឱ្យឃើញថា ជនរងគ្រោះភាគច្រើន គឺបានទទួលរងគ្រោះពីអំពើហិង្សាជាច្រើនអស់រយៈពេលជាយូរ និងរងគ្រោះពីការរំលោភបំពានផ្លូវកាយពីដៃគូដែលមានទំនាក់ទំនងជិតស្និទ្ធ ហើយជាញឹកញាប់ជនរងគ្រោះទាំងនោះទទួលការរំលោភបំពានផ្លូវចិត្ត និងអំពើហិង្សាផ្លូវភេទ[២៧] ។

## ១.៣ និយមន័យ: អំពើហិង្សាប្រឆាំងនឹងស្ត្រី និងការរំលោភសេពសន្ថវៈ

ការប្រកាសរបស់អង្គការសហប្រជាជាតិស្តី អំពីការលុបបំបាត់អំពើហិង្សាប្រឆាំងនឹងស្ត្រី (1993) បានឱ្យនិយមន័យនៃអំពើហិង្សាប្រឆាំងនឹងស្ត្រីថា ជា "អំពើណាមួយដែលជាអំពើហិង្សាយេនឌ័រ ដែលនឹងបណ្តាល ទំនងជានឹងបណ្តាលឱ្យមានគ្រោះថ្នាក់ផ្លូវកាយ ផ្លូវភេទ ឬផ្លូវចិត្តដល់ស្ត្រី ដោយរួមមានទាំងអំពើគំរាមកំហែង ការបង្ខិតបង្ខំ ឬការរំលោភបំពានលើសេរីភាពរស់នៅ ដែលទោះបីជាកើតឡើងជាសាធារណៈនិងឯកជនក៏ដោយ"។

ក្នុងអំឡុងពេលពិភាក្សាសេចក្តីព្រាងច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ និយមន័យនេះត្រូវបានគេកំណត់យកដូចតទៅ។ និយមន័យត្រូវបានប្រើប្រាស់ដោយក្រុមអ្នកស្រាវជ្រាវនេះថា "អំពើហិង្សាក្នុងគ្រួសារ គឺជាអំពើហិង្សាដែលកើតឡើងនៅក្នុងក្រុមគ្រួសារមួយដែលប្រព្រឹត្តដោយបុគ្គលម្នាក់ ដែលអាចត្រួតត្រាលើបុគ្គលផ្សេងទៀត។ ឧទាហរណ៍ ប្តីត្រួតត្រាលើប្រពន្ធរបស់ខ្លួន ម្តាយត្រួតត្រាលើកូនរបស់ខ្លួន។ អំពើហិង្សាអាចមានដូចជាអំពើហិង្សាផ្លូវកាយ អំពើហិង្សាផ្លូវភេទ អំពើហិង្សាផ្លូវចិត្ត ឬអំពើហិង្សាផ្នែកសេដ្ឋកិច្ច។ អំពើហិង្សាអាចរួមបញ្ចូលនូវការគំរាមកំហែង និងការទុកឱ្យនៅឯកោ។ អំពើហិង្សាក្នុងគ្រួសារតែងតែធ្វើឱ្យមានការឈឺចាប់ផ្លូវកាយ និងផ្លូវចិត្តរបស់អ្នកដែលត្រូវគេរំលោភបំពាន។ ជួនកាលកុមារក៏អាចទទួលរងគ្រោះផងដែរដោយចេតនា ឬអចេតនានៅពេលដែលម្តាយរបស់ពួកគេត្រូវបានគេវាយដំ។ ក៏ដូចជាមនុស្សចាស់ដែរ កូនក្មេងអាចរងគ្រោះដោយសារការរំលោភ បំពានផ្លូវកាយ ផ្លូវភេទ និងផ្លូវចិត្ត។ ការរបួសផ្លូវកាយ

[២៧] អង្គការសុខភាពពិភពលោក (២០០២) របាយការណ៍ពិភពលោកស្តីអំពីអំពើហិង្សា និងសុខភាព (ហ្សឺណែវ) ទំព័រទី ៨៩

អាចកើតមាននៅពេលម្តាយត្រូវបានគេវាយដំ ពេលដែលនាងកំពុងអោបកូនតូច ។ ការមានរបួសដល់កូនធំៗ កើតឡើងនៅពេលដែលពួកគេព្យាយាមធ្វើអន្តរាគមន៍នៅពេលដែលអំពើហិង្សា កំពុងតែកើតមានធ្ងន់ធ្ងរ" ។

អំពើរំលោភសេពសន្ថវៈ ត្រូវបានគេកំណត់និយមន័យថា "ជាអំពើរំលោភបំពានផ្លូវកាយ ដើម្បីរួមភេទនៃបុគ្គលមួយប្រព្រឹត្តលើបុគ្គលមួយទៀតដោយការបង្ខិតបង្ខំ" យោងទៅតាមតុលាការកាត់ក្តីអន្តរជាតិនៅរ៉ាវ៉ានដា[២៨] (International Criminal Tirbunal for Rwanda) ។ នៅក្នុងប្រទេសមួយចំនួន និយមន័យអំពីការរំលោភសេពសន្ថវៈ គឺមានន័យថាការរួមភេទដោយគ្មានការព្រមព្រៀង ប៉ុន្តែ និយមន័យអាចរាប់បញ្ចូលទាំងទង្វើណាដែលទាក់ទិននឹងការប្រើប្រាស់ឧបករណ៍រួមភេទ និង/ឬប្រើរាងកាយផ្សេងៗទៀតដែលពុំត្រូវបានគេចាត់ទុកថាការរួមភេទ ។ អំពើរំលោភសេពសន្ថវៈ គឺជាទង្វើមួយដែលប្រើអំពើហិង្សា ហើយមិនគួរឱ្យនិយមន័យត្រឹមតែលើការអធិប្បាយអំពីឧបករណ៍ និងផ្នែកណាមួយនៃរាងកាយនោះទេ ។

## ១.៤ អំពើហិង្សាក្នុងគ្រួសារនៅកម្ពុជា

អំពើហិង្សាក្នុងគ្រួសារ គឺជាបញ្ហាយ៉ាងធ្ងន់ធ្ងរមួយនៅកម្ពុជា ។ ក្រុមសិទ្ធិមនុស្សអាដហុក បានរកឃើញថា ស្ថានភាពកាន់តែធ្ងន់ធ្ងរឡើងៗ: "អំពើហិង្សាក្នុងគ្រួសារកាន់តែជាបញ្ហាធ្ងន់ធ្ងរ និងឃោរឃៅឡើងៗ នៅកម្ពុជាពីមួយឆ្នាំទៅមួយឆ្នាំ ពេលខ្លះមានដល់ទៅការធ្វើទារុណកម្មយ៉ាងធ្ងន់ធ្ងរ ដូចជាការជះទឹក អាស៊ីត ការវាយដំធ្ងន់ធ្ងរនាំឱ្យមានការរលូតកូន ស្លាប់ទារកក្នុងផ្ទៃ និងការស្លាប់របស់ម្តាយ និងមានរហូតដល់មានករណីខ្លះ ដែលប្តីបានចងជើងប្រពន្ធឡើងលើជាប់ពិដានផ្ទះហើយធ្វើទារុណកម្មនាងដោយមធ្យោបាយផ្សេងៗ[២៩] " ។

ឥរិយាបថរបស់ប្រជាពលរដ្ឋកម្ពុជាចំពោះអំពើហិង្សាក្នុងគ្រួសារ មានលក្ខណៈស្មុគស្មាញជាងនិយមន័យរបស់អន្តរជាតិដែលបានលើកឡើង ។ ឧទាហរណ៍ នៅខណៈដែលក្រុមគោលដៅរបស់អង្គការ PADV បានសួរទៅបុរសជាច្រើន ដើម្បីកំណត់ពាក្យថាហិង្សា មានបុរសភាគច្រើន (៤៤%) ឆ្លើយថា ជាការរំលោភបំពានដែលពុំប៉ះពាល់ដល់ផ្លូវកាយ ដូចជាការស្តីបន្ទោស[៣០] ។ មានបុរស ២៤% ហៅថាជាការធ្វើបាបផ្លូវកាយ (ជាធម្មតា ដូចជាការវាយដំ) និង ១៦% ថាជា "ការវាយតប់គ្នា" ដោយរួមទាំងការប្រើពាក្យសំដី និងការប្រើហិង្សាផ្លូវកាយ ។ គ្មាននរណាម្នាក់ឆ្លើយថាជាអំពើហិង្សាផ្លូវភេទនោះទេ[៣១] ។ នៅពេលដែលអង្កេតបានសួរពីករណីជាក់ស្តែងពីអំពើហិង្សាដែលពួកគេបានដឹង គឺពួកគេបានឆ្លើយប្រាប់ពីអំពើហិង្សាដែលពុំប៉ះពាល់ដល់ផ្លូវកាយ ច្រើនជាងអំពើហិង្សាផ្លូវកាយ ។ ទោះជាយ៉ាងណាក៏ដោយ អ្នកផ្តល់ចំលើយមួយចំនួននិយាយពីការរំលោភបំពានសេពសន្ថវៈ[៣២] ។

---

[២៨] From the Akayesu decision of the ICTR (2 September 1998)

[២៩] ADHOC (2004), Human Rights Situation Report 2004 (Phnom Penh) ទំព័រទី ២៥

[៣០] Giles, ទំព័រទី ៣២

[៣១] Ibid

[៣២] Ibid ទំព័រទី ៣១

នៅកម្ពុជា អំពើហិង្សាក្នុងគ្រួសារ គឺទាក់ទងដោយផ្ទាល់ទៅនឹងអំពើហិង្សាក្នុងសង្គមជាទូទៅ។ បន្ទាប់ពីសង្គ្រាមពាទសវត្សមក អំពើហិង្សាត្រូវបានគេទទួលយកជាមធ្យោបាយសំរាប់បញ្ចប់ជម្លោះ។ ដោយសារ ប្រវត្តិនៃបញ្ហាទាំងនេះហើយ ដែលឪពុកម្តាយសព្វថ្ងៃពុំមានឪពុកម្តាយដែលយកចិត្តទុកដាក់ក្នុងការថែរក្សាបីបាច់កូននោះឡើយ។ ផ្ទុយទៅវិញពួកគាត់មានតែប្រឈមមុខនឹងសង្គ្រាម និងអំពីហិង្សាផ្សេងៗដែលកើតមានរៀងរាល់ថ្ងៃ។ អង្គការលីកាដូ បានកត់សំគាល់ថា "នារីដែលមានអាយុច្រើននៅក្នុងសម័យខ្មែរក្រហមដែលឥឡូវនេះមានអាយុចន្លោះពី(៣៦-៥០ឆ្នាំ) បានរាយការណ៍ថា បានជួបប្រទះនូវអត្រាខ្ពស់នៃការរំលោភបំពានក្នុងគ្រួសារ"[៣៣]។ អង្គការលីកាដូ កត់សំគាល់ថា "អំពើហិង្សាក្នុងសង្គម ពាក់ព័ន្ធខ្លាំងទៅនឹងអំពើហិង្សានៅក្នុងផ្ទះ"[៣៤]។ ជាលទ្ធផល គឺថាអ្នកជំនាន់ក្រោយនឹងខ្វះជំនាញ ក្នុងការធ្វើជាឪពុកម្តាយល្អ និងគំរូ សំរាប់ដោះស្រាយជម្លោះផ្សេងៗ។

មនុស្សវ័យក្មេងក៏បានឱ្យដឹងថា អត្រានៃអំពើហិង្សាគឺមានកំរិតខ្ពស់នៅក្នុងគ្រួសាររបស់ពួកគេ។ តាមរយៈការអង្កេតស្តីពីឥរិយាបថប្រឈមមុខនឹងគ្រោះថ្នាក់របស់យុវជន ដែលធ្វើឡើងដោយក្រសួងអប់រំបានឱ្យដឹងថាមានយុវជន ២៧% បាននិយាយថា ពួកគេជួបប្រទះបទពិសោធន៍រងគ្រោះដោយសារអំពើហិង្សាក្នុងក្រុមគ្រួសាររបស់ពួកគេនៅក្នុងខែកន្លងទៅ[៣៥] ។

អ្នកជំនាញខាងអំពើហិង្សាក្នុងគ្រួសារ បានបង្ហាញពីមូលហេតុមួយចំនួនដែលបណ្តាលឱ្យមានឥរិយាបថហិង្សា ដូចជាការប្រើគ្រឿងស្រវឹង ភាពក្រីក្រ ការលេងល្បែង ជំលោះក្នុងគ្រួសារ ការខ្វះការអប់រំ និងអស្ថេរភាពសង្គម/នយោបាយ ដែលជាហេតុបង្កឱ្យមានអំពើហិង្សាក្នុងគ្រួសារ។ អ្នកជំនាញជឿថា ផ្នត់គំនិត វប្បធម៌អំពីយេនឌ័រ ក្បួនច្បាប់សង្គម និងឥរិយាបថអំពីអំពើហិង្សាក្នុងគ្រួសារ គឺជាមូលហេតុដែលបណ្តាលឱ្យមានឥរិយាបថហិង្សា និងបន្តឱ្យមានឥរិយាបថហិង្សា។

ផលប៉ះពាល់នៃអំពើហិង្សាក្នុងគ្រួសារគឺមានទំហំធំធេងណាស់។ តាមនិយមន័យអំពើហិង្សាគឺកើតឡើងនៅក្នុងផ្ទះរបស់អ្នកណាម្នាក់ ឬកើតឡើងរវាងដៃគូជិតស្និទ្ធ។ តាមទ្រឹស្តីផ្ទះសម្បែងជាកន្លែងមួយដែលមានសុវត្ថិភាពនិងមានសន្តិសុខ។ នៅពេលដែលផ្ទះក្លាយទៅជាកន្លែងដែលពោរពេញដោយការភ័យខ្លាច និងតក់ស្លុតនោះនឹងប៉ះពាល់ដល់ការគិត អារម្មណ៍ ឥរិយាបថ និងផ្លូវចិត្តរបស់ជនរងគ្រោះ។ ដៃគូដែលទន់ខ្សោយ ជានិច្ចកាលត្រូវតែពិនិត្យ និងកែសំរួលឥរិយាបថរបស់គាត់ ដើម្បីចៀសវាងកុំឱ្យដៃគូដែលមានអំណាចជាងខ្លួនខឹង និងប្រើអំពើហិង្សា។ អំពើហិង្សាក្នុងគ្រួសារធ្វើឱ្យស្ត្រីបាត់បង់នូវភាពជឿជាក់លើខ្លួនឯង សុវត្ថិភាព សមត្ថភាពក្នុងការដោះស្រាយបញ្ហា និងធ្វើផែនការសំរាប់អនាគត។ ទីបំផុតអំពើហិង្សាក្នុងគ្រួសារ ប៉ះពាល់ដល់តួនាទីរបស់នារីនៅក្នុងគ្រួសារ ដូចជាតួនាទីជាម្តាយ/ប្រពន្ធ បងប្អូនបង្កើត ព្រមទាំងតួនាទីនៅក្នុងសហគមន៍។ គ្រួសារដែលធ្លាប់មានអំពើហិង្សាក្នុងគ្រួសារមិនបានផ្តល់នូវបរិយាកាសសហការគ្នាល្អក្នុងការជួយជ្រោមជ្រែង និងការចិញ្ចឹមបីបាច់គ្រួសារឡើយ។ ផ្ទុយទៅវិញពួកគេគិតតែពីការបន្តឱ្យមានអំពើហិង្សា។

---

៣៣ LICADHO (2004), Situation of Women in Cambodia (Phnom Penh) ទំព័រទី ១៦

៣៤ Ibid

៣៥ ក្រសួងអប់រំ យុវជន និងកីឡា ការអង្កេតដែលមានអ្នកផ្តល់ចំលើយចំនួន ១០.០០០នាក់

មនុស្សជាច្រើនព្យាយាមកាត់បន្ថយផលប៉ះពាល់នៃអំពើហិង្សាក្នុងគ្រួសារ ។ មានមនុស្សខ្លះយល់ឃើញថា អំពើហិង្សាក្នុងគ្រួសារជាបញ្ហានៅក្នុងគ្រួសារ ពុំគិតថាជាបញ្ហាសុខភាពសាធារណៈ ឬជាបញ្ហាសង្គមឡើយ ។ ជារឿយៗពាក្យដំណែលខ្មែរបង្កឱ្យមានភាពពិបាកដល់នារី និងកុមារក្នុងការនិយាយស្ដីចេញនិងការស្វែងរកជំនួយ ។ហើយក៏មានមនុស្សជាច្រើនមិនចង់និយាយប្រាប់អ្នកក្រៅអំពីរឿងរបស់ខ្លួន ។ដូច្នេះហើយ ពួកគេមិនសុំឱ្យមានការជួយ ឬក៏ស្វែងរកការចោទប្រកាន់លើអ្នករំលោភបំពាននោះទេ ។ ជាលទ្ធផល មានករណីជាច្រើនមិនត្រូវបានរាយការណ៍ឱ្យដឹង ហើយក៏មានមនុស្សមួយចំនួនពុំបានគិតថា អំពើហិង្សាក្នុងគ្រួសារជាបញ្ហាសំខាន់នៅកម្ពុជាឡើយ ។

## ១.៥ អំពើរំលោភសេពសន្ថវៈនៅកម្ពុជា

អំពើរំលោភសេពសន្ថវៈកំពុងតែកើនឡើងនៅកម្ពុជា ។ អង្គការអាដហុកបានទទួលពាក្យបណ្ដឹង ៣២៦ ករណីនៅឆ្នាំ ២០០៤[៣៦] ប៉ុន្តែអង្គការនេះជឿថា មានករណីរំលោភសេពសន្ថវៈជាច្រើនទៀតមិនទាន់បានរាយការណ៍ឱ្យដឹង ពីព្រោះប្រជាជនពុំបានដឹងតើពួកគេគួរតែប្ដឹងតាមវិធីណានោះទេ ឬខ្លាចអំពីសុវត្ថិភាពផ្ទាល់ខ្លួន ។ អង្គការអាដហុកកត់សំគាល់ថា បទឧក្រិដ្ឋទាំងនេះកាន់តែធ្ងន់ធ្ងរឡើងតាមរយៈការកើនឡើងនូវចំនួនជនរងគ្រោះដែលបានស្លាប់កាលពីឆ្នាំកន្លងមក[៣៧] ។ មាន ៣៩% នៃករណីរំលោភសេពសន្ថវៈទាំងនេះ ដែលជនរងគ្រោះមានអាយុតិចជាង ១៨ឆ្នាំ ហើយប្រហែលជិត ៤% នៃករណីរំលោភសេពសន្ថវៈ ដែលជនរងគ្រោះមានអាយុតិចជាង ៥ឆ្នាំ[៣៨] ។ ប្រមាណជា ៣/៤ នៃអ្នករំលោភសេពសន្ថវៈគឺជាមនុស្សដែលជនរងគ្រោះស្គាល់ ។ ស្រដៀងនេះដែរអង្គការកម្ពុជាដើម្បីជួយស្ត្រីមានវិបត្តិបានឱ្យដឹងថាមាន២៤១ករណីនៅក្នុង៣ខែត្តតែប៉ុណ្ណោះកាលពីឆ្នាំ ២០០៤[៣៩] ។

អំពើរំលោភសេពសន្ថវៈ ប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់ស្ត្រីខ្មែរ ។ ពីព្រោះថា វប្បធម៌ខ្មែរឱ្យតំលៃខ្ពស់ទៅលើភាពបរិសុទ្ធរបស់នារី អ្នកដែលត្រូវគេរំលោភសេពសន្ថវៈត្រូវប្រឈមមុខជាមួយនឹងស្លាកស្នាមជីវិត និងភាពអាម៉ាស់[៤០] ។ មកដល់ដំណាក់កាលនេះ គឺលែងមានការយកចិត្តទុកដាក់អំពីឥរិយាបថរបស់អ្នកប្រព្រឹត្តបទល្មើសទៀតហើយ ប៉ុន្តែបែរទៅផ្ដោតយកចិត្តទុកដាក់លើបញ្ហាបាត់បង់ព្រហ្មចារីរបស់នារីទៅវិញ[៤១] ។ ការទទួលខុសត្រូវរបស់អ្នកប្រព្រឹត្តបទល្មើស ក៏ត្រូវបានកាត់បន្ថយដោយសារការយល់ឃើញថា ការរំលោភកើតឡើង ពីព្រោះបុរសមិនអាចគ្រប់គ្រងអារម្មណ៍ផ្លូវភេទរបស់ខ្លួនបាន ដោយពុំបានចាត់ទុកថាការរំលោភបំពានសេពសន្ថវៈគឺជាបទឧក្រិដ្ឋ ។ ជនរងគ្រោះដោយ

---

[៣៦] ADHOC ទំព័រទី ២១

[៣៧] Ibid ទំព័រទី ២២

[៣៨] Ibid

[៣៩] សម្ភាសន៍ជាមួយក្រសួងកិច្ចការនារី ខែមិថុនា ឆ្នាំ២០០៥

[៤០] LICADHO (2001) *Rape and Indecent Assault: Crimes in the Communicty* ភ្នំពេញ ទំព័រទី i

[៤១] Ibid ទំព័រទី ii

សារអំពើរំលោភសេពសន្ថវៈបានប្រាប់ថាមានការមាក់ងាយពីអ្នកជិតខាងរបស់នាង។ ពួកជនរងគ្រោះទាំងនោះបានបន្ទោសខ្លួនឯង ឬគ្រួសាររបស់នាងស្តីបន្ទោសដល់នាង ចំពោះការធ្វើឱ្យអាប់ឱនដល់កិត្តិយសគ្រួសារ[៤២] ។ ជាលទ្ធផល ក្រៅពីរបួសផ្លូវកាយ ស្ត្រីថែមទាំងរងគ្រោះដោយសារការឈឺចាប់ ភាពឯកោ តប់ប្រមល់ ខ្វះការជឿជាក់ និងភ័យខ្លាច។

ឥរិយាបថទាំងនេះធ្វើឱ្យស្ត្រីកាន់តែពិបាកក្នុងការស្វែងរកការជួយសង្គ្រោះ។ ស្ត្រីជាញឹកញាប់មានអារម្មណ៍ថាមានសម្ពាធធ្ងន់ធ្ងរពីសំណាក់ក្រុមគ្រួសារដែលមិនចង់ឱ្យគេឯងដឹង។ មានករណីមួយចំនួន ក្រុមគ្រួសារយល់ព្រមមិនឱ្យមានការផ្តន្ទាទោសដល់អ្នកប្រព្រឹត្ត ប្រសិនបើជននោះយល់ព្រមរៀបការជាមួយនឹងជនរងគ្រោះ។ នេះត្រូវបានចាត់ទុកថាជាទង្វើសំរាប់រក្សាកិត្តិយសគ្រួសារ ពីព្រោះថានារីរូបនោះត្រូវបានគេចាត់ទុកថាពុំអាចនឹងទៅរៀបការជាមួយនឹងនរណាផ្សេងទៀតឡើយ[៤៣]។ មានគ្រួសារដទៃទៀតទាមទារសំណងពីជនល្មើសក្រៅផ្លូវការ ដើម្បីចៀសវាងភាពអាម៉ាស់នៅពេលដែលមនុស្សដទៃទៀតបានដឹងរឿងនេះ[៤៤]។ ទោះបីជាយ៉ាងណាក៏ដោយ មានជនរងគ្រោះខ្លះបានស្វែងរកជំនួយពីសំណាក់អាជ្ញាធរជាផ្លូវការ និងក្រៅផ្លូវការ ដូចដែលបានពិភាក្សានៅក្នុងផ្នែកបន្ទាប់នៃការសិក្សាស្រាវជ្រាវនេះ។

## ១.៦ មធ្យោបាយដោះស្រាយតាមបែបប្រពៃណី ចំពោះអំពើហិង្សាក្នុងគ្រួសារៈ ការផ្សះផ្សា និងការលែងលះគ្នា

មនុស្សជាច្រើនដែលពាក់ព័ន្ធនឹងអំពើហិង្សាក្នុងគ្រួសារគិតថា ជាបញ្ហាឯកជន និងព្យាយាមដោះស្រាយបញ្ហាទាំងនេះដោយខ្លួនឯង ឬក៏តាមរយៈមធ្យោបាយនៅតាមមូលដ្ឋាន និងតាមរបៀបក្រៅផ្លូវការ[៤៥]។ មានសម្ពាធសង្គមយ៉ាងធ្ងន់ធ្ងរ ដែលបញ្ហានេះត្រូវបានចាត់ទុកជាបញ្ហានៅក្នុងគ្រួសារដូចដែលបាននិយាយត្រួសៗពីខាងលើមកនេះ។ ឥរិយាបថនេះនាំឱ្យនារីមានភាពរួញរាក្នុងការស្វែងរកការលែងលះគ្នា។ មនុស្សជាច្រើនជឿថានារីមិនគួរស្នើសុំលែងលះប្តីទេ ពីព្រោះកូនរបស់ពួកគេត្រូវការឪពុក។ ក៏ប៉ុន្តែកូនដែលរស់នៅក្នុងផ្ទះដែលមានការរំលោភបំពាន ទទួលការឈឺចាប់ជាងកូនដែលរស់នៅក្នុងគ្រួសារដែលមិនមានអំពើហិង្សា[៤៦] ។ ដូច្នេះការសំរេចចិត្តថា ត្រូវចាកចេញ និងលែងលះប្តីដែលជាអ្នកវាយដំ គឺជាធម្មតាមានប្រយោជន៍ដល់កូន ពុំមែននាំឱ្យគ្រោះថ្នាក់ដល់កូននោះឡើយ។

---

៤២ Ibid ទំព័រទី ១១

៤៣ Ibid ទំព័រទី ៤៧

៤៤ Ibid ទំព័រទី ៣១

៤៥ ឧទាហរណ៍ ការសិក្សារបស់ក្រុមហ៊ុន ដែលឧបត្ថម្ភដោយកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ និងក្រសួងយុត្តិធម៌ បានកត់សំគាល់ឃើញថាស្ត្រីជាងពាក់កណ្តាលនៅក្នុងការអង្កេត បាននិយាយថា នៅពេលឈ្លោះជាមួយបុរស ស្ត្រី "ចរចារដើម្បីទទួលបានលទ្ធផលល្អ" ២១%ទៀតនិយាយថាគឺនៅពេល ដែលពួកគេការពារសិទ្ធិរបស់ពួកគេ ហើយ១៨% ទៀតនិយាយថាពួកគេនឹងមិនធ្វើអ្វីឡើយ។ ២០%បាននិយាយថាពួកគេនឹងទៅរកមេភូមិ ឬឃុំ។ ឯកសាររបស់ ណឌុភ (2005) *Access to Justice* (ភ្នំពេញ) ទំព័រទី ៨៤

៤៦ ពួកគេទទួលនូវភាពតឹងតែងកាន់តែច្រើន ជាញឹកញាប់ទទួលនូវការវាយតប់ ឬការបំពារបំពាន។ ពួកគេរាយការណ៍ថា មានបញ្ហាក្នុងការដេក បញ្ហាក្នុងការផ្តោតអារម្មណ៍លើការរៀនសូត្រ និងការទៅសាលារៀន។ កូនក្មេងដែលទទួលរងនូវការបំពារបំពានច្រើនតែក្លាយទៅជាអ្នកបំពារបំពានគេ នៅពេលដែលពួកគេធំឡើង។

ទោះបីជាយ៉ាងណាក៏ដោយ នារីដែលលែងលះប្តីនឹងត្រូវប្រឈមមុខជាមួយនឹងឧបសគ្គជាច្រើន។ នៅកម្ពុជា គឺមានការពិបាកណាស់ក្នុងការរស់នៅជាម្តាយដែលគ្មានប្តី ពីព្រោះនាងជាញឹកញាប់ត្រូវបានគេគិតថាជា "នារីមិនល្អ ឬម្តាយមិនល្អ" ហើយនឹងត្រូវប្រឈម មុខជាមួយនឹងការលំបាកខាងផ្នែកសេដ្ឋកិច្ចគ្រួសារ។

ក្រុមគោលដៅរបស់អង្គការPADVក៏បានបង្ហាញឱ្យឃើញផងដែរនូវឥរិយាបថបែបនេះចំពោះការលែងលះគ្នា។ អង្គការ PADV ក៏បានសួរអ្នកចូលរួមថា តើអ្នកនឹងធ្វើដូចម្តេច ប្រសិនបើកូនប្រសាស្រីរបស់អ្នក និយាយថាចង់លែងលះគ្នានោះ ពីព្រោះកូនប្រុសរបស់អ្នកបានប្រើហិង្សាទៅលើរូបនាង។ ភាគច្រើនឆ្លើយថា ពួកគេគួរតែមានការផ្សះផ្សា និងសម្រុះសម្រួលគ្នា[៤៧]។ តាមពិតទៅមាននារី ២៣% និយាយថាពួកគេ នឹងនិយាយប្រាប់កូនប្រសាស្រីរបស់ខ្លួនអំពីភាពអាម៉ាស់ និងផលប៉ះពាល់នៃការលែងលះគ្នានេះ។

នៅទីបញ្ចប់ មានអ្នកខ្លះពុំបានជំរុញឱ្យអ្នកដទៃស្វែងរកជំនួយនោះទេ តាមរយៈការពុំសូវដាក់ទម្ងន់លើភាពធ្ងន់ធ្ងរនៃអំពើហិង្សា ដោយនិយាយថារឿងនេះតែងតែកើតឡើងនៅពេលខ្លះ ចំពោះគូស្វាមីភរិយា។ ប៉ុន្តែ អំពើហិង្សាមិនមែនជាការខ្វែងគំនិតគ្នាទេ វាគឺជាការប្រើកំលាំង ការរំលោភបំពានផ្លូវភេទ និងផ្លូវចិត្ត និងការគំរាមកំហែងផ្សេងៗ ដើម្បីគ្រប់គ្រង និងត្រួតត្រាលើការគិតយោបល់ ទស្សនៈ និងអារម្មណ៍របស់ជនរងគ្រោះ។ អំពើហិង្សា ពុំមានការពិភាក្សាស្មើភាពណាមួយអំពីគំនិតយោបល់ផ្សេងគ្នាៗនោះទេ។

ទោះជាយ៉ាងណាក៏ដោយ ជារឿយៗអាជ្ញាធរមូលដ្ឋានតាមភូមិឃុំបានចូលរួមចំណែកក្នុងការដោះស្រាយករណីលែងលះគ្នា ឬករណីអំពើហិង្សាក្នុងគ្រួសារ[៤៨]។ ជាការពិតណាស់ ចំនួនបណ្តឹងនៅថ្នាក់មូលដ្ឋានទាំងនេះ បង្ហាញឱ្យឃើញនូវការយកចិត្តទុកដាក់យ៉ាងខ្លាំងលើករណីអំពើហិង្សាក្នុងគ្រួសារ និងការលែងលះគ្នា។ តាមការស្ទង់មតិរបស់មជ្ឈមណ្ឌលសិក្សាជាន់ខ្ពស់ និងមូលនិធិអាស៊ីបានបង្ហាញថាជំលោះក្នុងគ្រួសារ រួមមានបញ្ហាដែលទាក់ទងនឹងកេរ្តិ៍មរតក ការលែងលះគ្នា ឬអំពើហិង្សាក្នុងគ្រួសារគឺជាបញ្ហាសំខាន់ទី២ដែលប្តឹងទៅអាជ្ញាធរភូមិ-ឃុំនោះ[៤៩]។ ស្រដៀងគ្នានេះផងដែរ អង្កេតរបស់ក្រុមប្រឹក្សា ឃុំ-សង្កាត់ បានបង្ហាញថា ជំលោះក្នុងគ្រួសារជាបញ្ហាសំខាន់ទី ២ ដែលមាននៅថ្នាក់ឃុំ-សង្កាត់[៥០] ។

---

[៤៧] Giles ទំព័រទី ៣៩

[៤៨] រចនាសម្ព័ន្ធរបស់រដ្ឋាភិបាលមូលដ្ឋាន រួមទាំងមេភូមិចំនួន១៣.៦៩៤ ដែលត្រូវបានតែងតាំងដោយក្រុមប្រឹក្សាឃុំ-សង្កាត់ និងក្រុមប្រឹក្សាឃុំ-សង្កាត់ ចំនួនពី៥ ទៅ១១នាក់ នៅក្នុងឃុំ-សង្កាត់ចំនួន១.៦២១។ ក្រុមប្រឹក្សាឃុំ-សង្កាត់ទាំងនេះ បានជាប់ឆ្នោតនៅក្នុងការបោះឆ្នោតលើកដំបូងបង្អស់នៅក្នុង ឆ្នាំ២០០២។ ក្រុមប្រឹក្សាឃុំ-សង្កាត់ មានអាណត្តិការងារចំនួន៥ឆ្នាំ។

[៤៩] Ninh, Kim, and Henke, Roger (2005) *Commune Councils in Cambodia: A National Survey on their Functions and Performance, with a Special Focus on Con ict Resolution,* (ភ្នំពេញ: The Asia Foundation) ទំព័រទី ៤២

[៥០] Ibid ទំព័រទី ៤៣ និង ៤៩

ករណីជំលោះក្នុងគ្រួសារ ទំនងជានឹងមានការចូលរួមធ្វើអន្តរាគមន៍មុនគេពីមេភូមិ បន្ទាប់មក នៅពេលដែលជំលោះមិនត្រូវបានដោះស្រាយ ពួកគេនឹងទៅរកចាស់ទុំឱ្យជួយ។ ហើយបន្ទាប់មកទៀត នឹងត្រូវបញ្ជូនរឿងក្តីទៅក្រុមប្រឹក្សាឃុំ-សង្កាត់[៥១] ។ ប្រជាជនកម្ពុជាពុំចង់ទៅរកតុលាការ ឬក៏អាជ្ញាធរផ្សេងៗទៀត ដោយពុំបានឆ្លងកាត់ថ្នាក់មូលដ្ឋានជាមុនឡើយ[៥២] ។

ដំណើរការសម្រុះសម្រួលគ្នាគឺមានកំរិតក្នុងករណីជំលោះក្នុងគ្រួសារ និងករណីលែងលះគ្នាៈ អាជ្ញាធរមូលដ្ឋាន មិនមានអំណាចក្នុងការផ្តល់សិទ្ធិជាក់លាក់ដល់អ្នកដែលស្វែងរកលែងលះគ្នានោះទេ។ អាជ្ញាធរមូលដ្ឋានគ្រាន់តែផ្តល់នូវវេទិកាសំរាប់ការព្រមព្រៀងគ្នា ហើយមិនមានអំណាចបង្ខិតបង្ខំឡើយ[៥៣] ។ ក្រុមប្រឹក្សាឃុំ-សង្កាត់ បានដឹងពីដែនកំណត់នៃអំណាចរបស់ពួកគេ។ ការសិក្សារបស់មូលនិធិអាស៊ី បានផ្តោតយកចិត្តទុកដាក់ ជាពិសេសក្នុងការសួរទៅក្រុមប្រឹក្សាឃុំ-សង្កាត់ ដើម្បីបញ្ជាក់អំពីប្រភេទជំលោះ ដែលពួកគេគិតថាសមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់ ពុំគួរដោះស្រាយ។ ប្រហែលជិត៥0% នៃសមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់ បានឆ្លើយថាគឺរឿងជំលោះក្នុងគ្រួសារ ដោយរួមទាំងការលែងលះគ្នា ការទទួលមរតក និងអំពើរំលោភសេពសន្ថវៈ។ ដូច្នេះហើយ គឺត្រូវការចាំបាច់នូវការស្រាវជ្រាវបន្ថែមទៀត ដើម្បីរកហេតុផលដែលធ្វើឱ្យការរារែក ព្រមទាំងផលប៉ះពាល់នៃឥរិយាបថទាំងនេះទៅលើជនដែលស្វែងរកជំនួយពីអជ្ញាធរមូលដ្ឋានទាំងនេះ[៥៤] ។

ការលែងលះគ្នាតាមផ្លូវការ គឺតាមរយៈតុលាការ។ ប្រជាពលរដ្ឋមួយចំនួនទៅរកតុលាការនៅពេលមិនមានដំណោះស្រាយនៅថ្នាក់មូលដ្ឋាន។ សំរាប់ប្រជាពលរដ្ឋភាគច្រើន ដំណោះស្រាយនេះមានតំលៃថ្លៃ និង មិនសូវងាយស្រួល ពីព្រោះតុលាការនៅឆ្ងាយពីផ្ទះសម្បែងរបស់គាត់[៥៥] ។ មានការចំណាយខ្ពស់ទៅលើការបង់ថ្លៃលើសេវាផ្នែកច្បាប់ ការធ្វើដំណើរ និងការធ្វើដំណើររបស់សាក្សី ការបង់ថ្លៃក្រៅផ្លូវការផ្សេងៗទៀត ហើយមានពេលខ្លះត្រូវចំណាយលើការធ្វើដំណើររបស់ប៉ូលីស ពីតុលាការទៅស្រុកវិញ ដើម្បីអនុវត្តក្រមតុលាការ។ ទោះបីជាយ៉ាងណាក៏ដោយ ករណីលែងលះគ្នាមានដល់ទៅ ៤0ភាគរយ នៃចំនួនពាក្យបណ្តឹងក្នុងតុលាការ ហើយមាន ៨0ភាគរយនៃរឿងក្តីទាំងនេះ ដែលអ្នកទាមទារការលែងលះគ្នាគឺជានារី[៥៦] ។ ការលែងលះគ្នាភាគច្រើន គឺកើតឡើងដោយសារតែមានការប្រព្រឹត្តិអំពើហិង្សាក្នុងគ្រួសារ ឬអាណាព្យាបាលមិនមានការទទួលខុសត្រូវ[៥៧] ។

---

[៥១] Ibid ទំព័រទី ៤៥

[៥២] Ibid ទំព័រទី ៤៧

[៥៣] UNDP ទំព័រទី ៩១

[៥៤] Ibid ទំព័រទី ៥៣ និង ៥៤

[៥៥] អ្នកផ្តល់ចំលើយជាច្រើន ៣៨% បាននិយាយថាពួកគេចាំបាច់ត្រូវធ្វើដំណើរ យ៉ាងហោចណាស់២ម៉ោង ដើម្បីទៅដល់តុលាការ។ ហើយ២៧%ទៀត បាននិយាយថាពួកគាត់ ត្រូវធ្វើដំណើររហូតដល់ទៅ៦ម៉ោង។ ប្រៀបធៀបជាមួយនឹងជំពូកទី២ នៃរបាយការណ៍នេះ។

[៥៦] UNDP ទំព័រទី ៩១

[៥៧] UNDP ទំព័រទី ៨៩

## ១.៧ ក្របខ័ណ្ឌច្បាប់បច្ចុប្បន្នសំរាប់អំពើហិង្សាក្នុងគ្រួសារនៅកម្ពុជា

មានករណីជាច្រើននៃអំពើហិង្សាក្នុងគ្រួសារ មិនត្រូវបានគេរាយការណ៍ ឬត្រូវបានគេដោះស្រាយតាមវិធីក្រៅផ្លូវការនៅថ្នាក់មូលដ្ឋាន។ ទោះជាយ៉ាងណាក៏ដោយ អំពើវាយដំ និងអំពើរំលោភសេពសន្ថវៈ គឺជាបទឧក្រិដ្ឋ ដែលមានចែងនៅក្នុងច្បាប់របស់ប្រទេសកម្ពុជា។ ច្បាប់ដែលចូលជាធរមានមានដូចខាងក្រោមនេះ:

### ១.៧.១ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

រដ្ឋធម្មនុញ្ញ គឺជាច្បាប់មូលដ្ឋានគ្រឹះសំរាប់ការពារស្ត្រី និងកុមារពីអំពើហិង្សាក្នុងគ្រួសារ។ ច្បាប់នេះចែងដូចតទៅ:

- សិទ្ធិក្នុងការរស់រានមានជីវិត សេរីភាព និងសុវត្ថិភាពផ្ទាល់ខ្លួន (មាត្រា ៣២)
- ច្បាប់ត្រូវធានាថាគ្មានការបំពានលើរាងកាយដល់បុគ្គលណាម្នាក់ឡើយ (មាត្រា ៣៨)
- សិទ្ធិស្មើភាពគ្នារវាងបុរស និងនារីនៅចំពោះមុខច្បាប់ (មាត្រា ៣១)
- ការការពារពីការរើសអើងយេនឌ័រ (មាត្រា ៤៥)
- ការការពារសិទ្ធិកុមារ (មាត្រា ៤៨)
- សិទ្ធិក្នុងការថែទាំសុខភាព (មាត្រា ៧២)

### ១.៧.២ បទបញ្ញត្តិទាក់ទងនឹងច្បាប់ និងនីតិវិធីតុលាការ និងព្រហ្មទណ្ឌដែលអនុវត្តន៍នៅកម្ពុជា នៅក្នុងរយៈពេលអន្តរកាល (ច្បាប់អ៊ុនតាក់)

មាន ច ្រ ា បេ ព៍ ក្នុងករណីនៃការវាយដំធ្ងន់ធ្ងរ ង េ ្រទ អំពើរំលោភសេពសន្ថវៈ ការបៀតបៀនកេរ្តិ៍ខ្មាស ជាអំពើខុសច្បាប់ដែលមានចែងនៅក្នុងច្បាប់ព្រហ្មទណ្ឌរបស់អ៊ុនតាក់។ អំពើរំលោភសេពសន្ថវៈក៏ជាឧក្រិដ្ឋកម្មមួយនៅក្នុងមាត្រា៩នៃច្បាប់ ស្តីពីការធ្វើបាបធ្ងន់ធ្ងរនៃ បទឧក្រិដ្ឋឆ្នាំ ២០០១។

ប៉ុន្តែចំពោះការអនុវត្តន៍ស្តង់ដាសំរាប់បង្ហាញភស្តុតាងថា ជាករណីបទឧក្រិដ្ឋ គឺមានការលំបាកណាស់សំរាប់នារីក្នុងការបន្តធ្វើការចោទប្រកាន់ពីបទឧក្រិដ្ឋ។ ទោះបីជាច្បាប់ ផ្តល់ឱ្យមានការពិនិត្យខាងនីតិវេជ្ជវិទ្យា ដោយសេរីសំរាប់ជនរងគ្រោះក៏ដោយ ក៏មានស្ត្រីរាយការណ៍ថាជាធម្មតាពួកគេត្រូវតែបង់ប្រាក់កាសសំរាប់ការពិនិត្យនេះ ដែលមានតំលៃថ្លៃជាងការចំណាយផ្លូវច្បាប់ផ្សេងៗ និងចំណាយលើការធ្វើដំណើរទៅកាន់តុលាការ ដែលនៅឆ្ងាយពីកន្លែងរស់នៅ។ ស្ត្រីបានប្រាប់ថាពួកគេបានជួបប្រទះការពិនិត្យដោយមិនសមរម្យ និងមិនល្អ ហើយគ្រូពេទ្យជារឿយៗមិនគោរពជនរងគ្រោះ។ជាលទ្ធផលស្ត្រីមានការរារែកក្នុងការទៅទទួលការពិនិត្យ ដូច្នេះ ស្ត្រីហាក់បីដូចជាពុំអាចបង្ហាញនូវភស្តុតាងសំរាប់ការចោទប្រកាន់ពីបទឧក្រិដ្ឋនេះទេ។ ស្ត្រីបានរាយការណ៍ថា គឺមានការ

លំបាកក្នុងការទទួលបាននូវភស្តុតាងចាំបាច់សំរាប់ចោទ ទៅជាករណីឧក្រិដ្ឋព្រហ្មទណ្ឌ ដូច្នេះការកាត់ទោសប្តីដែលប្រព្រឹត្តអំពើហិង្សាលើប្រពន្ធមានតិចតួចណាស់ ។ ទោះបីជាអំពើរំលោភសេពសន្ថវៈគឺជាអំពើឧក្រិដ្ឋនៅកម្ពុជាក៏ដោយ ក៏ករណីនៃការរួមភេទដោយបង្ខិតបង្ខំពុំត្រូវបានចាត់ទុកថាជាបទឧក្រិដ្ឋ នៅពេលដែលការពិតនេះកើតឡើងចំពោះគូស្វាមីភរិយានោះទេ ។

### ១.៧.៣ ច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ

យោងទៅតាមនិយមន័យនៅក្នុងច្បាប់អំពើហិង្សាក្នុងគ្រួសារ អំពើហិង្សាក្នុងគ្រួសារ រួមមានអំពើហិង្សាផ្លូវកាយ ផ្លូវចិត្ត ឬសេដ្ឋកិច្ច ។ និយមន័យនេះក៏រួមបញ្ចូលទាំងការគំរាមគំហែង ឬសំលុតជនរងគ្រោះផងដែរ ។ ច្បាប់ការពារប្តី ប្រពន្ធ កូនក្រោមបន្ទុក និងសមាជិកគ្រួសារផ្សេងៗទៀត ដែលរស់នៅក្នុងដំបូលផ្ទះតែមួយ ។ ច្បាប់បានផ្តល់អំណាចដល់អាជ្ញាធរមូលដ្ឋានក្នុងការចូលធ្វើអន្តរាគមន៍ និងការពារ តាមរយៈដីការការពារ ដែលនឹងចេញដោយតុលាការខេត្ត ។

### ១.៧.៤ មធ្យោបាយដោះស្រាយតាមបែបរដ្ឋបាលនៅកម្ពុជា

ជាជំរើសមួយផ្សេងទៀត មនុស្សមួយចំនួន ពឹងផ្អែកទៅលើវិធានការដោះស្រាយតាមផ្លូវរដ្ឋបាលរបស់អាជ្ញាធរមូលដ្ឋាន ដូចជាអាជ្ញាធរស្រុក ឬក្រុមប្រឹក្សាឃុំ-សង្កាត់ជាដើម ។ មេឃុំ ឬចៅសង្កាត់ជាអ្នកទទួលខុសត្រូវទៅលើសុវត្ថិភាពនៅក្នុងឃុំ-សង្កាត់របស់ខ្លួន ។ ទោះជាយ៉ាងណាក៏ដោយ មានប្រភពព័ត៌មានជាច្រើននិយាយថា ភារកិច្ចទាំងនេះពុំត្រូវបានអនុវត្តជាប្រចាំនោះទេ ។ នៅពេលមេឃុំ និងមេភូមិ ឬក៏អាជ្ញាធរដទៃទៀត ធ្វើការផ្សះផ្សាគូស្វាមីភរិយាទៅតាមទំលាប់ប្រពៃណី ពួកគេកម្រនឹងធ្វើអន្តរាគមន៍ផ្តល់ការការពារដល់ជនរងគ្រោះណាស់ ។

### ១.៧.៥ ច្បាប់អន្តរជាតិ

ប្រទេសកម្ពុជាបានអនុម័តសន្ធិសញ្ញាអន្តរជាតិ និងបានចុះហត្ថលេខាលើសេចក្តីប្រកាសអន្តរជាតិមួយចំនួនពាក់ព័ន្ធជាមួយនឹងអំពើហិង្សាលើបុរស-នារី និងកុមារ ។ ឯកសារអន្តរជាតិទាំងនេះផ្តល់ជាមូលដ្ឋានគ្រឹះ សំរាប់ពង្រឹងការអនុវត្តន៍ច្បាប់ហាមឃាត់អំពើហិង្សាក្នុងគ្រួសារ និងដោះស្រាយតំរូវការ និងការព្រួយបារម្ភរបស់នារី ដែលត្រូវគេរំលោភបំពាន ។

### សេចក្ដីប្រកាសជាសកលនៃសិទ្ធិមនុស្ស (១៩៤៨)

- មនុស្សគ្រប់រូបមានសិទ្ធិរស់រានមានជីវិត សេរីភាព និងសុវត្ថិភាពក្នុងការរស់នៅ ។
- គ្មាននរណាម្នាក់នឹងត្រូវបានជាឧបករណ៍សំរាប់គេធ្វើបាប និងប្រើអំពើឃោរឃៅ និងទទួលនូវភាពអមនុស្សធម៌ ឬអាប់អោន និងដាក់ទណ្ឌកម្មឡើយ ។

### សេចក្ដីប្រកាសរបស់អង្គការសហប្រជាជាតិស្ដីពីការលុបបំបាត់អំពើហិង្សាប្រឆាំងនឹងស្ដ្រី (១៩៩៣)

*សេចក្ដីប្រកាសនេះ ផ្ដល់នូវនិយមន័យនៃអំពើហិង្សាប្រឆាំងនឹងស្ដ្រី*

អំពើហិង្សាប្រឆាំងនឹងស្ដ្រី ជាអំពើហិង្សាយេនឌ័រ ដែលធ្វើឱ្យមានគ្រោះថ្នាក់កើតឡើង ឬបំរុងនឹងកើតឡើង ទាំងផ្លូវកាយ ផ្លូវភេទ ឬផ្លូវចិត្តលើនារី ដោយរួមទាំងការគំរាមកំហែងការបង្ខិតបង្ខំ ឬការរំលោភបំពានលើសេរីភាពរស់នៅ ដែលកើតឡើងជាសាធារណៈ ឬជីវិតផ្ទាល់ខ្លួន ។

អំពើហិង្សាប្រឆាំងនឹងស្ដ្រី រាប់បញ្ចូលសកម្មភាពដូចជាៈ អំពើហិង្សាផ្លូវកាយ ផ្លូវភេទ និងផ្លូវចិត្ត ដែលកើតឡើងក្នុងគ្រួសារ មានដូចជា ការវាយដំ ការរំលោភបំពានផ្លូវភេទលើស្ដ្រី-កុមារីនៅក្នុងគ្រួសារ និងអំពើហិង្សាពាក់ព័ន្ធនឹងចំណងដៃខាន់ស្លាអំពើរំលោភសេពសន្ថវៈក្នុងចំណងអាពាហ៍ពិពាហ៍ ការធ្វើឱ្យមានការឈឺចាប់លើសរីរាង្គភេទរបស់ស្ដ្រី និងការអនុវត្តន៍តាមបែបប្រពៃណីណាមួយ ដែលធ្វើឱ្យមានគ្រោះថ្នាក់ដល់ស្ដ្រី និងអំពើហិង្សាដែលកើតឡើងរវាងអ្នកមិនមែនជាសហព័ទ្ធ ក្នុងន័យកេងប្រវ័ញ្ចន៍ ។

### អនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រី (១៩៧៩)

អំពើហិង្សាប្រឆាំងនឹងនារី មិនត្រូវបានបញ្ជាក់ឱ្យបានច្បាស់លាស់នៅក្នុងអនុសញ្ញានេះទេ។ ទោះបីជាយ៉ាងណាក៏ដោយ គណៈកម្មាធិការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រី ដែលមានតួនាទីទទួលខុសត្រូវ ពិនិត្យការអនុវត្តន៍អនុសញ្ញានេះបានចែងយ៉ាងច្បាស់នៅក្នុងអនុសាសន៍ទូទៅលេខ ១៩ (១៩៩២) ដែលមានអត្ថន័យថាអំពើហិង្សាប្រឆាំងនឹងស្ត្រី គឺជាអំពើមួយដែលចាត់ទុកថាការរំលោភបំពានលើអនុសញ្ញានេះ។

យោងតាមអនុសាសន៍របស់គណៈកម្មាធិការ អំពើហិង្សាប្រឆាំងនឹងស្ត្រី គឺជាការរំលោភបំពានលើសិទ្ធិនារីដែលបានចែងនៅក្នុងអនុសញ្ញានេះៈ សិទ្ធិរស់រានមានជីវិត គ្មាននរណាម្នាក់នឹងត្រូវបានជាឧបករណ៍សំរាប់គេធ្វើបាប និងប្រើអំពើឃោរឃៅ សិទ្ធិមានសេរីភាព និងសុវត្ថិភាពក្នុងការរស់នៅ សិទ្ធិស្មើគ្នាក្នុងការទទួលបានការពារពីច្បាប់ សិទ្ធិស្មើភាពគ្នាក្នុងគ្រួសារ និងសិទ្ធិក្នុងការទទួលបាននូវស្តង់ដាសេវាសុខភាព។

ដើម្បីឱ្យស្របទៅនឹងអនុសាសន៍នេះ គណៈកម្មាធិការបានបញ្ជាក់យ៉ាងច្បាស់លាស់ អំពីកាតព្វកិច្ចរបស់រដ្ឋភាគីនៅក្នុងអនុសញ្ញានេះ រួមមានជំហាននានាដូចតទៅៈ

- ចាត់វិធានការឱ្យបានសមរម្យ និងមានប្រសិទ្ធភាពក្នុងការដោះស្រាយបញ្ហាអំពើហិង្សាយេនឌ័រ មិនថាជាសកម្មភាពសាធារណៈ ឬឯកជននោះឡើយ។
- ផ្តល់នូវនិតិវិធីតវ៉ា និងមធ្យោបាយដោះស្រាយប្រកបដោយប្រសិទ្ធភាព រួមទាំងការទូទាត់សងជំងឺចិត្តផងដែរ។
- បង្កើត និងគាំទ្រសេវានានា សំរាប់ជនរងគ្រោះ ដោយសារអំពីហិង្សាយេនឌ័រ។
- ចាត់វិធានការផ្នែកច្បាប់ និងវិធានការទប់ស្កាត់ប្រកបដោយប្រសិទ្ធភាព ដែលចាំបាច់ក្នុងការការពារដល់ជនរងគ្រោះដោយអំពើហិង្សាយេនឌ័រ។

### អនុសញ្ញាស្តីពីសិទ្ធិកុមារ ឆ្នាំ (១៩៨៩)

- កុមារ (អាយុក្រោម ១៨ ឆ្នាំ) នឹងត្រូវបានការពារពីអំពើហិង្សាផ្លូវកាយគ្រប់រូបភាពឬការរំលោភបំពានផ្លូវចិត្តពីសំណាក់ឪពុកម្តាយឬអាណាព្យាបាលដោយរួមទាំងការធ្វើទារុណកម្មយ៉ាងឃោរឃៅ ការមិនរវីរវល់ ការរំលោភបំពានផ្លូវភេទ និងការកេងប្រវ័ញ្ចន៍ជាដើម។
- ឪពុកម្តាយ/អាណាព្យាបាល មានសិទ្ធិ និង(កាតព្វកិច្ច) ក្នុងការបង្ហាញទិសដៅដល់កុមារឱ្យសមស្រប និងលទ្ធភាពរបស់កុមារនោះ។

## ១.៨ ក្របខ័ណ្ឌគោលនយោបាយបច្ចុប្បន្ន សំរាប់អំពើហិង្សាក្នុងគ្រួសារ

រាជរដ្ឋាភិបាលកម្ពុជា បានរៀបចំនូវសេចក្តីថ្លែងការផ្តែកគោលនយោបាយសំខាន់ៗមួយចំនួនអំពីសារៈសំខាន់របស់ស្ត្រីជាទូទៅ និងពិសេសអំពីអំពើហិង្សាក្នុងគ្រួសារ។ រាជរដ្ឋាភិបាលកម្ពុជាបានបញ្ជាក់អំពីការប្តេជ្ញាចិត្តក្នុងការកាត់បន្ថយអំពើហិង្សាក្នុងគ្រួសារ ដោយបានបញ្ចូលបញ្ហាប្រឈមមុខនេះទៅក្នុងគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា។ គោលបំណងនៃគោលដៅទាំងនេះរួមមានៈ សកម្មភាពជាក់លាក់ ចាប់ពីកំណែទំរង់ច្បាប់ និងការសិក្សាស្រាវជ្រាវរហូតដល់ការរៀបចំកម្មវិធីទប់ស្កាត់ និងពិគ្រោះបញ្ហាឱ្យបានច្បាស់លាស់ ដូចដែលបានបង្ហាញនៅក្នុងតារាងខាងក្រោម។ ដោយផ្អែកលើដំណើរការពិគ្រោះយោបល់ទូទៅ និងទូលំទូលាយ ដើម្បីពិភាក្សាឱ្យកាន់តែស៊ីជំរៅអំពីបញ្ហាប្រឈមមុខនៅកម្ពុជា មកនៅត្រឹមតែគោលដៅអាទិភាពចំនួន៩នោះ ឆ្លុះបញ្ចាំងពីការប្តេជ្ញាយ៉ាងខ្លាំងលើបញ្ហាទាំងនេះ។ ដំណើរការនៃការកំណត់គោលដៅអាទិភាពសំរាប់គោលដៅអភិវឌ្ឍន៍ សហស្សវត្សរ៍ មានរួមបញ្ចូលនូវយោបល់របស់បុគ្គល និងអង្គការនានានៅក្នុងប្រទេសកម្ពុជា ដូច្នេះការដាក់បញ្ចូលអំពើហិង្សាក្នុងគ្រួសារនៅក្នុងគោលដៅទាំងនេះបង្ហាញនូវការគាំទ្រពីសារធារណៈជនទូទៅ។ ខាងក្រោមនេះគឺដកស្រង់ចេញពី គ.អ.ស.ក។

### សេចក្តីដកស្រង់ចេញពីគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា

**ទិសដៅទូទៅ ៨:** កាត់បន្ថយរាល់ទម្រង់នៃអំពើហិង្សាប្រឆាំងនឹងស្ត្រី និងកុមារ

| | |
|---|---|
| **ទិសដៅ ៣.១៦:** | បង្កើត និងអនុវត្តច្បាប់ប្រឆាំងនឹងអំពើហិង្សាគ្រប់រូបភាពលើនារី និងកុមារស្របទៅតាមតំរូវការចាំបាច់ និងស្តង់ដាអន្តរជាតិនៅ ឆ្នាំ ២០០៥។ |
| **ទិសដៅ ៣.១៧:** | ប្រមូលទិន្នន័យស្ថិតិប្រចាំឆ្នាំដើម្បីត្រួតពិនិត្យអំពើហិង្សាលើនារី នៅឆ្នាំ ២០០៥។ |
| **ទិសដៅ ៣.១៨:** | បង្កើនអត្រានៃការយល់ដឹងរបស់ប្រជាជនពលរដ្ឋអំពីអំពើហិង្សាលើនារីថាជាឥរិយាបថខុសឆ្គង និងជាអំពើឧក្រិដ្ឋ ឱ្យបានដល់ ១០០% នៅឆ្នាំ ២០១៥។ |
| **ទិសដៅ ៣.១៩:** | បង្កើត និងអនុវត្តផែនការទប់ស្កាត់ នៅឆ្នាំ ២០០៥ |
| **ទិសដៅ ៣.២០:** | បង្កើនឱ្យបានដល់ ១០០% នៅក្នុងឆ្នាំ ២០១៥ នូវអត្រាផ្តល់សេវាពិគ្រោះបញ្ហាអំពើហិង្សាក្នុងគ្រួសារ ដោយអ្នកជំនាញឯកទេសច្បាស់លាស់។ |

ចាប់តាំងពីគោលដៅ និងទិសដៅទាំងនេះ ត្រូវបានអនុម័តមក រាជរដ្ឋាភិបាលកម្ពុជា បានធ្វើការឆ្លើយតបដោយជោគជ័យនៅក្នុងបញ្ហានេះ និងដោយមានការប្រុងប្រយ័ត្ន។ របាយការណ៍ត្រួតពិនិត្យរបស់រាជរដ្ឋាភិបាលនៅឆ្នាំ ២០០៣ បានកត់សំគាល់ថា " សមភាពយេនឌ័រ នៅតែជាបញ្ហាចំបងនៅក្នុងផ្នែកមួយភាគធំនៃវិស័យសង្គមកិច្ច សេដ្ឋកិច្ច ទោះបីជារដ្ឋាភិបាលបានប្តេជ្ញាចិត្តយ៉ាងច្បាស់លាស់ដើម្បីបង្កើនភាពអង់អាចរបស់ស្ត្រីក៏ដោយ។ មកដល់បច្ចុប្បន្ននេះ គឺជាការឆាប់រហ័សពេកនៅក្នុងការ

វាយតំលៃថា តើគោលដៅទាំងនេះបានសំរេចដែរឬទេ។ ទោះជាយ៉ាងនេះក៏ដោយការប្រឈមមុខគឺមានទំហំធំធេង ដោយហេតុថា ការបញ្ជ្រាបយេនឌ័រនៅក្នុងដំណើរការរៀបចំគោលនយោបាយ និងទំហំនៃការផ្លាស់ប្តូរអាកប្បកិរិយា និងឥរិយាបថ តំរូវឱ្យសំរេចឱ្យបាននៅឆ្នាំ ២០១៥ "[៥៨]។

រាជរដ្ឋាភិបាល ក៏បានបញ្ជាក់ផងដែរអំពីការប្តេជ្ញាចិត្តរបស់ខ្លួន ចំពោះស្ត្រីក្នុងយុទ្ធសាស្ត្រចតុកោណសំរាប់ការរីកចំរើន ការងារ សមធម៌ និងប្រសិទ្ធភាព ដែលយុទ្ធសាស្ត្រនេះ ត្រូវបានផ្សព្វផ្សាយនៅខែកក្កដា ឆ្នាំ ២០០៤។ ឯកសារគោលនយោបាយគ្រប់ជ្រុងជ្រោយនេះទទួលស្គាល់ថា *"នារីជាឆ្អឹងខ្នងនៃសេដ្ឋកិច្ច និងសង្គមជាតិយើង"*។ ក្នុងយុទ្ធសាស្ត្រចតុកោណ មានគោលបំណងផ្តល់ឱ្យនារីខ្មែរនូវគុណតំលៃ និងក្តីសង្ឃឹមក្នុងឆាកជីវិតតាមរយៈការលើកកំពស់ការបញ្ជ្រាបយេនឌ័រ។ យុទ្ធសាស្ត្រនេះផ្តល់ "អាទិភាពខ្ពស់ក្នុងការជំរុញឱ្យប្រសើរឡើងនូវតួនាទី និងឋានៈសង្គមរបស់នារីខ្មែរ ដោយផ្តោតការយកចិត្តទុកដាក់ជាសំខាន់លើការអនុវត្តន៍យុទ្ធសាស្ត្រយេនឌ័រ ការបង្កើនសមត្ថភាព ចំណេះដឹងដល់ស្ត្រីនៅគ្រប់វិស័យ កែប្រែឥរិយាបថសង្គមដែលរើសអើងលើស្ត្រី និងធានានូវសិទ្ធិរបស់ស្ត្រីនៅក្នុងចូលរួមយ៉ាងសកម្ម និងស្មើភាពការកសាងប្រទេសជាតិ"។

សេចក្តីថ្លែងការគោលនយោបាយទាំងនេះ ត្រូវបានរៀបចំឡើងបន្តពីគោលនយោបាយដំបូងរបស់រដ្ឋាភិបាលមានឈ្មោះថា **នារីរតនៈ** *(នារីជារតនៈសម្បត្តិ)*។ ការផ្តួចផ្តើមនេះ ធ្វើឡើងដោយក្រសួងកិច្ចការនារី និងអតីតយុវជននៅឆ្នាំ ១៩៩៩ ដើម្បីបង្ហាញពី *"ទិដ្ឋភាពថ្មីរបស់នារីខ្មែរដែលបានផ្លាស់ប្តូរពីក្រុមរងគ្រោះទៅជាមនុស្សដែលមានគុណតំលៃមិនអាចកាត់ថ្លៃបានរបស់ជាតិនិងជាសក្តានុពលនៃសេដ្ឋកិច្ចជាតិ*"។ នារីរតនៈ បង្ហាញអំពីទស្សនវិស័យ និងផែនការ៥ឆ្នាំ របស់ក្រសួងកិច្ចការនារី ដើម្បីបំពេញបន្ថែមលើការងាររបស់ក្រសួងដទៃទៀត ដែលសកម្មភាពរបស់ក្រសួងទាំងនេះមានផលប៉ះពាល់ដល់ស្ត្រី។

ផែនការយុទ្ធសាស្ត្ររយៈពេល៥ឆ្នាំ "នារីរតនៈទី២" "បានថែងយ៉ាងខ្លាំងក្លា អំពីអំពើហិង្សាក្នុងគ្រួសារ" អំពើហិង្សាប្រឆាំងនិងស្ត្រី គឺប្រឆាំងនឹងច្បាប់ ការរំលោភបំពានលើសិទ្ធិស្ត្រី និងធ្វើឱ្យប៉ះពាល់ដល់ផ្លូវចិត្ត និងផ្លូវកាយរបស់ស្ត្រី។ អំពើហិង្សាក្នុងគ្រួសារ អំពើរំលោភសេពសន្ថវៈរាប់ទាំងការរំលោភរបស់ក្រុមបងធំ អំពើហិង្សាលើអ្នករកស៊ីផ្លូវភេទ និងការជួញដូរមនុស្សដែលអំពើទាំងអស់នេះមានការទាក់ទងដល់ស្ត្រី ក្មេងស្រី និងសូម្បីតែក្មេងតូចៗគឺជាបញ្ហាចំបង។ ត្រូវការចាំបាច់បន្ទាន់ក្នុងការការពង្រីកសេវាពិគ្រោះបញ្ហាសំរាប់អំពើហិង្សាប្រឆាំងនឹងស្ត្រី និងបុរស និងក្មេងប្រុស ដែលជាអ្នកប្រព្រឹត្តអំពើហិង្សា។ ត្រូវការចាំបាច់ជាបន្ទាន់ផងដែរ គឺការប្រមូលទិន្នន័យដែលអាចទុកចិត្តបានស្តីអំពីទិដ្ឋភាពទាំងឡាយនៃបញ្ហាអំពើហិង្សាលើស្ត្រី និងកុមារ[៥៩]។

---

៥៨ របាយការណ៍របស់រាជរដ្ឋាភិបាល ស្តីពីគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា ឆ្នាំ២០០៣ (ភ្នំពេញ)

៥៩ ផែនការនារីរតនៈទី២ ទំព័រទី ១០

នារីរតនៈទី២ បានបញ្ជាក់អំពីតំរូវការផ្នែកច្បាប់ និងនយោបាយផ្សេងៗទៀត ដើម្បីកាត់បន្ថយអំពើហិង្សាក្នុងគ្រួសារ ។ "ប្រទេសកម្ពុជាមានមូលដ្ឋានល្អសំរាប់ក្របខ័ណ្ឌច្បាប់រួចទៅហើយ មាននៅក្នុងរដ្ឋធម្មនុញ្ញ ប៉ុន្តែចាំបាច់ត្រូវពង្រឹងស្ថាប័ននីតិបញ្ញត្តិ ត្រូវអនុវត្តការពង្រឹងច្បាប់ និងមិនត្រូវធ្វើឱ្យស្ត្រីក្លាយជាជនរងគ្រោះជាលើកទី២ ។ ចាំបាច់ត្រូវពិនិត្យលើច្បាប់ ដែលចូលជាធរមាន រកមើលភាពលំអៀងផ្នែកយេនឌ័រ ឬថាតើមានការដោះស្រាយបញ្ហាកង្វល់យេនឌ័រដែរឬទេ ។ ការងារនេះរាប់បញ្ចូលទាំងការពិនិត្យយ៉ាងហ្មត់ចត់លើក្រមព្រហ្មទណ្ឌ និងក្រមរដ្ឋប្បវេណី ។ ចាំបាច់ត្រូវឆ្លងច្បាប់ថ្មីស្តីពីអំពើហិង្សាក្នុងគ្រួសារ និងការជួញដូរ និងអនុស្សរណៈស្តីពីការយោគយល់គ្នាប្រឆាំងនឹងអំពើជួញដូរមនុស្ស ជាមួយប្រទេសជិតខាង"[៦០] ។

សេចក្តីថ្លែងការណ៍រួមមាន សេចក្តីថ្លែងការណ៍នៅក្នុងគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា យុទ្ធសាស្ត្រចតុកោណនិងនារីរតនៈ បានបញ្ជាក់យ៉ាងច្បាស់លាស់ថាអំពើហិង្សាក្នុងគ្រួសារជាអាទិភាពរបស់រាជរដ្ឋាភិបាលកម្ពុជា ។ ទោះបីយ៉ាងនេះក៏ដោយ ក៏នៅតែមានឧបសគ្គជាច្រើន ដែលរារាំងដល់ការសំរេចបាននូវគោលបំណងទាំងនេះ និងរាំងស្ទះដល់ការបញ្ឈប់អំពើហិង្សាក្នុងគ្រួសារ ។

ការសិក្សាស្រាវជ្រាវនេះ មានគោលបំណង ធ្វើការប៉ាន់ប្រមាណអំពីបញ្ហា និងផលប៉ះពាល់ដល់ប្រទេសកម្ពុជា ព្រមទាំងឥរិយាបថចំពោះអំពើហិង្សាក្នុងគ្រួសារ ។ នៅទីបញ្ចប់ការសិក្សាស្រាវជ្រាវនេះនឹងជួយឱ្យប្រទេសកម្ពុជាឈានទៅសំរេចគោលដៅអភិវឌ្ឍន៍ផ្សេងទៀត ។

---

៦០ Ibid

## ២. លទ្ធផលនៃការសិក្សាស្រាវជ្រាវ

ទោះបីជាពាក្យថាអំពើហិង្សាក្នុងគ្រួសារ រួមបញ្ចូលទាំងស្ត្រី ដែលប្រព្រឹត្តិអំពើហិង្សាលើបុរស ប៉ុន្តែករណីភាគច្រើនគឺផ្តោតលើបុរសដែលប្រើអំពើហិង្សាលើស្ត្រី[៦១] ។ ការសិក្សានេះមានព័ត៌មានមួយចំនួនស្តីពីប្រពន្ធប្រើអំពើហិង្សាលើប្តី និងឥទ្ធិពលនៃអំពើហិង្សាដែលប្រព្រឹត្តិដោយឪពុកម្តាយទៅលើកូនចៅ ប៉ុន្តែគោលបំណងចំបងរបស់ការសិក្សានេះ គឺផ្តោតលើអំពើហិង្សាប្រឆាំងនឹងស្ត្រី[៦២] ។ ការសិក្សាស្រាវជ្រាវអំពីអំពើហិង្សាទៅលើកុមារ ត្រូវបានធ្វើឡើងដោយអ្នកពាក់ពន្ធ័មួយចំនួនរួចទៅហើយ ហេតុដូច្នេះហើយ ការសិក្សានេះពុំបានពិភាក្សាអំពីអំពើហិង្សាទៅលើកុមារឡើយ[៦៣] ។

ការសិក្សាស្រាវជ្រាវ មានគោលបំណងប៉ាន់ប្រមាណអំពីឥរិយាបថ ចំពោះអំពើហិង្សាក្នុងគ្រួសារ។ ដោយសារតែរឿងរ៉ាវជុំវិញអំពើហិង្សាក្នុងគ្រួសារ មានលក្ខណៈស្មុគស្មាញ នោះការសិក្សាស្រាវជ្រាវក៏បានផ្តោតទៅលើបញ្ហាផ្សេងៗផងដែរ ។ លទ្ធផលនៃការអង្កេតត្រូវបានរៀបចំដូចតទៅៈ

- ការបំពានផ្លូវកាយ
  - ឥរិយាបថ ចំពោះអំពើហិង្សាក្នុងគ្រួសារ
  - បទពិសោធន៍ទទួលរងគ្រោះដោយសារអំពើហិង្សាក្នុងគ្រួសារ
  - ផលប៉ះពាល់នៃអំពើហិង្សាផ្លូវកាយ
  - ការប្រើគ្រឿងស្រវឹង ដែលបណ្តាលឱ្យមានអំពើហិង្សាក្នុងគ្រួសារ
- ការបំពានផ្លូវចិត្ត
- ការរំលោភសេពសន្ថវៈ និងការរំលោភសេពសន្ថវៈក្នុងចំណងអាពាហ៍ពិពាហ៍
- ការស្វែងរកជំនួយ
- ទស្សនៈរបស់អាជ្ញាធរមូលដ្ឋាន និងប៉ូលីស
- សិទ្ធិរបស់ប្រជាពលរដ្ឋខ្មែរ ។

---

៦១ ការសិក្សានេះ ផ្តោតលើអំពើហិង្សាប្រឆាំងនឹងស្ត្រី ក្នុងគោលបំណងសំរាប់យកទៅប្រើជាឧបករណ៍ដើម្បីអនុវត្តគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជាលើគោលដៅស្តីពីអំពើហិង្សាក្នុងគ្រួសារ ដែលពុំបានបញ្ចូលអំពើហិង្សាលើបុរសឡើយ ។

៦២ ការសិក្សានេះ ពុំបានពិភាក្សាលើអំពើហិង្សាក្នុងគ្រួសារ ទៅលើអ្នកធ្វើការផ្ទះឡើយ ។ ការសិក្សានេះផ្តោតតែលើអំពើហិង្សាប្រឆាំងនឹងស្ត្រី ដូចចែងនៅក្នុងគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា ។

៦៣ សំរាប់ព័ត៌មានបន្ថែមស្តីពីអំពើហិង្សាលើកុមារ សូមអានការសិក្សាថ្នាក់ជាតិរបស់ក្រសួងអប់រំ យុវជន និងកីឡា (ឆ្នាំ២០០៥) ស្តីពីឥរិយាបថប្រថុយនឹងគ្រោះថ្នាក់របស់យុវជន យុវនារី និង Tearfund (ឆ្នាំ២០០៥) Stop Violence Against Us (ភ្នំពេញ)

## ២.១ ការបំពានផ្លូវកាយ

### ២.១.១ ឥរិយាបថ ចំពោះអំពើហិង្សាក្នុងគ្រួសារ

ការអង្កេតនេះ បានផ្តោតឥរិយាបថចំពោះអំពើហិង្សារវាងប្តី និងប្រពន្ធ និងអំពើហិង្សាដែលបង្កឡើងដោយសមាជិកផ្សេងៗទៀតនៅក្នុងគ្រួសារផងដែរ។ អ្នកផ្តល់ចំលើយបានឆ្លើយ អំពើហិង្សាដោយប្រើពាក្យសំដី ដូចជាការស្រែកគំហ៊ក ការជេរបញ្ជោរ និងរូបភាពផ្សេងៗទៀតនៃអំពើហិង្សាផ្លូវកាយ ក៏ដូចជាការគប់ ឬចោលអ្វីមួយទៅលើមនុស្សម្នាក់ទៀត ដូចជាអំពើហិង្សាដ៏ឃោរឃៅរហូតដល់ទៅរូបភាពធ្ងន់ធ្ងរបំផុត គឺការជះទឹកអាស៊ីដ ការចាក់ ឬការបាញ់។ អ្នកផ្តល់ចំលើយបានរៀបរាប់អំពីការយល់ដឹងរបស់ពួកគេ អំពីច្បាប់ដែលអនុវត្តចំពោះអំពើហិង្សា និងមធ្យោបាយនៅក្នុងការទទួលបានជំនួយ។ ការអង្កេតនេះក៏ផ្តោតការយកចិត្តទុកដាក់ផងដែរ លើអ្វីដែលមានឥទ្ធិពលទៅលើឥរិយាបថរបស់បុរសចំពោះនារី និងការទទួលយករបស់នារីចំពោះឥរិយាបថនេះផងដែរ។

អ្នកផ្តល់ចំលើយ បានឆ្លើយអំពីកំរិតនៃការទទួលយកចំពោះប្រភេទផ្សេងៗនៃអំពើហិង្សាដែលរៀបតាមលំដាប់លំដោយ ចាប់ពីអាចទទួលយកបាន រហូតដល់មិនអាចទទួលយកបាន។ ជាពិសេសអ្នកផ្តល់ចំលើយ បានឆ្លើយអំពីកំរិតខុសគ្នាចំពោះការប្រព្រឹត្តិ ដែលរៀបតាមលំដាប់លំដោយពីលេខ ១ ដល់លេខ ៥ ដែលលេខ ១ គឺជានិច្ចជាកាលអាចទទួលយកបាន ហើយលេខ៥ មិនអាចទទួលយកបានទាល់តែសោះ។ សកម្មភាពទាំងនេះបានរៀបតាមលំដាប់លំដោយ គឺចាប់ពីការពិភាក្សាដោយសន្តិវិធីរហូតដល់អំពើហិង្សាដ៏ធ្ងន់ធ្ងរ ដែលអាចបណ្តាលឱ្យស្លាប់។ ពេលដែលកំរិតនៃអំពើហិង្សាកើនឡើង អ្នកផ្តល់ចំលើយភាគច្រើនហាក់ដូចជាវាយតំលៃថា សកម្មភាពទាំងនេះមិនអាចទទួលយកបានទេ។ នៅក្នុងករណីជាច្រើនស្ត្រីបង្ហាញនូវការអត់ឱនច្រើនចំពោះអំពើហិង្សា។

អ្នកផ្តល់ចំលើយមួយចំនួនធំ បាននិយាយថាអំពើហិង្សាដែលប្រព្រឹត្តឡើងដោយប្តីទៅលើប្រពន្ធ ជួនកាលអាចទទួលយកបាន ដូចដែលបានបង្ហាញនៅក្នុងតារាងទី១ ខាងក្រោមនេះ។ បុរស ៦៥% និងនារី ៧០% បានឆ្លើយថាការជះទឹកអាស៊ីដ ការចាក់ ការបាញ់ គឺមិនអាចទទួលយកបានទេ។ ៤% ឆ្លើយថាមិនដឹងទេ ហើយបុរស ៣០% និងនារី ២៦% ឆ្លើយថាសកម្មភាពទាំងនេះ ដែលជាសកម្មភាពអាចបណ្តាលឱ្យស្លាប់គឺជួនកាលអាចទទួលយកបាន។ ប្រហាក់ប្រហែលនេះដែរ បុរស ៧២% និងនារី ៦៩% ឆ្លើយថាការដុត ឬការច្របាច់ក គឺមិនអាចទទួលយកបានទាល់តែសោះ។ ៥% បានឆ្លើយថាមិនដឹងទេ ហើយបុរស ២១% និងនារី ២៦% ជឿថាសកម្មភាពដ៏ធ្ងន់ធ្ងរទាំងនេះជួនកាលអាចទទួលយកបាន។ ការទទួលយកអំពើហិង្សានេះ ក៏ត្រូវបានបង្ហាញនៅក្នុងសកម្មភាពផ្សេងៗដែរ។ ឧទាហរណ៍មានបុរស ២២% និងនារី ២០% បានឆ្លើយថាការវាយក្បាល ការទះ ការទាត់ ឬការវាយដំដោយប្រើកណ្តាប់ដៃ គឺមិនអាចទទួលយកបានទាល់តែសោះ។ អ្នកផ្តល់ចំលើយ ៦៩ភាគរយ បានឆ្លើយថាឥរិយាបថនេះ ជួនកាលអាចទទួលយកបាន។

អ្នកផ្តល់ចំលើយ ចំពោះសំណួរអំពីតរិយាបថ គឺខុស១គ្នានៅក្នុងក្រុមផ្សេង១ពីគ្នា ។ គ្រប់ករិតនៃអំពើហិង្សាទាំងអស់ ដោយលើកលែងតែអំពើហិង្សា ដែលស្ថិតនៅក្នុងប្រភេទធ្ងន់ធ្ងរ (ការជះទឹកអាស៊ីដ ការចាក់ ឬការបាញ់) គឺនារីមានចំនួនច្រើនជាង បានបង្ហាញថាដែលអាចទទួលយកបានចំពោះអំពើហិង្សានេះ ។




**តារាងទី ១**
**សំណួរទី ៨ a**
*ភាគរយនៃអ្នកផ្តល់ចំលើយ ដែលឆ្លើយថា "***ទេ មិនអាចទទួលយកបានទាល់តែសោះ***" ចំពោះសំណួរថា តើអ្នកអាចទទួលយកបានទេ ចំពោះប្តីប្រព្រឹត្តអំពើនេះទៅលើប្រពន្ធ?*
(N=3030)

### ២.១.១.១ ឥរិយាបថ អំពីហេតុផលនៅក្នុងការប្រព្រឹត្តអំពើហិង្សា

ការអង្កេត បានសាកសួរអ្នកផ្តល់ចំលើយទាំងឡាយ ដែលបាននិយាយថាអំពើហិង្សាជួនកាលអាចទទួលយកបាន អំពីហេតុផលសមស្របដែលនាំឱ្យប្តីប្រើអំពើហិង្សា[៦៤] ។ អ្នកផ្តល់ចំលើយភាគច្រើនបានឆ្លើយថា ជួនកាលអាកប្បកិរិយារបស់ប្រពន្ធ ជាពិសេសនៅពេលដែលប្រពន្ធតវ៉ាអំពីអំណាចត្រួតត្រារបស់ប្តីនោះគឺ ប្តីមានសិទ្ធិប្រើអំពើហិង្សាលើនាង មានបង្ហាញនៅក្នុងតារាងទី ២ ខាងក្រោម ។ អ្នកផ្តល់ចំលើយមួយចំនួនធំបានឆ្លើយថា ការឈ្លោះប្រកែក ការមិនគោរព ឬការសួរដេញដោលប្តីអំពីការចាយវាយលុយកាក់ ស្រីកំណាន់ចិត្ត ឬអ្នករកស៊ីផ្លូវភេទ គឺជាហេតុផលសមស្របដែលនាំឱ្យប្តីប្រើអំពើហិង្សា ដែលជួនកាលអាចមានដល់កំរិតធ្ងន់ធ្ងរបំផុត ។ ជាងពាក់កណ្តាលនៃអ្នកដែលឆ្លើយថាអំពើហិង្សាពេលខ្លះអាចទទួលយកបាន បាននិយាយថានៅពេលដែលប្រពន្ធឈ្លោះប្រកែកមិនគោរពប្តីរបស់ខ្លួន ឬមិនបង្ហាញការគោរព គឺអាចទទួលយកបានចំពោះការដែលប្តីជះទឹកអាស៊ីដ បាញ់ ឬចាក់នាង ទោះបីជាសកម្មភាពនេះអាចបណ្តាលឱ្យស្លាប់ក៏ដោយ ។ អ្នកផ្តល់ចំលើយចំនួនជាងមួយភាគបីបានឆ្លើយថានៅពេលដែលប្រពន្ធសួរដេញដោលប្តីអំពីរឿងស្រីកំណាន់ចិត្ត ឬការទៅរួមភេទជាមួយស្រីនៅខាងក្រៅ គឺអាចទទួលយកបានដែលប្តីប្រើរូបភាពដ៏ធ្ងន់ធ្ងរនៃអំពើហិង្សាទាំងនេះ ។

គួរឱ្យកត់សំគាល់ផងដែរថារូបភាពនៃអំពើហិង្សាមានលក្ខណៈខុសៗគ្នា ហើយនៅពេលដែលប្រពន្ធតវ៉ាអំពីតួនាទីគ្រប់គ្រងរបស់ប្តីនៅក្នុងគ្រួសារ អ្នកផ្តល់ចំលើយបានផ្តល់ចម្លើយស្រដៀងៗគ្នា ។ អ្នកដែលគិតថាអំពើហិង្សាធ្ងន់ធ្ងរបំផុត ពេលខ្លះអាចទទួលយកបាន បាននិយាយថា គឺសមហេតុផលនៅពេលដែលប្រពន្ធតវ៉ាអំពីឥរិយាបថរបស់ប្តី ជាជាងការខកខានដែលប្រពន្ធពុំបានបំពេញតួនាទីយេនឌ័រ ។

ឧទាហរណ៍ ៥៨% នៃអ្នកផ្តល់ចំលើយ បានឆ្លើយថា គឺសមហេតុផលដែលប្តីជះទឹកអាស៊ីត ឬបាញ់ នៅពេលដែលប្រពន្ធរករឿងឈ្លោះជាមួយប្តី ។ ប៉ុន្តែចំនួន ៦៦% បានឆ្លើយប្រហាក់ប្រហែលនេះដែរ គឺថាអាកប្បកិរិយាដូចគ្នានេះ សមតែនឹងទទួលការស្រែកសម្លុតដាក់ ។ ចំនួនអ្នកផ្តល់ចំលើយដែលនិយាយថា អាកប្បកិរិយាដែលសំដែង ដោយប្រពន្ធបែបនេះ សមែ ត នី ង ទបហិ ួ ងឃប្ដរអំពេ ី ពី ចន្លោះពី ៥៣%(ចំពោះការដុត) ដល់ ៧៦% (ចំពោះការជេរ) ។ ស្រដៀងៗគ្នានេះត្រូវបានបង្ហាញនៅពេលដែលប្រពន្ធតវ៉ាអំពីតួនាទីរបស់ប្តី តាមមធ្យោបាយផ្សេងៗ ។

[៦៤] អ្នកផ្តល់ចំលើយក្រុមនេះ ដែលបាននិយាយថា ពេលខ្លះអំពើហិង្សា ត្រូវបានចាត់ទុកថាសមហេតុផល គឺពុំមែនជាក្រុមតំណាងអោយក្រុមទូទៅឡើយ

| មានហេតុផល ពីព្រោះ | ពេលខ្លះអាចទទួលយកបាន | | | | | | | |
|---|---|---|---|---|---|---|---|---|
| | ស្រែកកំហកដាក់ N=3018 | ការជេរប្រមាថ N=2966 | ចោលរបស់ N=2558 | ការវាយ N=2392 | ការចង N=1498 | ការគំរាមកំហែង N=1348 | ការដុត N=896 | ជះទឹកអាស៊ីត N=972 |
| ប្រពន្ធឈ្លោះប្រកែកគ្នាជាមួយគាត់/ប្រពន្ធមិនធ្វើតាមគាត់ឬមិនសំដែងការគោរពគាត់ | ៦៦% | ៧៦% | ៦៧% | ៦៧% | ៥៨% | ៥៩% | ៥៣% | ៥៨% |
| ប្រពន្ធបានចេញទៅក្រៅដោយមិនប្រាប់គាត់ | ៥៨% | ២៧% | ២០% | ២០% | ១៤% | ១៤% | ៦% | ១០% |
| ប្រពន្ធមិនយកចិត្តទុកដាក់មើលកូន | ៥១% | ៤២% | ៣០% | ២៦% | ២៣% | ១៧% | ១០% | ១៣% |
| រៀបចំម្ហូបអាហារយឺត ឬមិនឆ្ងាញ់/មិនបានសំអាតផ្ទះ/សំលៀកបំពាក់មិនរៀបរយ | ៣០% | ២៩% | ២១% | ១៨% | ១៦% | ១២% | ៨% | ៨% |
| ប្រពន្ធចោទសួរគាត់ពីការចំណាយលុយ | ៣០% | ២៧% | ២៨% | ២៨% | ២៤% | ២៤% | ២០% | ២៥% |
| ប្រពន្ធចោទសួរគាត់អំពីស្រីញី/ការទៅរកស្រីខូច | ២៦% | ២៦% | ៣១% | ៣០% | ២៧% | ៣៤% | ៣០% | ៣៦% |
| ប្រពន្ធប្រើវិធីពន្យារកំណើតដោយមិនប្រាប់គាត់ | ៩% | ៧% | ៦% | ៧% | ៧% | ៩% | ៣% | ២% |
| ប្រពន្ធបដិសេធការរួមភេទជាមួយគាត់ | ៨% | ៨% | ៨% | ៧% | ៧% | ៦% | ៥% | ៣% |

**តារាងទី ២**
**សំណួរទី ៨ b**
*តើស្ថិតក្រោមកាលៈទេសៈខាងក្រោមនេះណាខ្លះ ដែលប្តីសមហេតុសមផលក្នុងការប្រព្រឹត្តអំពើនេះចំពោះប្រពន្ធ?*

ម្យ៉ាងវិញទៀត អ្នកផ្តល់ចំលើយមួយចំនួនដែលគិតថាពេលខ្លះ អំពើហិង្សាធ្ងន់ធ្ងរអាចទទួលយកបាន បានឆ្លើយថា នៅពេលដែលប្រពន្ធពុំបានតវ៉ាអំពីតួនាទីរបស់ប្តីនោះទេ ប៉ុន្តែប្រពន្ធខកខានពុំបានបំពេញតួនាទីរបស់គាត់ពេលនោះអំពើហិង្សាធ្ងន់ធ្ងរអាចទទួលយកបាន។ ឧទាហរណ៍នៅពេលដែលប្រពន្ធមានការធ្វេសប្រហែសចំពោះកូនចៅ នោះអ្នកផ្តល់ចំលើយជាងពាក់កណ្តាលឆ្លើយថា ការដែលប្តីរបស់នាង ស្រែកសម្លុតដាក់ គឺជាការត្រឹមត្រូវ ប៉ុន្តែអ្នកផ្តល់ចំលើយចំនួនតិចប៉ុណ្ណោះដែលឆ្លើយថាសមហេតុហើយ ដែលប្តីយករបស់គប់លើ (ចោល) នាង (៣០%) ការជះទឹកអាស៊ីដលើនាងឬបាញ់នាង (១៣%)។ ក្នុងករណី ដែលប្រពន្ធមិនបានបំពេញតួនាទីយេនឌ័ររបស់ខ្លួន អ្នកផ្តល់ចំលើយភាគច្រើនបានឆ្លើយថា ឥរិយាបថរបស់នាង គឺសមតែនឹងទទួលការស្តីបន្ទោស ប៉ុន្តែមិនមែនទទួលការរំលោភបំពានផ្លូវកាយនោះទេ។

សំណួរនេះ បានបង្ហាញនូវចំលើយខុសៗគ្នានៅក្នុងចំណោមអ្នកផ្តល់ចំលើយ។ យុវជន ដែលមានអាយុពី ១៥ ដល់ ២៤ឆ្នាំ មានទំនោរទទួលយកនូវអំពើហិង្សាក្នុងទម្រង់ធ្ងន់ធ្ងរ។ នេះបង្ហាញឱ្យឃើញថា ទោះបីជាកំរិតនៃការអប់រំមានការកើនឡើង ហើយអ្នករៀបចំគោលនយោបាយមានការប្តេជ្ញាចិត្តកាន់តែខ្លាំងឡើងក្នុងការបញ្ឈប់អំពើហិង្សាក្នុងគ្រួសារក៏ឥរិយាបថអំពើហិង្សាក្នុងគ្រួសារនៅតែមិនទាន់មានការល្អប្រសើរនៅឡើយ។ ផ្ទុយទៅវិញ ជាទូទៅឥរិយាបថទាំងនោះពុំមានការផ្លាស់ប្តូរហើយរឹតតែធ្ងន់ធ្ងរថែមទៀតនៅក្នុងក្រុមមួយចំនួន។

អ្នកនៅទីក្រុងភាគច្រើនមានទំនោរទទួលយកអំពើហិង្សាធ្ងន់ធ្ងរ ច្រើនជាងអ្នករស់នៅជនបទ ដែលមានទំនោរទទួលយកអំពើហិង្សាក្នុងកំរិតធ្ងន់ធ្ងរដែលប្រព្រឹត្តដោយប្តីរបស់ខ្លួន នៅពេលដែលប្រពន្ធសួរប្តីអំពីការចេញទៅរកស្រីនៅខាងក្រៅ។ លទ្ធផលនេះកើតមានឡើងដោយសារតែឱកាសចេញទៅរកស្រីខាងក្រៅរបស់អ្នកនៅទីក្រុងមានច្រើនជាងអ្នកនៅជនបទ។ អ្នកផ្តល់ចំលើយដែលមានប្រាក់ចំណូលតិចបំផុត ច្រើនជួបប្រទះនឹងអំពើហិង្សាដែលអាចទទួលយកបាននៅពេលដែលនាងបដិសេធមិនព្រមរួមភេទ ប៉ុន្តែមិនមែនជាអំពើហិង្សាក្នុងកំរិតធ្ងន់ធ្ងរបំផុតនោះទេ។

### ២.១.១.២ ឥរិយាបថចំពោះអំពើហិង្សាដែលបង្កឡើងដោយប្រពន្ធ និងសមាជិកគ្រួសារផ្សេងៗទៀត

អំពើហិង្សាដែលបង្កឡើងដោយប្រពន្ធចំពោះប្តីរបស់ខ្លួន ត្រូវបានគេយល់ឃើញថាជួនកាល គឺអាចទទួលយកបាន[៦៥]។ ប៉ុន្តែរាល់ទម្រង់នៃអំពើហិង្សាដែលបង្កឡើងដោយប្រពន្ធ គឺគេបានចាត់ទុកថាអាចទទួលយកបានតិចជាងអំពើហិង្សាដែលបង្កឡើងដោយប្តី។ ឧទាហរណ៍ បុរស ៤៦% និងស្ត្រី ៥០% បានឆ្លើយថា ការដែលប្រពន្ធវាយក្បាលប្តី ទាត់ប្តី ឬវាយប្តី គឺមិនអាចទទួលយកបានទាល់តែសោះ។ តាមការប្រៀបធៀបឃើញថាបុរស ២២% និងស្ត្រី ២០% ផ្តល់ចម្លើយដូចគ្នាអំពីឥរិយាបថរបស់ប្តីដែលប្រព្រឹត្តអំពើទាំងនេះ។ ដូចគ្នាដែរ បុរស ៣៨% និងស្ត្រី ៤១% ឆ្លើយថាការដែលប្រពន្ធចោលរបស់អ្វីមួយទៅលើប្តី រុញប្តី ឬច្រានប្តី គឺមិនអាចទទួលយកបានទាល់តែសោះ។ តិចជាងពាក់កណ្តាលនៃចំនួននេះ (បុរស ១៩% និងស្ត្រី ១២%) ឆ្លើយថាសកម្មភាពបែបនេះដែលប្រព្រឹត្តដោយប្តីគឺមិនអាចទទួលយកបានទាល់តែសោះ។ ក្នុងករណីជាច្រើនបង្ហាញអោយឃើញការទទួលយកអំពើហិង្សាដែលបង្កឡើងដោយនារី គឺមានកំរិតតិចជាងការទទួលយកអំពើហិង្សាដែលបង្កឡើងដោយបុរស។

ឥរិយាបថហិង្សាដែលបង្កឡើងដោយសមាជិកផ្សេងៗទៀតនៅក្នុងគ្រួសារ-មិនមែនជាសហព័ទ្ធ - ត្រូវបានគេយល់ឃើញថា អាចទទួលយកបាន ក្នុងកំរិតតិចជាងការទទួលយកអំពើហិង្សាដែលបង្កឡើងដោយប្រពន្ធទៅលើប្តី។ ក្នុងការរៀបតាមលំដាប់នៃអំពើហិង្សា ចាប់ពីអាចទទួលយកបានរហូតដល់មិនអាចទទួលយកបានទាល់តែសោះ: បុរស ៧៤% និងស្ត្រី ៨២% ឆ្លើយថារូបភាពធ្ងន់ធ្ងរបំផុតនៃអំពើហិង្សា (ការជះទឹក អាស៊ីដ កាចាក់ ឬការបាញ់) គឺមិនអាចទទួលយកបានទាល់តែសោះ។ នៅក្នុងផ្នែកនេះពុំសូវមានភាពខុសគ្នានៃយេនឌ័រដូចនៅក្នុងសំណួរមុនៗនោះទេ ដែលនៅក្នុងសំណួរទាំងនោះបង្ហាញអោយឃើញនូវភាពអត់អោនរបស់នារី ចំពោះអំពើហិង្សាដែលបង្កឡើងដោយសមាជិកគ្រួសារដែលមិនមែនជាសហពទ្ធ័។

---

[៦៥] ភាគរយនៃអ្នកផ្តល់ចំលើយ ដែលបានឆ្លើយថា "ទេ មិនអាចទទួលយកបានទាល់តែសោះ" នៅក្នុងសំណួរ: តើទទួលយកបានឬទេចំពោះប្តីប្រព្រឹត្តអំពើនេះទៅលើប្រពន្ធ? សូមអានតារាងទី៣៨ នៅក្នុងឧបសម្ពន្ធ័ A

### ២.១.១.៣ ឥទ្ធិពលទៅលើឥរិយាបថ

ការអង្កេតបានផ្ដល់នូវការស៊ើបអង្កេតជម្រៅមួយចំនួនអំពីកត្តាផ្សេងៗ ដែលអាចមានឥទ្ធិពលទៅលើឥរិយាបថទាំងនេះ ។ការអង្កេតក៏បានសួរសំណួរមួយចំនួនអំពីចំណេះដឹងរបស់អ្នកផ្ដល់ចំលើយអំពីច្បាប់ពាក់ពន្ធ័នឹងអំពើហិង្សា និងឥទ្ធិពលនៃវប្បធម៌ផងដែរ ។

ភាគច្រើននៃអ្នកផ្ដល់ចំលើយ និយាយថាអំពើហិង្សា ទោះបីជាពេលខ្លះអាចទទួលយកបានក៏ដោយ ក៏សុទ្ធតែជាអំពើល្មើសច្បាប់ទាំងអស់[៦៦] - ចំលើយនេះបង្ហាញអោយឃើញថាឥទ្ធិពលរបស់ច្បាប់មានទៅលើឥរិយាបថរបស់អ្នកផ្ដល់ចំលើយនៅមានកំរិត ។ អ្នកផ្ដល់ចំលើយចំនួនជាង៩៧% ឆ្លើយថាការដុត ការវាយ ការជះ ទឹកអាស៊ីដ ការចាក់ ឬការបាញ់ គឺខុសច្បាប់ ។ តួលេខទាំងនេះ គឺខុសគ្នាយ៉ាងខ្លាំងពីចំលើយដែលឆ្លើយថារូបភាពនៃអំពើហិង្សាទាំងនេះ ជួនកាលអាចទទួលយកបាន ។ ឧទាហរណ៍ បុរស ៣០% និងស្ត្រី ២៦% បានឆ្លើយថា ការជះទឹកអាស៊ីដ ការចាក់ ឬការបាញ់ ជួនកាលអាចទទួលយកបាន ហើយបុរស ២១% និងស្ត្រី ២៦% ឆ្លើយថាការដុត ការទះ ជួនកាលអាចទទួលយកបាន ។

ចម្លើយចំពោះសំណួរនេះ គឺខុសគ្នា ដោយផ្អែកទៅលើយេនឌ័រ និងប្រាក់ចំណូលរបស់អ្នកផ្ដល់ចំលើយដូចដែលបានបង្ហាញជូនខាងក្រោមនេះ៖

- បុរសច្រើនជាងស្ត្រី ដែលយល់ឃើញថាការចង ឬវាយដំជាសកម្មភាពខុសច្បាប់ ។ បុរសមានចំនួន ៩០% ឯស្ត្រីមាន ៨០% ដែលឆ្លើយថាសកម្មភាពទាំងនេះ ជាសកម្មភាពខុសច្បាប់ ។
- នារីជាច្រើនយល់ឃើញថា ការបំពារបំពានដោយពាក្យសំដី គឺខុសច្បាប់ ។ នៅក្នុងសំណួរនេះ ស្ត្រី ១៩% ប្រៀបធៀបនឹងបុរស ១៣% ឆ្លើយថាការស្រែកសម្លុតដាក់គឺខុសច្បាប់ ។ ស្ត្រី ២៧% ប្រៀបធៀបទៅនឹងបុរស ១៨% ឆ្លើយថា ការជេរ ឬការប្រមាថមើលងាយអ្នកដទៃគឺខុសច្បាប់ ។
- នៅគ្រប់ឥរិយាបថទាំងអស់ អ្នកមានចំណូលខ្ពស់ ឆ្លើយថាឥរិយាបថហិង្សា គឺខុសច្បាប់ ។

[៦៦] សូមមើលចម្លើយនៅក្នុងតារាងទី ៣៩ ក្នុងឧបសម្ព័ន្ធ A

ទំនាក់ទំនងរវាងការទទួលយកអំពើហិង្សា និងការយល់ឃើញថានេះជាអំពើខុសច្បាប់មានបញ្ជាក់បន្ថែមនៅក្នុងតារាងទី ៣។ អ្នកផ្តល់ចំលើយ បានបង្ហាញនូវភាពអត់ឱនយ៉ាងខ្លាំងចំពោះអំពើហិង្សា ទោះបីជាដឹងថាជាអំពើខុសច្បាប់ក៏ដោយ លើកលែងតែការចងដៃហើយវាយ។ ស្ត្រីបង្ហាញនូវភាពអត់ឱនខ្ពស់ជាងបុរសចំពោះអំពើហិង្សា។




| | អាចទទួលយកបាន | ផ្លូវច្បាប់ | |
|---|---|---|---|
| ជេរបញ្ចោរ ឬប្រមាថមើលងាយ ។ល។ | ៩៣% | ៧៤% | ១៩% |
| គុប ឬចោលអ្វីមួយ ។ល។ | ៧៤% | ៣៣% | ៤១% |
| ខោកក្បាល ។ល។ | ៦៩% | ២៤% | ៤៥% |
| ចងដៃហើយវាយ ។ល។ | ៤០% | ៩% | ៣១% |
| គំរាមកំហែងដោយកាំបិត ។ល។ | ៣៧% | ៨% | ២៩% |
| ដុត/ច្របាច់ក ។ល។ | ២៤% | ២% | ២២% |
| ជះទឹកអាស៊ីដ ។ល។ | ២៨% | ១% | ២៧% |

**តារាងទី ៣**
**សំណួរទី ១១,៨ a**
*ភាគរយនៃអ្នកផ្តល់ចំលើយ ដែលបានឆ្លើយថា*
*"ទេ មិនអាចទទួលយកបានទាល់តែសោះ" នៅក្នុងសំណួរៈ*
*តើអំពើទាំងនេះណាមួយ ដែលជាអំពើឧក្រិដ្ឋ?*
*តើទទួលយកបានឬទេចំពោះ ប្តីប្រព្រឹត្តអំពើនេះទៅលើប្រពន្ធ?*
*(Q11 N=3030, Q8a N=3030)*




ឥទ្ធិពលញឹកញាប់និងខ្លាំងបំផុតលើឥរិយាបថរបស់បុរសចំពោះនារី គឺកង្វះខាតនូវការអនុវត្តន៍ច្បាប់ដូចដែលបានបង្ហាញនៅក្នុងតារាងខាងក្រោម[៦៧] ។ អ្នកផ្តល់ចំលើយជាច្រើនបានបង្ហាញថាសម្ពាធពីមិត្តភ័ក្តិប្រុសៗ ឬក្រុមយុវជនស្រករៗគ្នា គឺមានឥទ្ធិពលលើឥរិយាបថរបស់ខ្លួនដែរ ។ អ្នកផ្តល់ចំលើយប្រហែលជាពាក់កណ្តាលទៀត អះអាងថាឥរិយាបថនេះកើតឡើងដោយសារប្រព័ន្ធផ្សព្វផ្សាយ ។

៦៧ លទ្ធផលនេះ គឺគួរឱ្យចាប់អារម្មណ៍ណាស់ បើសិនជាប្រៀបធៀបទៅនឹងចម្លើយដំបូង ដែលបង្ហាញថាមនុស្សភាគច្រើនទទួលយកនូវការប្រព្រឹត្តិអំពើហិង្សាមួយចំនួន សូម្បីតែគេដឹងថាជាអំពើខុសច្បាប់ ក៏ដោយ ។

ដើម្បីឱ្យលទ្ធផលនេះ ស្របទៅនឹងបរិបទនៃសង្គមនាពេលបច្ចុប្បន្ន អ្នកផ្ដល់ចំលើយក៏បានរាយការណ៍អំពីឥទ្ធិពលសំខាន់នៃទូរទស្សន៍ និងវិទ្យុផងដែរ។ ៥៧% បានឆ្លើយថាពួកគេមើលទូរទស្សន៍រាល់ថ្ងៃ ហើយ២៦%ទៀតឆ្លើយថាយ៉ាងហោចណាស់ពួកគេមើលទូរទស្សន៍ពីរដងក្នុងមួយសប្ដាហ៍។ ទោះយ៉ាងណាក៏ដោយ ទូរទស្សន៍ពុំមាននៅទូទាំងប្រទេសកម្ពុជានោះទេ ដូច្នេះហើយចំលើយ គឺមិនទូទៅទេ។ ដូចគ្នាដែរ អ្នកផ្ដល់ចំលើយ៤៣%ឆ្លើយថាពួកគេស្ដាប់វិទ្យុជារៀងរាល់ថ្ងៃ ហើយស្ទើរតែមួយភាគបីឆ្លើយថាយ៉ាងហោចណាស់ ពួកគេស្ដាប់វិទ្យុពីរដងក្នុងមួយសប្ដាហ៍។

ទោះបីយ៉ាងណាក៏ដោយ នៅពេលដែលសួរសំណួរដោយឡែកអំពីបញ្ហារឿងអាសអាភាស ភាគច្រើនបំផុតនៃអ្នកផ្ដល់ចំលើយឆ្លើយថា រឿងអាសអាភាសមានឥទ្ធិពលខ្លាំង។ បុរស ៨៤% និងស្ត្រី ៨០% ឆ្លើយថា រឿងអាសអាភាសមានឥទ្ធិពល "ខ្លាំង" លើឥរិយាបថរបស់បុរសចំពោះនារី។ ទោះជាយ៉ាងនេះក៏ដោយ គ្មានអ្នកផ្ដល់ចំលើយណាម្នាក់ឆ្លើយថា គ្មានអ្វីដែលគ្មានឥទ្ធិពលលើឥរិយាបថនោះឡើយ។ ចម្លើយទាំងនេះបង្ហាញអោយឃើញថា គួរតែធ្វើការសិក្សាស្រាវជ្រាវជាបន្ថែមទៀត ពីព្រោះថាមនុស្សខុសគ្នា ផ្ដល់នូវការយល់ឃើញខុសៗគ្នា ចំពោះរឿងអាសអាភាស។




**តារាងទី ៥**
**សំណួរទី ៣៣ a**
*តើ (កត្តា) ខាងក្រោមនេះ ជះឥទ្ធិពលលើឥរិយាបថរបស់បុរសទៅលើស្ត្រី ដែរឬទេ?*
*(N=3030)*

ការអង្កេតបានបង្ហាញនូវឥទ្ធិពលស្រដៀងគ្នាលើឥរិយាបថនារី ដែលមានចំពោះការប្រព្រឹត្តិរបស់បុរស លើកលែងតែក្នុងករណីដែលគួរឱ្យកត់សំគាល់មួយចំនួន ដូចដែលបានបង្ហាញនៅក្នុងតារាងទី៦ខាងក្រោម ។ ឥរិយាបថរបស់នារីត្រូវបានគេគិតថាបានទទួលឥទ្ធិពលយ៉ាងខ្លាំងពីកង្វះខាតការអនុវត្តន៍ច្បាប់ ។ ប៉ុន្តែតួលេខនេះ គឺតិចជាងបុរស ។ អ្នកផ្តល់ចំលើយបានឆ្លើយថា នារីទទួលឥទ្ធិពលពីមិត្តភ័ក្តិតិចជាងបុរសទទួលឥទ្ធិពលមិត្តភ័ក្តិរបស់គេ ប៉ុន្តែនារីទទួលឥទ្ធិពលច្រើនពីប្រព័ន្ធផ្សព្វផ្សាយ និងប្រពៃណីខ្មែរ ។

**តារាងទី ៦**

**សំណួរទី ៣៣ b**

*តើ (កត្តា) ខាងក្រោមនេះ ជះឥទ្ធិពលលើឥរិយាបថរបស់ស្ត្រី ទៅលើការប្រព្រឹត្តិរបស់បុរសដែរឬទេ?*

*(N= 3030)*



ភាគច្រើននៃអ្នកផ្តល់ចំលើយបានប្រាប់ឱ្យដឹងថា ពួកគេបានឃើញឥរិយាបថហិង្សាដែលប្រព្រឹត្តិដោយឪពុកម្តាយរបស់គេ និងប្តីប្រពន្ធរបស់ពួកគេ។ ២៥%នៃបុរស និង ២០%នៃនារីបានឃើញឪពុករបស់ខ្លួនវាយដំម្តាយរបស់ខ្លួន។ មានអ្នកផ្តល់ចំលើយមួយចំនួនតិចប៉ុណ្ណោះ ដែលបានឃើញម្តាយរបស់ខ្លួនវាយធ្វើបាបឪពុករបស់ខ្លួននោះ។ ជាងនេះទៅទៀត២១%នៃបុរស និង ១៦%នៃនារីបានឃើញប្តីប្រពន្ធវាយធ្វើបាបកូន បន្ទាប់ពីមានការទាស់ទែងគ្នា។ ទោះបីជាយ៉ាងណាក៏ដោយក៏ចំលើយអំពីបទពិសោធន៍ផ្ទាល់ខ្លួន ពេលខ្លះពុំអាចទុកចិត្តបានឡើយ ដូច្នេះត្រូវតែយល់ដឹងអំពីបរិបទនៃលទ្ធផលទាំងនេះ[៦៨]។

## សន្និដ្ឋាន

មានអ្នកផ្តល់ចំលើយជាច្រើន បង្ហាញនូវការអត់ឱនចំពោះឥរិយាបថហិង្សា ជាពិសេសនៅពេលដែលអំពើហិង្សានោះប្រព្រឹត្តិដោយប្តីទៅលើប្រពន្ធរបស់ខ្លួន។ មានអ្នកផ្តល់ចំលើយជាច្រើនបាននិយាយថាអំពើហិង្សាគឺសមហេតុផល នៅពេលដែលប្រពន្ធតវ៉ាអំពីតួនាទីរបស់ប្តី ដែលជាមេគ្រួសារនៅក្នុងរូបភាពមួយចំនួន។ តាមការពិត នៅពេលប្រពន្ធតវ៉ាអំពីតួនាទីរបស់ប្តីក្នុងគ្រួសារ អ្នកផ្តល់ចំលើយទទួលយកនូវអំពើហិង្សាផ្លូវកាយក្នុងសមាមាត្រប្រហាក់ប្រហែលទោះបីជាអំពើហិង្សាកើតឡើងប្រភេទណាក៏ដោយ។ (ម្យ៉ាងវិញទៀត នៅពេលដែលប្រពន្ធពុំបានតវ៉ាអំពីតួនាទីរបស់ប្តីទេ ប៉ុន្តែប្រពន្ធខកខានពុំបានបំពេញតួនាទីយេនឌ័ររបស់ខ្លួន នោះអ្នកផ្តល់ចំលើយមួយចំនួនធំទទួលយកអំពើហិង្សាជាពាក្យសំដីច្រើនជាងអំពើហិង្សាលើផ្លូវកាយ)។

អំពើហិង្សាដែលធ្វើឡើងដោយប្រពន្ធ គឺមិនសូវមានការទទួលយកនោះទេ ហើយអំពើហិង្សាដែលប្រព្រឹត្តិឡើងដោយជនណាម្នាក់នៅក្នុងគ្រួសារក៏កាន់តែមានការទទួលយកតិចជាងនេះទៅទៀត។ ការសិក្សាស្រាវជ្រាវបាននាំមកនូវចំលើយខុសៗគ្នាពីក្រុមផ្សេងៗគ្នានៃអ្នកដែលបានសម្ភាស។ ស្ត្រីទំនងជាយល់ឃើញថាអំពើហិង្សាដែលប្រព្រឹត្តិឡើងដោយប្តីទៅលើប្រពន្ធអាចទទួលយកបាន។ ម្យ៉ាងវិញទៀត ចំលើយរបស់អ្នកផ្តល់ចំលើយដែលមានវ័យក្មេង គឺពុំខុសពីចំលើយរបស់អ្នកផ្តល់ចំលើយដទៃទៀតដែរ នេះបង្ហាញឱ្យឃើញថាអាកប្បកិរិយាទាំងនេះ គឺពុំមានការផ្លាស់ប្តូរឡើយ បើទោះបីជាមានអន្តរាគមន៍អស់រយៈពេលមួយទសវត្សមកហើយក៏ដោយ។

អ្នកផ្តល់ចំលើយបាននិយាយថា ពួកគេទទួលឥទ្ធិពលយ៉ាងខ្លាំងពីកង្វះខាតការអនុវត្តន៍ច្បាប់ច្រើនជាងបញ្ហាអំពីច្បាប់ផ្ទាល់មានអ្នកផ្តល់ចំលើយជាច្រើនបានសារភាពថា ពួកគេបានអត់អោនចំពោះសកម្មភាពដែលខុសច្បាប់។ ហើយពួកគេក៏ប្រាប់ឱ្យដឹងដែរថា សម្ពាធពីមិត្តភ័ក្តអាយុប្រហែលគ្នា និងប្រព័ន្ធព័ត៌មានមានឥទ្ធិពលលើអាកប្បកិរិយារបស់ពួកគេ។ អ្នកផ្តល់ចំលើយមួយចំនួនធំបាននិយាយថាពួកគេបានឃើញនូវអំពើហិង្សាដែលប្រព្រឹត្តិឡើងដោយឪពុកម្តាយរបស់ពួកគេ។

---

[៦៧] អ្នកជំនាញខាងអំពើហិង្សាក្នុងគ្រួសារ បានប៉ាន់ស្មានថាប្រជាពលរដ្ឋរាយការណ៍អំពីបទពិសោធន៍របស់ខ្លួនឯងបានប្រហែល ៥០%ប៉ុណ្ណោះ ដូច្នេះសូចនាករដែលយកជាការបានស្តីពីប្រេវ៉ាឡង់នៃអំពើហិង្សាក្នុងគ្រួសារ គឺការរាយការណ៍អំពីប្រជាពលរដ្ឋដទៃទៀត។ អង្គការសុខភាពពិភពលោកបានសូមអោយអ្នកស្រាវជ្រាវមានការប្រុងប្រយត្ន័អំពីនិន្នាការនេះ និងផ្តល់នូវគោលការណ៍ណែនាំសំរាប់ធ្វើឱ្យនិន្នាការនេះមានតុល្យភាព គឺដូចជាការប្រើពាក្យនៅក្នុងសំណួរ និងបណ្តុះបណ្តាលអ្នកធ្វើសម្ភាសឱ្យបានល្អ។ ប្រភព: អង្គការសុខភាពពិភពលោក (២០០១) **ការចាត់ទុកនារីជាចំបង: អនុសាសន៍អំពីសីលធម៌ និងសុវត្ថិភាពសំរាប់ការសិក្សាស្រាវជ្រាវអំពីអំពើហិង្សាក្នុងគ្រួសារប្រឆាំងនឹងស្ត្រី** ទំព័រទី ១៤ ដល់១៧។

### ២.១.២ បទពិសោធន៍ទទួលរងគ្រោះដោយសារអំពើហិង្សាក្នុងគ្រួសារ

អង្កេតនេះបានធ្វើការវាស់វែងលើបទពិសោធន៍នៃការទទួលរងគ្រោះដោយសារអំពើហិង្សាក្នុងគ្រួសារតាមមធ្យោបាយជាច្រើន។ ដើម្បីធានាឱ្យបាននូវភាពត្រឹមត្រូវ អ្នកសម្ភាសន៍សួរអ្នកចូលរួមថា តើពួកគេស្គាល់អ្នកដទៃដែលបានប្រព្រឹត្តអំពើហិង្សាដែរឬទេ ហើយថាតើរូបគេផ្ទាល់ធ្លាប់ប្រព្រឹត្តិអំពើហិង្សា ឬទទួលរងគ្រោះដោយសារអំពើហិង្សាដែលប្រព្រឹត្តិដោយអ្នកដទៃដែរឬទេ។ រាល់ចំលើយដែលបានឆ្លើយបានបញ្ជាក់ពីកំរិតខុសគ្នានៃអំពើហិង្សាក្នុងគ្រួសារនៅកម្ពុជា។ អ្នកជំនាញខាងអំពើហិង្សាក្នុងគ្រួសារបានចង្អុលបង្ហាញថា មនុស្សភាគច្រើនពុំបានផ្តល់ព័ត៌មានអោយបានអស់អំពីបទពិសោធន៍ផ្ទាល់ខ្លួននោះទេ ប្រហែលជាបានត្រឹម ៥០% ហើយសូចនាករស្តីអំពីប្រេវ៉ាឡង់ដែលអាចយកជាបានការបំផុតនោះ គឺការរាយការណ៍អំពីអ្នកដទៃ។ អង្គការសុខភាពពិភពលោកបានកត់សំគាល់ឃើញថាក្នុងការសិក្សាអំពីអំពើហិង្សាក្នុងគ្រួសារ និងប្រធានបទទាក់ទងឯទៀតគឺ "និន្នាការគឺថាអ្នកចូលរួមពុំឆ្លើយអោយបានអស់អំពីបទពិសោធន៍ ដែលពួកគេធ្លាប់មាននោះទេ"។ អង្គការនេះបានស្នើសូមឱ្យអ្នកសិក្សាស្រាវជ្រាវប្រុងប្រយត្ន័ក្នុងការកាត់បន្ថយនិន្នាការនេះ ដោយការប្រើពាក្យដោយប្រុងប្រយ័ត្ននៅក្នុងសំណួរ (ជៀសវាងភាសាដែលបង្កប់ន័យវិនិច្ឆ័យ) និងបណ្តុះបណ្តាលអ្នកធ្វើសម្ភាសឱ្យបានល្អ[៦៩]។

ការស្ទង់មតិក៏បានពិនិត្យផងដែរទៅលើអំពីហិង្សាកើតមាននៅខាងក្រៅរង្វង់គ្រួសារ ដូចជាអំពើហិង្សាដែលធ្វើឡើងដោយមិត្តភ័ក្តិ អ្នកមិនស្គាល់ ប៉ូលីស និងទាហាន។ នៅទីបញ្ចប់ការសិក្សាស្រាវជ្រាវបានផ្តោតការយកចិត្តទុកដាក់ទៅលើកាលៈទេសៈ ដែលជាមូលហេតុបណ្តាលឱ្យមានអំពើហិង្សា។

និន្នាការទូទៅ នៅក្នុងការរាយការណ៍អំពីអំពើហិង្សាអាចមានបង្ហាញនៅក្នុងការប្រៀបធៀបចំលើយផ្សេងៗគ្នា។ តួលេខអំពីករណីជាក់ស្តែងនៃអំពើហិង្សាក្នុងគ្រួសារ ធ្លាក់យ៉ាងខ្លាំងចាប់ផ្តើមពីចំនួនអ្នកដែលបានស្គាល់អ្នកដទៃទៀតដែលប្រព្រឹត្តអំពើហិង្សា ទៅដល់ចំនួនប្រជាពលរដ្ឋដែលបានសារភាពថា ខ្លួនគាត់ក៏បាននៅក្នុងស្ថានភាពហិង្សានោះដែរ។ ឧទាហរណ៏ការបង្ហាញនៅក្នុងតារាងទី៧មាន ៦៤% បានស្គាល់អ្នកដទៃទៀត ដែលបានគប់របស់របរទៅលើប្តីប្រពន្ធរបស់ខ្លួន ឬក៏បង្ករឿងឱ្យមានការវាយតប់គ្នា ឬការរុញច្រានគ្នា ប៉ុន្តែមាន១៨%បានប្រាប់ថាពួកគេមានធ្លាប់ជួបប្រទះឥរិយាបថបែបនេះ។ គន្លឹះមួយផ្សេងទៀតនៃអត្រាប្រេវ៉ាឡង់ គឺឥរិយាបថរបស់អ្នកផ្តល់ចំលើយ។ ក្នុងករណីនេះ អ្នកផ្តល់ចំលើយទទួលយកនូវអំពើហិង្សាក្នុងអត្រាខ្ពស់ជាងអ្វីដែលពួកគេបានលើកឡើងពេលក្ខណៈផ្លូវច្បាប់ ហើយឥរិយាបថទទួលយកនេះ គឺមានកំរិតខ្ពស់ជាងកំរិតនៃអំពើហិង្សាដែលពួកគេធ្លាប់បានឆ្លើយថាពួកគេមានបទពិសោធន៍។

[៦៩] Ibid.




| | អាចទទួលយកបាន | កើតឡើងលើអ្នកដទៃ | ផ្លូវច្បាប់ | កើតឡើងលើអ្នកដទៃ |
|---|---|---|---|---|
| ជេរបញ្ឆោរ ឬប្រមាថមើលងាយ ។ល។ | ៩៣% | ៩២% | ៧៤% | ៤៤% |
| គប់ ឬចោលអ្វីមួយ ។ល។ | ៧៤% | ៦៤% | ៣៣% | ១៨% |
| ខោកក្បាល ។ល។ | ៦៩% | ៥៨% | ២៤% | ១២% |
| ចងដៃហើយវាយ ។ល។ | ៤០% | ២៦% | ៩% | ៤% |
| គំរាមកំហែងដោយកាំបិត ។ល។ | ៣៧% | ២១% | ៨% | ៥% |
| ដុត/ច្របាច់ក ។ល។ | ២៤% | ៩% | ២% | ១% |
| ជះទឹកអាស៊ីដ ។ល។ | ២៨% | ១២% | ២% | ១% |

**តារាងទី ៧**
**សំណួរទី ១១, ៨ a, ១២ a, ១៦ a**
*ការប្រៀបធៀបចំលើយនៃសំណួរចំនួនបួន ស្ដីអំពីអត្រាប្រេវ៉ាឡង់ នៃអំពើហិង្សា ការទទួលយកនូវអំពើហិង្សា[៧០] លក្ខណៈផ្លូវច្បាប់ និងបទពិសោធន៍ទទួលរងគ្រោះដោយសារអំពើហិង្សា ។*
*(Q11 N= 3030, Q8a N= 3030, Q12a N= 3030, Q16a N= 1984)*

៧០ ភាគរយនៃអ្នកផ្ដល់ចំលើយដែលបានឆ្លើយថា "ទេ ពុំអាចទទួលយកបានទេ" នៅក្នុងសំណួរទាំងបួនមាន: តើអាចទទួលយកបានទេ ដែលបុរសធ្វើបែបនេះទៅលើប្រពន្ធរបស់ខ្លួន? តើទង្វើមួយណាដែលជាបទឧក្រិដ្ឋ? តើអ្នកស្គាល់ប្ដីណាម្នាក់ ដែលធ្វើអំពើណាមួយដូចខាងក្រោមនេះទៅលើប្រពន្ធរបស់ខ្លួនទេ? តើប្ដីប្រពន្ធរបស់អ្នកធ្លាប់ធ្វើទង្វើណាមួយដូចខាងក្រោមនេះទៅលើរូបអ្នកដែរឬទេ?

### ២.១.២.១ ការរាយការណ៍អំពីអ្នកដទៃដែលទទួលរងគ្រោះដោយសារអំពើហិង្សា

ដូចដែលបានកត់សំគាល់មកខាងលើ ចំលើយអំពីឥរិយាបថរបស់អ្នកដទៃបានបង្ហាញអំពីអត្រាដ៏ខ្ពស់នៃអំពើហិង្សាជាងការសួរអំពីអ្នកផ្តល់ចំលើយដោយផ្ទាល់។ ចំនួនប្រហែល៦៤%បានស្គាល់ប្តីដែលប្រើអំពើហិង្សាផ្លូវកាយទៅលើប្រពន្ធ។ ជាពិសេសមាន៦១%នៃបុរស និង៦៦%នៃស្ត្រីបាននិយាយថា ពួកគេបានដឹងឮអំពីករណីនេះ។ ទោះបីជាយ៉ាងណាក៏ដោយ អ្នកផ្តល់ចំលើយមួយចំនួនធំ (១៥%) បាននិយាយថាពួកគេពុំដឹងទេ[៧១]។ តួលេខនេះគឺប្រហាក់ប្រហែលគ្នានឹងការរកឃើញនៅក្នុងការសិក្សាមួយរបស់អង្គការ PADV ដែលបានធ្វើឡើងកាលពីឆ្នាំ ១៩៩៦ ដែលការសិក្សានេះបានរកឃើញថា មានបុរស ៧៦% និងស្ត្រី ៧២%បានស្គាល់ប្តីដែលប្រើអំពើហិង្សាផ្លូវកាយទៅលើប្រពន្ធរបស់ខ្លួន។ ស្ត្រីដឹងអំពីករណីទាំងនេះច្រើនជាងបុរស។

ការសិក្សាស្រាវជ្រាវនេះ បានសួរអ្នកដែលបានរាយការណ៍អំពីអំពើហិង្សាទាំងនេះ ថាតើមានកត្តាអ្វីខ្លះ អាចបណ្តាលឱ្យមានឥរិយាបថរំលោភបំពាន។ ការតវ៉ាជាមួយប្តីអំពីភាពត្រួតត្រារបស់ប្តី ឬក៏សិទ្ធិរបស់គាត់ក្នុងការធ្វើអ្វីដែលគាត់ចង់ធ្វើ គឺជាកត្តាដែលនាំឱ្យមានកើតអំពើហិង្សាកាន់តែធ្ងន់ធ្ងរ[៧២]។ ដូចដែលបានបង្ហាញនៅក្នុងតារាងទី ៨ ខាងក្រោមនេះ ចំលើយទាំងនេះគឺ បង្ហាញពីចំលើយរបស់អ្នកផ្តល់ចំលើយអំពីឥរិយាបថរបស់ពួកគេ:

- ក្នុងករណីអំពើហិង្សាធ្ងន់ធ្ងរដូចជា: ការជះទឹកអាស៊ីត ការបាញ់ សំលាប់ ឬការកាប់ចាក់ជាដើមនោះច្រើនជាង៣/៤នៃផ្តល់ចំលើយនិយាយថា ប្រពន្ធមានការឈ្លោះប្រកែកជាមួយប្តីមិនស្តាប់បង្គាប់ប្តី ឬមិនគោរពប្តី។
- អ្នកផ្តល់ចំលើយប្រហែលជា១/៣ ឬក៏ច្រើនជាងនេះបាននិយាយថា ក្នុងករណីធ្ងន់ធ្ងរគឺដោយសារប្រពន្ធបានសួរនាំប្តីអំពីរឿងមានស្រីផ្សេង ឬក៏ស្រីរកស៊ីផ្លូវភេទ ឬក៏អំពីការចាយវាយលុយកាក់។

ការសិក្សាស្រាវជ្រាវនេះ បានរកឃើញផងដែរនូវកំរិតដ៏ខ្ពស់នៃអំពើហិង្សា ដែលបានប្រព្រឹត្តដោយអ្នកដទៃ ក្រៅពីប្តីប្រពន្ធ ដោយរួមទាំងអំពើហិង្សា ដែលកើតឡើងដោយសមាជិកគ្រួសារផ្សេងៗទៀត។ ប្រមាណ៦០%បានស្គាល់នារីដែលទួលរងគ្រោះដោយសារការបំពានផ្លូវកាយ (ដោយមានការចោលរបស់របរលើរូបនាង ឬក៏រុញច្រាន) ដែលប្រព្រឹត្តិដោយសមាជិកនៅក្នុងគ្រួសារ។ ប្រមាណជាពាក់កណ្តាលនៃអ្នកផ្តល់ចំលើយ បានស្គាល់អ្នកដែលទទួលរងគ្រោះការវាយបែកក្បាល និងទាត់ ឬក៏ដាល់ពីសំណាក់សមាជិកក្នុងគ្រួសារ។ ២០%នៃបុរស និង១៣%នៃស្ត្រីបានស្គាល់នារីដែលត្រូវបានគេជះទឹកអាស៊ីតលើ ឬក៏កាប់ចាក់ ការបាញ់ ការដុត ការច្របាច់ក ដោយអ្នកផ្សេងក្រៅពីប្តីរបស់នាង។

នៅពេលដែលការសិក្សាស្រាវជ្រាវនេះ បានសួរថាតើអ្នកប្រព្រឹត្តិបទឧក្រិដ្ឋបានព្យាយាមធ្វើអ្វីមួយដើម្បីបញ្ឈប់ឥរិយាបថហិង្សានេះដែរឬទេ? មានអ្នកផ្តល់ចំលើយ ៣៧% និយាយថាអ្នកដែលប្រព្រឹត្តិ "បានព្យាយាមកែប្រែឥរិយាបថ"[៧៣]។ មាន ១៦% និយាយថាអ្នកប្រព្រឹត្តិព្យាយាមឈប់ពិសាស្រា និងមាន១៤%បានឆ្លើយថាអ្នកប្រព្រឹត្តិបានព្យាយាម "ពន្យល់ និងសម្រុះសម្រួល"។

---

៧១ អ្នកផ្តល់ចំលើយថា "ពុំដឹង" អាចជាចំលើយបង្ហាញអោយឃើញនូវការព្រមព្រៀង ឬគ្មានបំណងផ្តល់ចំលើយ

៧២ អ្នកឆ្លើយចំលើយនៅក្នុងក្រុមនេះ ដែលបានរាយការណ៍អំពីការយល់ដឹងរបស់ពួកគេអំពីទង្វើហិង្សា ពុំអាចជាតំណាងឱ្យអ្នកដែលត្រូវបានសម្ភាសទាំងអស់នោះទេ

៧៣ សូមមើលចំលើយនៅក្នុងតារាងទី ៤២ ក្នុងឧបសម្ព័ន្ធ A




**តារាងទី ៤**
**សំណួរទី ១២ b**
*តើនៅក្នុងកាលៈទេសៈបែបណា ដែលបានកើតមានឡើងនូវអំពើហិង្សា?*

### ២.១.២.២ បទពិសោធន៍របស់អ្នកផ្តល់ចំលើយចំពោះការទទួលរងគ្រោះដោយសារអំពើហិង្សា

ដូចដែលបានប៉ាន់ស្មានទុក គឺមានតែអ្នកផ្តល់ចំលើយមួយចំនួនតិចប៉ុណ្ណោះ ដែលបាននិយាយថា ពួកគេធ្លាប់ប្រព្រឹត្តិអំពើហិង្សា ឬបានជួបប្រទះនូវអំពើហិង្សា បើប្រៀបធៀបជាមួយចំនួនអ្នកដែលរាយការណ៍អំពីអ្នកដទៃទៀត គឺមានចំនួនតិចជាង ។ នៅពេលសួរថាតើប្តី ឬប្រពន្ធពួកគេធ្លាប់ប្រព្រឹត្តិអំពើហិង្សាលើរូបពួកគេដែរឬទេ អ្នកផ្តល់ចំលើយមានចំនួនតិចតួចបំផុត ដូចដែលបង្ហាញត្រួសៗខាងក្រោមនេះ:[៧៤]

- ទោះបីជា៦៦%នៃនារី បាននិយាយថាពួកគេស្គាល់ប្តីដែលធ្លាប់ធ្វើបាបផ្លូវកាយទៅលើប្រពន្ធ[៧៥] ក៏ដោយក៏មានតែ ២២,៥% នៃចំនួននារីទាំងអស់បាននិយាយថាប្តីរបស់ពួកនាងបានធ្វើបាបផ្លូវកាយទៅលើពួកនាង ។
- ថ្វីត្បិតតែមានការទទួលយកតិចតួចនូវអំពើហិង្សាដែលប្រព្រឹត្តិដោយនារី ក៏មានបុរស ១២% បាននិយាយថាប្រពន្ធរបស់ពួកគេ ធ្លាប់បានប្រើអំពើហិង្សាមកលើរូបគេ[៧៦] ។
- ៨%នៃបុរស និងនារី ១៥% និយាយថាប្តី/ប្រពន្ធរបស់ពួកគេ បានវាយក្បាល ឬទាត់ ឬដាល់មកលើពួកគាត់ ។
- មានករណីចំនួនតិចប៉ុណ្ណោះ នៃអំពីអំពើហិង្សាធ្ងន់ធ្ងរដែលត្រូវបានរាយការណ៍ ។

អ្នកផ្តល់ចំលើយភាគច្រើន បាននិយាយថាតិរិយាបថហិង្សា កើតឡើងបួនដងក្នុងមួយឆ្នាំ ឬមិនសូវមានជាញឹកញាប់ទេ[៧៧] ។ ស្ត្រីភាគច្រើនទំនងជានិយាយថា ឧប្បត្តិហេតុកើតមានពី ៥ដង ទៅដល់ ២០ដង ក្នុងមួយឆ្នាំ។ ១២% នៃបុរស និង ២០%នៃនារីនិយាយថា ប្តី/ប្រពន្ធបានចោលរបស់របរដាក់ពួកគេ ឬក៏រុញច្រានពួកគេមានពី ៥ដង ទៅដល់ ២០ដង ក្នុងមួយឆ្នាំ។ ៨% នៃបុរស និង ១៥% នៃនារីនិយាយថា ប្តី/ប្រពន្ធ បានវាយក្បាលពួកគេមានពី ៥ដង ទៅដល់ ២០ដង ក្នុងមួយឆ្នាំ។

ការសិក្សាស្រាវជ្រាវនេះបានធ្វើការប្រៀបធៀបអំពីអត្រាប្រេវ៉ាឡង់នៃអំពើហិង្សាក្នុងគ្រួសារ រវាងប្តីប្រពន្ធ ដែលរស់នៅជាមួយឪពុកម្តាយក្មេកជាមួយនឹងអ្នកផ្តល់ចំលើយផ្សេងៗទៀត ។ មានភាពខុសប្លែកគ្នាដែលគួរឱ្យចាប់អារម្មណ៍តែមួយប៉ុណ្ណោះ គឺថាប្តីប្រពន្ធដែលរស់នៅជាមួយឪពុកម្តាយក្មេករាយការណ៍ថា មានការស្រែកគំហកដាក់គ្នាតិចតួច ។

ទោះជាយ៉ាងណាក៏ដោយ ការសិក្សាស្រាវជ្រាវនេះ បានបង្ហាញអំពីទំនាក់ទំនងរវាងអំពើហិង្សារបស់ឪពុក ម្តាយ និងបទពិសោធន៍ផ្ទាល់ខ្លួនរបស់អ្នកផ្តល់ចំលើយ ។ ដូចដែលបានបង្ហាញនៅក្នុងតារាងទី ៩ ខាងក្រោមនេះ គឺថាអ្នកផ្តល់ចំលើយដែលបានឃើញឪពុកម្តាយរបស់អ្នកដទៃ វាយតប់ប្តី/ប្រពន្ធ័ទំនងបានទទួលបទពិសោធន៍បែបនេះពីដៃគូរបស់ខ្លួនដែរ ។ ទំនាក់ទំនងគ្នានេះ មានក៏រិតកាន់តែខ្លាំងសំរាប់ទង្វើហិង្សាដែលពុំសូវធ្ងន់ធ្ងរខ្លាំងពេក ដូចជាការគប់របស់ទៅលើមនុស្សម្នាក់ទៀត ឬហិង្សាដោយប្រើពាក្យសំដីជាដើម ។

---

[៧៤] ភាគរយនៃប្រជាពលរដ្ឋទូទៅ ប្រៀបធៀបទៅនឹងអ្នកដែលបានឃើញឪពុកប្រើអំពើហិង្សាទៅលើម្តាយ និងអ្នកដែលបានឃើញម្តាយប្រើអំពើហិង្សាទៅលើឪពុកដែលបានឆ្លើយថា "ទេ មិនដែលទាល់តែសោះ" នៅក្នុងសំណួរៈ តើប្តី ឬប្រពន្ធរបស់អ្នកធ្លាប់បានប្រព្រឹត្តិអំពើទាំងនេះទៅលើខ្លួនអ្នកដែរឬទេ?

[៧៥] លទ្ធផលចំនួននារីដែលនិយាយថាពួកគេបានស្គាល់ ប្តីដែលប្រើអំពើហិង្សាផ្លូវកាយ សូមមើលតារាងទី ៤០ និង៤១ ក្នុងឧបសម្ព័ន្ធ A

[៧៦] លទ្ធផលនេះប្រៀបធៀបជាមួយ ការសិក្សាស្រាវជ្រាវរបស់អង្គការ PADV នៅឆ្នាំ ១៩៩៦ គឺមានបុរស ៣% បាននិយាយថា ប្រពន្ធរបស់គេប្រើអំពើហិង្សាផ្លូវកាយទៅលើគាត់ ។

[៧៧] សូមមើលតារាងទី ៤៦ ក្នុងឧបសម្ព័ន្ធ A ។ ក្រុមអ្នកផ្តល់ចំលើយ ដែលបានរាយការណ៍អំពីបទពិសោធន៍របស់ពួកគេផ្ទាល់ គឺមិនមែនតំណាងឱ្យអ្នកផ្តល់ចំលើយទាំងអស់នោះទេ ។




**តារាងទី ៩**

**សំណួរទី ១៦ a និង ៣៤ a, b**

*ភាគរយនៃប្រជាពលរដ្ឋទូទៅ ប្រៀបធៀបទៅនឹងអ្នកដែលបានឃើញឪពុកប្រើអំពើហិង្សា ទៅលើម្ដាយ និងអ្នកដែលបានឃើញម្ដាយ ប្រើអំពើហិង្សាទៅលើឪពុកអ្នកដែលបានឆ្លើយថា **"ទេមិនដែលទាល់តែសោះ"** នៅក្នុងសំណួរៈ តើប្ដី ឬប្រពន្ធរបស់អ្នក ធ្លាប់បានប្រព្រឹត្តអំពើទាំងនេះទៅលើខ្លួនអ្នកដែរឬទេ?*

*(Q16a N=1984, Q34a,b N=3030)*

នៅពេលសួរថា តើអ្វីអាចនឹងបញ្ឈប់ប្តី/ប្រពន្ធកុំឱ្យប្រើអំពើហិង្សាបាន? អ្នកផ្តល់ចំលើយភាគច្រើន ច្រើនជាង១/៣បាននិយាយថាពួកគេមិនដឹងទេ។ មានត្រឹមតែ១/៤ប៉ុណ្ណោះ ដែលនិយាយថាគឺមានតែការបកស្រាយពន្យល់ និងសម្រុះសម្រួលគ្នាទេ ដែលអាចបញ្ឈប់អំពើនេះបាន។ ហើយមាន១០%ទៀតឆ្លើយថា មានតែការកែកំហុសរបស់ពួកគេទេ ទើបមានប្រសិទ្ធភាពអាចបញ្ឈប់បញ្ហានេះ ហើយ៩%បាននិយាយថាគ្មានអ្វីដែលអាចបញ្ឈប់បានឡើយ។ មាន៨%នៃអ្នកផ្តល់ចំលើយថា ការមិនតបតអ្វីទាំងអស់ អាចបញ្ឈប់អំពើហិង្សារបស់ប្តី/ប្រពន្ធ ហើយ៨% ផ្សេងទៀតឆ្លើយថាគួរតែអត់ធ្មត់។ ម្យ៉ាងវិញទៀត ស្ត្រីក្នុងចំនួនមួយគួរឱ្យកត់សំគាល់បាននិយាយថា ឥរិយាបថរបស់ខ្លួនផ្ទាល់អាចទប់ស្កាត់អំពើហិង្សារបស់ប្តី/ប្រពន្ធបាន។

មានអ្នកផ្តល់ចំលើយជាច្រើន បានរាយការណ៍ថាអ្នកផ្សេងៗទៀតក្រៅពីប្តី/ប្រពន្ធមុន ឬ ប្តី/ប្រពន្ធ សព្វថ្ងៃរបស់គេ រួមទាំងមនុស្សក្រៅពីសមាជិកគ្រួសារ បានប្រព្រឹត្តអំពើហិង្សាមកលើពួកគេ។ មានប្រមាណជា៨៨% នៃចំនួនអ្នកផ្តល់ចំលើយទាំងអស់ធ្លាប់ត្រូវបានគេបំពានដោយពាក្យសំដីពីអ្នកផ្សេងៗទៀត ក្រៅពីប្តីប្រពន្ធរបស់ខ្លួន។ ប៉ុន្តែតួលេខចំពោះការបំពានផ្លូវកាយ គឺទាបជាងនេះ។២៩% និយាយថាមានអ្នកក្រៅបានបំពានផ្លូវកាយទៅលើពួកគេ។ គួរឱ្យកត់សំគាល់ថា គឺតួលេខនៃការបំពានផ្លូវកាយនេះនៅទាបជាងចំនួនករណីដែល "អ្នកដទៃទៀត" ទទួលនូវការបំពានពីសមាជិកក្នុងគ្រួសារ ទោះបីជាសំណួរនេះបានសួរអំពីអំពើហិង្សាដែលប្រព្រឹត្តដោយជនល្មើសណាមួយនោះក៏ដោយ។ លទ្ធផលនេះបង្ហាញពីការខុសគ្នាបន្តិចបន្តួចរវាងការវាយតប់ ការទះ ឬទាត់ ដែលមាន៥៣%នៃបុរស និងស្ត្រី៥០%បានស្គាល់អ្នកដែលត្រូវបានសមាជិកគ្រួសារប្រព្រឹត្តដូច្នេះមកលើខ្លួន ប៉ុន្តែមានតែបុរស៣១% និង ស្ត្រី១៤% ប៉ុណ្ណោះ ដែលបានរាយការណ៍ថា ត្រូវបានគេប្រព្រឹត្តមកលើខ្លួនតាមរបៀបបែបនេះ។

មនុស្សភាគច្រើនបាននិយាយថា សមាជិកគ្រួសារដទៃទៀត ជាពិសេសឪពុកម្តាយ និងបងប្អូនបង្កើនជាអ្នកដែលប្រព្រឹត្ត ដូចដែលបានបង្ហាញនៅក្នុងតារាងទី១០។ ក្នុងចំណោមអ្នកផ្តល់ចំលើយទាំងអស់មាន៨៤%នៃបុរស និងស្ត្រី៨៦% បានឆ្លើយថាអ្នកប្រព្រឹត្តភាគច្រើនបំផុត គឺជាឪពុកម្តាយរបស់អ្នកផ្តល់ចំលើយ។ ប្រមាណជិតពាក់កណ្តាលនៃអ្នកផ្តល់ចំលើយ បាននិយាយថាអ្នកដែលប្រព្រឹត្តជាបងប្អូនបង្កើតរបស់ពួកគេ។ បុរសទំនងជាធ្លាប់ទទួលបទពិសោធន៍នៃអំពើហិង្សាជាសាធារណៈដែលប្រព្រឹត្តដោយមិត្តភ័ក្តិ មនុស្សមិនស្គាល់គ្នា ប៉ូលីស និងទាហាន ច្រើនជាងស្ត្រី។ អ្នកផ្តល់ចំលើយដែលមានវ័យចំណាស់ បានរាយការណ៍ថាគាត់ទទួលនូវអំពើហិង្សាភាគច្រើន ពីប៉ូលីស និងទាហាន។ ជាពិសេស១០%នៃអ្នកផ្តល់ចំលើយដែលមានអាយុពី ៣០ឆ្នាំ ទៅ ៤០ឆ្នាំ ប្រាប់ថាមានអំពើហិង្សាបែបនេះមែន ហើយចំនួននេះកើនឡើងដល់ទៅ១៧% សំរាប់អ្នកដែលមានអាយុ ៤០ឆ្នាំ និងលើសពីនេះ។អ្នកផ្តល់ចំលើយដែលនៅទីក្រុងឆ្លើយថាអំពើហិង្សាដែលប្រព្រឹត្តដោយឪពុកម្តាយមានតិចតួច និងអំពើហិង្សាប្រព្រឹត្តដោយសារមិត្តភ័ក្តិមានច្រើន។

## តារាងទី ១០

### សំណួរទី ១៧ b

*តើនរណាដែលបានធ្វើដូចនោះ? (សំណួរបន្ទាប់ពីសំណួរ តើមាននរណាក្រៅផ្សេងទៀត ធ្លាប់មានឥរិយាបថបែបនេះ ទៅលើអ្នកដែរឬទេ?)*

*(N=2711)*



### ២.១.២.៣ អំពើហិង្សាដែលប្រព្រឹត្តិដោយអ្នកផ្តល់ចំលើយ

ការសិក្សាស្រាវជ្រាវនេះ ក៏បានសួរដល់អ្នកផ្តល់ចំលើយផងដែរអំពីឥរិយាបថហិង្សាផ្ទាល់ខ្លួនរបស់ពួកគេទៅកាន់ប្តី/ប្រពន្ធរបស់គាត់ ។ បើប្រៀបធៀបទៅនឹងចំនួនស្ត្រីដែលបានរាយការណ៍អំពីឥរិយាបថហិង្សារបស់ប្តី ចំនួនបុរសដែលបានរាយការណ៍ថាខ្លួនគាត់ធ្វើអំពើហិង្សាទៅលើប្រពន្ធ គឺមានចំនួនតិចជាងចំលើយរបស់ស្ត្រី[៧៨] ។ បុរស ១៦% ប្រាប់ថាពួកគេធ្លាប់ប្រព្រឹត្តអំពើហិង្សាផ្លូវកាយ បើប្រៀបធៀបនឹងចំលើយរបស់ស្ត្រី គឺមានស្ត្រី២២.៥%បានរាយការណ៍ថាប្តីធ្លាប់ប្រើអំពើហិង្សា[៧៩] ។ អ្នករស់នៅទីក្រុង ត្រូវបានទទួលស្គាល់ថាមានអំពើហិង្សាតិចជាងអ្នកដែលរស់នៅទីជនបទ ។

ភាគច្រើននៃអ្នកផ្តល់ចំលើយដែលបានទទួលស្គាល់ថាពួកគេបានប្រព្រឹត្តអំពើហិង្សា បាននិយាយថាពួកគេប្រព្រឹត្តអំពើហិង្សាតិចជាង៥ដង ក្នុងឆ្នាំ កន្លងទៅនេះ[៨០] ។ ជាថ្មីម្តងទៀត ស្ត្រីបានរាយការណ៍ថា ការប្រើអំពើហិង្សាដោយខ្លួនគាត់ផ្ទាល់មិនមានជាញឹកញាប់នោះទេ ។

អ្នកផ្តល់ចំលើយទាំងនោះត្រូវបានសួរថា "តើមានអ្វីដែលធ្វើឱ្យអ្នកអាចបញ្ឈប់ការប្រើអំពើនេះបាន?" - ដែលអ្នកជាអ្នកប្រព្រឹត្តអំពើនេះ ។ ចំលើយដែលឆ្លើយជាទូទៅ គឺការអត់ធ្មត់ សំរួលឥរិយាបថ និងពិភាក្សាអំពីបញ្ហាដែលបានកើតឡើង[៨១] ។ ត្រូវគិតថាទង្វើហិង្សានេះ គឺជាទង្វើដែលបណ្តាលអោយមានគ្រោះថ្នាក់ គឺជាចំលើយរបស់អ្នកផ្តល់ចំលើយមួយចំនួនតូច ព្រោះថាគ្មានទទួលផលចំណេញសំរាប់ប្តី/ប្រពន្ធនោះឡើយ ។ ទោះបីជាអ្នកផ្តល់ចំលើយជាច្រើនលើកហេតុផលថា មកពីការកង្វះការគោរព និងការស្តាប់បង្គាប់គ្នា ជាហេតុផលដែលនាំឱ្យកើតមានអំពើហិង្សាក៏ដោយ ប៉ុន្តែមានតែ៧%ប៉ុណ្ណោះ ដែលនិយាយថាការស្តាប់បង្គាប់ និងគោរពប្រណិប័តន៍របស់ពួកគាត់ នឹងអាចនាំឱ្យមានការឈប់ប្រើអំពើហិង្សា ហើយមាន៥%ឆ្លើយថា គឺការឈប់ផឹកស្រា ។

ការអង្កេតនេះ ក៏បានពិនិត្យមើលផងដែរអំពីទំនាក់ទំនងគ្នារវាងអំពើហិង្សា និងវត្តមាននៃឪពុកម្តាយរបស់ប្តី/ប្រពន្ធនៅក្នុងផ្ទះរួមគ្នា ។ លក្ខណៈខុសគ្នាគួរឱ្យកត់សំគាល់តែមួយគត់ គឺការស្រែកគំហក និងការជេរបញ្ឆោរ ត្រូវបានកាត់បន្ថយនៅក្នុងគ្រួសារដែលមានឪពុកម្តាយរស់នៅជាមួយដែរ ។

ជាថ្មីម្តងទៀត ការសិក្សាស្រាវស្រាវនេះបានរកឃើញនូវទំនាក់ទំនងគ្នារវាងចំនួនអ្នកផ្តល់ចំលើយដែលបានរាយការណ៍អំពីបទពិសោធន៍ផ្ទាល់ខ្លួនជាមួយនឹងអំពើហិង្សា និងចំនួននៃអ្នកផ្តល់ចំលើយដែលបានរាយការណ៍អំពីអំពើហិង្សាពីសំណាក់ឪពុកម្តាយដូចដែលបង្ហាញនៅក្នុងតារាងទី១១ខាងក្រោម ។

---

៧៨ អ្នកផ្តល់ចំលើយត្រូវបានសួរថា "តើអ្នកធ្លាប់មានប្រើអំពើណាមួយដូចរៀបរាប់ខាងក្រោមនេះ ទៅលើប្តី/ប្រពន្ធអ្នកដែរឬទេ?"

៧៩ តួលេខនេះប្រហាក់ប្រហែលគ្នាទៅនឹងនារីដែលធ្លាប់រៀបការរួច មាន ២៣% ចាប់ពីអាយុ ១៥ ឆ្នាំ ដល់ ៤៩ ឆ្នាំ នៅក្នុង CDHS ២០០០ ដែលបាននិយាយថាពួកគេធ្លាប់ទទួលរងគ្រោះដោយសារការបំពានផ្លូវកាយ ។ ក្នុងចំណោមនារីដែលរាយការណ៍ថា មានអំពើហិង្សាលើខ្លួនមាន៧៥% រាយការណ៍ថាប្តីជាអ្នកប្រព្រឹត្តិមកលើខ្លួនគាត់ - ប្រព្រឹត្តិតែម្នាក់ឯង ឬប្រព្រឹត្តិជាមួយអ្នកក្រៅផ្សេងទៀត ។ អង្កេតប្រជាសាស្ត្រ និងសុខភាព (CDHS) ឆ្នាំ២០០០ ខុសគ្នាពីការសិក្សានាពេលបច្ចុប្បន្ននេះ នៅត្រង់អាយុ និងស្ថានភាពអាពាហ៍ពិពាហ៍របស់ក្រុមអ្នកផ្តល់ចំលើយ ។

៨០ សូមមើលចំលើយ នៅក្នុងតារាងទី ៤៣ ក្នុងឧបសម្ព័ន្ធ A ។ ក្រុមអ្នកផ្តល់ចំលើយ ដែលនិយាយថាពួកគេប្រព្រឹត្តិអំពើហិង្សា ពុំមែនតំណាងឱ្យអ្នកផ្តល់ចំលើយទាំងមូលនោះទេ ។

៨១ សូមមើលចំលើយ នៅក្នុងតារាងទី ៤៤ ក្នុងឧបសម្ព័ន្ធ A ។

## សេចក្តីសន្និដ្ឋាន

ការសិក្សាស្រាវជ្រាវនេះ បានរកឃើញថា កំរិតនៃអំពើហិង្សាក្នុងគ្រួសារនៅកម្ពុជាអង្កេតដែលធ្វើនៅឆ្នាំ ១៩៩៦ ដោយអង្គការ PADV ទោះពីជាអង្គការក្រៅរដ្ឋាភិបាលនានា និងអ្នកផ្តល់ជំនួយនានាបានខិតខំធ្វើការអស់រយៈពេលយូរឆ្នាំហើយក៏ដោយ ។ លទ្ធផលនេះ គឺបង្ហាញនូវភាពដែលអាចអោយទុកចិត្តបានលើការសិក្សានេះ និងលើកឡើងនូវសំណួរអំពីប្រសិទ្ធភាពនៃកិច្ចខិតខំប្រឹងប្រែងដោះស្រាយអំពើហិង្សាក្នុងគ្រួសារ នៅក្នុងរយៈពេល៩ ឆ្នាំកន្លងទៅនេះ ។ ប្រមាណ ៦៤%នៃអ្នកផ្តល់ចំលើយបានស្គាល់ប្តីដែលបានបំពានផ្លូវកាយទៅលើប្រពន្ធ ។ ស្ត្រីសរុបចំនួន ២២,៩% បាននិយាយថាប្តីរបស់គាត់មានឥរិយាបថហិង្សាមកលើពួកគាត់ ដែលចំនួននេះប្រហែលទៅនឹង២៣%នៃស្ត្រីដែលធ្លាប់រៀបការរួច អាយុ១៥ ឆ្នាំ ដល់ ៤៩ ឆ្នាំ ដែលបានផ្តល់ចំលើយនៅក្នុងអង្កេតប្រជាសាស្ត្រ និងសុខភាព ឆ្នាំ២000ដែលបាននិយាយថាពួកគេមានបទពិសោធន៍ទទួលរងគ្រោះដោយសារអំពើហិង្សា ។ ទោះបីជាមានឥរិយាបថមួយចំនួន ពុំទទួលយកនូវអំពើហិង្សាដែលប្រព្រឹត្តដោយស្ត្រី ប៉ុន្តែចំនួនបុរសដែលនិយាយថាប្រពន្ធរបស់ពួកគេមានអាកប្បកិរិយាហិង្សាចំពោះពួកគេកើនឡើងពី ៣%ដែលជាលទ្ធផលអង្កេតរបស់អង្គការ PADV នៅឆ្នាំ ១៩៩៦ ដល់ទៅ ១២%នៅក្នុងការសិក្សាស្រាវជ្រាវនេះ ។ នៅក្នុងសំណួរអំពីឥរិយាបថចំពោះអំពើហិង្សាអ្នកផ្តល់ចំលើយបានបង្ហាញអំពីទំនាក់ទំនងរវាងឥរិយាបថមួយចំនួនរបស់ប្រពន្ធជាមួយនឹងឥរិយាបថរបស់ប្តី ។ មានករណីជាច្រើន សូម្បីតែក្នុងករណីអំពើហិង្សាធ្ងន់ធ្ងរ អ្នកផ្តល់ចំលើយបានឆ្លើយថានៅពេលដែលប្រពន្ធតវ៉ាអំពីតួនាទីត្រួតត្រារបស់ប្តី ឬសិទ្ធិរបស់ប្តីក្នុងការធ្វើអ្វីតាមចិត្ត គឺជាមូលហេតុដែលនាំឱ្យមានអំពើហិង្សាកាន់តែធ្ងន់ធ្ងរបំផុត ។ ការសិក្សាស្រាវជ្រាវនេះបានបង្ហាញយ៉ាងច្បាស់លាស់អំពីទំនាក់ទំនងគ្នារវាងអំពើហិង្សា និងប្រវត្តិនៃការប្រើអំពើហិង្សារបស់ឪពុកម្តាយ ។

ការសិក្សាស្រាវជ្រាវនេះ ក៏បានរកឃើញផងដែរនូវកំរិតដែលគួរអោយកត់សំគាល់នៃអំពើហិង្សាដែលបានប្រព្រឹត្តឡើងដោយអ្នកផ្សេងៗទៀតក្រៅពីប្តី/ប្រពន្ធ ។ អ្នកដែលប្រព្រឹត្តអំពើហិង្សាលើស្ត្រីភាគច្រើន គឺជាសមាជិកផ្សេងៗទៀតនៅក្នុងគ្រួសារ ។ បុរសទំនងជាធ្លាប់មានបទពិសោធន៍ទទួលនូវអំពើហិង្សាជាសាធារណៈដែលប្រព្រឹត្តដោយមិត្តភ័ក្តិ មនុស្សមិនស្គាល់គ្នា ប៉ូលីស និងទាហានច្រើនជាងស្ត្រី ។




**តារាងទី ១១**

**សំណួរទី ១៥ a និង ៣៤ a, b**

*សមាមាត្រនៃប្រជាពលរដ្ឋទូទៅ ប្រៀបធៀបទៅនឹងអ្នកដែលបានឃើញឪពុកវាយម្តាយរបស់ពួកគេ និង អ្នកដែលបានឃើញម្តាយវាយឪពុករបស់ពួកគេ អ្នកដែលបានឆ្លើយថា "**ទេមិនដែលទាល់តែសោះ**" នៅក្នុងសំណួរៈ តើប្តី ឬប្រពន្ធរបស់អ្នកធ្លាប់បានប្រព្រឹត្តអំពើទាំងនេះទៅលើខ្លួនអ្នកដែរឬទេ?*

*(Q15a N=1995, Q34a,b N=3030)*

### ២.១.៣ ផលប៉ះពាល់នៃអំពើហិង្សាផ្លូវកាយពីសំណាក់សហព័ទ្ធ

អំពើហិង្សាផ្លូវកាយ ប៉ះពាល់យ៉ាងខ្លាំងដល់ជីវភាពសេដ្ឋកិច្ច ផ្លូវកាយ និងផ្លូវចិត្តរបស់អ្នកដែលនៅក្នុងរងគ្រោះទាំងគ្រួសារអ្នកមាន និងគ្រួសារអ្នកក្រីក្រ។ អំពើហិង្សាផ្លូវកាយបណ្តាលឱ្យមានរបួសយ៉ាងធ្ងន់ធ្ងរដែលតម្រូវឱ្យមានការព្យាបាល ការខូចខាតទ្រព្យសម្បត្តិ និងការបាត់បង់សមត្ថភាពធ្វើការងារ និងការរកប្រាក់ចំណូល។ ស្ត្រីដែលរស់នៅក្នុងស្ថានភាពដែលមានការរំលោភបំពាន ទទួលរងនូវផលប៉ះពាល់ផ្នែកផ្លូវចិត្តរហូតអស់មួយជីវិត។ ជាទូទៅ អ្នកជំនាញផ្សេងៗទៀតបានរកឃើញថា ពួកគេនិយាយថាពួកគេត្រូវតែពិនិត្យ និងកែប្រែអាកប្បកិរិយារបស់គេជាប្រចាំដើម្បីព្យាយាមទប់ស្កាត់ប្តីរបស់គេកុំឱ្យប្រើអំពើហិង្សាមកលើខ្លួន។ បញ្ហានេះបំផ្លាញនូវការទុកចិត្តលើខ្លួនឯងរបស់ពួកគេ និងធ្វើឱ្យសមត្ថភាពរបស់ពួកគេនៅក្នុងការបំពេញការងារទៅជាទន់ខ្សោយ។

អំពើហិង្សាផ្លូវកាយ ក៏មានផលប៉ះពាល់ផ្នែករាងកាយ ផ្លូវចិត្ត និងអារម្មណ៍របស់កុមារផងដែរ។ អំពើហិង្សាអាចប៉ះពាល់ដល់ការលូតលាស់របស់ពួកគេ និងធ្វើពួកគេបាត់បង់សមត្ថភាព ដើម្បីក្លាយទៅជាមនុស្សពេញវ័យដែលមានសុខភាពល្អ និងជាសមាជិកដ៏មានប្រយោជន៍នៅក្នុងសង្គម។ ក្មេងៗអាចមានរបួសផ្នែករាងកាយ ដោយសារតែអំពើហិង្សាក្នុងគ្រួសារ។ ភាពគង់វង្ស និងការអភិវឌ្ឍន៍របស់ទារក ការធ្លាក់ទឹកចិត្តរបស់ម្តាយក៏ប៉ះពាល់ផងដែរដល់ភាពគង់វង្ស។ មានការចងក្រងជាឯកសារថា ការធ្លាក់ទឹកចិត្តរបស់ម្តាយដែលកំពុងមានកំណើតរបស់កូនក្នុងរយៈពេលមុន ឬក្រោយពេលមានគភ៌ គឺបណ្តាលអោយមានការថយចុះនៃភាពគង់វង្ស និងការអភិវឌ្ឍន៍របស់ក្មេងមានលក្ខណៈយឺត[៨២]។ ក្មេងៗដែលបានមើលឃើញនូវអំពើហិង្សាក្នុងគ្រួសារ ក៏អាចជួបការលំបាកនៅក្នុងផ្នែកមួយចំនួនដូចជាៈ ការដេក ការហូបចុក ការត្អូញត្អែរអំពីការឈឺចាប់ផ្លូវកាយ ដោយគ្មានមូលហេតុច្បាស់លាស់ មានបញ្ហាជាមួយកិច្ចការសាលារៀន ដោយសារការខកខានមិនបានទៅសាលារៀន និងការលំបាកនៅក្នុងការផ្តោតអារម្មណ៍នៅក្នុងការសិក្សា ការធ្លាក់ទឹកចិត្ត ឬការមួរម៉ៅជាដើម។

ការអង្កេតនេះ បានផ្តោតការយកចិត្តទុកដាក់ជាចម្បងទៅលើផលប៉ះពាល់ផ្នែកជីវភាពសេដ្ឋកិច្ចដោយសារអំពើហិង្សាផ្លូវកាយ ព្រមទាំងផលប៉ះពាល់ទៅលើសុខភាពនិងសុខុមាលភាពរបស់អ្នកផ្តល់ចំលើយ។

#### ២.១.៣.១ ផលប៉ះពាល់ផ្នែកជីវភាពសេដ្ឋកិច្ច

អ្នកផ្តល់ចំលើយជាច្រើន បាននិយាយថា ពួកគេបានបាត់បង់ការងារ និងប្រាក់ចំណូល[៨៣] ដោយសារអំពើហិង្សាពីសំណាក់ប្តីប្រពន្ធរបស់គេ។ ការបាត់បង់ផ្នែកជីវភាពសេដ្ឋកិច្ចនេះ កាន់តែមានផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរចំពោះអ្នកផ្តល់ចំលើយដែលក្រីក្របំផុតដែលរកចំណូលបានតិចជាង២០ដុល្លា ក្នុងមួយខែ។ អ្នកផ្តល់ចំលើយ ក៏បានរាយការណ៍អំពីផលប៉ះពាល់ទៅលើសុខភាព និងសុខុមាលភាពផងដែរ។

---

៨២ ប្រៀបធៀបជាមួយនឹងឯកសាររបស់ Patel, Vikram (e.a.) (ខែមេសា ២០០៤) ស្តីពីផលប៉ះពាល់នៃបញ្ហាសុខភាពផ្លូវចិត្តរបស់ម្តាយទៅលើការរីកលូតលាស់របស់ទារកនៅក្នុងប្រទេសដែលមានប្រាក់ចំណូលទាបៈ ភស្តុតាងថ្មីពីអាស៊ីខាងត្បូង "លេខ BMJ" ទំព័រ ៨២០ ដល់ ៨២៣។
៨៣ ការបាត់បង់ទាំងនេះ ពុំគិតត្រឹមតែការបាត់បង់ការងារដែលទទួលបានប្រាក់កំរៃ ឬចំណូលជាសាច់ប្រាក់នោះទេ។

ឧទាហរណ៍ អ្នកខ្លះបាននិយាយថាពួកគេត្រូវការសេវាថែរក្សាសុខភាព ហើយភាគច្រើនបាននិយាយថា ពួកគេមានបញ្ហាសុខភាព ដូចជាការដេកមិនលក់ ការមួរម៉ៅ ឬការភ័យខ្លាច។ អ្នកផ្តល់ចំលើយមួយចំនួននិយាយថា កូនរបស់ពួកគេខកខានពុំបានទៅរៀនដោយសារអំពើហិង្សានេះ ដែលនេះបង្ហាញឱ្យឃើញថា ផលប៉ះពាល់នៃអំពើហិង្សារវាងប្តីប្រពន្ធនេះ បានរាលដាលដល់អ្នកដទៃទៀត។

អ្នកដែលធ្លាប់ទទួលរងគ្រោះដោយសារអំពើហិង្សាពីសំណាក់សហព័ទ្ធ បានរាយការណ៍ថាការបាត់បង់ការងារ គឺជាផលប៉ះពាល់ទូទៅបំផុត ដូចបានបង្ហាញនៅក្នុងតារាងទី ១២ ខាងក្រោមនេះ។ សូម្បីតែអ្នកផ្តល់ចំលើយមួយចំនួនធំនៅក្នុងលំដាប់ប្រាក់ចំណូលទាបបំផុត - ២៤% បាននិយាយថា ពួកគេបានបាត់បង់ការងារប្រចាំថ្ងៃរបស់គេ ដោយសារអំពើហិង្សា។

ភាគច្រើននៃអ្នកផ្តល់ចំលើយ បាននិយាយថាពួកគេបានបាត់បង់ការងារយូរៗម្តង។ ២/៣នៃអ្នកទាំងនេះបាននិយាយថាពួកគេខកខានពុំបានទៅធ្វើការរៀងរាល់៣ខែម្តង ឬមិនសូវទៀងទាត់។ ការខកខានការងារនេះអាចកើតមានឡើងពុំសូវញឹកញាប់ ដែលពុំមានផលប៉ះពាល់ទៅលើការធ្វើការងារ ឬពុំអាចទាញយកការយកចិត្តទុកដាក់របស់អ្នកដទៃទៀត ចំពោះស្ថានភាពនៃអំពើហិង្សាក្នុងគ្រួសារ។




**តារាងទី ១២**

**សំណួរទី ១៩ a**

*តើអ្វីខាងក្រោមនេះណាខ្លះ ធ្លាប់បានកើតឡើងចំពោះអ្នកដែរឬទេ?*

*(N = 1574)*

ដូចគ្នានេះដែរ មនុស្សជាច្រើនបាននិយាយថាពួកគេបានបាត់បង់ប្រាក់ចំណូល ដោយសារអំពើហិង្សាក្នុងគ្រួសារ។ ការអង្កេតនេះបានវាស់វែងអំពីការបាត់បង់ប្រាក់ចំណូលតាមមធ្យោបាយមួយចំនួន។ ជាសរុប១៦%នៃអ្នកតំណាងបាននិយាយថា ក្នុងឆ្នាំកន្លងទៅពួកគេបានបាត់បង់ប្រាក់ចំណូល ដោយសារអំពើហិង្សាក្នុងគ្រួសារ។ ប្រជាពលរដ្ឋក្រីក្រភាគច្រើន ទំនងជានិយាយថាពួកគេបានបាត់បង់ប្រាក់ចំណូល ប្រហែល១/៤នៃក្រុមនេះបានរាយការណ៍ថាបានបាត់បង់ប្រាក់ចំណូល។ ថ្វីបើបុរសច្រើនជាងស្ត្រីបាននិយាយថា ពួកគេបានបាត់បង់ប្រាក់ចំណូល ប៉ុន្តែស្ត្រីបានរាយការណ៍ថាពួកគេបានបាត់បង់ប្រាក់ចំណូលញឹកញាប់ជាងបុរស។ ២៨%នៃស្ត្រីបានបាត់បង់ប្រាក់ចំណូលពី៥ ទៅ២០ដង ក្នុងរយៈពេល១២ខែកន្លងទៅនេះ បើប្រៀបធៀបជាមួយបុរសមានតែ១៥%ប៉ុណ្ណោះ។

ការបាត់បង់ផ្នែកជីវភាពសេដ្ឋកិច្ចនេះ គឺខុសគ្នាទៅតាមយេនឌ័រ ភូមិសាស្ត្រ និងប្រាក់ចំណូលរបស់អ្នកផ្តល់ចំលើយដែលមានដូចខាងក្រោមនេះ:

- ចំនួនជាមធ្យមនៃប្រាក់ចំណូលដែលបានបាត់បង់ កាលពីឆ្នាំទៅ គឺ ៣៦,២២ ដុល្លា។
- អ្នកផ្តល់ចំលើយក្រីក្របំផុត ដែលរកប្រាក់ចំណូលបានទាបជាង២០ដុល្លា ក្នុងមួយខែ បាននិយាយថា ពួកគេបាត់បង់ចំនួនជិតពីរដងនៃចំនួនប្រាក់ចំណូល ដែលពួកគេរកបានក្នុងមួយខែ។
- ស្ត្រី គឺជាអ្នកដែលបាត់បង់ប្រាក់ចំណូលច្រើនជាងបុរស - ស្ត្រីបានរាយការណ៍ថាកាលពីឆ្នាំទៅពួកគេបានបាត់បង់ចំនួន៤៦,០៩ដុល្លា ចំណែកបុរសឆ្លើយថាបានបាត់បង់ចំនួន២៦.០២ដុល្លា។
- អ្នកផ្តល់ចំលើយនៅជនបទ បាត់បង់ប្រាក់ចំណូលចំនួនច្រើនជាងអ្នកផ្តល់ចំលើយនៅទីក្រុង។

### ២.១.៣.២ ផលប៉ះពាល់ទៅលើកុមារ ដែលធ្លាប់ជួបប្រទះការបំពាន

ក្មេងដែលធ្លាប់ជួបប្រទះនឹងអំពើហិង្សា ក៏ទទួលនូវផលប៉ះពាល់ផងដែរ។ ជិត១/៥នៃអ្នកផ្តល់ចំលើយដែលបានរងគ្រោះដោយសារអំពើរំលោភបំពានបានរាយការណ៍ថា កូនៗរបស់គេបានខកខានមិនបានទៅសាលារៀនពី៥ដង ទៅ២០ដងកាលពីឆ្នាំមុន ដោយសារតែមានអំពើហិង្សាក្នុងគ្រួសារ។ ស្ត្រីមួយចំនួនបាននិយាយថា កូនរបស់ពួកគេ (៧%) បានខកខានមិនបានទៅរៀនពី២០ដង ឬច្រើនជាងនេះ ក្នុងរយៈពេលនេះ។ សមាមាត្រច្រើនជាងនេះ៦៨%នៃបុរស និង៥៨%នៃស្ត្រីបាននិយាយថា កូនរបស់ពួកគាត់ខកខានមិនបានទៅរៀនពី ១ ទៅ ៥ ដងកាលពីឆ្នាំកន្លងមកនេះ។

### ២.១.៣.៣ ផលប៉ះពាល់ទៅលើសុខភាព និងសុខុមាលភាព

អំពើហិង្សាផ្លូវកាយមានឥទ្ធិពលយ៉ាងខ្លាំងទៅលើសុខភាព និងសុខុមាលភាពរបស់អ្នកផ្តល់ចំលើយ។ អ្នកតំណាងជាងពាក់កណ្តាលបានរាយការណ៍ថា ពួកគេមានបញ្ហាផ្លូវចិត្តក្នុងរូបភាពមួយចំនួន។ ពួកគេបាននិយាយថាពួកគេមានអាការៈឆាប់ខឹង ដេកមិនលក់ មួរម៉ៅ ភ័យខ្លាច ឬការធ្លាក់ទឹកចិត្ត ដូចបានបង្ហាញក្នុងតារាងទី១៣ខាងក្រោម។ ស្ត្រី ប្រជាពលរដ្ឋក្រីក្រ និងយុវជនវ័យក្មេង គឺបានទទួលរងគ្រោះដោយសារផលប៉ះពាល់នេះច្រើនជាងគេបំផុត។

- បុរសច្រើនទំនងជាឆាប់ខឹងជាងស្ត្រី ហើយបុរសច្រើនជាងស្ត្រីចំនួយ៣ដង បាននិយាយថាពួកគេផឹកស្រាដោយសារមានអំពើហិង្សា[៨៤] ។
- ប៉ុន្តែស្ត្រីហាក់ដូចជាទទួលរងគ្រោះ ដោយសារលទ្ធផលអវិជ្ជមានច្រើនលើផ្នែកសុខភាពនៅក្នុងរាល់ប្រភេទផ្សេងៗដែលមាននៅក្នុងការអង្កេតនេះ ។
- សមាមាត្រខ្ពស់នៃប្រជាពលរដ្ឋក្រីក្រ បានបង្ហាញថាមានបញ្ហាផ្លូវកាយ ផ្លូវចិត្ត និងអារម្មណ៍នៅក្នុងគ្រប់រូបភាពទាំងអស់ បើប្រៀបធៀបជាមួយនឹងអ្នកដែលមានប្រាក់ចំណូលខ្ពស់ជាង ។

ការភ័យខ្លាចខ្លាំង គឺជាការប៉ះពាល់មួយទៀត ដែលត្រូវបានរាយការណ៍ដោយប្រជាពលរដ្ឋជាច្រើនដែលធ្លាប់មានបទពិសោធន៍ទទួលរងគ្រោះដោយសារអំពើហិង្សា។ ៤៥%នៃអ្នកផ្តល់ចំលើយនិយាយថាគេមានការភ័យខ្លាចចំពោះការរស់នៅរបស់កូនៗរបស់ពួកគេ ដូចបានបង្ហាញក្នុងតារាងទី១៤។ ស្ត្រីទំនងមានចំនួនច្រើនជាងបុរសបានរាយការណ៍ថាពួកគេមានការភ័យខ្លាចចំពោះជីវិតរស់របស់ពួកគេ និងកូនៗរបស់ពួកគេ។ បុរសជាច្រើនទំនងជារាយការណ៍ថា ពួកគេមានការភ័យខ្លាចចំពោះជីវិតរស់នៅរបស់សមាជិកផ្សេងៗទៀតនៅក្នុងគ្រួសារ។ ប្រជាពលរដ្ឋក្រីក្រ និយាយថាពួកគេកាន់តែមានការភ័យខ្លាចគ្រប់បែបយ៉ាង ហើយពាក់កណ្តាលនៃអ្នកក្រីក្របាននិយាយថា ពួកគេមានការភ័យខ្លាចចំពោះការរស់នៅរបស់ពួកគេ។មនុស្សវ័យក្មេងអាយុពី១៥ទៅ១៩ឆ្នាំ ភាគច្រើនទំនងជានិយាយថា ពួកគេមានការភ័យខ្លាចចំពោះជីវិតរស់នៅរបស់ពួកគេ។

[៨៤] សូមកត់សំគាល់ថា ក្នុងករណីនេះ ការផឹកស្រា គឺត្រូវបានរាយការណ៍ថាជាលទ្ធផលនៃអំពើហិង្សាក្នុងគ្រួសារ ដែលផ្ទុយទៅ នឹងមូលហេតុនៃអំពើហិង្សាក្នុងគ្រួសារ ដែលបានពិភាក្សានៅក្នុងផ្នែកផ្សេងៗក្នុងរបាយការណ៍នេះ ។




**តារាងទី ១៣**

**សំណួរទី ២០ a**

*តើអ្នកធ្លាប់មានទទួលរងគ្រោះថ្នាក់អ្វីខ្លះ ដូចខាងក្រោមនេះដែរឬទេ?*

*N=1574*




**តារាងទី ១៤**

**សំណួរទី ២០ b**

*តើអ្នកធ្លាប់មានទទួលរងគ្រោះថ្នាក់អ្វីខ្លះ ដូចខាងក្រោមនេះដែរឬទេ?*

*(N=1515)*

## សេចក្តីសន្និដ្ឋាន

ផលប៉ះពាល់នៃអំពើហិង្សាផ្លូវកាយ គឺមានលក្ខណៈធ្ងន់ធ្ងរ។ ក្រៅពីការរងរបួស និងឈឺចាប់ អ្នកផ្តល់ចំលើយនិយាយថា ពួកគេទទួលរងនូវការខាតបង់ផ្នែកជីវភាពសេដ្ឋកិច្ច។ ការខាតបង់ផ្នែកជីវភាពសេដ្ឋកិច្ច គឺមានលក្ខណៈកាន់តែធ្ងន់ធ្ងរចំពោះស្ត្រី និងប្រជាពលរដ្ឋក្រីក្រ។ អ្នកផ្តល់ចំលើយក៏បានរៀបរាប់ផងដែរពីផលប៉ះពាល់ជាបន្តបន្ទាប់ចំពោះសុខភាព និងសុខុមាលភាពរបស់ពួកគេ ជាពិសេសក្នុងចំណោមស្ត្រីមានដូចជា ចាប់ពីការធុញថប់នៅក្នុងអារម្មណ៍ ទៅជាជំងឺផ្លូវកាយ។ ចុងក្រោយអ្នកផ្តល់ចំលើយបាននិយាយថា ពួកគេមានការភ័យខ្លាចចំពោះជីវិតរស់នៅរបស់ពួកគេ និងជីវិតរស់នៅរបស់គ្រួសាររបស់ពួកគេ។ ការភ័យខ្លាចធ្វើឱ្យគេបាត់បង់នូវជំនឿលើខ្លួនឯង សុវត្ថិភាព សមត្ថភាពដោះស្រាយបញ្ហា ឬការកសាងផែនការសំរាប់អនាគត។

### ២.១.៤ គ្រឿងស្រវឹង និងអំពើហិង្សាក្នុងគ្រួសារ

ការសេពគ្រឿងស្រវឹងជារឿយៗ ធ្វើឱ្យសមត្ថភាពក្នុងការគ្រប់គ្រងខ្លួនឯងធ្លាក់ចុះ ដែលអាចធ្វើឱ្យមនុស្សបាត់បង់លទ្ធភាពក្នុងការទប់ស្កាត់ខ្លួនឯង និងប្រព្រឹត្តក្នុងផ្លូវខុចខាត។ ហេតុដូច្នេះហើយ ការអង្កេតនេះ បានវាស់ស្ទង់ការប្រើប្រាស់គ្រឿងស្រវឹងក្នុងចំណោមអ្នកផ្តល់ចំលើយ និងសហព័ទ្ធរបស់ពួកគេ និងប្រៀបធៀបកំរិតនៃអំពើហិង្សាក្នុងគ្រួសារក្នុងចំណោមក្រុមទាំងនោះ ដោយអនុលោមទៅតាមទម្លាប់នៃការប្រើគ្រឿងស្រវឹងរបស់អ្នកផ្តល់ចំលើយ។

ការអង្កេតបានសង្កត់ធ្ងន់ទៅលើការប្រើប្រាស់គ្រឿងស្រវឹង ដោយការសួរទៅអ្នកផ្តល់ចំលើយអំពីទម្លាប់នៃការប្រើគ្រឿងស្រវឹងរបស់ពួកគេ និងទម្លាប់នៃការប្រើគ្រឿងស្រវឹងរបស់សហព័ទ្ធរបស់ពួកគេ។ ដូចបង្ហាញនៅក្នុងតារាងខាងក្រោម មានគម្លាតយ៉ាងធំរវាងយេនឌ័រ និងគម្លាតយ៉ាងធំរវាងការរាយការណ៍របស់អ្នកផ្តល់ចំលើយខ្លួនឯងផ្ទាល់ និងអំពីសហព័ទ្ធរបស់ពួកគេ។ អ្នកស្រាវជ្រាវបានរកឃើញថាចំលើយអំពី "អ្នកដទៃទៀត" គឺអាចជឿទុកចិត្តបានជាង ដែលក្នុងនោះចំលើយគឺថាមានបុរសប្រហែល៨០% យ៉ាងហោចណាស់ សេពគ្រឿងស្រវឹងម្តងម្កាលដែរ។

| | សរុប | ស្ត្រី |
|---|---|---|
| ទេ,មិនដែលទេ | ៤៥% | ៧១% |
| ម្តងម្កាល | ៤៣% | ២៦% |
| ប្រហែលម្តងក្នុងមួយសប្តាហ៍ | ២% | ១% |
| ប្រហែល២ដងក្នុងមួយសប្តាហ៍ | ២% | ១% |
| រៀងរាល់២ថ្ងៃម្តង | ១% | ០% |
| រៀងរាល់ថ្ងៃ ឬ ស្ទើរតែរាល់ថ្ងៃ | ២% | ១% |

**តារាងទី ១៥**
**សំណួរទី ១៧ a**
*តើអ្នកធ្លាប់ពិសាស្រា ឬស្រាបៀ និងគ្រឿងស្រវឹងដទៃទៀតដែរឬទេ?*
(N=3030)

| | សរុប | ស្ត្រី |
|---|---|---|
| ទេ,មិនដែលទេ | ៤២% | ២២% |
| ម្តងម្កាល | ៤៤% | ៥៨% |
| ប្រហែលម្តងក្នុងមួយសប្តាហ៍ | ៤% | ៦% |
| ប្រហែល២ដងក្នុងមួយសប្តាហ៍ | ២% | ៣% |
| រៀងរាល់២ថ្ងៃម្តង | ២% | ៣% |
| រៀងរាល់ថ្ងៃ ឬ ស្ទើរតែរាល់ថ្ងៃ | ៥% | ៩% |

**តារាងទី ១៦**
**សំណួរទី ១៧ b**
*តើប្តីឬប្រពន្ធអ្នកផឹកស្រា ឬ ស្រាបៀរដែរឬទេ?*
(N=1995)

ការទទួលរងគ្រោះដោយសារអំពើហិង្សាដែលរាយការណ៍ដោយអ្នកផ្តល់ចំលើយ គឺមានការទាក់ទងគ្នាដោយផ្ទាល់ជាមួយនឹងការសេពគ្រឿងស្រវឹងជាប្រចាំរបស់សហព័ទ្ធ ដូចមានបង្ហាញនៅក្នុងតារាងទី១៧ខាងក្រោមនេះ។ សហព័ទ្ធដែលប្រើគ្រឿងស្រវឹងញឹកញាប់ "រាល់ថ្ងៃ" ប្រើអំពើហិង្សាកាន់តែខ្លាំង។

ការអង្កេតក៏បានបង្ហាញផងដែរនូវការជាប់ពាក់ពន្ធ័គ្នារវាងអំពើហិង្សា ដែលប្រព្រឹត្តិដោយអ្នកផ្តល់ចំលើយផ្ទាល់ និងការរាយកាណ៍អំពីការប្រើប្រាស់គ្រឿងស្រវឹងរបស់ពួកគេ។ អ្នកដែលសេពគ្រឿងស្រវឹងពីរដងក្នុងមួយសប្តាហ៍ ទំនងជាប្រព្រឹត្តអំពើហិង្សាច្រើនជាងអ្នកដែលសេពគ្រឿងស្រវឹងតិចជាងនេះ ឬមិនដែលសេពគ្រឿងស្រវឹង ដូចបង្ហាញក្នុងតារាងទី១៨។ ការស្រែកគំហ៊ក និងការជេរបញ្ចោរទំនងជាកើនឡើង នៅពេលដែលការសេពគ្រឿងស្រវឹងកើនឡើង។




**តារាងទី ១៧**

**សំណួរទី ១៦ a និងសំណួរទី ៧ b**

*ភាគរយនៃអ្នកដែលឆ្លើយ "ចាស ឬបាទ" ចំពោះសំណួរដូចខាងក្រោមនេះ:*
*តើសហព័ទ្ធរបស់លោកអ្នកធ្លាប់បានប្រព្រឹត្តដូចខាងក្រោមដែរឬទេ? តើសហព័ទ្ធរបស់លោកអ្នកធ្លាប់ពិសាស្រា ស្រាបៀរ ឬគ្រឿងស្រវឹងដទៃទៀតដែរឬទេ?*
*(សំណួរ ១៦ a N=1984 សំណួរ ៧b N= 1995)*




**តារាងទី ១៨**

**សំណួរទី ១៥ a, និងសំណួរទី ៧ a**

*ភាគរយនៃអ្នកដែលឆ្លើយ "ចាស ឬបាទ" ចំពោះសំណួរដូចខាងក្រោមនេះ: តើអ្នកធ្លាប់ប្រព្រឹត្តអំពើខាងក្រោម ចំពោះសហព័ទ្ធរបស់លោកអ្នកដែរឬទេ? តើអ្នកពិសាស្រាស្រាបៀ ឬគ្រឿងស្រវឹងផ្សេងៗទៀតដែរឬទេ?*

*(សំណួរ ១៥a N=1995 សំណួរ ៧a N= 3030)*

## សេចក្តីសន្និដ្ឋាន

ការអង្កេតក៏បានបង្ហាញនូវទំនាក់ទំនងគ្នាយ៉ាងខ្លាំងរវាងគ្រឿងស្រវឹង និងអំពើហិង្សា ។ ជាទូទៅ នៅពេលការប្រើគ្រឿងស្រវឹងកើនឡើង ការប្រព្រឹត្តអំពើហិង្សាក៏កើនឡើងដែរ ។ ករណីនេះបាន បង្ហាញទាំងនៅក្នុងចំលើយអំពីសហព័ទ្ធ និងចំលើយរបស់អ្នកផ្តល់ចំលើយអំពីខ្លួនគាត់ផ្ទាល់ ។ ចំលើយ របស់អ្នកផ្តល់ចំលើយអំពីទម្លាប់ប្រើគ្រឿងស្រវឹងរបស់ខ្លួនផ្ទាល់ និងចំលើយរបស់អ្នកផ្តល់ចំលើយ អំពីទម្លាប់របស់សហព័ទ្ធរបស់គាត់ពុំស៊ីគ្នានោះទេ ។ ចំណុចនេះបង្កើតអោយមានសំណួរអំពីប្រេវ៉ាឡង់ នៃការសេពគ្រឿងស្រវឹង និងភាពស្មោះត្រង់ក្នុងការបង្ហាញពីទម្លាប់សេពគ្រឿងស្រវឹង ព្រោះថា សង្គមពុំឱ្យតំលៃដល់ការសេពគ្រឿងស្រវឹង ។

## ២.២ ការបំពានផ្លូវចិត្ត

អំពើហិង្សាក្នុងគ្រួសារ រួមមានការបំពានផ្លូវកាយ និងផ្លូវចិត្ត។ ការបំពានផ្លូវចិត្តកើតឡើងនៅពេលដែលស្វាមីដាក់សម្ពាធលើភរិយាឱ្យគោរព និងស្តាប់តាមគំនិតរបស់គាត់ថា តើប្រពន្ធត្រូវប្រព្រឹត្តដូចម្តេច ហើយប្រពន្ធគួរអនុវត្តតួនាទីយេនឌ័រដូចម្តេចខ្លះ។ សម្ពាធទាំងនេះធ្វើឱ្យប្រពន្ធបាត់បង់ជំនឿចិត្តលើខ្លួនឯង នឹងនាំឱ្យមានការភ័យខ្លាច ខ្វល់ខ្វាយ និងក្រៀមក្រំចិត្ត។ លក្ខណៈនេះអាចកាន់តែកើនខ្លាំងឡើងៗទៅតាមកំរិតនៃភាពខឹងចំពោះការបំពាន។ ដោយសារតែភាពខឹងចំពោះការបំពាននេះ មិនអាចបញ្ចេញមកខាងក្រៅបានទ្រាំទប់ភាពខឹងនេះនៅក្នុងចិត្តជាលទ្ធផលធ្វើឱ្យមានការបាត់បង់ការគោរពខ្លួនឯង មើលងាយខ្លួនឯង និងអស់សង្ឃឹម។

ការសិក្សាស្រាវជ្រាវនេះ បានផ្តោតការយកចិត្តដាក់ទៅលើការបំពានផ្លូវចិត្តពីរយ៉ាងៈ ស្វាមីខឹងនឹងភរិយាដែលមិនបានបំពេញតួនាទីយេនឌ័ររបស់ខ្លួន និងស្វាមីព្យាយាមគ្រប់គ្រងប្រពន្ធ ដូចជាការស្នៀកពាក់ ឬប្រពន្ធទៅណា ឬជួបនឹងអ្នកណាជាដើម។ អ្នកជំនាញការខាងអំពើហិង្សាក្នុងគ្រួសាររាយការណ៍ថា ការគ្រប់គ្រងក្នុងចំណងអាពាហ៍ពិពាហ៍បែបនេះ ជារឿយៗពាក់ព័ន្ធទៅនឹងអំពើហិង្សាផ្លូវចិត្ត រាងកាយ និងហិង្សាផ្លូវភេទក្នុងជីវិតអាពាហ៍ពិពាហ៍។ ការអង្កេតនេះបានពិនិត្យទៅលើករណីទាំងពីរនេះ និងបានសួរអ្នកផ្តល់ចំលើយ ថាតើដោះស្រាយបញ្ហានេះយ៉ាងដូចម្តេច? ការអង្កេតនេះក៏បានរកឃើញផងដែរនូវដំណោះស្រាយសំរាប់ស្ថានភាពទាំងនេះ [៨៥]។

### ២.២.១ ការខឹងរបស់បុរស

សំណួរសំរាប់អ្នកផ្តល់ចំលើយអំពីកំរិតនៃការអាចទទួលយកបាននូវអំពើហិង្សារបស់បុរស គឺចាប់ពីកំរិតអាចទទួលយកបានទៅដល់កំរិតមិនអាចទទួលយកបាន។ ជាពិសេសអ្នកផ្តល់ចំលើយបានឆ្លើយអំពីកំរិតនៃការខឹងរបស់បុរសក្នុងស្ថានភាពផ្សេងៗគ្នា គឺកំរិតពីទីមួយដល់ទីប្រាំ ដែលកំរិតទីមួយគឺរបស់បុរស "សមហេតុសមផលណាស់" ហើយកំរិតទី៥ គឺការខឹងរបស់បុរស "មិនសមហេតុផលទាល់តែសោះ"។ ជាងពាក់កណ្តាលនៃអ្នកផ្តល់ចំលើយបាននិយាយថា ប្តីខឹងគឺសមហេតុសមផលនៅពេលដែលប្រពន្ធមិនបានបំពេញការងារផ្ទះ[៨៦]។ ផ្ទុយពីការរំលោភបំពានផ្លូវកាយ ដែលអំពើហិង្សាដែលធ្ងន់ធ្ងរបំផុត អ្នកត្រូវផ្តល់ចំលើយគិតថាសមហេតុផល គឺនៅពេលដែលភរិយាសួរនាំអំពីអំណាចរបស់ស្វាមី ប៉ុន្តែអំពើហិង្សាផ្លូវចិត្ត និងការត្រួតត្រាលើឥរិយាបថរបស់ប្រពន្ធ ត្រូវបានឆ្លើយថាសមហេតុផល នៅពេលដែលភរិយាមិនបានយកចិត្តទុកដាក់ថែទាំកូនរបស់ខ្លួន និងមិនយកចិត្តទុកដាក់ការងារផ្ទះសម្បែង។ ហេតុផលចំបងដែលផ្តល់ហេតុផលសមរម្យសំរាប់ការខឹងរបស់ប្តី គឺភរិយាមិនបានយកចិត្តទុកដាក់ថែទាំកូនរបស់ខ្លួន ចាយវាយប្រាក់កាក់ដោយមិនបានប្រាប់ស្វាមីរបស់ខ្លួននិងមិន

---

៨៥ ដូចចែងនៅក្នុងអង្កេតប្រជាសាស្ត្រ និងសុខភាព ឆ្នាំ២០០០ ទំព័រទី២៣៥ បានបង្ហាញអោយឃើញថា ស្ត្រីកម្ពុជាម្នាក់ក្នុងចំណោមដប់នាក់រស់នៅជាមួយស្វាមី ដែលប្រើចំណងអាពាហ៍ពិពាហ៍ ដើម្បីត្រួតត្រានាង។

៨៦ សូមកត់ចំណាំថា ចំលើយនេះ រួមទាំងអ្នកផ្តល់ចំលើយដែលបាននិយាយថាបុរសគឺ "មានហេតុផលខ្លះ" ចំពោះការខឹងរបស់ពួកគេ។ ចំលើយនេះមិនបានបញ្ចូលភាគរយនៃអ្នកផ្តល់ចំលើយ ដែលបាននិយាយថា មិនបានដឹង ហើយចំលើយនេះ អាចបញ្ជាក់អំពីការយល់ព្រម។

យកចិត្តទុកដាក់ការងារផ្ទះសម្បែង ដូចបង្ហាញក្នុងតារាងខាងក្រោម។ ស្ត្រី និងអ្នកដែលមានប្រាក់ចំណូលទាបបំផុត បានបង្ហាញអោយឃើញនូវការទទួលយកការខឹងរបស់បុរសច្រើនជាងគេ នៅក្នុងស្ថានភាពទាំងនេះ។

ក្នុងស្ថានភាពជាក់ស្តែង ការដឹងឮរបស់អ្នកផ្តល់ចំលើយអំពីស្វាមីដែលមានឥរិយាបថខឹងនៅក្នុងស្ថានការណ៍ទាំងនេះ ឆ្លុះបញ្ចាំងអោយឃើញនូវការទទួលយកជាទូទៅចំពោះឥរិយាបថនេះ។ ពីរភាគបីនៃអ្នកផ្តល់ចំលើយ ឬច្រើនជាងនេះបាននិយាយថាគេដឹងករណីដែលស្វាមីខឹងក្នុងស្ថានភាពមួយក្នុងចំណោមស្ថានភាពដូចតទៅនេះ: ភរិយាមិនយកចិត្តទុកដាក់ថែទាំកូនរបស់ខ្លួន ចាយវាយប្រាក់កាក់ដោយមិនប្រាប់ស្វាមី ឬជជែកលេងជាមួយប្រុសផ្សេង[៨៧]។ ភាគច្រើននៃអ្នកផ្តល់ចំលើយដែលបានរាយកាណ៍ថាបានដឹងករណីនេះ បាននិយាយថាករណីនេះកើតឡើងតែមួយរយៈ ឬកើតឡើងដោយកំរ។ ហេតុផលចម្បងជាទូទៅដែលប្តីខឹងប្រពន្ធ គឺនៅពេលដែលប្រពន្ធរបស់គាត់មិនបានយកចិត្តទុកដាក់ថែទាំកូន - ៧៩ភាគរយនៃអ្នកផ្តល់ចំលើយ បាននិយាយថាបានដឹងអំពីករណីដូចនេះ។ ភាគច្រើនគឺស្ត្រី និងអ្នកក្រីក្រដែលបានរាយការណ៍អំពីករណីនៃការខឹងរបស់បុរស។

លទ្ធផល គឺប្រហាក់ប្រហែលគ្នា គឺនៅពេលបុរសត្រូវបានសួរថាតើខ្លួនគាត់ផ្ទាល់ធ្លាប់ខឹងប្រពន្ធដែរឬទេ[៨៨]។ សរុប ៧៤% បាននិយាយថា គេខឹងនៅពេលដែលប្រពន្ធមិនយកចិត្តទុកដាក់ថែរក្សាកូន ហើយ៤៧%បាននិយាយថាពួកគាត់ខឹងព្រោះដោយសារសំលៀកបំពាក់មួយចំនួនដែលប្រពន្ធគាត់ស្លៀក។ ៤១% នៃបុរសនិយាយថាពួកគាត់ ខឹងនៅពេលដែលប្រពន្ធរបស់គាត់ចាយលុយដោយពុំបានប្រាប់គាត់។ បុរសភាគច្រើនបាននិយាយថា ពួកគាត់ខឹងម្តងម្កាល ឬដោយកម្រ។ បុរសដែលមានប្រាក់ចំណូលទាបហាក់ដូចជាខឹងភរិយាច្រើនជាងអ្នកដែលមានប្រាក់ចំណូលខ្ពស់ជាង ចំពោះហេតុផលដូចបានលើកឡើងខាងលើ។

---

៨៧ ទិន្នន័យទាំងនេះ គឺហាក់ដូចជាមិនសូវសុក្រឹត ព្រោះថាអ្នកផ្តល់ចំលើយមួយចំនួន បានឆ្លើយថាពួកគេមិន ដឹងទេ។ ជាញឹកញាប់ចំលើយនេះបង្ហាញនូវការព្រមព្រៀងគ្នា មិនមែនបង្ហាញនូវចំលើយអវិជ្ជមាននោះទេ។

៨៨ សំរាប់ភាគរយនៃអ្នកផ្តល់ចំលើយ ដែលបានឆ្លើយ "ទេ មិនដែលទាល់តែសោះ" ក្នុងសំណួរៈ តើខ្លួនអ្នកផ្ទាល់ ដែលធ្លាប់មិនសប្បាយចិត្ត ឬខឹងខ្លាំងជាមួយប្រពន្ធរបស់អ្នកនៅកាលៈទេសៈខាងក្រោមនេះណាខ្លះដែរឬទេ?




**តារាងទី ១៩**

**សំណួរទី ២១ a**

*ភាគរយនៃអ្នកផ្តល់ចំលើយ ដែលបានឆ្លើយថា "**មិនសមហេតុផលទាល់តែសោះ**" នៅក្នុងសំណួរៈ តើការខឹងរបស់ស្វាមីក្នុងស្ថានភាពខាងក្រោមនេះ សមហេតុសមផលដែរឬទេ?*

*(N=3030)*

នៅពេលដែលការអង្កេតសួរស្ត្រីថា តើស្វាមីរបស់នាងធ្លាប់ខឹងដែរឬទេ នោះចំនួនអ្នកដែលរាយការណ៍អំពីការខឹងរបស់បុរសមានការផ្លាស់ប្តូរ[៨៩] ។ ក្នុងករណីខ្លះ ការផ្លាស់ប្តូរនេះប្រហែលមកពីស្ត្រីដែលជាអ្នកផ្តល់ចំលើយពុំបានរាយការណ៍អោយអស់ ពីព្រោះថាជាទូទៅចំលើយអំពីអ្នកដទៃមានភាពសុក្រឹតជាង ។ ឬមួយក៏ចំលើយនេះ អាចបង្ហាញអំពីភាពធម្មតាសំរាប់ការខឹងនេះ ។ គួរឱ្យកត់សំគាល់ផងដែរថាចំនួនស្ត្រីដែលបានរាយការណ៍អំពីការខឹងរបស់ប្តី គឺតិចជាងបុរសខ្លួនឯងដែលបានឆ្លើយអំពីការខឹងរបស់ខ្លួន (ដូចមានលំអិតខាងក្រោមនេះ)[៩០] ។

---

[៨៩] ភាគរយនៃអ្នកផ្តល់ចំលើយ ដែលបានឆ្លើយ "ទេ មិនដែលទាល់តែសោះ" ក្នុងសំណួរៈ តើប្តីរបស់អ្នកដែលធ្លាប់មិនសប្បាយចិត្ត ឬខឹងខ្លាំងជាមួយអ្នកនៅកាលៈទេសៈខាងក្រោមនេះណាខ្លះដែរឬទេ?

[៩០] អ្នកផ្តល់ចំលើយទាំងពីរក្រុមនេះ – បុរសនិយាយថា ពួកគេខឹងនឹងប្រពន្ធរបស់ពួកគេ ហើយស្ត្រីបាននិយាយថា ប្តីរបស់ពួកគេខឹងនឹងពួកគេ – គឺពុំមែនតំណាងរបស់អ្នកផ្តល់ចំលើយទាំងអស់នោះទេ ។

- ទោះបីជាបុរស ៧៤%បាននិយាយថា គេខឹង ពីព្រោះភរិយារបស់ពួកគាត់មិនសូវមើលថែរក្សាកូនឱ្យបានល្អ ប៉ុន្តែភាគរយនៃស្ត្រី ដែលបានរាយការណ៍ថា ស្វាមីរបស់នាងខឹងនាង ដោយសារហេតុផលនេះ គឺមានចំនួនទាបជាងបុរស គឺមានតែ៦១% ប៉ុណ្ណោះ។
- ស្រដៀងគ្នានេះផងដែរបុរស៤៦%បាននិយាយថាពួកគាត់ខឹងនៅពេលដែលប្រពន្ធចំណាយពេលវេលានៅក្រៅផ្ទះ បើប្រៀបធៀបនឹងស្ត្រី គឺ៤១% បាននិយាយថាស្វាមីរបស់នាងខឹងដោយសារហេតុផលនេះ។
- បុរស ៦១% បាននិយាយថា ពួកគាត់ខឹងភរិយា ពីព្រោះភរិយាចាយប្រាក់កាក់ដោយមិនបានប្រាប់ពួកគាត់ ផ្ទុយទៅវិញស្ត្រី ៥១%បាននិយាយថាប្ដីរបស់ពួកគាត់ ខឹងដោយសារហេតុផលនេះ។
- បុរស ៥៣%បានរាយកាណ៍ថា ពួកគាត់ខឹងភរិយា ពីព្រោះភរិយារបស់ពួកគាត់មិនថែទាំផ្ទះសម្បែងឱ្យបានស្អាត ក៏ប៉ុន្តែស្ត្រី៥៣%បានរាយការណ៍ថា ស្វាមីរបស់គាត់ខឹងដោយសារហេតុផលនេះ។
- ស្ត្រីក្រៃក្រ បាននិយាយថា ស្វាមីរបស់ពួកគាត់ខឹងគាត់ញឹកញាប់ជាងនេះ។

### ២.២.២ ឥរិយាបថត្រួតត្រា

អ្នកផ្តល់ចំលើយ បានឆ្លើយអំពីកំរិតនៃការទទួលយកសកម្មភាពរបស់បុរស ក្នុងការត្រួតត្រាភរិយាពីកំរិតអាចទទួលយកបាន ទៅដល់កំរិតមិនអាចទទួលយកបាន។ អ្នកផ្តល់ចំលើយបានដាក់កំរិតលើប្រភេទផ្សេងៗគ្នាអំពីឥរិយាបថត្រួតត្រាចាប់ពីកំរិតពី១ ទៅ៥ ដែលកំរិត១ តំណាងឱ្យឥរិយាបថ "សមហេតុផលណាស់" ហើយកំរិត៥ គឺ "មិនសមហេតុផលទាល់តែសោះ"។ ការអង្កេតនេះក៏បានបង្ហាញអោយឃើញនូវការគាំទ្រចំពោះបុរសក្នុងការចាត់វិធានការផ្សេងៗ ដើម្បីត្រួតត្រាភរិយារបស់ពួកគាត់ ឬក៏អាចនិយាយម្យ៉ាងទៀតបានថា ដើម្បីពង្រឹងការអនុវត្តន៍តួនាទីយេនឌ័រដូចបង្ហាញក្នុងតារាងខាងក្រោម។ ស្ត្រីហាក់ដូចជាច្រើនជាងបុរសដែលបាននិយាយថា គឺសមហេតុផលហើយ ដែលបុរសហាមឃាត់ភរិយាក្នុងការស្លៀកសំលៀកបំពាក់មួយចំនួន ឬក៏សួរប្រពន្ធគ្រប់ពេលវេលាអំពីទីកន្លែងដែលនាងនឹងទៅ។ ផ្ទុយទៅវិញការហាមឃាត់ស្ត្រីមិនឱ្យទៅជួបក្រុមគ្រួសារត្រូវបានគេយល់ឃើញថា អាចទទួលយកបានតិចតួចបំផុត ជាពិសេសការយល់ឃើញរបស់ស្ត្រី។ ស្ទើរគ្រប់ករណីទាំងអស់អ្នកដែលមានប្រាក់ចំណូលទាប ហាក់ដូចជាយល់ឃើញថា ឥរិយាបថត្រួតត្រាគឺសមហេតុសមផលដូចចំលើយដែលបង្ហាញនៅក្នុងតារាងទី២០ ខាងក្រោមនេះ។

ការអង្កេតក៏បានសួរផងដែរថា តើភរិយាគួរចាត់វិធានការបែបណា នៅពេលដែលស្វាមីប្រព្រឹត្ត បែបនេះ ។ ចំលើយភាគច្រើនបំផុត គឺនាងអាច "ពន្យល់អំពី (ស្ថានភាព) ដោយមានហេតុផល ទៅស្វាមីរបស់នាង"[៩១] - អ្នកផ្តល់ចំលើយជាងពាក់កណ្តាលបានឆ្លើយដូច្នេះ ។ ស្ត្រី ១៥%ហាក់ដូចជាច្រើនជាងបុរសដែលមានតែ ១០% និយាយថា ស្ត្រីគួរតែគោរព និងស្តាប់បង្គាប់ស្វាមីរបស់នាង ។ ប៉ុន្តែនៅក្នុងវិធានការផ្សេងៗទៀត បុរសមានចំនួន១៧% គឺច្រើនជាងស្ត្រីដែលមានតែ៧%បានស្នើសុំឱ្យស្ត្រីប្រាប់បញ្ហានេះទៅអ្នកដទៃទៀត ដូចជាឪពុកម្តាយ បងប្អូន ឬក៏មិត្តភ័ក្តិ ។

អាកប្បកិរិយាទាំងនេះ ត្រូវបានឆ្លុះបញ្ចាំងនៅក្នុងបទពិសោធន៍ផ្ទាល់របស់អ្នកផ្តល់ចំលើយ ។ នៅពេលសួរអំពីអាកប្បកិរិយារបស់អ្នកដទៃទៀត អ្នកផ្តល់ចំលើយជាច្រើនបាននិយាយថា ពួកគេបានស្គាល់ស្វាមីដែលប្រព្រឹត្តក្នុងន័យគ្រួតត្រាចំពោះភរិយា ដែលមានបង្ហាញដូចខាងក្រោមនេះ[៩២] ។




**តារាងទី ២០**

**សំណួរទី ២១ b**

*ភាគរយនៃអ្នកផ្តល់ចំលើយ ដែលបានឆ្លើយថា "មិនសមហេតុផលទាល់តែសោះ" ចំពោះសំណួរ: តើសមហេតុផលដែរឬទេ ដែលស្វាមីប្រព្រឹត្ត ដូចខាងក្រោម?*

*(N=3030)*

[៩១] សូមមើលតារាងទី ៤៨ ក្នុងឧបសម្ព័ន្ធ A

[៩២] ភាគរយនៃអ្នកផ្តល់ចំលើយ ដែលបានឆ្លើយ "ទេ មិនដែលទាល់តែសោះ" ក្នុងសំណួរ: តើខ្លួនអ្នកផ្ទាល់ដឹង / ជួបប្រទះនឹងករណីដែលប្តីបានប្រព្រឹត្តដូចខាងក្រោមទៅកាន់ប្រពន្ធដែរឬទេ?

- ហាសិបប្រាំពីភាគរយនៃតំណាងបាននិយាយថាគេស្គាល់ស្វាមីដែលមិនអនុញ្ញាតឱ្យប្រពន្ធស្លៀកសំលៀកបំពាក់មួយចំនួន។
- ហាសិបប្រាំមួយភាគរយនៃតំណាងបាននិយាយថា គេស្គាល់ស្វាមីដែលបានចោទប្រកាន់ភរិយាថាមិនស្មោះត្រង់។
- សែសិបប្រាំបួនភាគរយនៃតំណាងបាននិយាយថា គេបានស្គាល់ស្វាមីដែលតែងតែចង់ដឹងថាតើប្រពន្ធរបស់ខ្លួននៅទីណាគ្រប់ពេលវេលា។
- តិចជាងពាក់កណ្តាលនៃអ្នកផ្តល់ចំលើយបាននិយាយថា គេមិនបានស្គាល់ស្វាមីដែលនឹងមិនឱ្យប្រាក់ប្រពន្ធនោះទេ។
- ប៉ុន្តែ បើសិនជាគិតអំពីភាពញឹកញាប់ មនុស្សភាគច្រើនបានរាយការណ៍ថា ការប្រព្រឹត្តបែបនេះកើតមានម្តងម្កាល ឬកំរកើតមាន។
- ស្ត្រី និងអ្នកក្រីក្រហាក់ដូចជាបានដឹងអំពីករណីទាំងនេះច្រើនជាង។

នៅពេលដែលសួរស្ត្រី ថាតើនាងឆ្លើយតបទៅនឹងអាកប្បកិរិយានេះយ៉ាងដូចម្តេច ចំលើយគឺផ្ទុយគ្នាពីចំលើយអំពីស្ថានភាពដែលមើលមិនឃើញ ដែលបានកត់សំគាល់ដូចខាងក្រោមនេះ[៩៣]។

- សែសិបពីរភាគរយ នៃបុរសបាននិយាយថាភរិយាបានពន្យល់អំពីហេតុផលទៅស្វាមីរបស់នាងបើប្រៀបធៀបជាមួយនឹង៥៧% នៃបុរសដែលបាននិយាយថាតាមទ្រឹស្តីភរិយាត្រូវតែធ្វើដូចនេះ។
- ដូចគ្នានេះដែរ ៤៩%នៃស្ត្រីបាននិយាយថា ភរិយាត្រូវតែធ្វើតាមជំរើសនេះ បើប្រៀបធៀបទៅ នឹង ៦៣% នៃស្ត្រី ដែលបាននិយាយថាជាទ្រឹស្តីភរិយាគួរតែធ្វើដូចនេះ។
- ផ្ទុយទៅវិញសមាមាត្រអ្នកដែលបាននិយាយថា ភរិយាគួរតែឆ្លើយតបដោយ "ការគោរព និង ស្តាប់បង្គាប់" ទៅស្វាមីមានការកើនឡើង។ បុរសដប់ភាគរយ បាននិយាយថាតាមទ្រឹស្តី ប្រពន្ធគួរតែធ្វើដូចនេះ ប៉ុន្តែ ១៣% បាននិយាយថាភរិយាដែលគាត់បានស្គាល់ ហើយភរិយានោះគឺជាអ្នកដែលទទួលរងនូវការរំលោភបំពានផ្លូវចិត្ត បានជ្រើសរើសយកការឆ្លើយតបរបៀបនេះ។ ១៥%នៃស្ត្រីបាននិយាយថាជាទ្រឹស្តីប្រពន្ធគួរធ្វើដូចនេះ ហើយ ១៦% បាននិយាយថាភរិយាដែលពួកគាត់បានស្គាល់ និងជាអ្នកដែលទទួលនូវការរំលោភបំពានបានជ្រើសរើសយកការឆ្លើយតបរបៀបនេះ។

នៅពេលសួរអំពីអាកប្បកិរិយាផ្ទាល់ខ្លួនរបស់គេ បុរសភាគច្រើនបាននិយាយថា គេខ្លួនឯងមិនមានឥរិយាបថត្រួតត្រាភរិយានោះទេ[៩៤]។ មួយភាគបីបាននិយាយថាគេបានហាមប្រពន្ធមិនឱ្យស្លៀកសំលៀកបំពាក់មួយចំនួន ហើយមួយភាគបួនបាននិយាយថា ពួកគេបានទទូចចង់ដឹងថា ប្រពន្ធរបស់ខ្លួននៅទីណាគ្រប់ពេលវេលា។ បុរសដែលមានប្រាក់ចំណូលខ្ពស់ជាង ហាក់ដូចជាពុំសូវប្រព្រឹត្តដូចនេះដើម្បីត្រួតត្រាភរិយារបស់ពួកគាត់នោះទេ។

---

៩៣ ក្រុមអ្នកផ្តល់ចំលើយដែលបានឆ្លើយថាបានស្គាល់ស្ត្រីដែលទទួលរងនូវការរំលោភបំពានផ្លូវចិត្ត គឺពុំមែនជាតំណាងរបស់អ្នកផ្តល់ចំលើយទាំងអស់ នោះទេ។

៩៤ ភាគរយនៃអ្នកផ្តល់ចំលើយ ដែលបានឆ្លើយ "ទេ មិនដែលទាល់តែសោះ" ក្នុងសំណួរ : តើអ្នកធ្លាប់ធ្វើអ្វីខ្លះខាងក្រោមនេះដែរឬទេ?

បុរសជិតពាក់កណ្ដាលបាននិយាយថា ការជជែកគ្នាដោយស្ងៀមស្ងាត់ អាចបញ្ឈប់ពួកគេកុំអោយប្រព្រឹត្តអំពើហិង្សា[៩៥] ។១៦%ទៀតបាននិយាយថា ការដែលភរិយារបស់ពួកគាត់ស្ដាប់បង្គាប់និងគោរពតាម អាចមានឥទ្ធិពលមិនអោយមានការប្រព្រឹត្តិអំពើហិង្សា ។ អ្នកផ្ដល់ចំលើយមួយចំនួនតូចបាននិយាយថា ការគិតថាការប្រព្រឹត្តិអំពើហិង្សា គឺបណ្ដាលឱ្យមានគ្រោះថ្នាក់ ឬការអត់ធ្មត់ អាចបញ្ឈប់ពួកគេកុំឱ្យប្រព្រឹត្តដូចនេះ ។

នៅពេលដែលស្ត្រីត្រូវបានសួរ ថាតើស្វាមីរបស់នាងប្រព្រឹត្តអំពើហិង្សានាងដែរឬទេ ចំលើយ គឺខុសគ្នា[៩៦] ។ ក្នុងករណីខ្លះ អ្នកផ្ដល់ចំលើយជាស្ត្រី បានរាយកាណ៍អំពីការប្រព្រឹត្តិអំពើហិង្សាច្រើនជាងបុរសដែលជាអ្នកផ្ដល់ចំលើយ ។ ទោះបីជា១៩%នៃបុរសបាននិយាយថា គេបានបដិសេធមិនឱ្យលុយភរិយា ប៉ុន្តែស្ត្រី១៧%ប៉ុណ្ណោះ បាននិយាយថាស្វាមីរបស់នាងបានធ្វើដូចនេះ ។ បុរស១៧% ច្រើនជាងស្ត្រី(១៦%) និយាយថាប្ដី មិនអនុញ្ញាតឱ្យភរិយាចេញពីផ្ទះ ។

ក្នុងករណីផ្សេងទៀត អ្នកផ្ដល់ចំលើយជាស្ត្រី បានរាយការណ៍អំពីការប្រព្រឹត្តិអំពើហិង្សាច្រើនជាងអ្នកផ្ដល់ចំលើយជាបុរស ដូចមានបង្ហាញខាងក្រោមនេះ:

- ស្ត្រី៣៨% ច្រើនជាងបុរស៣៣% និយាយថាស្វាមីរបស់នាងបានហាមនាងមិនឱ្យស្លៀកសំលៀកបំពាក់មួយចំនួន ។
- ស្ត្រី៣៤% ច្រើនជាងបុរសដែលមានតែ២៥% បាននិយាយថាស្វាមីបានទទូចចង់ដឹងថា នាងនៅទីណាគ្រប់ពេលវេលា ។
- ដូចគ្នានេះដែរ ស្ត្រី ២៨% ច្រើនជាងបុរស ១៧% និយាយថាស្វាមីបានចោទប្រកាន់នាងថាមិនស្មោះត្រង់ ។
- ស្ត្រីក្រីក្រ បានរាយការណ៍ថាមានការប្រព្រឹត្តិអំពើហិង្សាច្រើនជាងអ្នកដែលមានប្រាក់ចំណូលខ្ពស់ ។
- ស្ត្រីនៅទីក្រុង បានរាយការណ៍ថាមានការប្រព្រឹត្តិអំពើហិង្សាតិចជាង ។

ស្ត្រីច្រើនជាងបុរស បាននិយាយថាការពន្យល់អំពីហេតុផលអាចបញ្ឈប់ស្វាមីមិនឱ្យប្រព្រឹត្តិអំពើហិង្សានេះ[៩៧] ។ សរុប ៦៩% នៃស្ត្រីបានឱ្យចំលើយនេះ បើប្រៀបធៀបជាមួយនឹងបុរសមានតែ ៤៦% ។ ស្ត្រីហាក់ដូចជាច្រើនជាងបុរសដែលបាននិយាយថាការគោរព និងស្ដាប់បង្គាប់ស្វាមីអាចបញ្ឈប់អំពើហិង្សានេះបាន ។

---

៩៥ សូមមើលតារាងទី ៥២ ក្នុងឧបសម្ព័ន្ធ A

៩៦ ភាគរយនៃអ្នកផ្ដល់ចំលើយដែលបានឆ្លើយ "ទេ មិនដែលទាល់តែសោះ" ក្នុងសំណួរៈ តើប្ដីរបស់អ្នកធ្លាប់ធ្វើអ្វីខ្លះខាងក្រោមនេះដែរឬទេ?

៩៧ សូមមើលតារាងទី ៥៥ ក្នុងឧបសម្ព័ន្ធ A

### សេចក្ដីសន្និដ្ឋាន

តាមការអង្កេតបានរកឃើញថា ប្ដីខឹងប្រពន្ធនៅពេលដែលប្រពន្ធពុំបានធ្វើកិច្ចការផ្ទះ និងដើម្បីគ្រប់គ្រងទៅលើសកម្មភាពរបស់ប្រពន្ធ។ ទោះបីយ៉ាងណាក្ដី ការអង្កេតនេះក៏បានរកឃើញនូវភាពខុសគ្នាមួយចំនួននៅក្នុងចំណោមក្រុមខ្លះនៃក្រុមអ្នកផ្ដល់ចំលើយៈ ស្ដ្រី និងប្រជាពលរដ្ឋក្រីក្របានបង្ហាញនូវការទទួលយកការខឹងរបស់បុរស និងអាកប្បកិរិយាត្រួតត្រារបស់ប្ដី។ ការអង្កេតនេះបានរកឃើញថាមានការឯកភាពគ្នាខ្លាំងចំពោះដំណោះស្រាយ។ បុរសភាគច្រើនបាននិយាយថា ការជជែកគ្នាដោយស្ងៀមស្ងាត់អាចបញ្ឈប់តំរិយាបថនេះបាន ហើយស្ដ្រីភាគច្រើនបាននិយាយថាការពន្យល់អំពីហេតុផលអាចមានប្រសិទ្ធភាពនៅក្នុងការបញ្ឈប់តំរិយាបថនេះបាន។

### អនុសាសន៍សំរាប់ការរំលោភបំពានផ្លូវកាយ និងផ្លូវចិត្ត[៩៨]

#### ការបណ្ដុះបណ្ដាល និងការអប់រំ

- បណ្ដុះបណ្ដាលមន្ដ្រីឃុំ-សង្កាត់ និងប៉ូលីសអំពីបញ្ហាអំពើហិង្សាក្នុងគ្រួសារ។ ការបណ្ដុះបណ្ដាលត្រូវបញ្ចូលនូវបញ្ហាមួយចំនួនដូចជា ការដោះស្រាយជំលោះ ការផ្ដោតការយកចិត្តទុកដាក់ទៅលើដំណោះស្រាយដែលមានប្រសិទ្ធភាព (ការជជែកគ្នាដោយស្ងៀមស្ងាត់ និងការពន្យល់អំពីហេតុផល) ការប្រឈមមុខជាមួយនឹងទស្សនៈអំពីអំណាចនិងការត្រួតត្រាការពិនិត្យឡើងវិញលើរូបភាពនៃការសម្រុះសម្រួលគ្នា ការលើកទឹកចិត្តដល់រូបភាពជាគំរូវិជ្ជមាន និងព័ត៌មានស្ដីពីការបញ្ជូនទៅកាន់សេវានានា។
- បណ្ដុះបណ្ដាលអាជ្ញាធរមូលដ្ឋានអំពីកាតព្វកិច្ចរបស់ពួកគេ ដែលមានចែងនៅក្នុងច្បាប់ស្ដីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ។
- បណ្ដុះបណ្ដាលនិយោជក បណ្ដាញក្រៅប្រព័ន្ធ និងសាធារណៈជន អំពីយេនឌ័រ និងស្វែងយល់អំពីសញ្ញានៃការរំលោភបំពានផ្លូវកាយ និងផ្លូវចិត្ត ហើយបញ្ជូនអ្នកដែលទទួលរងគ្រោះដោយសារការរំលោភបំពានទាំងនោះ ទៅកាន់ទីកន្លែងជួយសង្គ្រោះ។

#### ការផ្សព្វផ្សាយការយល់ដឹងជាសាធារណៈ និងការលើកកំពស់តំលៃសង្គម និងគ្រួសារៈ

- ផ្សព្វផ្សាយឱ្យមានការយល់ដឹងថា អំពើហិង្សា គឺពុំអាចទទួលយកបានទេ តាមរយៈ
  - ការផ្សព្វផ្សាយអំពីកិច្ចខិតខំប្រឹងប្រែងដើម្បីទទួលជោគជ័យក្នុងការអនុវត្តន៍ច្បាប់ ដើម្បីបង្ហាញថាអំពើហិង្សា ពុំត្រូវបានអនុគ្រោះឡើយ។

---

[៩៨] ដើម្បីផ្ដល់នូវរូបភាពគ្រប់ជ្រុងជ្រោយនៃដំណោះស្រាយ ដែលបានស្នើឡើង រាល់អនុសាសន៍ទាំងអស់ដែលទាក់ទងនឹងផ្នែកនីមួយៗនៃរបាយការណ៍នឹងត្រូវបានដាក់បញ្ចូល។ បញ្ហាទាំងអស់នៅក្នុងការសិក្សា គឺមានការទាក់ទងគ្នា ទៅវិញទៅមក ដូច្នេះអនុសាសន៍ដូចគ្នាមួយចំនួនបានសរសេរនៅក្នុងផ្នែកខ្លះ នៃរបាយការណ៍នេះ។

- ការសង្កត់ធ្ងន់ទៅលើតំលៃគ្រួសារកម្ពុជា ។
- ការសង្កត់ធ្ងន់ទៅលើផលប៉ះពាល់នៃការរំលោភបំពានផ្លូវកាយ និងផ្លូវចិត្តលើកុមារ និងទៅលើស្ថានភាពសេដ្ឋកិច្ចគ្រួសារ ។

■ លើកកំពស់ជំនាញផ្នែកប្រាស្រ័យទាក់ទង និងជំនាញដោះស្រាយជំលោះក្នុងគ្រួសារ ។ បង្កើនការដោះស្រាយជំលោះក្នុងគ្រួសារដែលមានប្រសិទ្ធិភាព ការជជែកគ្នាដោយស្ងៀមស្ងាត់ និងការពន្យល់អំពីហេតុផល តាមរយៈយុទ្ធនាការបង្កើនការយល់ដឹងជាសាធារណៈ ។

■ លើកកំពស់រូបភាពគំរូវិជ្ជមានរបស់បុរស ដោយប្រើប្រាស់តំលៃរបស់បុរស និងក្រុមគ្រួសាររប សំពួកគេនាពេលបច្ចុប្បន្ននេះ ។ កំណត់ឡើងវិញនូវតួនាទីរបស់បុរសដែលជាមេគ្រួសារដោយសង្កត់ធ្ងន់ទៅលើការទទួលខុសត្រូវរបស់បុរសនៅក្នុងគ្រួសារ ពោលគឺពុំមែនជាអំណាចរបស់បុរសនៅក្នុងគ្រួសារនោះទេ ។

■ លើកកំពស់តួនាទីជាឪពុកម្តាយ ដែលមិនប្រើអំពើហិង្សា ពីព្រោះកូនដែលទទួលរងគ្រោះដោយសារអំពើហិង្សាពីសំណាក់ឪពុកម្តាយ ច្រើនតែអនុវត្តតាមគំរូនៃអំពើហិង្សាទាំងនោះវិញដែរ ។

■ បង្កើនការយល់ដឹងជាសាធារណ ឱ្យយល់ដឹងថាការរំលោភបំពានផ្លូវចិត្ត និងអារម្មណ៍គឺជាទង្វើខុសឆ្គង ទោះបីវាពុំប៉ះពាល់ផ្លូវកាយក៏ដោយចុះ ។

■ លើកកំពស់ការទទួលខុសត្រូវក្នុងការប្រើប្រាស់ជាតិស្រវឹង ។ ដោះស្រាយទស្សនៈដែលថាជាតិស្រវឹង គឺជាបុព្វហេតុនៃអំពើហិង្សាក្នុងគ្រួសារ ដែលនាំឱ្យមានការដោះលែងអ្នកប្រព្រឹត្ត ពីការទទួលខុសត្រូវ ។

■ បង្កើនការយល់ដឹងអំពីសិទ្ធិរបស់ជនរងគ្រោះ ក្នុងការទទួលបានការការពារ ដូចដែលមានចែងនៅក្នុងច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ព្រមទាំងទីកន្លែងដែលអាចស្វែងរកជំនួយសង្គ្រោះ ។

■ បង្កើនការយល់ដឹងអំពីច្បាប់ស្តីពីគ្រួសារ ដែលចែងអំពីអាពាហ៍ពិពាហ៍ និងការលែងលះគ្នា ។

■ ផ្តល់ការប្រកួតប្រជែងក្នុងចំណោមក្រុមប្រឹក្សាឃុំ-សង្កាត់ ដើម្បីលើកកំពស់ និងអនុវត្តការរកដំណោះស្រាយប្រកបដោយការច្នៃប្រឌិតខ្ពស់ ចំពោះអំពើហិង្សាក្នុងគ្រួសារ ។

■ ត្រូវមានការសំរបសំរួលក្នុងចំណោមយុទ្ធនាការទាំងនេះដើម្បីផ្សព្វផ្សាយសារជាប្រចាំជាពិសេសនៅថ្នាក់មូលដ្ឋាន ។ ការពិនិត្យ និងការវាយតំលៃមានសារៈសំខាន់ណាស់ ក្នុងការពិនិត្យមើលឡើងវិញនូវភាពជោគជ័យនៃយុទ្ធនាការទាំងនោះ ។

■ យុទ្ធនាការយល់ដឹងជាសាធារណៈ ត្រូវផ្តោតគោលដៅទៅរកយុវជន យុវនារីវ័យក្មេង និងឪពុកម្តាយ ។

■ យុទ្ធនាការបង្កើនការដឹងជាសាធារណៈនេះ គួរតែប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយដែលពេញនិយមរួមមានវីដេអូ ល្ខោនភាគ ចំរៀងដែលច្រៀងដោយអ្នកចំរៀងល្បីៗ លេងល្ខោនតាមភូមិ និងខារ៉ាអូខេ ។

**ការរៀបចំគោលនយោបាយ និងសកម្មភាព:**

- ដាក់បញ្ចូលយុទ្ធសាស្ត្រនានា ដើម្បីបញ្ឈប់អំពើហិង្សាក្នុងគ្រួសារ ទៅក្នុងគោលនយោបាយ និងកម្មវិធីនានា ដែលមានគោលបំណងកាត់បន្ថយភាពក្រីក្រ ដូចជាផែនការអភិវឌ្ឍន៍យុទ្ធសាស្ត្រជាតិ វិមជ្ឈការ និងវិសហមជ្ឈការ គំនិតផ្តួចផ្តើមកម្មវិធីរបស់អ្នកផ្តល់ជំនួយ និងកម្មវិធីនានា ដែលរៀបចំឡើងដោយអង្គការក្រៅរដ្ឋាភិបាល ។
- បញ្ជ្រាបចំណេះដឹងអំពីអំពើហិង្សាយេនឌ័រ ទៅក្នុងកម្មវិធីទប់ស្កាត់មេរោគអេដស៍ ដោយរួមទាំងឯកសារសំភារៈស្តីពីការស្ម័គ្រចិត្ត និងការបង្ខិតបង្ខំ ។
- បញ្ជ្រាបបញ្ហាអំពើហិង្សាក្នុងគ្រួសារ ទៅក្នុងអង្កេតថ្នាក់ជាតិ ដែលធ្វើឡើងដោយស្ថាប័នរដ្ឋាភិបាល ។
- បង្កើតការិយាល័យទទួលបន្ទុកស្ថិតិជាតិស្តីពីអំពើហិង្សាប្រឆាំងនឹងស្ត្រី ។
- បង្កើតបទដ្ឋានគោលសំរាប់សេវាសង្គមកិច្ច សំរាប់ទីភ្នាក់ងារ និងអ្នកប្រកបវិជ្ជាជីវៈនានា ។
- អ្នកផ្តល់ជំនួយ គួរតែប្រើប្រាស់បទដ្ឋានគោលទាំងនេះ នៅក្នុងការរៀបចំបង្កើតកម្មវិធី និងការវិភាជថវិកា ជាពិសេសទាក់ទងទៅនឹងការផ្តល់ទីជំរក ។
- ពង្រីកការអប់រំផ្នែកសង្គមកិច្ច ដោយការវិភាជថវិកាបន្ថែមទៀត ។
- កម្មវិធីនានាដែលធ្វើការជាមួយជនរងគ្រោះ និងជនមុខសញ្ញា ត្រូវពិនិត្យឡើងវិញលើគំរូនៃការសម្រុះសម្រួលគ្នា ។
- នាំយកមធ្យោបាយដោះស្រាយបញ្ហាតាមផ្លូវតុលាការ (ឧ-ដីកាការពារ និងការលែងលះគ្នា) ឱ្យទៅដល់ជិតប្រជាពលរដ្ឋកម្ពុជាគ្រប់រូបនៅតាមភូមិសាស្ត្រនានា ។
- ដាក់បញ្ចូលការបណ្តុះបណ្តាលស្តីពីការដោះស្រាយជំលោះ ដោយគ្មានប្រើអំពើហិង្សាទៅក្នុងកម្មវិធីសិក្សាតាមសាលារៀន ។
- ការតាមដានត្រួតពិនិត្យ និងការវាយតំលៃ: អ្នកផ្តល់ជំនួយ ត្រូវជំរុញឱ្យមានរបាយការណ៍ស្តីពីផលប៉ះពាល់នៃកម្មវិធីរបស់ខ្លួន ហើយផ្សព្វផ្សាយលទ្ធផលសំរេចបាន និងការអនុវត្តន៍ដែលល្អបំផុត ។

**ការសិក្សាស្រាវជ្រាវ:**

- សិក្សាស្រាវជ្រាវអំពីបញ្ហា ដែលកើតឡើងចំពោះបុរសនៅក្នុងសង្គម ដែលមានឋានន្តរក្រម និងអំពីបទពិសោធន៍របស់បុរសចំពោះអំពើហិង្សាជាទូទៅ និងឪពុកម្តាយ ដែលប្រើអំពើហិង្សា ។
- សិក្សាស្រាវជ្រាវបន្ថែមទៀតទៅលើភាពជាបុរស ភាពជាឪពុក និងគំរូវការសុខភាពផ្លូវចិត្តរបស់បុរស ។
- សិក្សាស្រាវជ្រាវបន្ថែមទៀត ចំពោះឥទ្ធិពលផ្សេងៗទៅលើឥរិយាបថ ដែលនាំឱ្យមានអំពើហិង្សា ដូចជាប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន និងរូបអាសអាភាស ។

**ការផ្តល់សេវា:**

- ផ្តល់កម្មវិធីនានា និងអ្នកសម្របសម្រួលប្រកបដោយសមត្ថភាព សំរាប់ការធ្វើការងារជាក្រុមជាមួយបុរស (ដោយសង្កត់ធ្ងន់ថា "អំពើហិង្សា មិនអាចទទួលយកបានទេ" ។)
- បណ្តុះបណ្តាលចំណេះដឹងអំពីយេនឌ័រ ដល់អ្នកផ្តល់សេវាថែទាំសុខភាព និងសេវាសង្គមកិច្ច និងអង្គការសិទ្ធិមនុស្ស និងអំពីការស្វែងយល់អំពីសញ្ញានៃការរំលោភបំពានផ្លូវកាយ និងផ្លូវចិត្ត ហើយបញ្ជូនជនរងគ្រោះដោយសារការរំលោភបំពានទាំងនោះទៅកាន់ទីកន្លែងជួយសង្គ្រោះ ។
- លើកកំពស់ការអប់រំផ្នែកសង្គមកិច្ច និងការអនុវត្តន៍ តាមរយៈការជំរុញឱ្យអ្នកពិគ្រោះបញ្ហា ដើម្បីផ្តល់អំណាចដល់អតិថិជន ស្តាប់អតិថិជន ផ្តល់ជំរើសដល់ពួកគេ ឬជៀសវាងការមើលងាយដល់ពួកគេ ។
- ធ្វើឱ្យប្រសើរឡើង និងសាងសង់ទីជំរក សំរាប់ជនរងគ្រោះដោយសារការរំលោភបំពាន ។ ទីជំរកទាំងនេះ ត្រូវផ្តល់ជាទីកន្លែងសុវត្ថិភាពរយៈពេលខ្លី ដោយពុំមានការដាក់កំរិត ចំពោះស្ត្រីដែលស្នាក់នៅទីនោះ និងត្រូវមានផែនការសុវត្ថិភាព ចំពោះស្ត្រីនៅក្នុងការវិលត្រលប់ទៅផ្ទះសំបែងរបស់ពួកគេវិញ ។
- បណ្តុះបណ្តាលអង្គការក្រៅរដ្ឋាភិបាលតាមមូលដ្ឋាន ដែលធ្វើការលើវិស័យផ្សេងៗទៀត (ឧ-វិស័យសុខភាព វិស័យច្បាប់) ស្តីពីអំពើហិង្សាក្នុងគ្រួសារ ដើម្បីធ្វើឱ្យប្រសើរឡើងនូវការផ្តល់សេវា នៅក្នុងវិស័យទាំងនោះ ។

## ២.៧ អំពើរំលោភសេពសន្ថវៈ និងអំពើរំលោភសេពសន្ថវៈក្នុងចំណងអាពាហ៍ពិពាហ៍

### ២.៧.១ អំពើរំលោភសេពសន្ថវៈ ជាទូទៅ

នៅក្នុងការអង្កេតនេះ អំពើរំលោភសេពសន្ថវៈត្រូវបានចាត់ទុកថាជាទង្វើខុសប្លែកពីទង្វើផ្សេងៗទៀតនៃអំពើហិង្សាក្នុងគ្រួសារ។ អ្នកផ្តល់ចំលើយបានចាត់ទុកអំពើរំលោភសេពសន្ថវៈថាជាបទឧក្រិដ្ឋមួយដែលត្រូវជាប់ពន្ធនាគារ ឬត្រូវផាកពិន័យ។ ទោះបីជាយ៉ាងណាក៏ដោយ ការអង្កេតនេះបានបង្ហាញឱ្យឃើញនូវករណីលើកលែងចំនួនពីរៈ គឺការរំលោភសេពសន្ថវៈក្នុងចំណងអាពាហ៍ពិពាហ៍ និងការរំលោភសេពសន្ថវៈពីសំណាក់មិត្តប្រុស ឬគូសង្សារ[៩៩]។ ការរំលោភសេពសន្ថវៈក្នុងចំណងអាពាហ៍ពិពាហ៍ នឹងត្រូវលើកមកពិភាក្សានៅក្នុងផ្នែកបន្ទាប់នៃជំពូកនេះ។ ការអង្កេតនេះ ក៏បានសាកសួរអំពីមធ្យោបាយដែលស្ត្រីបានស្វែងរកការជួយសង្គ្រោះចំពោះអំពើរំលោភសេពសន្ថវៈ និងបានតាមដានមើលលទ្ធផលនៃករណីទាំងនេះផងដែរ។

ក្រុមអ្នកផ្តល់ចំលើយទាំងអស់ បានចាត់ទុកអំពើរំលោភសេពសន្ថវៈ ថាជាបញ្ហាដ៏ធ្ងន់ធ្ងរ។ អ្នកផ្តល់ចំលើយចំនួន ៩៤% បានចាត់ទុកអំពើរំលោភសេពសន្ថវៈថា ជាបទឧក្រិដ្ឋ។ អ្នកផ្តល់ចំលើយមួយចំនួនតូចដែលជាបុរស បុរសចំនួន (១៨នាក់ ក្នុងចំណោមក្រុមមនុស្សដែលបានសាកសួរចំនួន ៣.០៣០ នាក់) បាននិយាយថាការរំលោភសេពសន្ថវៈ គឺពុំមែនជាបទឧក្រិដ្ឋនោះទេ ពីព្រោះ "ការរំលោភសេពសន្ថវៈនេះ ពុំមែនធ្វើឱ្យរងគ្រោះធ្ងន់ធ្ងរដែលនាំឱ្យប៉ះពាល់ដល់ជីវិតនោះឡើយ"។ បើទោះបីជាយ៉ាងណាក៏ដោយ អ្នកផ្តល់ចំលើយភាគច្រើនបំផុត បាននិយាយថាអំពើរំលោភសេពសន្ថវៈ គួរតែផ្តន្ទាទោសជាប់ពន្ធនាគារលើសពីបីឆ្នាំ លើកលែងតែការរំលោភសេពសន្ថវៈនោះ ប្រព្រឹត្តឡើងដោយមិត្តប្រុស ឬគូសង្សារ។ អ្នកផ្តល់ចំលើយចំនួន ៩២% ការចង់ឱ្យមានការដាក់ពន្ធនាគារលើសពីបីឆ្នាំចំពោះសមាជិកក្រុមបងធំ ដែលបានប្រព្រឹត្តអំពើរំលោភសេពសន្ថវៈ និងចំនួន ៩១% ចង់ឱ្យមានការដាក់ទោសដូចគ្នានេះដែរ ចំពោះឪពុកដែលបានរំលោភសេពសន្ថវៈកូនស្រីរបស់ខ្លួន។ ស្ត្រីមានការអត់អោនជាងបុរសចំពោះរាល់ជនល្មើសទាំងអស់ ដោយសារស្ត្រីទាំងនោះជាអ្នកដែលមានប្រាក់ចំណូលទាប។

ប៉ុន្តែការរំលោភសេពសន្ថវៈដោយមិត្តប្រុស និងគូសង្សារ ត្រូវបានគេចាត់ទុកថាជាករណីដែលខុសពីករណីខាងលើ យោងតាមចំលើយនៅក្នុងតារាងទី ២១ ខាងក្រោម[១០០]។ ផ្ទុយគ្នានឹងករណីដែលអ្នកផ្តល់ចំលើយភាគច្រើនចង់ឱ្យមានការដាក់ពន្ធនាគារលើសពីបីឆ្នាំ ចំពោះអ្នកប្រព្រឹត្តបទរំលោភសេពសន្ថវៈ ប៉ុន្តែអ្នកផ្តល់ចំលើយចំនួនជាងពាក់កណ្តាល ចង់ឱ្យមានការផ្តន្ទាទោសស្រាលជាងនេះ

---

[៩៩] ក្នុងប្រទេសកម្ពុជា ពាក្យថា "មិត្តប្រុស" ត្រូវបានប្រើដើម្បីពិពណ៌នាអំពីទំនាក់ទំនងដែលកើតមានមុនពេលរៀបការ ហើយពាក្យថា "គូសង្សារ" ត្រូវបានប្រើដើម្បីបញ្ជាក់អំពីទំនាក់ទំនងក្រៅអាពាហ៍ពិពាហ៍ (ឧទាហរណ៍ៈ ដើម្បីសំដៅដល់ "អាពាហ៍ពិពាហ៍លើកទីពីរ") ដែលពុំមែនជាសកម្មភាពរកស៊ីផ្លូវភេទនោះទេ។

[១០០] Compare Rebecca Surtees (2003), "ការចាប់រំលោភ និងការបំពានផ្លូវភេទក្នុងប្រទេសកម្ពុជា" *អំពើហិង្សាប្រឆាំងនឹងស្ត្រីក្នុងសង្គមអាស៊ី សកលវិទ្យាល័យ* (Macquarie) ទំព័រ៩៣-១០៣ ស្តីពីការចាប់រំលោភដោយមិត្តប្រុស និងគូសង្សារ។

ចំពោះមិត្តប្រុសដែលរំលោភសេពសន្ថវៈដៃគូរបស់ខ្លួន។ ក្នុងករណីទាំងនេះ ភាគច្រើនគឺដោះស្រាយតាមរយៈសំណងជាប្រាក់ដល់ជនរងគ្រោះ ជាជាងការផ្តន្ទាទោស។ ទស្សនៈទាំងនេះ គឺដូចគ្នានឹងទស្សនៈស្តីពីការរំលោភសេពសន្ថវៈក្នុងចំណងអាពាហ៍ពិពាហ៍ ដែលនឹងត្រូវលើកយកមកពិភាក្សានៅក្នុងផ្នែកបន្ទាប់។ ករណីនេះអាចដោយសារតែមិត្តប្រុស និងគូសង្សារ ត្រូវបានគេចាត់ទុកថា មានឋានៈដូចជាប្តី ពោលគឺពុំមែនជាសមាជិកគ្រួសារ ឬជនចំឡែកដែលប្រព្រឹត្តអំពើរំលោភសេពសន្ថវៈនោះទេ។ លទ្ធផលនេះ អាចបង្ហាញអំពីកម្មសិទ្ធិភាពរបស់ប្តី ឬមិត្តប្រុសទៅលើស្ត្រី។

អ្នកផ្តល់ចំលើយក៏បាននិយាយថា អ្នកប្រព្រឹត្តបទរំលោភសេពសន្ថវៈ គួរត្រូវបានផ្តន្ទាទោសខុសៗគ្នា នៅពេលដែលជនរងគ្រោះ ជាអនីតិជន ឬជាស្ត្រីរកស៊ីផ្លូវភេទ។ អ្នកផ្តល់ចំលើយស្ទើរតែទាំងអស់បាននិយាយថា អ្នកប្រព្រឹត្តបទរំលោភសេពសន្ថវៈ គួរតែត្រូវបានផ្តន្ទាទោសឱ្យកាន់តែធ្ងន់ថែមទៀតនៅពេលដែលជនរងគ្រោះមានអាយុក្រោម១៥ឆ្នាំ។ ប៉ុន្តែចំពោះជនរងគ្រោះជាស្ត្រីរកស៊ីផ្លូវភេទ ចំលើយគឺខុសពីករណីខាងលើ។ អ្នកផ្តល់ចំលើយជាបុរសបានស្នើឱ្យមានការផ្តន្ទាទោសធ្ងន់ធ្ងរ ហើយស្ត្រីបានសុំឱ្យមានការផ្តន្ទាទោសស្រាលនៅក្នុងករណីទាំងនេះ។ ចំលើយទាំងនេះទំនងជាពាក់ព័ន្ធទៅនឹងឥរិយាបថចំពោះស្ត្រីរកស៊ីផ្លូវភេទ និងផលប៉ះពាល់ទៅលើអាពាហ៍ពិពាហ៍។

ភាគច្រើននៃអ្នកផ្តល់ចំលើយ បានស្គាល់ជនរងគ្រោះដោយសារអំពើរំលោភសេពសន្ថវៈ។ ជារួមអ្នកផ្តល់ចំលើយចំនួន ២៧% បានស្គាល់ជនរងគ្រោះដោយសារអំពើរំលោភសេពសន្ថវៈ។ សមាមាត្រភាគច្រើននៃអ្នកផ្តល់ចំលើយ ដែលមានប្រាក់ចំណូលទាបបំផុត (៤២%) បានស្គាល់ជនរងគ្រោះដោយសារអំពើរំលោភសេពសន្ថវៈ។ ស្ត្រី ដែលស្គាល់ជនរងគ្រោះដោយសារអំពើរំលោភសេពសន្ថវៈទំនងជាមានចំនួនច្រើនជាងបុរស។

ភាគច្រើននៃអ្នកប្រព្រឹត្តអំពើរំលោភសេពសន្ថវៈ គឺជាសមាជិកគ្រួសារ ដែលមានចំនួនសរុប ៤៤%[១០១]។ ឪពុកបង្កើត និងឪពុកចុងមានចំនួន ២៧% ហើយមិត្តប្រុស ឬអ្នកស្គាល់គ្នា មានចំនួន ២០% ក្នុងចំណោមចំនួនសរុបនៃអ្នកប្រព្រឹត្ត។

---

១០១ សូមមើលចំលើយឆ្លើយតបទៅនឹងសំណួរ ៣២ a ក្នុងឧបសម្ព័ន្ធ A ។




**តារាងទី ២១**
**សំណួរទី ៣១ a**
*ប្រសិនបើការរំលោភសេពសន្ថវៈត្រូវបានប្រព្រឹត្តឡើងដោយមនុស្សខាងក្រោមនេះ តើអ្នកគិតថាវានឹងត្រូវផ្ដន្ទាទោសយ៉ាងណា? (N = 3030)*

## សេចក្ដីសន្និដ្ឋាន

អ្នកផ្ដល់ចំលើយបានបញ្ជាក់ច្បាស់ថា អំពើរំលោភសេពសន្ថវៈ គឺជាបញ្ហាដ៏ធ្ងន់ធ្ងរ ហើយអំពើរំលោភសេពសន្ថវៈនេះ គឺជាទំរង់មួយខុសពីទំរង់ដទៃទៀតនៃការរំលោភបំពានដែលបានសិក្សាស្រាវជ្រាវនៅក្នុងការអង្កេតនេះ។ ក្រុមទាំងអស់នៃអ្នកផ្ដល់ចំលើយ បាននិយាយថាអំពើរំលោភសេពសន្ថវៈគឺជាបទឧក្រិដ្ឋដែលត្រូវតែផ្ដន្ទាទោសយ៉ាងធ្ងន់ធ្ងរ ប្រសិនបើជនល្មើសពុំមែនជាមិត្តប្រុសនោះទេ។ ស្ត្រីច្រើនតែមានការអត់អោនជាងបុរសចំពោះរាល់ជនល្មើសទាំងអស់។

ការអង្កេតនេះបានបង្ហាញថា ប្រេវ៉ាឡង់នៃអំពើរំលោភសេពសន្ថវៈ មានកំរិតខ្ពស់។ ចំនួនប្រមាណ១ភាគ៤នៃក្រុមអ្នកផ្តល់ចំលើយ បានស្គាល់ជនរងគ្រោះដោយសារអំពើរំលោភសេពសន្ថវៈ។ តួលេខនេះ ក៏កាន់តែខ្ពស់ផងដែរ (៤២%) ចំពោះអ្នកដែលមានប្រាក់ចំណូលទាបបំផុត។ ភាគច្រើននៃអ្នកប្រព្រឹត្តនៅក្នុងករណីរំលោភសេពសន្ថវៈនេះ គឺជាសមាជិកគ្រួសារ ជាពិសេសឪពុកបង្កើត និងឪពុកចុង។

## ២.៣.២ ការរំលោភសេពសន្ថវៈក្នុងចំណងអាពាហ៍ពិពាហ៍

ការអង្កេតបានរកឃើញថា ការរំលោភសេពសន្ថវៈពីសំណាក់ប្តី ត្រូវបានគេចាត់ទុកជាករណីខុសពីការរំលោភសេពសន្ថវៈដែលប្រព្រឹត្តដោយអ្នកផ្សេងៗទៀត។ ការរំលោភសេពសន្ថវៈក្នុងចំណងអាពាហ៍ពិពាហ៍ គឺជាប្រធានបទមួយ ដែលគួរតែយកចិត្តទុកដាក់។ ភាគច្រើននៃសំណួរទាំងនេះ គឺជាផ្នែកដ៏លំបាកបំផុតនៅក្នុងការធ្វើអង្កេតនេះ ទាំងសំរាប់អ្នកធ្វើសម្ភាស និងអ្នកដែលត្រូវបានសម្ភាស ដូច្នេះនាំឱ្យមានការពិបាកក្នុងការទទួលបានចំលើយដោយស្មោះត្រង់។ ដោយសារតែហេតុផលនេះហើយ បានជាការអង្កេតនេះពុំបានដាក់បញ្ចូលនូវសំណួរអំពីបទពិសោធន៍ផ្ទាល់ខ្លួនរបស់អ្នកចូលរួមនោះទេ។ ផ្ទុយទៅវិញ ការអង្កេតនេះបានផ្តោតទៅលើការយល់ដឹងរបស់អ្នកផ្តល់ចំលើយអំពីអ្នកដទៃទៀត ដែលទទួលរងគ្រោះដោយសារការរំលោភសេពសន្ថវៈក្នុងចំណងអាពាហ៍ពិពាហ៍ និងទៅលើឥរិយាបថចំពោះការរំលោភសេពសន្ថវៈក្នុងចំណងអាពាហ៍ពិពាហ៍ ព្រមទាំងវិធីស្វែងរកការជួយសង្គ្រោះ។

ការអង្កេតបានបង្ហាញអំពីការទទួលយកការរំលោភសេពសន្ថវៈក្នុងចំណងអាពាហ៍ពិពាហ៍ច្រើនជាងការរំលោភសេពសន្ថវៈដែលប្រព្រឹត្តដោយអ្នកដទៃទៀត។ ចំនួន ១២%នៃអ្នកផ្តល់ចំលើយបាននិយាយថា ប្តីមានសិទ្ធិបង្ខំប្រពន្ធរបស់ខ្លួនដើម្បីរួមភេទ ដែលផ្ទុយនឹងឆន្ទៈរបស់នាង។ នៅពេលសួរអ្នកដែលផ្តល់ចំលើយទាំងនេះថា ហេតុអ្វីបានជាឆ្លើយថាប្តីមានសិទ្ធិធ្វើបែបនេះ មានចំនួន ៩៥% បាននិយាយថា "ពីព្រោះពួកគេរៀបការរួចហើយ"។ ករណីនេះបង្ហាញនូវឥរិយាបថថា ប្តីមានសិទ្ធិយកប្រពន្ធធ្វើជាកម្មសិទ្ធិរបស់ខ្លួន។

អ្នកផ្តល់ចំលើយត្រូវបានគេសួរថា "តើប្តីមានសិទ្ធិបង្ខំប្រពន្ធរបស់ខ្លួនរួមភេទបានដែរឬទេប្រសិនបើប្រពន្ធពុំចង់រួមភេទ?" ចំលើយមានលក្ខណៈខុសគ្នា ដោយផ្អែកទៅតាមយេនឌ័រ ប្រាក់ចំណូល និងអាយុ ដែលលទ្ធផលលំអិតមានដូចខាងក្រោមនេះ៖

- ស្ត្រីមានចំនួនច្រើនជាងបុរសពីរដងបាននិយាយថា បុរសមានសិទ្ធិបង្ខំប្រពន្ធរបស់ខ្លួនរួមភេទបាន។ ស្ត្រីចំនួន ១៨% បានផ្តល់នូវចំលើយនេះបើប្រៀបធៀបនឹងបុរសមានចំនួន ៧%។
- ប្រជាពលរដ្ឋដែលមានប្រាក់ចំណូលទាប (១៨%) មានចំនួនច្រើនជាងពីរដងនៃអ្នកមានប្រាក់ចំណូលខ្ពស់ (៩%) បាននិយាយថា បុរសមានសិទ្ធិបង្ខំប្រពន្ធរបស់ខ្លួនរួមភេទបាន។
- ប្រជាពលរដ្ឋមានអាយុចាប់ពី ៤០ ឆ្នាំឡើងទៅ ទំនងជាទទួលយកការរំលោភសេពសន្ថវៈក្នុងចំណងអាពាហ៍ពិពាហ៍ ច្រើនជាងមនុស្សដែលមានអាយុពី ១៥ ទៅ ១៩ឆ្នាំ។ ក្រុមមនុស្សវ័យចាស់ចំនួន ១៥% បាននិយាយថាបុរសមានសិទ្ធិបង្ខំប្រពន្ធរបស់ខ្លួនរួមភេទបាន បើប្រៀបធៀបទៅនឹងក្រុមមនុស្សវ័យក្មេងមានចំនួន ៩ %។

ការរំលោភសេពសន្ថវៈក្នុងចំណងអាពាហ៍ពិពាហ៍ទំនងដូចជាពុំត្រូវបានគេចាត់ទុកជាបទឧក្រិដ្ឋ ដូចការរំលោភសេពសន្ថវៈដែលប្រព្រឹត្តដោយអ្នកដទៃទៀតនោះទេ។ បើប្រៀបធៀបទៅនឹងចំនួន ៩៤% នៃក្រុមអ្នកផ្តល់ចំលើយដែលបាននិយាយថាអំពើរំលោភសេពសន្ថវៈ ជាបទឧក្រិដ្ឋ គឺមានអ្នកផ្តល់ចំលើយចំនួន ៦៦% ដែលបាននិយាយថា បុរសដែលបានបង្ខំប្រពន្ធរបស់ខ្លួនដើម្បីរួមភេទ ដោយផ្ទុយនឹងឆន្ទៈរបស់នាង គឺកំពុងប្រព្រឹត្តបទឧក្រិដ្ឋ។

អ្នកផ្តល់ចំលើយ បានបង្ហាញនូវការឯកភាពយ៉ាងខ្លាំងលើហេតុផល ដែលស្ត្រីអាចមានសិទ្ធិបដិសេធពុំរួមភេទជាមួយប្តីរបស់ខ្លួន ដូចដែលបានបង្ហាញនៅក្នុងតារាងទី ២២ខាងក្រោម:

- ហេតុផលជាទូទៅបំផុតដែលស្ត្រី មានសិទ្ធិបដិសេធមិនរួមភេទជាមួយប្តីរបស់ខ្លួននោះ គឺថានាងទើបតែសំរាលកូនរួច។
- មានចំនួនច្រើនជាង ៣ភាគ៤ នៃក្រុមអ្នកផ្តល់ចំលើយបាននិយាយថា ស្ត្រីមានសិទ្ធិបដិសេធនៅពេលនាងមានការនឿយហត់ ឬមានជម្ងឺ។
- ក្រុមអ្នកផ្តល់ចំលើយ មានចំនួនពាក់កណ្តាលបាននិយាយថា ស្ត្រីអាចបដិសេធដោយសមហេតុផលជាមួយប្តី នៅក្នុងករណីប្តីមានមេរោគអេដស៍/ជម្ងឺអេដស៍ ឬជម្ងឺកាមរោគផ្សេងៗទៀត។
- ក្រុមអ្នកផ្តល់ចំលើយ មានចំនួនច្រើនជាង ១ភាគ៣ បាននិយាយថា ស្ត្រីមានសិទ្ធិបដិសេធនៅពេលប្តីរបស់ខ្លួនរួមភេទជាមួយស្ត្រីផ្សេងទៀត។

## តារាងទី ២២

### សំណួរទី ២៧ c

*តើក្នុងកាលៈទេសៈណាដែលប្រពន្ធមានភាពសមហេតុផលត្រឹមត្រូវក្នុងការបដិសេធការរួមភេទជាមួយប្ដីរបស់គាត់?*

*(N = 3030)*



មានចំលើយខុសៗគ្នា ដោយផ្អែកទៅតាមយេនឌ័រ ប្រាក់ចំណូល និងទីកន្លែងរស់នៅរបស់អ្នកផ្តល់ចំលើយ។ ស្ត្រីទំនងជានៅតែមានចំនួនតិចជាងបុរសដែលនិយាយថា ប្រពន្ធមានសិទ្ធិបដិសេធការរួមភេទបាន។ ប្រហាក់ប្រហែលគ្នានេះដែរ ប្រជាពលរដ្ឋដែលមានប្រាក់ចំណូលខ្ពស់ និងអ្នកដែលរស់នៅក្នុងតំបន់ទីប្រជុំជន ចំនួនតិចប៉ុណ្ណោះដែលនិយាយថា ស្ត្រីមានហេតុផលបដិសេធជាមួយប្តីរបស់ខ្លួនបាន។

អ្នកផ្តល់ចំលើយក្នុងចំនួនមួយគួឱ្យកត់សំគាល់ខ្លះ (១៤%) បាននិយាយថា ពួកគេស្គាល់ស្ត្រីដែលប្តីរបស់នាងបានបង្ខំនាងឱ្យរួមភេទដោយផ្ទុយនឹងឆន្ទៈរបស់នាង។ ប៉ុន្តែក្រុមអ្នកផ្តល់ចំលើយផ្សេងៗទៀតដែលមានភាគរយច្រើនជាងនេះ បានរាយការណ៍អំពីករណីនេះ។ ឧទាហរណ៍ មានចំនួនស្ទើរតែ ១ភាគ៤នៃប្រជាពលរដ្ឋដែលមានប្រាក់ចំណូលទាបបំផុតបាននិយាយថា ពួកគេបានដឹងអំពីករណីបែបនេះ។ ប្រជាពលរដ្ឋដែលមានប្រាក់ចំណូលខ្ពស់បំផុត និងស្ត្រីជាច្រើនទំនងជាបាននិយាយថា ពួកគេបានស្គាល់ស្ត្រីដែលត្រូវបានប្តីរបស់ខ្លួនរំលោភសេពសន្ថវៈ។

អ្នកផ្តល់ចំលើយ បានគាំទ្រយ៉ាងខ្លាំងចំពោះការសម្រុះសម្រួល ដែលជាមធ្យោបាយមួយដើម្បីទប់ស្កាត់ស្ថានភាពទាំងនេះ។ ក្រុមអ្នកផ្តល់ចំលើយស្ទើរតែពាក់កណ្តាល បាននិយាយថា ការពន្យល់និងការសម្រុះសម្រួល អាចបញ្ឈប់ប្តីពីការធ្វើឥរិយាបថបែបនេះ។ អ្នកផ្តល់ចំលើយមានចំនួនតិចតួចបំផុត (បុរស ១១% និងស្ត្រី ៦%) បាននិយាយថា "ការអប់រំប្តីប្រពន្ធទាំងពីរនាក់" អាចនឹងមានប្រសិទ្ធភាព។ ពុំមាននរណាម្នាក់បានលើកឡើងនូវជំរើសក្នុងការអប់រំបុរសនោះទេ។

## សេចក្តីសន្និដ្ឋាន

ការរំលោភសេពសន្ថវៈក្នុងចំណងអាពាហ៍ពិពាហ៍ ត្រូវបានគេចាត់ទុកថាមានលក្ខណៈផ្សេងពីករណីរំលោភសេពសន្ថវៈដែលប្រព្រឹត្តដោយអ្នកដទៃទៀត។ ទោះបីជាអ្នកផ្តល់ចំលើយភាគច្រើនបានគិតថា បុរសពុំមានសិទ្ធិបង្ខំប្រពន្ធរបស់ខ្លួន ដើម្បីរួមភេទនោះក៏ដោយ ប៉ុន្តែមានចំនួនតែ ៥៥% ប៉ុណ្ណោះបានគិតថា ការរំលោភសេពសន្ថវៈក្នុងចំណងអាពាហ៍ពិពាហ៍ គឺជាបទឧក្រិដ្ឋ។ ស្ត្រីហាក់ដូចជាមានចំនួនច្រើនជាងបុរសពីរដង ដែលគិតថាបុរសមានសិទ្ធិបង្ខំប្រពន្ធរួមភេទ។ ចំនួនសមាមាត្រដ៏ច្រើននៃក្រុមអ្នកផ្តល់ចំលើយ (១៤%) ពិតជាបានស្គាល់ស្ត្រីដែលត្រូវបានប្តីរបស់ខ្លួនបង្ខំរួមភេទ ហើយតួលេខនេះក៏កាន់តែមានកំរិតខ្ពស់ថែមទៀត ក្នុងចំណោមប្រជាពលរដ្ឋក្រីក្រ។

ទោះបីជាយ៉ាងណាក៏ដោយ អ្នកផ្តល់ចំលើយទាំងឡាយបាននិយាយថា មានហេតុផលមួយចំនួនដែលស្ត្រីមានសិទ្ធិបដិសេធមិនរួមភេទជាមួយប្តីរបស់នាង ជាពិសេសនៅពេលនាងទើបតែសំរាលកូនរួច។ ស្ត្រីហាក់ដូចជានៅតែមានចំនួនតិចជាងបុរសដែលនិយាយថា ប្រពន្ធមានសិទ្ធិបដិសេធការរួមភេទជាមួយប្តីរបស់ខ្លួនបាន។ អ្នកផ្តល់ចំលើយចំនួនប្រហែលពាក់កណ្តាលបាននិយាយថា ស្ត្រីមានហេតុផលក្នុងការបដិសេធជាមួយប្តីរបស់ខ្លួន នៅពេលដែលប្តីមានមេរោគអេដស៍/ជម្ងឺអេដស៍ ឬជម្ងឺកាមរោគផ្សេងៗទៀត។

## អនុសាសន៍សំរាប់អំពើរំលោភសេពសន្ថវៈ និងការរំលោភសេពសន្ថវៈក្នុងចំណោមអាពាហ៍ពិពាហ៍

### ការបណ្តុះបណ្តាល និងការអប់រំ:

- បណ្តុះបណ្តាលប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន និងអង្គការសិទ្ធិមនុស្ស ដើម្បីឱ្យគោរពដល់បុគ្គលភាព និងការសម្ងាត់របស់ជនរងគ្រោះដោយសារអំពើរំលោភសេពសន្ថវៈ ( "ពុំត្រូវបង្ហាញអំពីឈ្មោះ និងទីកន្លែង" ) ។
- កសាងសមត្ថភាពរបស់មន្ត្រីសុខាភិបាល ដើម្បីផ្តល់សេវាដល់ជនរងគ្រោះ ដោយសារអំពើរំលោភសេពសន្ថវៈ ដោយយកចិត្តទុកដាក់អំពីយេនឌ័រ ។

### ការផ្សព្វផ្សាយការយល់ដឹងជាសាធារណៈ:

- បង្កើនការយល់ដឹងជាសាធារណៈអំពីការស្ម័គ្រចិត្ត និងការបង្ខិតបង្ខំនៅក្នុងទំនាក់ទំនងផ្លូវភេទ ។
- ជំរុញក្រុមគ្រួសារឱ្យផ្តល់ការគាំទ្រដល់ជនរងគ្រោះដោយសារអំពើរំលោភសេពសន្ថវៈ ពោលគឺពុំត្រូវបដិសេធជនរងគ្រោះ ឬពុំត្រូវទទួលយកសំណងបន្តិចបន្តួចនោះឡើយ ។ ត្រូវប្រឈមមុខនឹងទស្សនៈដែលយល់ឃើញថា កិត្តិយសរបស់ជនរងគ្រោះ គឺអាចសម្រុះសម្រួលគ្នាបាន ។
- លើកកំពស់តួនាទីជាឪពុកម្តាយដែលមិនប្រើអំពើហិង្សា ពីព្រោះកូនដែលទទួលរងគ្រោះដោយសារអំពើហិង្សាពីសំណាក់ឪពុកម្តាយ ច្រើនតែអនុវត្តតាមគំរូនៃអំពើហិង្សាទាំងនោះដែរ ។
- លើកកំពស់រូបភាពគំរូវិជ្ជមានរបស់បុរស ដោយប្រើប្រាស់តំលៃរបស់បុរស និងក្រុមគ្រួសាររបស់ពួកគេនាពេលបច្ចុប្បន្ននេះ ។ កំណត់ឡើងវិញនូវតួនាទីរបស់បុរសដែលជាមេគ្រួសារ ដោយសង្កត់ធ្ងន់ទៅលើការទទួលខុសត្រូវរបស់បុរសនៅក្នុងគ្រួសារ ពោលគឺពុំមែនជាអំណាចរបស់បុរសនៅក្នុងគ្រួសារនោះទេ ។
- ផ្សព្វផ្សាយករណីគំរូ អំពីការការចោទប្រកាន់អ្នកប្រព្រឹត្តបទរំលោភសេពសន្ថវៈ ដើម្បីបង្កើនការយល់ដឹង និងលើកកំពស់ប្រសិទ្ធភាពនៃប្រព័ន្ធច្បាប់ ។
- បង្កើនការយល់ដឹងអំពីច្បាប់គ្រួសារ ដែលចែងអំពីអាពាហ៍ពិពាហ៍ និងការលែងលះគ្នា ។
- លើកកំពស់ការទទួលខុសត្រូវក្នុងការប្រើប្រាស់ជាតិស្រវឹង ។ ប្រឈមដោះស្រាយនឹងទស្សនៈដែលថាជាតិស្រវឹង គឺជាបុព្វហេតុនៃអំពើហិង្សាក្នុងគ្រួសារ ដែលនាំឱ្យមានការដោះលែងអ្នកប្រព្រឹត្តពីការទទួលខុសត្រូវទាំងអស់ ។
- ពិនិត្យឡើងវិញលើគំរូនៃការសម្រុះសម្រួលគ្នា ( កំណត់និងរៀបចំឡើងវិញនូវវិធីសម្រុះសម្រួលគ្នា) ។

### ការរៀបចំគោលនយោបាយ និងសកម្មភាព :

- ពង្រីកឱកាសក្នុងការទទួលបាននូវសេវាផ្លូវច្បាប់សំរាប់ជនរងគ្រោះ ដោយសារអំពើរំលោភសេពសន្ថវៈ ដែលមានបំណងចង់រកដំណោះស្រាយតាមផ្លូវច្បាប់ ។ ត្រូវផ្តល់ការគាំទ្រផ្លូវចិត្តដល់ជនរងគ្រោះ និងធានាថាអត្តសញ្ញាណរបស់ពួកគេ ពុំត្រូវបានបង្ហាញនៅអំឡុងពេលដំណើរការទាំងស្រុងនោះទេ ។

- នាំយកមធ្យោបាយដោះស្រាយតាមផ្លូវតុលាការ (ឧ-ដីកាការពារ និងការលែងលះគ្នា)ឱ្យទៅដល់ជិតប្រជាពលរដ្ឋកម្ពុជាគ្រប់រូបនៅតាមភូមសាស្ត្រនានា។
- បញ្ជ្រាបចំណេះដឹងអំពីអំពើហិង្សាយេនឌ័រ ទៅក្នុងកម្មវិធីទប់ស្កាត់មេរោគអេដស៍ ដោយរួមទាំងឯកសារសំភារៈស្តីពីការស្ម័គ្រចិត្ត និងការបង្ខិតបង្ខំ (ជាពិសេសពាក់ព័ន្ធទៅនឹងលទ្ធផលរកឃើញស្តីពីការរំលោភសេពសន្ថវៈក្នុងចំណងអាពាហ៍ពិពាហ៍ )។
- ប៉ាន់ប្រមាណ និងដោះស្រាយតំរូវការសុខភាពផ្លូវចិត្តរបស់ជនរងគ្រោះដោយសារអំពើហិង្សា។
- ដាក់បញ្ចូលយុទ្ធសាស្ត្រស្តីពីការដោះស្រាយអំពើហិង្សាក្នុងគ្រួសារ ទៅក្នុងគោលនយោបាយ និងកម្មវិធីកាត់បន្ថយភាពក្រីក្រ ដូចជាយុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ ផែនការអភិវឌ្ឍន៍យុទ្ធសាស្ត្រជាតិ វិមជ្ឈការ និងវិសហមជ្ឈការ គំនិតផ្តួចផ្តើមកម្មវិធីរបស់អ្នកផ្តល់ជំនួយ និងកម្មវិធីនានាដែលរៀបចំឡើងដោយអង្គការក្រៅរដ្ឋាភិបាល ព្រោះរបាយការណ៍បានបង្ហាញឱ្យឃើញថាអំពើហិង្សាក្នុងគ្រួសារមានកំរិតខ្ពស់ ក្នុងចំណោមប្រជាពលរដ្ឋក្រីក្រ (និងស្ត្រីមានសមាមាត្រខ្ពស់ ក្នុងចំណោមប្រជាពលរដ្ឋក្រីក្រ)។
- បង្កើតការិយាល័យទទួលបន្ទុកស្ថិតិជាតិស្តីពីអំពើហិង្សាប្រឆាំងនឹងស្ត្រី។
- ការតាមដានត្រួតពិនិត្យ និងការវាយតំលៃ៖ អ្នកផ្តល់ជំនួយ ត្រូវជំរុញឱ្យមានរបាយការណ៍ស្តីពីផលប៉ះពាល់របស់កម្មវិធីរបស់ខ្លួន ហើយផ្សព្វផ្សាយលទ្ធផលសំរេចបាន និងការអនុវត្តន៍ដែលល្អបំផុត។

## ការសិក្សាស្រាវជ្រាវ៖

- ធ្វើការសិក្សាស្រាវជ្រាវទៅលើបញ្ហាផ្លូវភេទ ដោយផ្តោតទៅលើឥរិយាបថ គោលបំណង និងបញ្ហាកម្មសិទ្ធិជុំវិញប្តី មិត្តប្រុស និងគូសង្សារ ហើយនិងការយល់ដឹងអំពីសិទ្ធិផ្លូវភេទ។

## ការផ្តល់សេវា៖

- ផ្តល់កម្មវិធីនានា និងអ្នកសម្របសម្រួលប្រកបដោយសមត្ថភាពសំរាប់ការការងារជាក្រុមជាមួយបុរសដោយសង្កត់ធ្ងន់ថា ("អំពើហិង្សា មិនអាចទទួលយកបានទេ"។)
- បណ្តុះបណ្តាលចំណេះដឹងអំពីយេនឌ័រ ដល់អ្នកផ្តល់សេវាថែទាំសុខភាព និងសេវាសង្គមកិច្ច និងអង្គការសិទ្ធិមនុស្ស និងអំពីការស្វែងយល់អំពីសញ្ញានៃការរំលោភបំពានលើរាង្គកាយ និងផ្លូវចិត្ត ហើយបញ្ជូនជនរងគ្រោះដោយសារការរំលោភបំពានទាំងនោះទៅទីកន្លែងជួយសង្គ្រោះ។
- លើកកំពស់ការអប់រំផ្នែកសង្គមកិច្ច និងការអនុវត្តន៍ និងតាមរយៈការជំរុញឱ្យអ្នកពិគ្រោះបញ្ហាដេ ីម្បីផ្តល់អំណាចដល់អតិថិជន ស្តាប់អតិថិជនផ្តល់ជំរើសដល់ពួកគេ ឬជៀសវាងការមើលងាយដល់ពួកគេ។
- ធ្វើឱ្យប្រសើរឡើង និងសាងសង់ទីជំរកការពារសំរាប់ជនរងគ្រោះដោយសារការរំលោភបំពាន។ ទីជំរកទាំងនេះ ត្រូវផ្តល់ជាទីកន្លែងសុវត្ថិភាពរយៈពេលខ្លី ដោយពុំមានការដាក់កំរិតចំពោះស្ត្រីដែលស្នាក់នៅទីនោះ និងត្រូវមានផែនការសុវត្ថិភាពសំរាប់ស្ត្រីក្នុងការវិលត្រលប់ទៅផ្ទះសំបែងរបស់ពួកគេវិញ។

## ២.៤ ការស្វែងរកជំនួយ

ការអង្កេត បានសាកសួរអ្នកឆ្លើយសំណួរអំពីទីកន្លែងដើម្បីស្វែងរកការជួយសង្គ្រោះចំពោះករណីអំពើហិង្សាក្នុងគ្រួសារ និងអំពីលទ្ធផលនៃករណីទាំងនេះ។ ការអង្កេតបានដាក់ បញ្ចូលនូវសំណួរនានាអំពីការស្វែងរកជំនួយសង្គ្រោះក្នុងករណីរំលោភសេពសន្ថវៈ និងករណីរំលោភបំពានផ្លូវកាយ។ ដូចមាននៅក្នុងផ្នែកផ្សេងទៀតនៃការអង្កេតនេះ អ្នកឆ្លើយសំណួរត្រូវបានគេសាកសួរអំពីការយល់ដឹងរបស់ពួកគេអំពីជំរើសដែលមនុស្សដទៃទៀតបានប្រើប្រាស់សំរាប់ការជួយសង្គ្រោះ និងជំរើសដែលពួកគេបានអនុវត្តដោយខ្លួនឯង។ អ្នកឆ្លើយសំណួរបានពិភាក្សាអំពីមធ្យោបាយជាច្រើនដែលមានចាប់ពីការសម្រុះសម្រួលគ្នាក្រៅផ្លូវការរហូតដល់ការលែងលះគ្នា។

### ២.៤.១ ជំរើសដែលមានក្នុងការស្វែងរកជំនួយ

សមត្ថភាពរបស់អ្នកផ្តល់ចំលើយនៅក្នុងការទទួលបានជំនួយ នៅមានកំរិតទាបនៅឡើយនៅពេលពួកគេកំពុងទទួលរងគ្រោះដោយសារការរំលោភបំពាន ពីព្រោះជំរើសដែលមានក្នុងការស្វែងរកជំនួយ ឬការយល់ដឹងអំពីសេវាជួយសង្គ្រោះដែលមានស្រាប់។ អ្នកផ្តល់ចំលើយបានបញ្ជាក់យ៉ាងច្បាស់ថាមានតែកន្លែងពីរប៉ុណ្ណោះដែលពួកគេអាចទទួលបានការជួយសង្គ្រោះនោះ គឺអាជ្ញាធរឃុំ-សង្កាត់ ឬអាជ្ញាធរភូមិ ឬប៉ូលីស។ មានអ្នកផ្តល់ចំលើយតិចតួចបំផុតបាននិយាយអំពីតុលាការ ដែលជាញឹកញាប់តុលាការទាំងនោះច្រើននៅឆ្ងាយពីលំនៅឋាន។ តាមពិតក្រុមអ្នកផ្តល់ចំលើយចំនួន ៣៨% បាននិយាយថា ពួកគេនឹងត្រូវធ្វើដំណើរចំនួនពីរម៉ោង ដើម្បីបានទៅដល់តុលាការ ហើយអ្នកផ្តល់ចំលើយចំនួន ២៧% បាននិយាយថា ពួកគេនឹងត្រូវធ្វើដំណើររហូតដល់ប្រាំមួយម៉ោង។ ការចំណាយនៅក្នុងការធ្វើដំណើរទៅដល់តុលាការ ជាមធ្យមអស់ចំនួន ៤ ដុល្លាអាមេរិក។ ពួកគេកាន់តែពុំមានលទ្ធភាពទៅដល់ទីភ្នាក់ងារដែលផ្តល់ការពិគ្រោះបញ្ហា ជំនួយផ្លូវច្បាប់ ឬទីជំរកនោះទេ។

**តារាងទី ២៣**
**សំណួរទី ៣៥ a**
*នៅក្នុងឃុំ ឬភូមិរបស់អ្នក តើមានសេវាណាខ្លះដែលអាចរកបាន?*
*(N= 3030)*




## ២.៤.២ ការស្វែងរកជំនួយ សំរាប់អំពើរំលោភសេពសន្ថវៈ

អ្នកផ្ដល់ចំលើយបាននិយាយថា ស្ត្រីច្រើនតែស្វែងរកការជួយសង្គ្រោះសំរាប់ករណីរំលោភសេពសន្ថវៈ ហើយស្ត្រីតិចតួចបំផុតដែលស្វែងរកការជួយសង្គ្រោះសំរាប់ករណីរំលោភសេពសន្ថវៈក្នុងចំណងអាពាហ៍ពិពាហ៍ ។ អំពើរំលោភសេពសន្ថវៈគឺជាទំរង់នៃការរំលោភបំពានតែមួយគត់ ដែលរបាយការណ៍នេះបានសិក្សា ដែលស្ត្រីស្វែងរកការជួយសង្គ្រោះ និងការផ្ដន្ទាទោសដល់អ្នកប្រព្រឹត្ដដូចដែលបានបង្ហាញនៅក្នុងតារាង ២៤ គ ខាងក្រោមនេះ ។ ផ្ទុយពីករណីផ្សេងៗទៀតនៃអំពើហិង្សាក្នុងគ្រួសារ គឺថាក្នុងករណីរំលោភសេពសន្ថវៈ មានតែចំនួន ១២% ប៉ុណ្ណោះ បាននិយាយថា ស្ត្រីដែលត្រូវបានគេរំលោភសេពសន្ថវៈ បានរក្សាភាពស្ងប់ស្ងាត់ និងពុំបានធ្វើអ្វីឡើយ ។ អ្នកផ្ដល់ចំលើយភាគច្រើន

បាននិយាយថា ជាទូទៅស្ត្រីទាំងនោះបានស្វែងរកការជួយសង្គ្រោះពីមិត្តភ័ក្តិ និងសាច់ញាតិ ។ ក្រុមអ្នកផ្តល់ចំលើយច្រើនជាងពាក់កណ្តាលបាននិយាយថា ស្ត្រីទាំងនោះបានវិលត្រលប់ទៅរកប៉ូលីស និងតុលាការ ព្រមទាំងអាជ្ញាធរភូមិ ឬឃុំ-សង្កាត់វិញ ។ អ្នកផ្តល់ចំលើយចំនួនតិចជាង ១ភាគ៤ បាននិយាយថា ស្ត្រីទាំងនោះបានទៅមន្ទីរពេទ្យ ឬមណ្ឌលសុខភាព ហើយមួយចំនួនតូចបាននិយាយថា ស្ត្រីបានស្វែងរកការទូទាត់សងជាប្រាក់ពីអ្នកប្រព្រឹត្តបទរំលោភសេពសន្ថវៈ ។

**តារាងទី ២៤**

**សំណួរទី ៣២ c**

*តើស្ត្រីនោះមានបានធ្វើអ្វីខ្លះ បន្ទាប់ពីបានកើតរឿងនេះឡើង (បន្ទាប់ពីត្រូវបានគេរំលោភសេពសន្ថវៈ) ?*

*(N = 820)*



អ្នកផ្តល់ចំលើយជាច្រើនបានរាយការណ៍ថា ការសងជំងឺចិត្តត្រូវបានគេបង់ឱ្យ និង/ឬថាអ្នកប្រព្រឹត្តត្រូវបានចាប់ខ្លួន[១០២] ។ បុរសចំនួន ២០% និងស្ត្រីចំនួន ២៧%បាននិយាយថា អ្នកប្រព្រឹត្តត្រូវបានរកឃើញថា មានកំហុស និងត្រូវបានផ្តន្ទាទោស ប៉ុន្តែករណីនេះអាចរួមបញ្ចូលនូវលទ្ធផលក្រៅផ្លូវការផងដែរ(ដោយរួមទាំងការចាត់ចែងឱ្យមានការសងជំងឺចិត្ត) ។ បើទោះបីយ៉ាងណាក្តី អ្នកផ្តល់ចំលើយបាន និយាយថាចំនួនប្រមាណ ៣០% នៃករណីរំលោភសេពសន្ថវៈ ដែលពួកគេបានដឹងនោះ គឺថាអ្នកប្រព្រឹត្តិ គ្រាន់តែត្រូវបានគេព្រមានតែប៉ុណ្ណោះ ឬពុំមានអ្វីកើតឡើងចំពោះអ្នកប្រព្រឹត្តទាល់តែសោះ[១០៣] ។

ចំពោះករណីរំលោភសេពសន្ថវៈក្នុងចំណងអាពាហ៍ពិពាហ៍ បុរសចំនួន ៦៦% និងស្ត្រីចំនួន ៤៦% បាននិយាយថា ស្ត្រីរងគ្រោះនឹងប្រាប់សាច់ញាតិ និងមិត្តភ័ក្តិនូវអ្វីដែលបានកើតឡើង[១០៤] ។ ស្ត្រីហាក់ដូចជាមានចំនួនច្រើនជាងបុរសដែលបានលើកឡើងនូវជំរើសនៅក្នុងការរក្សាភាពស្ងប់ស្ងាត់ និងពុំធ្វើអ្វីឡើយ ទាំងខាងទ្រឹស្តី និងការអនុវត្តន៍ ។ តាមពិត អ្នកផ្តល់ចំលើយច្រើនជាងពាក់កណ្តាលបាននិយាយថាពួកគេបានដឹង/ស្គាល់ស្ត្រី ដែលត្រូវបានប្តីរបស់នាងចាប់រំលោភសេពសន្ថវៈ បានរក្សាភាពស្ងប់ស្ងាត់ និងពុំបានស្វែងរកការជួយសង្គ្រោះនោះទេ[១០៥] ។

បុរសទំនងជាបាននិយាយថា តាមទ្រឹស្តីរងគ្រោះអាចប្រាប់សាច់ញាតិ ឬមិត្តភ័ក្តិ ឬទៅរកអាជ្ញាធរភូមិ ឬឃុំ-សង្កាត់ ។ ប៉ុន្តែនៅពេលដែលបុរសទាំងនោះ ត្រូវបានគេសាកសួរអំពីករណីពិតប្រាកដនៃការរំលោភសេពសន្ថវៈក្នុងចំណងអាពាហ៍ពិពាហ៍ ពេលនោះពួកគេបានធ្វើការផ្លាស់ប្តូរចំលើយទៅវិញ ។ ដូច្នេះហើយ ចំនួនបុរសដែលបាននិយាយថា ស្ត្រីរងគ្រោះបានរក្សាភាពស្ងប់ស្ងាត់ និងពុំបានធ្វើអ្វីសោះនោះមានរហូតចាប់ពី៣២%ដល់៤០% ។ ម្យ៉ាងទៀត ដោយសារភាពខុសគ្នាក្នុងទស្សនៈយេនឌ័រ ប្រការនេះក៏អាចបង្ហាញនូវគម្លាតរវាងជំរើសនានា សំរាប់ការជួយសង្គ្រោះដែលមាននៅក្នុងទ្រឹស្តី ប៉ុន្តែពុំមាននៅក្នុងការអនុវត្តន៍នោះទេ ។ ដោយសារតែមានការយកចិត្តទុកដាក់អំពីការរំលោភសេពសន្ថវៈក្នុងចំណងអាពាហ៍ពិពាហ៍ ចំលើយទាំងនេះក៏ទំនងជាឆ្លុះបញ្ចាំងអំពីសម្ពាធសង្គមដែលចង់រក្សាទុកបញ្ហានេះជាបញ្ហានៅក្នុងរង្វង់គ្រួសារ ដោយពុំនាំទៅដល់អាជ្ញាធរ ឬអ្នកខាងក្រៅដទៃទៀតឡើយ ។

---

១០២ សូមមើលចំលើយក្នុងតារាងទី ៥៩ ក្នុងឧបសម្ព័ន្ធ A

១០៣ ប្រៀបធៀបទៅនឹងលទ្ធផលនៃករណីនានាដែលបានស្រាវជ្រាវដោយអង្គការ LICADHO ដែលរាយការណ៍ថា ប្រាំករណីក្នុងចំណោមការរំលោភសេពសន្ថវៈ ១៧៧ ករណី ឬករណីរំលោភសេពសន្ថវៈដែលបានកើតឡើង ដែលបានរាយការណ៍ឱ្យអង្គការនោះក្នុងឆ្នាំ ២០០៣ បានបញ្ជូនទៅតុលាការហើយ ដោយទទួលបានការផ្តន្ទាទោសចំនួនបួនករណី ។ ក្នុងចំណោម ១៧៩ ករណី ដែលបានរាយការណ៍ជូនអង្គការ LICADHO ក្នុងឆ្នាំ ២០០២ មាន ៧១ ករណីបានបញ្ជូនទៅតុលាការ ដោយទទួលបានការផ្តន្ទាទោសចំនួន ៦៣ករណី ។

១០៤ សូមមើលចំលើយក្នុងតារាងទី ៥៦ ក្នុងឧបសម្ព័ន្ធ A

១០៥ សូមមើលចំលើយក្នុងតារាងទី ៥៧ ក្នុងឧបសម្ព័ន្ធ A

### ២.៤.៣ ការស្វែងរកជំនួយសំរាប់ក្នុងករណីរំលោភបំពានផ្សេងៗទៀត

អត្រានៃស្ត្រីដែលស្វែងរកការជួយសង្គ្រោះសំរាប់ការរំលោភបំពានផ្លូវកាយ ឬការធ្វើឱ្យរបួសស្នាម ឬការរំលោភបំពានផ្លូវចិត្ត គឺមាននៅក្នុងចន្លោះអត្រានៃអំពើរំលោភសេពសន្ថវៈ និងការរំលោភសេពសន្ថវៈក្នុងចំណងអាពាហ៍ពិពាហ៍ ។[១០៦] អ្នកផ្តល់ចំលើយបាននិយាយថា ស្ត្រីច្រើនតែទៅរកការជួយសង្គ្រោះពីអាជ្ញាធរឃុំ-សង្កាត់ ឬចាស់ទុំនៅក្នុងភូមិ មន្ទាប់មកទៅរកប៉ូលីស ឬតុលាការ ។ អ្នកផ្តល់ចំលើយបាននិយាយថា ស្ត្រីពុំសូវទៅរកការជួយពីមេធាវី ឬជំនួយផ្លូវច្បាប់ ឬអង្គការក្រៅរដ្ឋាភិបាលដែលផ្តល់ការពិគ្រោះបញ្ហា[១០៧] ឬការគាំទ្រនោះទេ ហើយភាគតិចបំផុត សុំការជួយពីទីភ្នាក់ងារដែលផ្តល់ទីជំរក ជាពិសេសក្នុងករណីរំលោភបំពានផ្លូវចិត្ត ឬការរំលោភសេពសន្ថវៈក្នុងចំណងអាពាហ៍ពិពាហ៍ ។ អ្នកផ្តល់ចំលើយ ដែលមកពីតំបន់ទីប្រជុំជន និងអ្នកដែលមានប្រាក់ចំណូលខ្ពស់បាននិយាយថា ស្ត្រីទំនងច្រើនតែទៅស្វែងរកជំនួយពីអង្គការក្រៅរដ្ឋ ាភិបាល ។ ចំលើយនេះអាចបង្ហាញឱ្យឃើញថាលទ្ធភាពដែលអាចរកបានជំនួយពីអង្គការក្រៅរដ្ឋាភិបាលក្នុងតំបន់ទីប្រជុំជន គឺមានកំរិតខ្ពស់ ។

ការស្វែងរកការជួយសង្គ្រោះ សំរាប់ការលែងលះគ្នា ត្រូវបានគេចាត់ទុកជាករណីមិនធម្មតា ។ អ្នកផ្តល់ចំលើយបាននិយាយថា ការស្វែងរកការលែងលះគ្នាក្នុងករណីទាំងនេះ គឺកម្រមានណាស់ ។ ការ លែងលះគ្នា ជាធម្មតាកើតឡើងក្នុងករណីរំលោភបំពានផ្លូវកាយ ឬការធ្វើឱ្យមានរបួសស្នាមជាងករណី រំលោភបំពានផ្លូវចិត្តដោយការរួមភេទដោយបង្ខំ។ ភាគច្រើនបំផុតនៃអ្នកផ្តល់ចំលើយ (បុរស = ៩៨% និង ស្ត្រី = ៩៥%) បាននិយាយថា អ្នកដែលស្វែងរកការលែងលះគ្នា នឹងទៅរកអាជ្ញាធរឃុំ-សង្កាត់ គឺពុំទៅរកតុលាការទេ ។[១០៨]

---

១០៦ សូមមើលចំលើយក្នុងតារាងទី ៦០ ក្នុងឧបសម្ព័ន្ធ A

១០៧ របាយការណ៍ស្តីពីសុខភាពផ្លូវចិត្ត បានបង្ហាញអោយឃើញថា ការពិគ្រោះយោបល់ពុំទាន់មានគ្រប់គ្រាន់នៅឡើយទេ ឬពុំទាន់មានគេស្គាល់នៅកម្ពុជា ហើយជាញឹកញាប់ត្រូវគេមើលឃើញថាជាការស្តីបន្ទោស ។

១០៨ សូមមើលតារាងទី ៦១ ក្នុងឧបសម្ពន្ធ័ A ។ ប្រជាពលរដ្ឋកម្ពុជា ទៅរកជំនួយពីអាជ្ញាធរមូលដ្ឋាន សំរាប់ករណីលែងលះ ទោះបីជាអាជ្ញាធរនៅក្នុងថ្នាក់នេះ ពុំមានសិទ្ធិអំណាចផ្តល់នូវការលែងលះ ប៉ុន្តែបានត្រឹមតែការសំរបសំរួលប៉ុណ្ណោះ ។ ច្បាប់គ្រួសារ ចែងអំពីនីតិវិធីសំរាប់ការចុះលិខិតអត្រានុកូលដ្ឋាន នៅថ្នាក់ឃុំ ដើម្បីអោយស្របទៅតាមផ្លូវច្បាប់ ហេតុដូច្នេះហើយមានការគិតថា ក្រុមប្រឹក្សាឃុំ-សង្កាត់សិទ្ធិអំណាចក្នុងការសំរេចការលែងលះផងដែរ ។ ក្នុងករណីភាគច្រើន ទោះបីជាអាពាហ៍ពិពាហ៍ពុំបានចុះក្នុងបញ្ជីអត្រានុកូលដ្ឋាន ប៉ុន្តែប្តី និងប្រពន្ធចាត់ទុកថាពួកគេបានរៀបការហើយ ។ ជំនាញផ្នែកច្បាប់មានការលំបាកក្នុងការសំរេចថាតើប្តីប្រពន្ធនេះ ចាំបាច់ត្រូវទាមទារការលែងលះនៅក្នុងតុលាការដែរឬទេ ។ ជាញឹកញាប់ប្រជាពលរដ្ឋជឿថា ពួកគេអាចទៅរកអាជ្ញាធរមូលដ្ឋាន ដើម្បីការលែងលះ ហេតុដូច្នេះហើយពួកគេ ទៅរកមន្ត្រីមូលដ្ឋានទាំងនេះដើម្បីទទួលបានប្រាក់ឧបត្ថម្ភដល់កូន និងដើម្បីបញ្ចប់អាពាហ៍ពិពាហ៍ ។ និងដោយហេតុថា ការទៅរកតុលាការ គឺជាបន្ទុកមួយ ប្រជាពលរដ្ឋជាញឹកញាប់ ទៅរកអាជ្ញាធរមូលដ្ឋាន ដើម្បីដោះស្រាយបញ្ហារបស់ពួកគេ ។ បើសិនជាប្តីប្រពន្ធព្រមព្រៀង ពួកគេ នឹងទទួលបាន "ការលែងលះ" ទៅតាមកំណត់ហេតុនៃកិច្ចប្រជុំជាមួយនឹងអាជ្ញាធរមូលដ្ឋាន UNDP (ទំព័រទី៩១)




**តារាងទី ២៥**

**សំណួរទី ១៦ c**

*តើអ្នកបានធ្វើអ្វីខ្លះ ដើម្បីបញ្ឈប់អំពើបែបនេះ ទាក់ទងនឹងការរំលោភបំពានផ្នែកពាក្យសំដី ឬផ្លូវកាយពីប្តី/ប្រពន្ធ?*

*(N = 1961)*

### ២.៤.៤ បទពិសោធន៍ផ្ទាល់ខ្លួនរបស់អ្នកផ្តល់ចំលើយ ក្នុងការស្វែងរកជំនួយ

ចំលើយរបស់អ្នកផ្តល់ចំលើយអំពីបទពិសោធន៍ផ្ទាល់ខ្លួននៅក្នុងការស្វែងរកការជួយសង្គ្រោះគឺផ្ទុយពីចំលើយអំពីអ្វីដែលអ្នកផ្សេងអាចធ្វើបានតាមទ្រឹស្តី អ្នកផ្តល់ចំលើយមានចំនួនតិចតួចបំផុតបានរាយការណ៍ថា ពួកគេធ្លាប់បានស្វែងរកការជួយសង្គ្រោះ។ ការអង្កេតនេះបានសាកសួរអ្នកផ្តល់ចំលើយនូវសំណួរមួយចំនួនអំពីការខិតខំប្រឹងប្រែងរបស់ពួកគេនៅក្នុងការស្វែងរកជំនួយ ។ជាដំបូងការអង្កេតបានសួរអ្នកផ្តល់ចំលើយនូវអ្វីដែលពួកគេបានធ្វើ ដើម្បីបញ្ឈប់ការរំលោភបំពានផ្នែកពាក្យសំដី ឬផ្លូវកាយពីសហព័ទ្ធរបស់ខ្លួន។ ការរក្សាភាពស្ងប់ស្ងាត់ និងការពុំធ្វើអ្វីសោះ គឺជាចំលើយដែលច្រើនបំផុតដូចដែលបានបង្ហាញក្នុងតារាងទី ២៥ ខាងក្រោម។ ដោយមានភាពខុសគ្នារវាងទ្រឹស្តី និងការអនុវត្តន៍ សំណួរនេះបង្ហាញនូវភាពខុសគ្នាចំពោះការយល់ឃើញអំពីអ្វីដែលមនុស្សដទៃទៀតធ្វើ និងអ្វីដែលអ្នកផ្តល់ចំលើយធ្វើសំរាប់ខ្លួនគាត់។ មនុស្សដែលមានប្រាក់ចំណូលទាប ហាក់ដូចជាមានចំនួនច្រើនជាងអ្នកដែលមានប្រាក់ចំណូលខ្ពស់ បាននិយាយថាពួកគេពុំបានធ្វើអ្វីឡើយ ។

ការអង្កេតក៏បានសាកសួរអ្នកផ្តល់ចំលើយទាំងអស់ថា "តើអ្នកធ្លាប់ស្វែងរកជំនួយចំពោះបញ្ហាទាំងនេះដែរឬទេ (ការរំលោភបំពានផ្លូវកាយ ឬផ្លូវចិត្ត ឬការរួមភេទដោយបង្ខំ) ?។ មានតែ ១១% តែប៉ុណ្ណោះក្នុងចំណោមក្រុមអ្នកផ្តល់ចំលើយទាំងអស់បាននិយាយថា ពួកគេផ្ទាល់ធ្លាប់បានស្វែងរកជំនួយ ។ ចំលើយទាំងនេះមានលក្ខណៈខុសគ្នាបន្តិចបន្តួច ទៅតាមយេនឌ័រៈ ស្ត្រី ចំនួន ១២% បាននិយាយថាពួកគេធ្លាប់បានស្វែងរកជំនួយ បើប្រៀបធៀបនឹងបុរសមានចំនួន ១០%។ អ្នកផ្តល់ចំលើយដែលមានប្រាក់ចំណូលទាប ហាក់ដូចជាមានចំនួនតិចជាងអ្នកផ្តល់ចំលើយដែលមានប្រាក់ចំណូលខ្ពស់ ដែលបាននិយាយថាពួកគេធ្លាប់បានស្វែងរកជំនួយ។ ក្នុងករណីតិចតួចប៉ុណ្ណោះដែលបុរសនិងស្ត្រីមានចំនួនសមាមាត្រស្មើគ្នា បានទៅរកជំនួយពីភ្នាក់ងារនានាដូចដែលបានបង្ហាញតាមក៏រិតខាងលើ ។

នៅក្នុងក្រុមអ្នកផ្តល់ចំលើយនេះ ដែលធ្លាប់បានស្វែងរកការជួយសង្គ្រោះ[១០៩] ស្ត្រីច្រើនទៅរកអាជ្ញាធរឃុំ-សង្កាត់ ឬចាស់ទុំក្នុងភូមិ បន្ទាប់មកទៅរកតុលាការ ឬប៉ូលីស ហើយមានចំនួនតិចបំផុតទៅស្វែងរកទីជំរកការពារ[១១០] ដូចមានបង្ហាញក្នុងតារាងខាងក្រោម។ ស្ត្រីមានតិចតួចបំផុតបាននិយាយថា ពួកគេបានសុំជំនួយពីមេធាវី ឬការិយាល័យជំនួយផ្លូវច្បាប់ និងស្ត្រីមួយចំនួនតូចទៀត បានទៅរកទីភ្នាក់ងារដែលផ្តល់ការពិគ្រោះបញ្ហា ឬការគាំទ្រ។

អ្នកផ្តល់ចំលើយដែលជាបុរស បានអនុវត្តតាមវិធីប្រហាក់ប្រហែលនឹងស្ត្រីដែរ។ បុរសភាគច្រើន (៥៤%) បាននិយាយថាពួកគេបានសុំជំនួយពីអាជ្ញាធរភូមិ ឬឃុំ-សង្កាត់។ ប៉ុន្តែបុរសហាក់ដូចជាមានចំនួនច្រើនជាងស្ត្រី ដែលទៅរកប៉ូលីស ឬតុលាការ។

អ្នកផ្តល់ចំលើយមានចំនួនតិចតួចបាននិយាយថា ពួកគេបានស្វែងរកជំនួយសំរាប់អំពើហិង្សាដែលបានប្រព្រឹត្តឡើងដោយអ្នកផ្សេងទៀត ក្រៅពីរសហព័ទ្ធរបស់ខ្លួន។ ការទទួលយកដោយស្ងៀមស្ងាត់នូវអំពើហិង្សានេះ គឺជាចំលើយជាទូទៅបំផុតៈ ៧៥% នៃក្រុមតូច ដែលមានអ្នកឆ្លើយសំណួរចំនួន ២,៧១១ នាក់ បាននិយាយថា ពួកគេបានរក្សាភាពស្ងៀមស្ងាត់ និងពុំបានធ្វើអ្វីឡើយ។[១១១]




**តារាងទី ២៦**
**សំណួរទី ៣៨ a**
*តើលោកអ្នកធ្លាប់ស្វែងរកជំនួយដែរឬទេ?*
*(N = 330)*

---

១០៩ ក្រុមតូចនៃអ្នកដែលបានស្វែងរកជំនួយនេះ គឺពុំមែនតំណាងឱ្យអ្នកផ្តល់ចំលើយទាំងអស់នោះទេ។

១១០ ទីជំរកពុំទាន់មាននៅទូទាំងប្រទេសនោះទេ។ ទីជំរកស្នាក់នៅ ក្នុងប្រទេសកម្ពុជា ជាញឹកញាប់ពុំលក្ខណៈសមរម្យ និងមានភាពតឹងតែងចំពោះស្ត្រីដែលនៅទីនោះ។

១១១ សូមមើលចំលើយក្នុងតារាងទី ៤៧ ក្នុងឧបសម្ព័ន្ធ A។




**តារាងទី ២៧**
**សំណួរទី ៣៨ a**
*តើលោកអ្នកធ្លាប់ស្វែងរកជំនួយពីភ្នាក់ងារខាងក្រោមនេះ ចំពោះបញ្ហាទាំងនេះដែរឬទេ?*
*(N = 330)*

## ២.៤.៥ បទពិសោធន៍ក្នុងការស្វែងរកការលែងលះ

ជាងពាក់កណ្ដាលនៃអ្នកផ្ដល់ចំលើយទាំងអស់ដែលមានចំនួន៣៣០នាក់ ដែលបានស្វែងរកជំនួយជាដំបូងគឺបានស្វែងរកការលែងលះគ្នា។[១១២] ស្ត្រី និងអ្នកដែលមានប្រាក់ចំណូលទាប ច្រើនតែស្វែងរកការសុំលែងលះគ្នា ដោយសារការរំលោភបំពានផ្លូវកាយ ឬការធ្វើឱ្យរបួសស្នាម ឬការរំលោភបំពានផ្លូវចិត្ត។ អ្នកផ្ដល់ចំលើយតិចតួចបំផុត បានស្វែងរកការលែងលះគ្នាដោយសារការរួមភេទដោយបង្ខំ។ ភាគច្រើននៃអ្នកទាំងនេះ បានវិលត្រលប់ទៅរកអាជ្ញាធរឃុំ-សង្កាត់ ដើម្បីលែងលះគ្នា។

ភាគច្រើនបំផុតនៃអ្នកផ្ដល់ចំលើយដែលបានស្វែងរកការលែងលះគ្នា ត្រូវបានអាជ្ញាធរជំរុញឱ្យមានការសម្រុះសម្រួលគ្នា។ បុរសចំនួន ៨២% និងស្ត្រីចំនួន ៩៦% ត្រូវបានគេជំរុញឱ្យធ្វើការសម្រុះសម្រួលគ្នា។ លទ្ធផលចុងក្រោយ គឺថាមានចំនួនប្រមាណ ៣ភាគ៤ នៃអ្នកផ្ដល់ចំលើយត្រូវបានសម្រុះសម្រួលគ្នា។ ចំនួនតិចជាង ១ភាគ៤ នៃអ្នកផ្ដល់ចំលើយ បានលែងលះគ្នា។ ការចំណាយជាមធ្យមសំរាប់ករណីលែងលះគ្នា គឺ ១០ ដុល្លា សំរាប់ដំណើរការលែងលះគ្នានីមួយៗ។

---

[១១២] សូមមើលចំលើយក្នុងតារាងទី ៦២ ក្នុងឧបសម្ព័ន្ធ A។ ប្រៀបធៀបនឹង UNDP ប៉ុន្តែ ការអង្កេតនោះ បានកំណត់យកក្រុមអ្នកផ្ដល់ចំលើយ និងសំណួរខុសគ្នាពីការអង្កេតនេះ។

## សេចក្តីសន្និដ្ឋាន

ជាទូទៅ ស្ត្រីច្រើនតែ ស្វែងរកជំនួយ និងយុត្តិធម៌ ក្នុងករណីរំលោភសេពសន្ថវៈ និងការរំលោភបំពានផ្លូវកាយ ជាងករណីរំលោភបំពានផ្សេងៗទៀត ។ តាមពិតមានតែ ១១% តែប៉ុណ្ណោះក្នុងចំណោមក្រុមអ្នកផ្តល់ចំលើយ ពិតជាបានស្វែងរកជំនួយសំរាប់បញ្ហាទាំងនេះ - ស្ត្រី ច្រើនតែស្វែងរកជំនួយពីអាជ្ញាធរឃុំ-សង្កាត់ហើយបុរសរកជំនួយពីប្រព័ន្ធយុត្តិធម៌ ។ ពុំសូវមានការលើកឡើងអំពីការរកជំនួយពីអង្គការក្រៅរដ្ឋាភិបាលទេ លើកលែងតែនៅក្នុងតំបន់ទីប្រជុំជន ។

ការសម្រុះសម្រួលគ្នាឡើងវិញ គឺជាយុទ្ធសាស្ត្រចំបង ដែលទទួលបានការលើកទឹកចិត្តពីអ្នកដទៃ និងជាលទ្ធផលដ៏ចំបងនៅក្នុងករណីអំពើហិង្សា និងការរំលោភបំពាន ។ ទោះបីការលែងលះគ្នាគឺជាមធ្យោបាយដែលមានជាចំបង សំរាប់អំពើហិង្សា និងការរំលោភបំពានផ្លូវកាយក្តី ក៏មានករណីតិចតួចប៉ុណ្ណោះត្រូវបានបញ្ចប់ដោយការលែងលះគ្នា ។ ជាងពាក់កណ្តាលនៃអ្នកដែលបានស្វែងរកជំនួយក៏បានស្វែងរកការលែងលះគ្នាផងដែរ ប៉ុន្តែមានតែ ១ភាគ៤ ប៉ុណ្ណោះនៃស្ត្រីដែលបានស្វែងរកការលែងលះគ្នាបានទទួលជោគជ័យតាមគោលបំណង ។

### អនុសាសន៍សំរាប់ការស្វែងរកជំនួយសង្គ្រោះ

#### ការបណ្តុះបណ្តាល និងការអប់រំ:

- បណ្តុះបណ្តាលនិយោជក មន្ត្រីផ្តល់សេវាថែទាំសុខភាព បណ្តាញក្រៅប្រព័ន្ធ និងសាធារណៈជនអំពីចំណេះដឹងយេនឌ័រ និងដើម្បីស្វែងយល់អំពីសញ្ញានៃការរំលោភបំពានផ្លូវកាយ និងផ្លូវចិត្ត ហើយបញ្ជូនអ្នកដែលទទួលរងគ្រោះដោយសារការរំលោភបំពានទាំងនោះ ទៅកាន់ទីកន្លែងជួយសង្គ្រោះ ។
- បណ្តុះបណ្តាលមន្ត្រីថ្នាក់ឃុំ-សង្កាត់ និងប៉ូលីសអំពីអំពើហិង្សាក្នុងគ្រួសារ ។ ការបណ្តុះបណ្តាលត្រូវបញ្ចូលនូវបញ្ហាមួយចំនួនដូចជា: ការដោះស្រាយជំលោះ ការលើកកំពស់ដំណោះស្រាយដែលអាចអនុវត្តបាន (ការជជែកគ្នាដោយស្មៀមស្ងាត់ និងការពន្យល់អំពីហេតុផល) ការប្រឈមនឹងទស្សនៈអំពីអំណាច និងការត្រួតត្រា ការពិនិត្យឡើងវិញលើរូបភាពនៃការសម្រុះសម្រួលគ្នា ការលើកកំពស់គំរូតួនាទីវិជ្ជមាន និងព័ត៌មានក្នុងការបញ្ជូនទៅរកសេវានានា ។
- បណ្តុះបណ្តាលអង្គការក្រៅរដ្ឋាភិបាលតាមមូលដ្ឋាន ដែលមកពីវិស័យដទៃទៀត (ឧ- សុខភាព វិស័យច្បាប់) អំពីអំពើហិង្សាក្នុងគ្រួសារ ដើម្បីធ្វើឱ្យប្រសើរឡើងនូវការផ្តល់សេវា ។

#### ការផ្សព្វផ្សាយការយល់ដឹងជាសាធារណៈ:

- បង្កើនការយល់ដឹងជាសាធារណៈអំពីវិធីស្វែងរកជំនួយ នៅថ្នាក់មូលដ្ឋាន ។

**ការរៀបចំគោលនយោបាយ និងសកម្មភាព:**

- លើកកំពស់សេវាមួយចំនួន ចាប់ពីសេវានៅមូលដ្ឋានដល់សេវាប្រចាំសហគមន៍ និងទីជំរកការពារដែលជាជំរើសចុងក្រោយ ហើយបង្កើតឱ្យមាននៅទូទាំងប្រទេសកម្ពុជា។
- បង្កើតបទដ្ឋានគោលសំរាប់សេវាសង្គមកិច្ច សំរាប់ទីភ្នាក់ងារ និងអ្នកប្រកបវិជ្ជាជីវៈនានា។
- ពង្រីកការអប់រំផ្នែកសង្គមកិច្ច ដោយការវិភាជថវិកាបន្ថែមទៀត។
- អ្នកផ្តល់ជំនួយ គួរតែប្រើប្រាស់បទដ្ឋានគោលទាំងនេះ ដើម្បីរៀបចំបង្កើតកម្មវិធី និងការវិភាជថវិកា ជាពិសេសទាក់ទងទៅនឹងការផ្តល់ទីជំរកសំរាប់កិច្ចការពារ។
- អ្នកផ្តល់សេវានានា ចាំបាច់ត្រូវពិនិត្យឡើងវិញលើគំរូនៃការសម្រុះសម្រួលគ្នា។
- នាំមកនូវមធ្យោបាយដោះស្រាយតាមផ្លូវតុលាការ (ឧ- ដីកាការពារ និងការលែងលះគ្នា) ឱ្យកាន់តែខិតជិតដល់ប្រជាពលរដ្ឋគ្រប់រូបទៅតាមភូមិសាស្ត្រនានា ។
- ពង្រីកលទ្ធភាពទទួលបាននូវសេវាផ្លូវច្បាប់ សំរាប់ជនរងគ្រោះដោយសារអំពើរំលោភសេពសន្ថវៈ ដែលជ្រើសរើសយកដំណោះស្រាយតាមផ្លូវច្បាប់។ ត្រូវផ្តល់ការគាំទ្រផ្លូវចិត្តដល់ជនរងគ្រោះ និងធានាថាអត្តសញ្ញាណរបស់ពួកគេ ពុំត្រូវបានបង្ហាញនៅអំឡុងពេលដំណើរការទាំងស្រុងនោះទេ។
- ការតាមដានត្រួតពិនិត្យ និងការវាយតំលៃ: អ្នកផ្តល់ជំនួយត្រូវជំរុញឱ្យមានរបាយការណ៍ស្តីពីផលប៉ះពាល់ ហើយផ្សព្វផ្សាយលទ្ធផលសំរេចបាន និងការអនុវត្តន៍ល្អបំផុត។

**ការផ្តល់សេវា:**

- ធ្វើឱ្យប្រសើរឡើង និងសាងសង់ទីជំរកសំរាប់ជនរងគ្រោះដោយសារការរំលោភបំពាន។ ទីជំរកទាំងនេះ ត្រូវផ្តល់ជាទីកន្លែងសុវត្ថិភាពរយៈពេលខ្លី ដោយពុំមានការដាក់កំរិតចំពោះស្ត្រី ដែលស្នាក់នៅទីនោះ និងត្រូវមានផែនការសុវត្ថិភាពសំរាប់ស្ត្រីនៅក្នុងការវិលត្រលប់ទៅផ្ទះសំបែងរបស់ពួកគេវិញ។
- ផ្តល់កម្មវិធីនានា និងអ្នកសម្របសម្រួលប្រកបដោយសមត្ថភាពសំរាប់ការធ្វើការងារជាក្រុមជាមួយបុរសដោយសង្កត់ធ្ងន់ថា ("អំពើហិង្សា មិនអាចទទួលយកបានទេ"។)
- លើកកំពស់ការអប់រំផ្នែកសង្គមកិច្ច និងការអនុវត្តន៍ តាមរយៈការជំរុញឱ្យអ្នកពិគ្រោះបញ្ហាផ្តល់អំណាចដល់អតិថិជន ស្តាប់អតិថិជន ផ្តល់ជំរើសដល់ពួកគេ និងជៀសវាងការវាយតំលៃ ឬមើលងាយដល់ពួកគេ។

## ២.៥ អាជ្ញាធរមូលដ្ឋាន និងប៉ូលីស

ដើម្បីទទួលបានចំលើយជាក់លាក់អំពីតួនាទីរបស់អាជ្ញាធរមូលដ្ឋាន និងប៉ូលីស ការសិក្សាស្រាវជ្រាវនេះបានធ្វើការស្ទាបស្ទង់ទៅលើក្រុមអាជ្ញាធរ និងប៉ូលីសមូលដ្ឋានចំនួន ៣០០នាក់ លើប្រធានបទដូចគ្នា ដូចដែលមាននៅក្នុងតារាងសំណួរដោយបន្ថែមសំណួរមួយចំនួនទៀតទៅ ដើម្បីឆ្លុះបញ្ចាំងនូវតួនាទីនីមួយៗរបស់ពួកគេ។ ក្រុមអ្នកផ្តល់ចំលើយនេះគឺពុំមែនតំណាងឱ្យអាជ្ញាធរ និងប៉ូលីសមូលដ្ឋានទាំងអស់នៅក្នុងប្រទេសកម្ពុជានោះទេ។ដូចដែលបានកត់សំគាល់នៅក្នុងឧបសម្ព័ន្ធB ក្រុមនេះរួមមានទាំងអាជ្ញាធរថ្នាក់ស្រុក អាជ្ញាធរឃុំ-សង្កាត់ ប៉ូលីសថ្នាក់អនុសេនីយទោ និងនាយប៉ូលីសជាន់ខ្ពស់ព្រមទាំងមន្ត្រីប៉ូលីសថ្នាក់ទាប។

### ២.៥.១ ឥរិយាបថរបស់អាជ្ញាធរមូលដ្ឋាន និងប៉ូលីសចំពោះអំពើហិង្សាក្នុងគ្រួសារ

ការអង្កេតបានបង្ហាញឱ្យឃើញថា អាជ្ញាធរមូលដ្ឋាន និងប៉ូលីស មានឥរិយាបថភាគច្រើន ដូចគ្នាទៅនឹងឥរិយាបថរបស់ប្រជាពលរដ្ឋទូទៅដែរ។ឥរិយាបថទាំងនេះត្រូវបានវាស់វែងតាមការសួរសំណួរខុសៗគ្នាជាច្រើន។

ការឱ្យលំដាប់លេខរៀង លើការទទួលយកអំពើហិង្សាមួយចំនួនរបស់អាជ្ញាធរមូលដ្ឋាន និងប៉ូលីសបានបង្ហាញនូវភាពខុសគ្នាខ្លះពីក្រុមឆ្លើយសំណួរទូទៅ។ ការឱ្យលំដាប់លេខរៀងលើអំពើហិង្សាធ្ងន់ធ្ងរបំផុតទាំងបួនក្រុម គឺស្ថិតនៅក្នុងលំដាប់ដូចគ្នាជាមួយនឹងក្រុមអ្នកផ្តល់ចំលើយទូទៅដែរ ប៉ុន្តែអាជ្ញាធរមូលដ្ឋាន និងប៉ូលីសមានការទទួលយកអំពើហិង្សាប្រភេទផ្សេងៗទៀតច្រើនជាងអ្នកផ្តល់ចំលើយទូទៅ។ បើទោះបីជាយ៉ាងណាក្តី ការអង្កេតបានបង្ហាញនូវចំលើយខុសៗគ្នាជាច្រើន ដោយអាស្រ័យទៅលើថាតើអ្នកផ្តល់ចំលើយជាអាជ្ញាធរថ្នាក់ស្រុក អាជ្ញាធរឃុំ-សង្កាត់ មន្ត្រីប៉ូលីស ថ្នាក់អនុសេនីយទោឡើងទៅ ឬក៏មន្ត្រីប៉ូលីសថ្នាក់ទាប។[១១៣]

អាជ្ញាធរមូលដ្ឋាន និងប៉ូលីស ក្នុងសមាមាត្រស្មើនឹងអ្នកផ្តល់ចំលើយទូទៅដែរ បាននិយាយថាអំពើហិង្សាធ្ងន់ធ្ងរ គឺពុំគួរទទួលយកទាល់តែសោះ។ ចំនួនចន្លោះពី ៦០% និង ៦៨% នៃមន្ត្រីទាំងនេះបាននិយាយថា ការជះទឹកអាស៊ីត ចាក់ កាប់ ឬបាញ់សំលាប់ គឺពុំអាចទទួលយកបានឡើយ បើប្រៀបធៀបនឹងក្រុមអ្នកផ្តល់ចំលើយទូទៅ គឺបុរសមានចំនួន ៦៥% និងស្ត្រីមានចំនួន ៧០%។[១១៤] ក្នុងករណីនេះអាជ្ញាធរស្រុកមានការអត់អោនច្រើនជាងគេ ចំពោះទង្វើទាំងនេះ ហើយប៉ូលីសថ្នាក់ទាបមានការអត់អោនតិចជាង។

ទស្សនៈចំពោះការទទួលយកករណីអំពើហិង្សាដែលពុំសូវធ្ងន់ធ្ងរ គឺមានចំនួនប្រហាក់ប្រហែលទៅនឹងទស្សនៈរបស់អ្នកផ្តល់ចំលើយទូទៅ ដែលមានដូចខាងក្រោមនេះ:

---

១១៣ ភាគរយនៃអ្នកផ្តល់ចំលើយ ដែលបានឆ្លើយ "ទេ មិនដែលទាល់តែសោះ" នៅក្នុងសំណួរៈ
តើអាចទទួលយកបានឬទេចំពោះប្តីប្រព្រឹត្តអំពើនេះទៅលើប្រពន្ធ?

១១៤ ចំពោះលទ្ធផលនៃសំណួរនេះ ដែលបានសួរទៅអ្នកផ្តល់ចំលើយទូទៅ សូមពិនិត្យចំលើយក្នុងតារាងទី ១ ទំព័រទី

- សមាមាត្រនៃអ្នកផ្តល់ចំលើយដែលបាននិយាយថា ការដុត ឬការច្របាច់ករ គឺពុំអាចទទួលយកបានឡើយ មានចាប់ពី ៥៨% (អាជ្ញាធរស្រុក) ដល់ ៦៨% (មន្ត្រីប៉ូលីសថ្នាក់ទាប)។ បើប្រៀបធៀបនឹងក្រុមអ្នកផ្តល់ចំលើយទូទៅ ដែលបានឆ្លើយនឹងសំណួរនេះ គឺបុរសមានចំនួន៧២% និងស្ត្រីមានចំនួន៦៥%។
- នៅពេលដែលត្រូវបានគេសួរថាតើអាចទទួលយកបានដែរឬទេចំពោះប្តី ដែលគំរាមកំហែងប្រពន្ធរបស់ខ្លួនដោយកាំបិតឬកាំភ្លើង-សមាមាត្រនៃអ្នកផ្តល់ចំលើយដែលបាននិយាយថាទង្វើនេះពុំអាចទទួលយកបាន គឺមានចាប់ពី ៤០% (អាជ្ញាធរស្រុក) ដល់ ៦១% (មន្ត្រីប៉ូលីសថ្នាក់ទាប)។ មន្ត្រីឃុំ-សង្កាត់ចំនួន ៤៤% និងនាយប៉ូលីសជាន់ខ្ពស់ចំនួន ៥១% បាននិយាយថាការគំរាមកំហែងទាំងនេះ គឺពុំអាចទទួលយកបានឡើយ។ បើប្រៀបធៀបនឹងក្រុមអ្នកផ្តល់ចំលើយទូទៅ គឺបុរសមានចំនួន ៥៧% និងស្ត្រីមានចំនួន ៥៤%។
- ចំនួនចន្លោះពី ៤៤% (នៃអាជ្ញាធរឃុំ-សង្កាត់) និង៤៨% (នៃអាជ្ញាធរស្រុក) បាននិយាយថា ប្តីដែលចាប់ចងប្រពន្ធហើយវាយដំ គឺពុំអាចទទួលយកបានឡើយ។ នៅក្នុងចំណោមក្រុមអ្នកផ្តល់ចំលើយទូទៅ ដែលបានឆ្លើយនឹងសំណួរនេះ គឺបុរសមានចំនួន ៥៧% និងស្ត្រីចំនួន ៤៤%។

ក្នុងចំណោមអាជ្ញាធរមូលដ្ឋាន និងប៉ូលីស ដែលបាននិយាយថា អំពើហិង្សា ពេលខ្លះអាចទទួលយកបានយល់ឃើញថា ឥរិយាបថរបស់ប្រពន្ធ គឺជាមូលហេតុដែលនាំឱ្យប្តីប្រើអំពើហិង្សា ដូចដែលបានបង្ហាញក្នុងតារាងទី២៨ខាងក្រោម-ចំនួននេះប្រហាក់ប្រហែលនឹងចំលើយរបស់ក្រុមអ្នកផ្តល់ចំលើយទូទៅផងដែរ។[115]ដូចគ្នានឹងក្រុមអ្នកផ្តល់ ចំលើយទូទៅផងដែរ[116] អាជ្ញាធរមូលដ្ឋាន និងប៉ូលីសបាននិយាយថា អំពើហិង្សារបស់ប្តីជាញឹកញាប់ គឺសមហេតុផលនៅពេលដែលប្រពន្ធជំទាស់នឹងអំណាច ឬសិទ្ធិរបស់ប្តីនៅក្នុងការធ្វើអ្វីតាមចិត្តចង់។ ដូចគ្នានឹងក្រុមអ្នកផ្តល់ចំលើយទូទៅផងដែរ ចំលើយរបស់មន្ត្រីទាំងនេះ ចំពោះការទទួលយកនូវអំពើហិង្សា បើទោះបីជាក្នុងកំរិតធ្ងន់ធ្ងរ ឬស្រាលក្តី ដែលអំពើហិង្សានេះ កើតមានឡើងដោយសារប្រពន្ធសួរដេញដោលអំពីអំណាចរបស់ប្តី គឺខុសគ្នាបន្តិចបន្តួចតែប៉ុណ្ណោះ។ នៅពេលដែលមន្ត្រីទាំងនោះត្រូវបានសួរអំពីការស្រែកគំហកដាក់ ឬអំពើរំលោភបំពានធ្ងន់ធ្ងរដែលបណ្តាលឱ្យស្លាប់ ចំនួននៃអ្នកដែលបាននិយាយថា មានហេតុផលសំរាប់ការប្រព្រឹត្តិអំពើហិង្សាបែបនេះ គឺមានភាពខុសគ្នាតិចតួចណាស់។ ប៉ុន្តែអ្នកផ្តល់ចំលើយមួយចំនួនតូចបាននិយាយថា ប្តីមានមូលហេតុនៅក្នុងការប្រើអំពើហិង្សានៅពេលប្រពន្ធរបស់ខ្លួនពុំបានយកចិត្តទុកដាក់នឹងការងារផ្ទះ ពុំមើលថែទាំកូន និងផ្ទះសំបែង ឬចេញទៅដើរលេងពុំបានប្រាប់ប្តី។ ដូចគ្នានឹងក្រុមអ្នកផ្តល់ចំលើយទូទៅផងដែរ ឥរិយាបថប្រភេទនេះ មានការពាក់ព័ន្ធទៅនឹងការរំលោភបំពានខាងពាក្យសំដីគឺពុំទាក់ទងនឹងការរំលោភបំពានផ្លូវកាយនោះទេ។ហេតុដូច្នេះហើយកត្តាដែលបណ្តាល

---

[115] ដូចបានរៀបរាប់ខាងលើ អ្នកផ្តល់ចំលើយទាំងនេះ ពុំមែនជាតំណាងរបស់ប៉ូលីស និងអាជ្ញាធរទាំងមូលនោះទេ ហើយអ្នកដែលផ្តល់ចំលើយទាំងនេះ គឺជាក្រុមតូចនៃអ្នកផ្តល់ចំលើយដែលជាអាជ្ញាធរមូលដ្ឋាន និងប៉ូលីសតែប៉ុណ្ណោះ។

[116] ចំពោះលទ្ធផលនៃសំណួរនេះ ដែលបានសួរទៅអ្នកផ្តល់ចំលើយទូទៅ សូមពិនិត្យចំលើយក្នុងតារាងទី ២ ទំព័រទី១៩

ឱ្យមានអំពើហិង្សានៅក្នុងករណីទាំងនេះត្រូវបានគេមើលឃើញថា គឺដោយសារិយាបថរបស់ប្រពន្ធ គឺពុំមែនឥរិយាបថហិង្សារបស់ប្ដីនោះទេ។

ហេតុផលទូទៅបំផុត ដែលធ្វើឱ្យប្ដីប្រើអំពើហិង្សា គឺនៅពេលប្រពន្ធឈ្លោះប្រកែកជាមួយប្ដី ឬប្រពន្ធ ពុំគោរពគាត់។ អាជ្ញាធរមូលដ្ឋាន និងប៉ូលីសហាក់ដូចជាមានចំនួនច្រើនជាងក្រុមអ្នកផ្ដល់ចំលើយទូទៅ ដែលនិយាយថាអាកប្បកិរិយារបស់ប្រពន្ធនាំឱ្យមានអំពើហិង្សាពីប្ដីរបស់ខ្លួន។ ទោះបីជាយ៉ាងណាក៏ដោយ ចំនួនអ្នកដែលគិតថាអំពើហិង្សាអាចទទួលយកបាន គឺមានចំនួនតិចតួចណាស់។

- អាជ្ញាធរមូលដ្ឋាន និងប៉ូលីសចំនួន ៧១% បាននិយាយថា រូបភាពនៃអំពើហិង្សាដ៏ធ្ងន់ធ្ងរបំផុតដែលអាចបណ្ដាលឱ្យស្លាប់ គឺស្ថិតនៅក្នុងហេតុផលទាំងនេះ បើធៀបនឹងក្រុមអ្នកផ្ដល់ចំលើយទូទៅមានចំនួន ៥៨%។
- ប្រហាក់ប្រហែលគ្នានេះដែរ អាជ្ញាធរមូលដ្ឋាន និងប៉ូលីសចំនួន ៧៣% បាននិយាយថាការដុតសំលាប់ និងការច្របាច់ក ត្រូវបានកើតឡើងនៅពេលដែលប្រពន្ធមានឥរិយាបថបែបនេះ បើធៀបនឹងក្រុមអ្នកផ្ដល់ចំលើយទូទៅ មានចំនួន ៥៣%។
- អាជ្ញាធរមូលដ្ឋាន និងប៉ូលីសចំនួន ៦៦% បើធៀបនឹងក្រុមអ្នកផ្ដល់ចំលើយទូទៅមានចំនួន ៥៩% បាននិយាយថា ទង្វើទាំងនេះបាននាំឱ្យមានការគំរាមកំហែងពីប្ដីទៅលើប្រពន្ធ ដោយប្រើកាំបិត ឬកាំភ្លើង។
- អាជ្ញាធរមូលដ្ឋាន និងប៉ូលីស ហាក់ដូចជាមានចំនួនច្រើនជាងក្រុមអ្នកផ្ដល់ចំលើយទូទៅ ដែលបាននិយាយថាឥរិយាបថរបស់ប្រពន្ធបែបនេះ បានបណ្ដាលឱ្យប្ដីចាប់ប្រពន្ធចង វាយក្បាលរបស់ប្រពន្ធ ឬគប់ប្រពន្ធនឹងវត្ថុផ្សេងៗ។
- ក្នុងចំណោមអ្នកដែលបាននិយាយថាអំពើហិង្សា នៅពេលខ្លះកើតឡើងដោយសមហេតុផល អាជ្ញាធរមូលដ្ឋាន និងប៉ូលីសភាគច្រើនបាននិយាយថា ប្ដីបានប្រើអំពើហិង្សាទៅលើប្រពន្ធនៅពេលដែលនាងសាកសួរគាត់អំពីមិត្តស្រី ឬអំពីការទៅរករួមភេទជាមួយស្ត្រីរកស៊ីផ្លូវភេទ។ ទោះបីជាយ៉ាងណាក៏ដោយ ចំលើយរបស់អាជ្ញាធរមូលដ្ឋាន គឺដូចគ្នានឹងចំលើយរបស់ក្រុមអ្នកផ្ដល់ចំលើយទូទៅផងដែរ គឺថាចំនួននៃអ្នកដែលបានឆ្លើយថានេះជាហេតុផលនៃការប្រព្រឹត្តអំពើហិង្សា មានចំនួនតិចជាងអ្នកដែលបានឆ្លើយថា ការឈ្លោះប្រកែករបស់ប្រពន្ធ ឬការដែលពុំគោរពប្ដី គឺជាហេតុផលនាំឱ្យមានអំពើហិង្សា។ ក្នុងករណីខ្លះ សមាមាត្រនៃអាជ្ញាធរមូលដ្ឋាន និងប៉ូលីស ដែលបានឆ្លើយថាអំពើហិង្សាបណ្ដាលមកពីបញ្ហាទាំងនេះ គឺមានចំនួនច្រើនជាងក្រុមអ្នកផ្ដល់ចំលើយទូទៅ និងក្នុងករណីខ្លះទៀតមានចំនួនតិចជាង។

អាជ្ញាធរមូលដ្ឋាន និងប៉ូលីសក្នុងចំនួនសមាមាត្រតូចតែប៉ុណ្ណោះ ប៉ុន្តែនៅតែជាចំនួនដ៏សំខាន់ ដែលបាននិយាយថា ប្ដីមានហេតុផលត្រឹមត្រូវនៅក្នុងការប្រើអំពើហិង្សាផ្លូវកាយ នៅពេលប្រពន្ធរបស់គាត់សាកសួរអំពីការចំណាយលុយ។ ម្យ៉ាងវិញទៀត ចំនួននៃអាជ្ញាធរមូលដ្ឋាន និងប៉ូលីសដែលបានលើកឡើងនូវហេតុផលនេះ ពេលខ្លះមានចំនួនច្រើនជាង និងពេលខ្លះមានចំនួនតិចជាងក្រុមអ្នកផ្ដល់ចំលើយទូទៅ ដូចដែលបង្ហាញខាងក្រោមនេះ។

- អាជ្ញាធរមូលដ្ឋាន និងប៉ូលីសមានចំនួនជិត ១ ភាគ ៤ ២៣% បាននិយាយថាប្រពន្ធដែលសាកសួរប្ដីអំពីលុយកាក់ សមនឹងទទួលការជះទឹកអាស៊ីដ ការចាក់សំលាប់ ឬការបាញ់សំលាប់។ ក្រុមអ្នកផ្តល់ចំលើយទូទៅដែលមានចំនួនសមាមាត្រច្រើនជាងនេះបន្តិច ២៥% បានឆ្លើយដូចគ្នានេះដែរ។
- អាជ្ញាធរមូលដ្ឋាន និងប៉ូលីសចំនួន ២៦% បាននិយាយថាប្រពន្ធដែលសាកសួរប្ដីអំពីលុយ សមនឹងទទួលការដុតសំលាប់ ឬការច្របាច់កឱ្យស្លាប់ពីប្ដីរបស់ខ្លួន បើធៀបនឹងក្រុមអ្នកផ្តល់ចំលើយទូទៅមានចំនួន ២០%។

| មានហេតុផល ពីព្រោះ | ពេលខ្លះអាចទទួលយកបាន<br>ស្រែកកំហកដាក់ (N=301) | ការជេរប្រមាថ (N=294) | ចោលរបស់ (N=251) | ការវាយ (N=242) | ការចង (N=165) | ការគំរាមកំហែង (N=157) | ការដុត (N=110) | ជះទឹកអាស៊ីត (N=106) |
|---|---|---|---|---|---|---|---|---|
| ប្រពន្ធឈ្លោះប្រកែកគ្នាជាមួយគាត់/ប្រពន្ធមិនធ្វើតាមគាត់ឬមិនសំដែងការគោរពគាត់ | ៦៦% | ៧៣% | ៧៥% | ៧៧% | ៦៨% | ៦៦% | ៧៣% | ៧១% |
| ប្រពន្ធបានចេញទៅក្រៅដោយមិនប្រាប់គាត់ | ៦៥% | ២៩% | ១៧% | ២១% | ២១% | ១៧% | ៨% | ៩% |
| ប្រពន្ធមិនយកចិត្តទុកដាក់មើលកូន | ៥៨% | ៤៦% | ៣០% | ២៦% | ២០% | ១៨% | ៥% | ១៨% |
| រៀបចំម្ហូបអាហារយឺត ឬមិនឆ្ងាញ់/មិនបានសំអាតផ្ទះ/សំលៀកបំពាក់មិនរៀបរយ | ៣៨% | ៣១% | ២៤% | ២៦% | ២២% | ១២% | ១០% | ១០% |
| ប្រពន្ធចោទសួរគាត់ពីការចំណាយលុយ | ៣១% | ៣២% | ២៩% | ២៦% | ២២% | ២០% | ២៦% | ២៣% |
| ប្រពន្ធចោទសួរគាត់អំពីស្រីញី/ការទៅរកស្រីខូច | ៣០% | ២៨% | ៣៥% | ៤០% | ៣៨% | ៣៤% | ២៣% | ៤២% |
| ប្រពន្ធប្រើវិធីពន្យារកំណើតដោយមិនប្រាប់គាត់ | ១៥% | ១០% | ១០% | ៧% | ៥% | ៦% | ៤% | ៥% |
| ប្រពន្ធបដិសេធការរួមភេទជាមួយគាត់ | ១៣% | ៧% | ៥% | ៧% | ៦% | ៣% | ៣% | ២% |

**តារាងទី ២៨**
**សំណួរទី ៨ b**
*តើស្ថិតក្នុងកាលៈទេសៈណាខ្លះ ដែលប្ដីសមហេតុផលនៅក្នុងការប្រព្រឹត្តិអំពើនេះចំពោះប្រពន្ធ ?*
*(សំណួរនេះត្រូវបានដាក់ឱ្យបកស្រាយចំពោះតែអ្នកដែលបាននិយាយថាអំពើហិង្សានៅពេលខ្លះ គឺសមហេតុផល)*

អាជ្ញាធរមូលដ្ឋាន និងប៉ូលីសបានទទួលយកនូវអំពើហិង្សារបស់ប្រពន្ធចំពោះប្ដីនៅក្នុងកំរិតដូចគ្នាជាមួយអ្នកផ្តល់ចំលើយនៅក្នុងក្រុមអ្នកផ្តល់ចំលើយទូទៅផងដែរ។[១១៧] ប៉ុន្តែនៅក្នុងករណីខ្លះ ពួកគេមានភាពអត់អោនចំពោះអំពើហិង្សារបស់ប្រពន្ធ តិចជាងអ្នកផ្តល់ចំលើយទូទៅ។

---

១១៧ តើអាចទទួលយកបានទេដែលប្រពន្ធប្រព្រឹត្តិអំពើទាំងនេះ ទៅលើប្ដី?

### ២.៥.២ ទស្សនៈរបស់អាជ្ញាធរមូលដ្ឋាន និងប៉ូលីសចំពោះការស្វែងរកការជួយសង្គ្រោះ

អាជ្ញាធរមូលដ្ឋាន និងប៉ូលីស មានទស្សនៈខុសប្លែកបន្តិច ចំពោះជំរើសដែលអាចរកបានសំរាប់អ្នកដែលត្រូវបានសហព័ទ្ធរបស់ខ្លួនរំលោភបំពាន។[១១៨] ពួកគេបានលើកឡើងនូវជំរើសប្រហាក់ប្រហែលគ្នាជាមួយក្រុមអ្នកផ្តល់ចំលើយទូទៅផងដែរ ប៉ុន្តែក្នុងសមាមាត្រមួយខុសគ្នា។ ភាពខុសគ្នាគួរឱ្យកត់សំគាល់បំផុតនោះ គឺថាអាជ្ញាធរមូលដ្ឋាន និងប៉ូលីសច្រើននិយាយថា ជនរងគ្រោះគួរទៅរកប៉ូលីស។ សមាមាត្រនៃអាជ្ញាធរដែលឱ្យជនរងគ្រោះទៅរកប៉ូលីសមានចាប់ពី ៥៤% (អាជ្ញាធរឃុំ-សង្កាត់) ដល់ ៧៧% (មន្ត្រីប៉ូលីសថ្នាក់ទាប) បើប្រៀបធៀបនឹងក្រុមអ្នកផ្តល់ចំលើយទូទៅគឺ បុរសមាន ៣៩% និងស្ត្រីមាន ២៦% ដែលបានជ្រើសរើសយកជំរើសនេះសំរាប់ការស្វែងរកជំនួយ។ ប៉ុន្តែដូចគ្នានឹងក្រុមអ្នកផ្តល់ចំលើយទូទៅផងដែរ ជំរើសដែលបានលើកឡើងទូទៅបំផុតនោះ ៧៥% ដល់ ៩០% (នៃអាជ្ញាធរ) គឺការទៅរកអាជ្ញាធរភូមិ ឬឃុំ-សង្កាត់។

### ២.៥.៣ ទស្សនៈរបស់អាជ្ញាធរមូលដ្ឋាន និងប៉ូលីសចំពោះស្ថានភាពផ្លូវច្បាប់នៃអំពើហិង្សាក្នុងគ្រួសារ

ដូចគ្នានឹងប្រជាពរដ្ឋទូទៅផងដែរ អាជ្ញាធរមូលដ្ឋាន និងប៉ូលីស បានទទួលយកនូវអំពើហិង្សាក្នុងគ្រួសារក្នុងស្ថានភាពជាក់លាក់មួយចំនួន បើទោះបីជាពួកគេ ដឹងថាទង្វើទាំងនេះខុសច្បាប់ក៏ដោយ។ ក្នុងករណីខ្លះ អាជ្ញាធរទាំងនេះមានការយល់ដឹងច្រើនអំពីច្បាប់ ដែលទាក់ទងនឹងករណីអំពើហិង្សាក្នុងគ្រួសារ។ អាជ្ញាធរមូលដ្ឋាន និងប៉ូលីសច្រើនជាងពាក់កណ្តាលបានដឹងថាអំពើហិង្សាផ្លូវកាយ គឺខុសនឹងច្បាប់ ហើយមានអាជ្ញាធរមូលដ្ឋាន និងប៉ូលីសក្នុងចំនួនសមាមាត្រខ្ពស់ជាងក្រុមអ្នកផ្តល់ចំលើយទូទៅ បានដឹងថារូបភាពនៃអំពើហិង្សាដ៏ធ្ងន់ធ្ងរបំផុត គឺជាទង្វើខុសច្បាប់។[១១៩]

- ជាង ៩៧% នៃអាជ្ញាធរមូលដ្ឋាន និងប៉ូលីស បានដឹងថារូបភាពនៃអំពើហិង្សាដ៏ធ្ងន់ធ្ងរបំផុត (ដូចជាការជះទឹកអាស៊ីត ការបាញ់សំលាប់ និងការចាក់សំលាប់ ឬការដុតសំលាប់ ឬការច្របាច់ក) គឺជាទង្វើខុសច្បាប់ បើធៀបនឹងក្រុមអ្នកផ្តល់ចំលើយទូទៅ គឺមានជាង៩៥%។
- ដូចគ្នានឹងក្រុមអ្នកផ្តល់ចំលើយទូទៅដែរ អាជ្ញាធរមូលដ្ឋាន និងប៉ូលីសភាគច្រើនបានដឹងថា ការរំលោភសេពសន្ថវៈជាបទឧក្រិដ្ឋ។ អាជ្ញាធរថ្នាក់ស្រុកទាំងអស់ បានដឹងថាការរំលោភសេពសន្ថវៈគឺជាបទឧក្រិដ្ឋ បន្ទាប់មកមាននាយប៉ូលីសជាន់ខ្ពស់ចំនួន ៩៧% ហើយទាំងអាជ្ញាធរឃុំ-សង្កាត់ និងមន្ត្រីប៉ូលីសថ្នាក់ទាបមានចំនួន ៩៦% បើធៀបនឹងក្រុមអ្នកផ្តល់ចំលើយទូទៅមាន ៩៤% ។

[១១៨] សូមមើលតារាងទី ៦៧ ក្នុងឧបសម្ព័ន្ធ A

[១១៩] សូមមើលតារាងទី ៦៨ ក្នុងឧបសម្ព័ន្ធ A

ការអង្កេតនេះ បានសួរអាជ្ញាធរមូលដ្ឋាន និងប៉ូលីស អំពីឥរិយាបថរបស់ពួកគេចំពោះការផ្ដន្ទាទោសអំពើរំលោភសេពសន្ថវៈ។ មន្ត្រីទាំងនេះបានឯកភាពស្ទើរតែទាំងស្រុងចំពោះការផ្ដន្ទាទោសយ៉ាងធ្ងន់ធ្ងរចំពោះអ្នកដែលបានរំលោភសេពសន្ថវៈក្មេងស្រីអាយុក្រោម ១៥ឆ្នាំ។ ប៉ុន្តែពួកគេបានឆ្លើយខុសគ្នាពីក្រុមអ្នកផ្ដល់ចំលើយទូទៅ ចំពោះឥរិយាបថរបស់ពួកគេអំពីការផ្ដន្ទាទោស ចំពោះអ្នកដែលបានរំលោភសេពសន្ថវៈស្ត្រីរកស៊ីផ្លូវភេទ។ អាជ្ញាធរមូលដ្ឋាន និងប៉ូលីសចំនួន ៤០% បាននិយាយថាអ្នកដែលបានរំលោភសេពសន្ថវៈស្ត្រីរកស៊ីផ្លូវភេទ គួរត្រូវបានផ្ដន្ទាទោសឱ្យបានធ្ងន់ធ្ងរជាងជនល្មើសផ្សេងៗទៀត។ ក្នុងករណីនេះចំនួនសមាមាត្ររបស់អាជ្ញាធរមូលដ្ឋាន គឺមានចំនួនដូចគ្នាទៅនឹងចំនួនបុរសនៅក្នុងក្រុមអ្នកផ្ដល់ចំលើយទូទៅដែលបានគាំទ្រយុទ្ធវិធីនេះ។ អាជ្ញាធរមូលដ្ឋាន និងប៉ូលីសមានចំនួនខុសគ្នាពីក្រុមអ្នកផ្ដល់ចំលើយទូទៅ ពីព្រោះមានតែ ១៥% តែប៉ុណ្ណោះបាននិយាយថាអ្នកដែលបានរំលោភសេពសន្ថវៈស្ត្រីរកស៊ីផ្លូវភេទ គួរត្រូវបានផ្ដន្ទាទោសស្រាល បើប្រៀបធៀបនឹងក្រុមអ្នកផ្ដល់ចំលើយទូទៅ គឺបុរសមាន ២៤% និងស្ត្រីមាន២៩%។

អាជ្ញាធរមូលដ្ឋាន និងប៉ូលីស មានការយល់ដឹងប្រហាក់ប្រហែលគ្នានឹងក្រុមអ្នកផ្ដល់ចំលើយផងដែរអំពីស្ថានភាពផ្លូវច្បាប់ចំពោះករណីរំលោភសេពសន្ថវៈក្នុងចំណងអាពាហ៍ពិពាហ៍។ដោយពុំគិតអំពីច្បាប់ អាជ្ញាធរមូលដ្ឋាន និងប៉ូលីស ក៏ច្រើនតែនិយាយថាប្ដីពុំមានសិទ្ធិបង្ខំប្រពន្ធដើម្បីរួមភេទឡើយ។ ប្រមាណ៩៥% នៃមន្ត្រីទាំងនេះបាននិយាយថា ប្ដីពុំមានសិទ្ធិធ្វើបែបនេះឡើយ បើធៀបនឹងក្រុមអ្នកផ្ដល់ចំលើយទូទៅមានចំនួន ៧៩%។

## ២.៥.៤ ឥរិយាបថរបស់អាជ្ញាធរមូលដ្ឋាន និងប៉ូលីចំពោះការខឹងរបស់បុរស

អាជ្ញាធរមូលដ្ឋាន និងប៉ូលីស ក៏មានឥរិយាបថយល់ស្របជាមួយប្រជាពលរដ្ឋទូទៅផងដែរចំពោះការខឹងរបស់បុរស ដែលជារូបភាពមួយនៃការរំលោភបំពានផ្លូវចិត្ត។ ការឱ្យហេតុផលរបស់អាជ្ញាធរមូលដ្ឋាន និងប៉ូលីស ចំពោះការខឹងរបស់ប្ដីទៅលើប្រពន្ធ គឺប្រហាក់ប្រហែលគ្នានឹងក្រុមអ្នកផ្ដល់ចំលើយទូទៅដែរ។ ឧទាហរណ៍ ជាទូទៅ អាជ្ញាធរមូលដ្ឋាន និងប៉ូលីស បានឯកភាពជាមួយក្រុមអ្នកផ្ដល់ចំលើយទូទៅថា ប្ដីមានហេតុផលនៅក្នុងការខឹងជាមួយប្រពន្ធនៅពេលប្រពន្ធពុំបានយកចិត្តទុកដាក់ថែទាំងកូន ឬពុំបានរៀបចំផ្ទះសំបែងឱ្យបានស្អាត។

## ២.៥.៥ ទស្សនៈរបស់អាជ្ញាធរមូលដ្ឋាន និងប៉ូលីសចំពោះឥទ្ធិពលនៃវប្បធម៌ទៅលើបុរស

អាជ្ញាធរមូលដ្ឋាន និងប៉ូលីស មានទស្សនៈខុសគ្នាពីអ្នកផ្ដល់ចំលើយទូទៅចំពោះឥទ្ធិពលនៃវប្បធម៌ទៅលើឥរិយាបថរបស់បុរសធ្វើទៅលើស្ត្រី។ ពួកគេច្រើនលើកឡើងអំពីមិត្តភក្តិ ដែលជាបុរស (សម្ពាធពីមិត្តភក្តិ) ។ដូចដែលបានបង្ហាញក្នុងតារាងទី២៩ខាងក្រោម គឺចំនួនស្ទើរតែ៣ភាគ៤ នៃមន្ត្រីទាំងនេះបានលើកឡើងអំពីឥទ្ធិពលនេះ បើធៀបនឹងក្រុមអ្នកផ្ដល់ចំលើយទូទៅ មានបុរសចំនួន ៥៦% និងស្ត្រីចំនួន ៥៩%។ បើទោះបីជានេះជាតួនាទីវិជ្ជាជីវៈរបស់ពួកគេក្ដី ក៏មន្ត្រីទាំងនេះច្រើនតែ

លើកឡើងនូវភាពខ្វះខាតក្នុងការអនុវត្តន៍ច្បាប់។ មន្ត្រីមូលដ្ឋាន និងប៉ូលីស ពុំសូវលើកឡើងអំពីប្រព័ន្ធផ្សព្វផ្សាយព័ត៌មានដូចក្រុមអ្នកផ្តល់ចំលើយទូទៅនោះទេ ហើយច្រើនតែលើកឡើងអំពីឥទ្ធិពលនៃគ្រួសារ និងប្រពៃណីខ្មែរ។




**តារាងទី ២៩**
**សំណួរទី ១៨ a**
*តើកត្តាខាងលើនេះ មានឥទ្ធិពលលើការប្រព្រឹត្តិរបស់បុរសទៅលើស្ត្រីដែរឬទេ?*
*(N= 301)*

### ២.៥.៦ បទពិសោធន៍របស់អាជ្ញាធរមូលដ្ឋាន និងប៉ូលីស ចំពោះករណីអំពើហិង្សាក្នុងគ្រួសារ

អាជ្ញាធរមូលដ្ឋាន និងប៉ូលីស បានរាយការណ៍អំពីបទពិសោធន៍របស់ពួកគេ ចំពោះករណីអំពើហិង្សាក្នុងគ្រួសារ ក្នុងកំរិតខុសៗគ្នា អាស្រ័យទៅលើតួនាទីការងាររបស់ពួកគេ។ ជាទូទៅអាជ្ញាធរស្រុកបានរាយការណ៍ថាពួកគេទទួលបានពាក្យបណ្តឹងតិចជាងមន្ត្រីថ្នាក់ភូមិ ឬឃុំ-សង្កាត់។ ភាគច្រើននៃអ្នកដែលបាននិយាយថា ពួកគេបានទទួលពាក្យបណ្តឹងពីស្ត្រីដែលប្តីរបស់នាងបានវាយដំខ្លួនបាននិយាយថា ពួកគេបានទទួលពាក្យបណ្តឹងបែបនេះចំនួនពី ២ ទៅ ៤ ដង កាលពីឆ្នាំមុនដូចបានបង្ហាញក្នុងតារាងទី ៣០ ខាងក្រោម។ ចំនួនតិចជាង ១ ភាគ ៣ នៃមន្ត្រីទាំងនេះបាននិយាយថាពួកគេបានទទួលពាក្យបណ្តឹងពី ៣ ទៅ ៥ ករណីនៅក្នុងរយៈពេលនេះ។ ចំនួន ១ ភាគ ៣

ទៀតបានទទួលពាក្យបណ្ដឹងប្រាំករណី ឬច្រើនជាងនេះ។ ការប្ដឹងផ្ដល់អំពីការវាយដំពីសំណាក់សមាជិកគ្រួសារដទៃទៀតមានចំនួនតិចតួចជាងនេះ។ ទាក់ទងទៅនឹងអំពើរំលោភសេពសន្ថវៈ អាជ្ញាធរមូលដ្ឋាន និងប៉ូលីស ហាក់ដូចជារាយការណ៍ថា ពួកគេបានទទួលមួយពាក្យបណ្ដឹង កាលពីឆ្នាំមុន។ ប៉ុន្តែស្ទើរតែដូចគ្នានឹងមន្ត្រីជាច្រើនដែរ ក្រុមប៉ុលីសបានរាយការណ៍ថា ពួកគេបានទទួលពីរទៅបួនពាក្យបណ្ដឹង។ ក្រុមអ្នកផ្ដល់ចំលើយទូទៅចំនួន ២ ភាគ ៣ បាននិយាយថា ពួកគេបានទទួលមួយពាក្យបណ្ដឹងអំពើរំលោភសេពសន្ថវៈក្នុងចំណោមអាពាហ៍ពិពាហ៍កាលពីឆ្នាំមុន។ ចំនួន ២១% ទៀតបាននិយាយថា ពួកគេបានទទួលពីរទៅបួនពាក្យបណ្ដឹងបែបនេះ។




**តារាងទី ៣០**

**សំណួរទី ២៤**

*តើករណីចំនួនប៉ុន្មាន ដែលលោកអ្នក បានទទួលពីស្ត្រី នៅក្នុងរយៈពេល ១២ ខែចុងក្រោយនេះ?*

*(N = 301)*

អាជ្ញាធរមូលដ្ឋាន និងប៉ូលីស បានរាយការណ៍អំពីការអង្កេតរបស់ពួកគេលើលទ្ធផលនៃករណីរំលោភសេពសន្ថវៈ និងបានវាយតំលៃទៅលើភាពត្រឹមត្រូវនៃលទ្ធផលទាំងនេះ។ ដូចបានបង្ហាញក្នុងតារាងទី៣១ ខាងក្រោម អាជ្ញាធរមូលដ្ឋាន និងប៉ូលីស បានបង្ហាញនូវការគាំទ្រយ៉ាងខ្លាំងចំពោះការផ្តន្ទាទោសដាក់ពន្ធនាគារដល់អ្នករំលោភសេពសន្ថវៈ ក៏ដូចជាគាំទ្រឱ្យមានសំណងដល់ស្ត្រីរងគ្រោះ។ ការប្រៀបធៀបនេះបង្ហាញនូវគម្លាតដ៏ធំមួយ រវាងទស្សនៈរបស់អាជ្ញាធរអំពីវិធីដែលគួរត្រូវដោះស្រាយករណីទាំងនេះ និងដំណោះស្រាយជាក់ស្តែងរបស់ពួកគេ ជាពិសេសពាក់ព័ន្ធនឹងការផ្តន្ទាទោសដាក់ពន្ធនាគារអ្នករំលោភសេពសន្ថវៈ។

| | កើតឡើងញឹកញាប់/ ញឹកញាប់ណាស់ | យុត្តិធម៌/យុត្តិធម៌ណាស់ | |
|---|---|---|---|
| ស្ត្រីម្នាក់ត្រូវបានគេចាប់រំលោភ ហើយគ្មានបណ្តឹងណាត្រូវបានធ្វើឡើងទេ | ៦% | ៩% | ៣% |
| ស្ត្រីម្នាក់ត្រូវបានគេចាប់រំលោភ បានប្តឹង ហើយអ្នកចាប់រំលោភទទួលការព្រមាន | ១៨% | ៣០% | ១២% |
| ស្ត្រីម្នាក់ត្រូវបានចាប់រំលោភ បានប្តឹង ហើយអ្នកចាប់រំលោភបានសងជំងឺចិត្ត | ២៦% | ៥១5 | ២៥5 |
| ស្ត្រីម្នាក់ត្រូវបានចាប់រំលោភ បានប្តឹង ហើយអ្នកចាប់រំលោភត្រូវជាប់ពន្ធនាគារ | ៣១% | ៨៣% | ៥២% |




**តារាងទី ៣១**

**សំណួរទី ២៧ a, និង ២៧ b**

*តើករណីមួយណាខ្លះដែលកើតឡើងញឹកញាប់ ឬញឹកញាប់បំផុត (ក្នុងករណីរំលោភសេពសន្ថវៈ)?*

*តើអ្វីគួរតែកើតមាន (ក្នុងករណីរំលោភសេពសន្ថវៈ)?*

*(N = 301)*

អាជ្ញាធរមូលដ្ឋាន និងប៉ូលីស បាននិយាយថា ពួកគេមិនពេញចិត្តនឹងអំពើហិង្សាក្នុងគ្រួសារ និងស្ថានភាពនៃអំពើរំលោភសេពសន្ថវៈនៅក្នុងសហគមន៍របស់ពួកគេនោះទេ។ ដូចបានបង្ហាញក្នុងតារាងទី ៣២ ខាងក្រោម ក្រុមខុសគ្នាក្នុងចំណោមក្រុមអ្នកផ្តល់ចំលើយបានផ្តល់ការវាយតំលៃខុសៗគ្នា ដោយអាស្រ័យទៅលើតួនាទីការងារ។ ទាំងអាជ្ញាធរឃុំ-សង្កាត់ និងនាយប៉ូលីសជាន់ខ្ពស់បានបង្ហាញនូវការមិនពេញចិត្តច្រើនជាងក្រុមអ្នកផ្តល់ចំលើយទូទៅ ហើយមន្ត្រីប៉ូលីសថ្នាក់ទាប បានបង្ហាញថា ពួកគេមានការពេញចិត្តច្រើនជាង។ ករណីនេះ អាចបង្ហាញនូវអត្រាប្រេវ៉ាឡង់ខ្ពស់នៃករណីទាំងនេះ ឬភាពគ្មានអំណាចដែលបណ្តាលមកពីកង្វះធនធាន។




**តារាងទី ៣២**
**សំណួរទី ៣២ a**
*កំរិតនៃការវាយតំលៃរបស់អាជ្ញាធរមូលដ្ឋាន និងប៉ូលីស ទៅលើស្ថានភាពនៃអំពើហិង្សាក្នុងគ្រួសារនៅក្នុងស្រុក/ឃុំ-សង្កាត់របស់ពួកគេ (កំរិតមានចាប់ពីលេខ ១ = មិនពេញចិត្តទាល់តែសោះ ដល់លេខ ៧ = ពេញចិត្តខ្លាំងណាស់)*
*(N = 301)*

បើទោះបីជាពុំមានការពេញចិត្តបែបនេះក្តី អាជ្ញាធរមូលដ្ឋាន និងប៉ូលីស បាននិយាយថាពួកគេមានការព្រួយបារម្ភយ៉ាងខ្លាំងអំពីបញ្ហាច្បាប់ និងសណ្តាប់ធ្នាប់សង្គម ដូចដែលបានបង្ហាញនៅក្នុងចំលើយនៅក្នុងតារាងទី ៣៣ ខាងក្រោម។ ពួកគេបាននិយាយថាបញ្ហាច្បាប់ និងសណ្តាប់ធ្នាប់សង្គមដែលសំខាន់បំផុតនៅក្នុងប្រទេសកម្ពុជា គឺថ្នាំញៀន បន្ទាប់មក គឺឧក្រិដ្ឋកម្មដ៏ឃោរឃៅ។ អាជ្ញាធរមូលដ្ឋាន និងប៉ូលីសបានដាក់លំដាប់លេខរៀងចំពោះអំពើរំលោភសេពសន្ថវៈ និងអំពើហិង្សាក្នុងគ្រួសារ ថាពុំសូវសំខាន់ដូចបញ្ហាថ្នាំញៀន បទឧក្រិដ្ឋដ៏ឃោរឃៅអំពើពុករលួយ ឬក្រុមស្ទាវបងធំនោះទេ។ អាជ្ញាធរទាំងនេះបានផ្តល់អាទិភាពទាបចំពោះករណីអំពើហិង្សាក្នុងគ្រួសារ និងជំលោះដែលទាក់ទងនឹងអាពាហ៍ពិពាហ៍ ឬជីធ្លី។ ចំលើយនេះគឺសំដៅដល់ការដោះស្រាយតាមរយៈការពង្រឹងការអនុវត្តន៍ច្បាប់ព្រហ្មទណ្ឌ។ ការផ្តល់ចំលើយបែបនេះ ក៏អាចទាក់ទងទៅនឹងទស្សនៈនៃប្រពៃណីខ្មែរចំពោះអំពើហិង្សាក្នុងគ្រួសារដែលថាជាបញ្ហាក្នុងគ្រួសារ ពោលគឺពុំមែនជាបញ្ហាសង្គម ឬសហគមន៍នោះទេ។




**តារាងទី ៣៣**
**សំណួរទី ២២**

*ការផ្តល់ចំណាត់ថ្នាក់របស់អាជ្ញាធរមូលដ្ឋាន និងប៉ូលីស ទៅលើបញ្ហាច្បាប់ និងសណ្តាប់ធ្នាប់សង្គម ទៅតាមកំរិតពីលេខ ១ = មិនសំខាន់ទាល់តែសោះ ដល់ លេខ ៧ = សំខាន់ខ្លាំងណាស់ (N = 301)*

## សេចក្តីសន្និដ្ឋាន

អាជ្ញាធរមូលដ្ឋាន និងប៉ូលីសបានផ្តល់ចំលើយដូចគ្នាជាច្រើនជាមួយនឹងចំលើយរបស់អ្នកផ្តល់ចំលើយទូទៅ។ ហើយដោយសារអ្នកផ្តល់ចំលើយជាច្រើន បាននិយាយថាស្ត្រីត្រូវទៅរកមន្ត្រីទាំងនេះនៅពេលដែលពួកគេទទួលរងការរំលោភបំពាន នេះមានន័យថាស្ត្រី ជាញឹកញាប់ប្រឈមមុខនឹងឥរិយាបថដដែលៗអំពីអំពើហិង្សាក្នុងគ្រួសារ ដូចដែលពួកគេប្រឈមមុខនៅក្នុងគ្រួសាររបស់ខ្លួននៅក្នុងខណៈពេលដែលពួកគេ ស្វែងរកជំនួយ។

ករណីកើតឡើងញឹកញាប់បំផុត ដែលអាជ្ញាធរមូលដ្ឋាន និងប៉ូលីសបានជួបប្រទះ គឺអំពើហិង្សាផ្លូវកាយពីសំណាក់ប្តី និងការរំលោភសេពសន្ថវៈ ដែលស្របជាមួយនឹងការរកឃើញនៅក្នុងចំណោមអ្នកផ្តល់ចំលើយទូទៅក្នុងសំណួរដែលពាក់ព័ន្ធនឹងការស្វែងរកជំនួយ។ អាជ្ញាធរមូលដ្ឋាន និងប៉ូលីសបានរាយការណ៍ថា ខ្លួនមិនពុំពេញចិត្តទាល់តែសោះ ចំពោះស្ថានភាពនៅក្នុងតំបន់មូលដ្ឋានរបស់ខ្លួន។ ឧទាហរណ៍ ដូចជាករណីអំពើរំលោភសេពសន្ថវៈ ដែលនៅក្នុងករណីនេះមានគម្លាតគ្នាយ៉ាងធំរវាងអ្វីដែលបានកើតឡើងជាក់ស្តែង និងភាពត្រឹមត្រូវនៃលទ្ធផលសំរាប់ជនរងគ្រោះ។ ប៉ុន្តែ អំពើហិង្សាក្នុងគ្រួសារពុំត្រូវបានគេចាត់ទុកថា មានសរៈសំខាន់ ដូចបញ្ហាច្បាប់ និងសណ្តាប់ធ្នាប់សង្គមនោះទេ។

## អនុសាសន៍សំរាប់អាជ្ញាធរមូលដ្ឋាន និងប៉ូលីស

### ការបណ្តុះបណ្តាល និងការអប់រំ:

- បណ្តុះបណ្តាលមន្ត្រីឃុំ-សង្កាត់ និងប៉ូលីសអំពីបញ្ហាអំពើហិង្សាក្នុងគ្រួសារ ។ ការបណ្តុះបណ្តាលត្រូវបញ្ចូលនូវបញ្ហាមួយចំនួនដូចជា ការដោះស្រាយជំលោះ ការផ្តោតការយកចិត្តទុកដាក់ទៅលើដំណោះស្រាយដែលមានប្រសិទ្ធភាព (ការជជែកគ្នាដោយស្មៀមស្ងាត់ និងការពន្យល់អំពីហេតុផល) ការប្រឈមមុខជាមួយនឹងទស្សនៈអំពីការប្រើអំណាច និងការត្រួតត្រា ការពិនិត្យឡើងវិញលើរូបភាពនៃការសម្រុះសម្រួលគ្នា ការលើកទឹកចិត្តដល់រូបភាពជាគំរូវិជ្ជមាន និងព័ត៌មានស្តីពីការបញ្ជូនទៅកាន់សេវានានា ។
- បណ្តុះបណ្តាលអាជ្ញាធរមូលដ្ឋានអំពីកាតព្វកិច្ចថ្មីរបស់ពួកគេ ដែលមានចែងនៅក្នុងច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ។
- ពិនិត្យឡើងវិញលើគំរូនៃការសម្រុះសម្រួលគ្នា ( កំណត់និងរៀបចំឡើងវិញនូវវិធីសម្រុះសម្រួល ។

### ការផ្សព្វផ្សាយការយល់ដឹងជាសាធារណៈ:

- លើកទឹកចិត្តដល់ប៉ូលីសប្រុស និងមន្ត្រីដែលជាបុរសគំរូ ដោយផ្អែកលើការឱ្យតំលៃរបស់សង្គមបច្ចុប្បន្ននេះទៅលើបុគ្គលិកលក្ខណៈល្អសំរាប់បុរស និងក្រុមគ្រួសាររបស់ពួកគេ ។
- ពន្យល់អំពីឥទ្ធិពលនៃជាតិស្រវឹង ដែលនាំឱ្យមានអំពើហិង្សាក្នុងគ្រួសារ ។ លើកកំពស់ការទទួលខុសត្រូវនៅក្នុងការប្រើប្រាស់ជាតិស្រវឹង ។
- ផ្តល់ការប្រកួតប្រជែងក្នុងចំណោមក្រុមប្រឹក្សាឃុំ-សង្កាត់ ដើម្បីលើកកំពស់ និងអនុវត្តការរកដំណោះស្រាយប្រកបដោយការច្នៃប្រឌិតខ្ពស់ ចំពោះអំពើហិង្សាក្នុងគ្រួសារ ។

### ការរៀបចំគោលនយោបាយ និងសកម្មភាព:

- នាំយកមធ្យោបាយដោះស្រាយតាមផ្លូវតុលាការ (ឧ- ដីកាការពារ និងការលែងលះគ្នា) ឱ្យកាន់តែខិតជិតដល់ប្រជាពលរដ្ឋខ្មែរគ្រប់រូបនៅតាមភូមិសាស្ត្រនានា ។
- សង្គមស៊ីវិល និងមន្ត្រីរដ្ឋាភិបាល ត្រូវសហការគ្នាដើម្បីគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងរបស់រដ្ឋាភិបាលនៅក្នុងការអនុវត្តន៍ច្បាប់ ។
- ការតាមដានត្រួតពិនិត្យ និងការវាយតំលៃ: អ្នកផ្តល់ជំនួយ ត្រូវជំរុញឱ្យមានរបាយការណ៍ស្តីពីផលប៉ះពាល់នៃកម្មវិធីរបស់ខ្លួន ហើយផ្សព្វផ្សាយលទ្ធផលសំរេចបាន និងការអនុវត្តន៍ល្អបំផុត ។

### ការផ្តល់សេវា:

- ដាក់បញ្ចូលសេវាសង្គមកិច្ច នៅក្នុងការធ្វើផែនការឃុំ-សង្កាត់ និងដំណើរការវិភាជថវិកា ។

## ២.៦ ប្រជាពលរដ្ឋកម្ពុជា និងសិទ្ធិរបស់ពួកគេ

ឥរិយាបថ និងអាកប្បកិរិយាជុំវិញអំពើហិង្សាក្នុងគ្រួសារ ពុំបានកើតមានឡើងដោយឯកឯងនោះទេ។ ភាពអត់ធ្មត់ចំពោះអំពើហិង្សាក្នុងគ្រួសារ និងការសំរេចចិត្តក្នុងការស្វែងរកជំនួយគឺកើតឡើងពីទស្សនៈជាមូលដ្ឋានរបស់មនុស្សអំពីសិទ្ធិរបស់ខ្លួននៅក្នុងសង្គម និងទស្សនៈរបស់ពួកគេ អំពីការការពារសិទ្ធិទាំងនោះ។ អាស្រ័យហេតុនេះ ការសិក្សានេះបានធ្វើការវិភាគយ៉ាងជ្រៅ ទៅដល់ក្នុងការយល់ដឹងជាមូលដ្ឋានគ្រឹះអំពីសិទ្ធិរបស់បុគ្គលម្នាក់ៗ និងវិធីការពារសិទ្ធិទាំងនេះ។

### ២.៦.១ សិទ្ធិមួយចំនួនដែលត្រូវបានគេចាត់ទុកថាជាសិទ្ធិសំខាន់ចំពោះប្រជាពលរដ្ឋកម្ពុជា

នៅពេលដែលការអង្កេតនេះ បានសុំឱ្យអ្នកផ្តល់ចំលើយកំណត់យកសិទ្ធិ ដែលសំខាន់បំផុតជាពលរដ្ឋ[១២០] ពេលនោះចំនួនភាគច្រើននៃក្រុមអ្នកផ្តល់ចំលើយ បានកំណត់យកសិទ្ធិក្នុងការរស់នៅ និងសិទ្ធិរស់រានដូចដែលបានបញ្ជាក់នៅក្នុងតារាងទី ៣៤ ខាងក្រោម។




**តារាងទី ៣៤**
សំណួរទី ៤០ a
*សិទ្ធិដែលបានកំណត់យកដោយអ្នកផ្តល់ចំលើយក្នុងសំណួរអំពីសិទ្ធិជាពលរដ្ឋកម្ពុជា*
*(N = 3030)*

១២០ អ្នកផ្តល់ចំលើយ បានផ្តល់នូវចំលើយភ្លាមៗដោយពុំបានគ្រោងទុកចំពោះសំណួរដែលសុំឱ្យពួកគេកំណត់យកនូវសិទ្ធិ ដែលសំ ខាន់បំផុតជាពលរដ្ឋ។ ដូច្នេះចំលើយទាំងនេះបានឆ្លុះបញ្ចាំងនូវកំរិតយល់ដឹងអំពីសិទ្ធិរបស់ពួកគេក្នុងចំណោមអ្នកផ្តល់ចំលើយ និងឆ្លុះបញ្ចាំងនូវសិទ្ធិដែលសំខាន់បំផុតសំរាប់ជាអាទិភាពផ្ទាល់របស់ពួកគេ។

សិទ្ធិនេះ អាចជាការឆ្លុះបញ្ចាំងអំពីជំនឿខាងពុទ្ធសាសនា។ បុរសបានលើកឡើងអំពីសិទ្ធិច្រើនជាងស្ត្រី។ ប៉ុន្តែស្ត្រីច្រើនជាងបុរស បានលើកឡើងអំពីសិទ្ធិការពារខ្លួន សមភាព និងកម្មសិទ្ធិ។ អ្នកដែលរកប្រាក់ចំណូលតិចជាង ២០ដុល្លា ក្នុងមួយខែ បានលើកឡើងញឹកញាប់ជាងក្រុមដទៃទៀតអំពីសិទ្ធិទទួលបានការងារធ្វើ សិទ្ធិការពារខ្លួន និងសមភាព។

អ្នកផ្តល់ចំលើយមានចំនួនតិចតួចបំផុត ដែលបានលើកឡើងអំពីសិទ្ធិ ដែលអាចជួយទប់ស្កាត់អំពើហិង្សាប្រឆាំងនឹងស្ត្រី។ ឧទាហរណ៍ សិទ្ធិទទួលបានសមភាពត្រូវបានលើកឡើងដោយបុរសចំនួន ១៧% និងស្ត្រី ១៩%។ សិទ្ធិទទួលបានការសិក្សាអប់រំ ត្រូវបានលើកឡើងដោយបុរសចំនួន ១៧% និងស្ត្រី ១៣%។ សិទ្ធិរៀបការ ឬសិទ្ធិជ្រើសរើសគូស្រករ ត្រូវបានលើកឡើងដោយបុរសចំនួន ១៦% និងស្ត្រី ១៣%។

វិធីសាមញ្ញបំផុតសំរាប់ឱ្យប្រជាពលរដ្ឋ បានយល់ដឹងអំពីសិទ្ធិរបស់ខ្លួន គឺតាមរយៈប្រព័ន្ធផ្សព្វផ្សាយព័ត៌មានការអប់រំ និងអាជ្ញាធរឃុំ-សង្កាត់។

- បុរសចំនួន ៩៣% និងស្ត្រីចំនួន ៧៨% បានលើកឡើងអំពីប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន។
- បុរសចំនួន ៧៦% និងស្ត្រីចំនួន ៥១% បានលើកឡើងអំពីការអប់រំ ដែលឆ្លុះបញ្ចាំងអំពីគម្លាតយេនឌ័រនៅក្នុងការិតសិក្សា។
- តែចំនួនតែ ៣% ទៅ៤% តែប៉ុណ្ណោះ បានយល់ដឹងអំពីសិទ្ធិរបស់ខ្លួនពីតុលាការ ឬមេធាវី។

### ២.៦.២ ទស្សនៈវិស័យស្តីអំពីវិសមភាព

សមាមាត្រដ៏សំខាន់មួយនៃអ្នកផ្តល់ចំលើយ បានរាយការណ៍ថាមានវិសមភាពនៅក្នុងសង្គមខ្មែរ។ អ្នកផ្តល់ចំលើយចំនួន ២៦% បាននិយាយថាអ្នកខ្លះ មានសិទ្ធិច្រើនជាងអ្នកខ្លះទៀត។[១២១] ស្ត្រី និងអ្នកដែលមានប្រាក់ចំណូលខ្ពស់បានផ្តល់ចំលើយដូចខាងលើនេះ ដែលចំលើយនេះបានបង្កើតនូវសំណួរអំពីបទពិសោធន៍ផ្ទាល់របស់ខ្លួនរបស់ពួកគេ។ភាគច្រើននៃអ្នកដែលបានរាយការណ៍អំពីវិសមភាពនេះ បាននិយាយថា អាជ្ញាធរមូលដ្ឋានមានសិទ្ធិច្រើនជាងប្រជាជនដទៃទៀត។ អ្នកផ្សេងទៀតបាននិយាយថា អ្នកដែលមាន "ទ្រព្យសម្បត្តិ និងអំណាច" មានសិទ្ធិច្រើនជាងគេ បើតាមការរាយការណ៍ពីបុរសចំនួន ៤៨% និង ស្ត្រីចំនួន ៣១%។

អ្នកផ្តល់ចំលើយជាច្រើនក៏បាននិយាយថា បុរសមានសិទ្ធិខុសពីស្ត្រី ដូចដែលបានបង្ហាញក្នុងតារាងទី ៣៥ និង៣៦ ខាងក្រោម។ ស្ត្រីមានចំនួនច្រើនជាងបុរសជិតបីដង បានផ្តល់ចំលើយដូចខាងលើនេះ។ អ្នកដែលមានប្រាក់ចំណូលខ្ពស់បំផុត (២០០ដុល្លា ឡើងទៅ ក្នុងមួយខែ) គឺជាក្រុមដែលបានលើកឡើងច្រើនបំផុតនូវភាពខុសគ្នានេះ។ ច្បាស់លាស់ជាងនេះទៅទៀត គឺមានស្ត្រីចំនួន ៥២% និងបុរសចំនួន ៤៤% បាននិយាយថា បុរសមានសិទ្ធិធ្វើជាមេគ្រួសារ។ ស្ត្រីចំនួន ១ ភាគ ៣ និងបុរសចំនួន ២៣% បាននិយាយថា បុរសអាចធ្វើដំណើរឆ្ងាយពីផ្ទះបាន។

---

១២១ ភាគរយនៃអ្នកផ្តល់ចំលើយ ដែលបានឆ្លើយ "ចាស/បាទ" នៅក្នុងសំណួរ: តើមានមនុស្សខ្លះ មានសិទ្ធិច្រើនជាងមនុស្សដទៃទៀតដែរឬទេ?




**តារាងទី ៣៥**

**សំណួរទី ៤០ e**

*ភាគរយនៃអ្នកផ្ដល់ចំលើយដែលបានឆ្លើយ ចាស់/បាទ ចំពោះសំណួរៈ តើបុរសមានសិទ្ធិផ្សេងពីស្ត្រីដែរឬទេ?*

*(N = 3030)*




**តារាងទី ៣៦**

**សំណួរទី ៤០ f**

*តើសិទ្ធិទាំងនេះមានអ្វីខ្លះ?*

*(N = 3030)*

### ២.៦.៣ ការស្វែងរកជំនួយ ដើម្បីការពារសិទ្ធិ

អ្នកផ្តល់ចំលើយភាគច្រើន បាននិយាយថា ពួកគេមានវិធីទទួលបានជំនួយដើម្បីអនុវត្តសិទ្ធិរបស់ពួកគេ។[១២២] មានការយល់ស្របគ្នាជាទូទៅថារដ្ឋាភិបាល មានកាតព្វកិច្ចការពារសិទ្ធិរបស់ប្រជាពលរដ្ឋ។ មានចំនួនស្ទើរតែ ៣ ភាគ ៤ នៃក្រុមអ្នកផ្តល់ចំលើយ និងស្ត្រីជាងពាក់កណ្តាលបាននិយាយថារដ្ឋាភិបាលត្រូវតែមានកាតព្វកិច្ចនេះ។ ជាង ៣ ភាគ ៤ នៃក្រុមអ្នកផ្តល់ចំលើយ ក៏បាននិយាយថារដ្ឋាភិបាលត្រូវបំពេញកាតព្វកិច្ចនេះដើម្បីការពារសិទ្ធិរបស់ប្រជាជន។ មានចំនួនសមាមាត្រខ្ពស់នៃប្រជាពលរដ្ឋក្រីក្របាននិយាយថាពួកគេ គិតថារដ្ឋាភិបាលបានការពារសិទ្ធិរបស់ពួកគេ។




**តារាងទី ៣៧**
**សំណួរទី ៤១ b**
*តើមាននរណាម្នាក់នៅក្នុងសហគមន៍របស់អ្នកអាចជួយអ្នកអោយទទួលបានសិទ្ធិរបស់អ្នក?*
*(N = 3030)*

---

១២២ លទ្ធផលពុំបានបញ្ជាក់ច្បាស់លាស់ថា តើសិទ្ធិណាមួយដែលត្រូវគេរំលោភបំពានបផុតនោះទេ ដូចច្នេះចាំបាច់ត្រូវការការសិក្សាស្រាវជ្រាវបន្ថែមទៀត។

ដូចបានបញ្ជាក់នៅក្នុងតារាងទី ៣៧ អ្នកផ្តល់ចំលើយភាគច្រើន បាននិយាយថាអាជ្ញាធរឃុំ-សង្កាត់ និងប៉ូលីស បានជួយពួកគេដើម្បីមានលទ្ធភាពក្នុងការអនុវត្តន៍សិទ្ធិរបស់ពួកគេ។ ការឆ្លើយបែបនេះ គឺដោយសារតែអាជ្ញាធរទាំងនេះមាននៅគ្រប់ទីកន្លែងទាំងអស់នៅក្នុងសង្គមខ្មែរ គឺពុំដូចជាអង្គការក្រៅរដ្ឋាភិបាល តុលាការ និងមេធាវីនោះទេ។ ស្ត្រី និងអ្នកដែលមានប្រាក់ចំណូល ២០០ ដុល្លា ឬច្រើនជាងនេះក្នុងមួយខែ មានជំនឿតិចតួចជាងក្រុមដទៃទៀត ចំពោះក្រុមប្រឹក្សាឃុំ-សង្កាត់ និងប៉ូលីស។ បុរស និងអ្នកដែលមានប្រាក់ចំណូលខ្ពស់បំផុត មានជំនឿទៅលើអង្គការក្រៅរដ្ឋាភិបាល ហើយអ្នកដែលមានប្រាក់ចំណូលតិចជាង ២០ ដុល្លា មានជំនឿតិចបំផុតទៅលើអង្គការក្រៅរដ្ឋាភិបាល។

## ២.៦.៤ សិទ្ធិកាន់កាប់ដីធ្លី

បញ្ហាដីធ្លី គឺជាអាទិភាពដ៏សំខាន់សំរាប់រដ្ឋាភិបាល និងពលរដ្ឋខ្មែរ ហើយបញ្ហាទាក់ទងនឹងកម្មសិទ្ធិដីធ្លី និងជំលោះដីធ្លីជាច្រើន ត្រូវបានរៀបចំទុកជាឯកសារយ៉ាងត្រឹមត្រូវ។ នៅក្នុងការអង្កេតនេះចំនួនភាគច្រើនបំផុតនៃក្រុមអ្នកផ្តល់ចំលើយ (៩០%) បាននិយាថា ពួកគេមានកម្មសិទ្ធិដីធ្លី ឬផ្ទះ ដែលមានន័យថា សិទ្ធិកាន់កាប់ដីធ្លីរបស់ពួកគេ គឺជាកង្វល់ដ៏ចំបងសំរាប់ពួកគេ។ អ្នកផ្តល់ចំលើយជាច្រើន (៤២%) បាននិយាយថាពួកគេមានប័ណ្ណកម្មសិទ្ធិសំរាប់ទ្រព្យសម្បត្តិរបស់ពួកគេ។ មានចំនួនស្ទើរតែទាំងអស់នៃអ្នកផ្តល់ចំលើយ បាននិយាយថាពួកគេមានអារម្មណ៍កក់ក្តៅចំពោះសិទ្ធិរបស់ពួកគេ ក្នុងការថែរក្សា និងគ្រប់គ្រងដីធ្លីរបស់ខ្លួន។

អ្នកផ្តល់ចំលើយភាគច្រើន ស្ទើរតែ ៣ ភាគ ៤ (នៃក្រុមអ្នកផ្តល់ចំលើយ) បាននិយាយថាពួកគេអាចការពារសិទ្ធិកាន់កាប់ដីធ្លីបាន បើមានប័ណ្ណកម្មសិទ្ធិដីធ្លី ទោះបីជាញឹកញាប់ ការអនុវត្តន៍ពុំទាន់មានប្រសិទ្ធភាពក៏ដោយ។ អ្នកផ្តល់ចំលើយតិចតួចបំផុតបាននិយាយថា ពួកគេអាចការពារសិទ្ធិកាន់កាប់ដីធ្លីបាន ប្រសិនបើមានសាក្សី ឬតាមរយៈនៃការចុះបញ្ជីនៅគណៈកម្មការសុរិយោដីថ្នាក់មូលដ្ឋាន។ ចំលើយទាំងនេះ គឺគួរឱ្យចាប់អារម្មណ៍ ព្រោះទាក់ទងទៅនឹងការពិតដែលថា ប័ណ្ណទទួលស្គាល់កម្មសិទ្ធិដីធ្លីដែលមានសុពលភាពចំនួនតិចតួចប៉ុណ្ណោះ ត្រូវបានគេចេញឱ្យប្រើ។

## ២.៦.៥ ទស្សនៈរបស់អាជ្ញាធរមូលដ្ឋាន និងប៉ូលីស ចំពោះសិទ្ធិរបស់បុគ្គលម្នាក់ៗ

ឥរិយាបថ និងបទពិសោធន៍របស់អាជ្ញាធរមូលដ្ឋាន និងប៉ូលីស គឺពាក់ព័ន្ធទៅនឹងទស្សនៈរបស់ពួកគេអំពីសិទ្ធិរបស់ប្រជាពលរដ្ឋខ្មែរ និងតួនាទីរបស់ពួកគេក្នុងការការពារសិទ្ធិទាំងនេះ។ ក្រៅពី-បរិបទអំពើហិង្សាក្នុងគ្រួសារ មន្ត្រីទាំងនេះប្រកាន់ទស្សនៈរឹងមាំអំពីសិទ្ធិជាទូទៅ។ អាជ្ញាធរមូលដ្ឋាន និង ប៉ូលីស បាននិយាយដូចគ្នានឹងក្រុមអ្នកផ្តល់ចំលើយថា សិទ្ធិមានសារៈសំខាន់បំផុតចំពោះប្រជាពលរដ្ឋខ្មែរនិងមានអាទិភាពដូចគ្នា។[១២៣] ភាពខុសគ្នាខ្លាំងបំផុតរវាងក្រុមទាំងពីរនេះគឺថាមន្ត្រីទាំងនេះច្រើនតែបានលើកឡើងនូវសិទ្ធិក្នុងការនិយាយស្តីដោយសេរី។ សិទ្ធិនេះត្រូវបានលើកឡើងដោយមន្ត្រី

១២៣ សូមមើលតារាងទី ៦៩ ក្នុងឧបសម្ព័ន្ធ A

ទាំងនេះចំនួន ៦៩% បើធៀបនឹងក្រុមអ្នកផ្តល់ចំលើយទូទៅ គឺបុរសមាន ៥៥% និងស្ត្រីមាន ៤៧%។ មន្ត្រីទាំងនេះទំនងជានិយាយថា សិទ្ធិភាគច្រើនមានសារៈសំខាន់ ជាពិសេសសិទ្ធិរស់នៅ សិទ្ធិធ្វើដំណើរ សិទ្ធិធ្វើការងារ សិទ្ធិការពារខ្លួន សិទ្ធិបោះឆ្នោត និងសមភាព។

អាជ្ញាធរមូលដ្ឋាន និងប៉ូលីសមួយចំនួនតូចបាននិយាយថា អ្នកខ្លះមានសិទ្ធិតិចជាងអ្នកខ្លះទៀត។ បើទោះបីជាក្រុមអ្នកផ្តល់ចំលើយទូទៅចំនួន ២៦% បានលើកឡើងអំពីវិសមភាពនៃសិទ្ធិ ក៏ចំលើយរបស់អាជ្ញាធរមូលដ្ឋាន និងប៉ូលីសមានចំនួនចាប់ពី ៨% ក្នុងចំណោមនាយប៉ូលីសជាន់ខ្ពស់ ដល់ ២៣% ក្នុងចំណោមអាជ្ញាធរថ្នាក់ស្រុក។ អាជ្ញាធរមូលដ្ឋាន និងប៉ូលីសដែលបានមើលឃើញនូវវិសមភាពនេះបានឆ្លើយថា "អាជ្ញាធរមូលដ្ឋាន" ថាជាអ្នកមានសិទ្ធិច្រើនជាង (៥១%)។ ប៉ុន្តែពួកគេហាក់ដូចជាពុំបាននិយាយដូចនេះ ច្រើនដូចក្រុមអ្នកផ្តល់ចំលើយទូទៅនោះទេ ពោលគឺអ្នកដែលបាននិយាយដូចនេះ នៅក្នុងក្រុមអ្នកផ្តល់ចំលើយទូទៅ មានបុរសចំនួន ៧៥% និងស្ត្រីចំនួន ៩៦% ។ចំនួន ៤៩% នៃមន្ត្រីទាំងនេះបាននិយាយថា "អ្នកមាន និងអ្នកមានអំណាច" មានសិទ្ធិច្រើនជាងគេ បើធៀបនឹងក្រុមអ្នកផ្តល់ចំលើយទូទៅ គឺបុរសមានចំនួន ៤៨% និងស្ត្រីមានចំនួន ៣១%។ ចំនួនភាគច្រើន (៨៣%) នៃមន្ត្រីទាំងនេះបាននិយាយថាបុរស និងស្ត្រីមានសិទ្ធិដូចគ្នា បើធៀបនឹងក្រុមអ្នកផ្តល់ចំលើយទូទៅ គឺបុរសមានចំនួន ៩៣% និងស្ត្រីមានចំនួន ៨០%។ មន្ត្រីទាំងនេះក៏បាននិយាយថា រដ្ឋាភិបាលមានកាតព្វកិច្ចការពារសិទ្ធិរបស់ប្រជាពលរដ្ឋ។

## សេចក្តីសន្និដ្ឋាន

អ្នកផ្តល់ចំលើយភាគច្រើនពុំបានយល់ដឹងអំពីសិទ្ធិទូទៅភាគច្រើនបំផុតនោះទេ។ ស្ត្រីមានចំនួនច្រើនជាងបុរសបានលើកឡើងអំពីសិទ្ធិការពារខ្លួន សមភាព និងសិទ្ធិកាន់កាប់ដីធ្លី។ ស្ត្រីមានចំនួនច្រើនជាងពីរដងបានគិតថា បុរសមានសិទ្ធិខុសពីខ្លួន ដូចជាតំណែងរបស់បុរសនៅក្នុងគ្រួសារ បុរសមានសេរីភាព និងស្វ័យតភាពច្រើនជាង។ ចំណុចនេះស្របទៅនឹងលទ្ធផលរកឃើញផ្សេងៗទៀតនៅក្នុងការសិក្សាស្រាវជ្រាវនេះ។

នៅក្នុងបរិបទដ៏ធំមួយ ចំនួន ៣ ភាគ ៤ នៃក្រុមអ្នកផ្តល់ចំលើយបាននិយាយថា រដ្ឋាភិបាលត្រូវការពារសិទ្ធិរបស់ពួកគេ។ ពាក់ព័ន្ធទៅនឹងសំណូមពរសុំឱ្យជួយការពារសិទ្ធិរបស់ពួកគេ អាជ្ញាធរឃុំ -សង្កាត់ គឺជាប្រភពជំនួយដ៏ចំបងបន្ទាប់ពីប៉ូលីស។ ជាថ្មីម្តងទៀតមានអ្នកផ្តល់ចំលើយមួយចំនួនប៉ុណ្ណោះបាននិយាយថា ពួកគេបានទៅរកអង្គការក្រៅរដ្ឋាភិបាលឱ្យជួយ។ មនុស្សភាគច្រើនហាក់ដូចជាមានជំនឿថាប័ណ្ណកម្មសិទ្ធិដីធ្លី នឹងជួយដល់ពួកគេដើម្បីការពារសិទ្ធិកាន់កាប់ទ្រព្យសម្បត្តិរបស់ខ្លួន បើទោះបីជាញើកញាប់ការអនុវត្តន៍ពុំទាន់មានប្រសិទ្ធភាពក៏ដោយ។

ការធ្វើតេស្តសាកល្បងលើបញ្ហាទាំងនេះ តាមរយៈស្ថិតិពុំបានបង្ហាញនូវភាពពាក់ព័ន្ធគ្នាទៅវិញទៅមកជានិរន្តរ៍ ឬសំខាន់រវាងការយល់ឃើញរបស់អ្នកផ្តល់ចំលើយ អំពីសិទ្ធិរបស់ពួកគេ និងចំណេះដឹងរបស់ពួកគេលើបញ្ហាអំពើហិង្សាក្នុងគ្រួសារនោះទេ។

## ៣. សេចក្តីសន្និដ្ឋាន

ការស្រាវជ្រាវនេះ បង្ហាញឱ្យឃើញថា ត្រូវតែពិនិត្យមើលរូបភាពនៃអំពើហិង្សាក្នុងគ្រួសារនៅក្នុងបរិបទដ៏ធំនៃសង្គមខ្មែរដែលមានការយល់ឃើញថាអំណាចនិងឋានៈតួនាទីបានកំណត់ទំនាក់ទំនងនៅក្នុងសង្គម ហើយវប្បធម៌និទ្ទណ្ឌភាពនៅតែមាន។ ប្រវត្តិឡង់នៃអំពើហិង្សាក្នុងគ្រួសារ មានការពាក់ព័ន្ធដោយផ្ទាល់ទៅនឹងប្រវត្តិឡង់នៃអំពើហិង្សាក្នុងសង្គមទូទៅ និងប្រវត្តិនៃអំពើហិង្សារបស់ប្រទេសកម្ពុជាក្នុងសម័យទំនើប។ អំពើហិង្សានៅក្នុងសង្គមខ្មែរបច្ចុប្បន្ននេះ ត្រូវបានគេចាត់ទុកថាជារឿងធម្មតាក្នុងការបញ្ចប់ជំលោះ។

ឥរិយាបថ និងប្រពៃណីខ្មែរ បានកំណត់តួនាទីយេនឌ័រជាក់លាក់ ហើយស្ត្រីមានការទទួលខុសត្រូវចំពោះការថែរក្សាភាពសុខដុមក្នុងគ្រួសារ ទោះក្នុងកាលៈទេសៈណាក៏ដោយ បើទោះបីជាត្រូវពលិកម្មខ្លួនក៏ដោយ។ បុរសត្រូវបានគេផ្តល់តួនាទីជាមេគ្រួសារ។ ក្រៅពីនៅក្នុងរង្វង់គ្រួសារ ស្ត្រីជាញឹកញាប់ពុំត្រូវបានគេលើកទឹកចិត្តឱ្យបន្តការសិក្សា ឬចូលរួមធ្វើសេចក្តីសំរេចក្នុងសហគមន៍នោះទេ។ ដូច្នេះស្ត្រីមានឱកាសតិចតួចនៅក្នុងការទទួលបានព័ត៌មានផ្សេងៗ ឬធ្វើការក្រៅពីតួនាទីយេនឌ័រតាមបែបប្រពៃណីរបស់ពួកគេ។

អំពើហិង្សាក្នុងគ្រួសារ នៅតែជាបញ្ហាដែលកើតមាននៅក្នុងប្រទេសកម្ពុជា។ នៅក្នុងការសិក្សាស្រាវជ្រាវនេះមានអ្នកផ្តល់ចំលើយប្រមាណ ៦៤% បានដឹង/ស្គាល់ប្តីដែលបានប្រើអំពើហិង្សាផ្លូវកាយទៅលើប្រពន្ធ។ លើសពីនេះអ្នកផ្តល់ចំលើយជាស្ត្រីចំនួន ២២,៥% ធ្លាប់បានទទួលរងគ្រោះដោយសារអំពើហិង្សាពីសំណាក់ប្តីរបស់ខ្លួន។ អ្នកផ្តល់ចំលើយចំនួនជាង ១ ភាគ ៤ បានដឹង/ស្គាល់អ្នកដែលត្រូវបានគេរំលោភសេពសន្ថវៈ ហើយតួលេខនេះអាចមានខ្ពស់ជាងនេះ (៤២%) នៅក្នុងចំណោមប្រជាពលរដ្ឋក្រីក្រ។ បើទោះបីជាមានការគាំទ្រយ៉ាងខ្លាំងឱ្យមានការផ្តន្ទាទោសដាក់ពន្ធនាគារក្តី ក៏ការទូទាត់សងជាប្រាក់ដល់ជនរងគ្រោះ ឬការរៀបការជនរងគ្រោះជាមួយអ្នករំលោភសេពសន្ថវៈ នៅតែត្រូវបានអ្នកផ្តល់ចំលើយភាគច្រើនបំផុតឆ្លើយថា ជាលទ្ធផលនៃការដោះស្រាយករណីរំលោភសេពសន្ថវៈនេះ។

អំពើហិង្សាប្រឆាំងនឹងស្ត្រី បង្ហាញឱ្យឃើញនូវឋានៈតួនាទីតូចទាបរបស់ស្ត្រីក្នុងសង្គមខ្មែរ។ តួនាទីតូចតាចនេះបានបង្ហាញយ៉ាងជាក់ស្តែងនៅក្នុងរង្វង់គ្រួសារ និងក្នុងទំនាក់ទំនងផ្លូវភេទ។ ស្ត្រីទទួលយកនូវអំពើហិង្សាពីដៃគូរបស់ខ្លួន ក្នុងសមាមាត្រមួយដ៏ខ្ពស់ជាងបុរស។ ស្ត្រីមានចំនួន ២៦% យល់ឃើញថា អំពើហិង្សាធ្ងន់ធ្ងរ (ដូចជាការដុតសំលាប់ការច្របាច់ក ឬការបាញ់សំលាប់) ពេលខ្លះអាចទទួលយកបាន ក្នុងករណីប្រពន្ធពុំគោរពប្តីរបស់ខ្លួន។ ស្ត្រីជាច្រើនក៏បាននិយាយថាពួកគេអាចកែប្រែឥរិយាបថហិង្សារបស់ប្តីបាន ដោយការបង្ហាញនូវការគោរព និងការស្តាប់ឱវាទ។ អ្នកផ្តល់ចំលើយមានចំនួន ៤៥% បាននិយាយថា ពួកគេមានការព្រួយបារម្ភចំពោះជីវិតកូនៗរបស់គាត់ ពីព្រោះតែអំពើហិង្សាក្នុងគ្រួសារ។ គួរភ្ញាក់ផ្អើលនោះ គឺថាអ្នកផ្តល់ចំលើយ មានចំនួនតិចជាងពាក់កណ្តាល

បាននិយាយ ថាប្ដីដែលបានឆ្លងមេរោគអេដស៍ គឺជាហេតុផលសមរម្យសំរាប់ប្រពន្ធធ្វើការបដិសេធពុំរួមភេទជាមួយ ។ ជាច្រើនជំនាន់មកហើយ ឥរិយាបថទាំងនេះ នៅតែពុំមានការផ្លាស់ប្ដូរ ហើយពុំបានបង្ហាញនូវសញ្ញាណាមួយថានឹងមានភាពល្អប្រសើរឡើងទៅអនាគតនោះទេ ។ យុវជនហាក់ដូចជាព្រមទទួលយកនូវរូបភាពខ្លះនៃអំពើហិង្សាជាពិសេសនៅក្នុងតំបន់ទីប្រជុំជន ។

តំណែរបស់គ្រួសារ ក៏បានដើរតួនាទីយ៉ាងសំខាន់នៅក្នុងការសិក្សាស្រាវជ្រាវនេះផងដែរ ។ ការស្រាវជ្រាវនេះបានរកឃើញថាអំពើហិង្សា និងការរំលោភបំពានដែលកើតមានឡើងនៅក្នុងរង្វង់គ្រួសារជាពិសេសរវាងប្ដី និងប្រពន្ធត្រូវបានគេចាត់ទុកថាខុសគ្នាពីការរំលាភបំពាននៅក្រៅរង្វង់គ្រួសារ ឧទាហរណ៍ដូចជាអំពើរំលោភសេពសន្ថវៈ ។ ការពន្យល់បកស្រាយមួយ ដែលអាចមាននោះគឺថា ការរៀបការត្រូវបានគេមើលឃើញថាជាកម្មសិទ្ធិមួយប្រភេទ ដែលបុរសមានសិទ្ធិទៅលើស្ត្រីដូចដែលលទ្ធផលនៃការស្រាវជ្រាវនេះបានបង្ហាញឱ្យឃើញថា ស្ត្រីគិតថាខ្លួនគ្មានហេតុផលក្នុងការបដិសេធចំពោះការរួមភេទជាមួយប្ដីឡើយ ។ អ្នកផ្ដល់ចំលើយបានផ្ដល់នូវភាពខុសគ្នាយ៉ាងច្បាស់រវាងការរំលោភសេពសន្ថវៈក្នុងចំណងអាពាហ៍ពិពាហ៍ និងអំពើរំលោភសេពសន្ថវៈក្រៅចំណងអាពាហ៍ពិពាហ៍ ។ ការរំលោភសេពសន្ថវៈដោយនរណាម្នាក់ ដែលនៅក្រៅអាពាហ៍ពិពាហ៍ត្រូវបានគេចាត់ទុកថាពុំអាចទទួលយកបាន មានភាពធ្ងន់ធ្ងរជាង និងទំនងជាតំរូវឱ្យមានការផ្ដន្ទាទោសច្រើនជាង ។

អាជ្ញាធរមូលដ្ឋាន និងប៉ូលីស មិនត្រឹមតែពុំបានអនុវត្តច្បាប់ ដែលមានស្រាប់ប្រឆាំងនឹងអំពើហិង្សានោះទេ[១២៤] ប៉ុន្តែថែមទាំងផ្ដល់ចំលើយក្នុងចំនួនប្រហាក់ប្រហែលនឹងក្រុមអ្នកផ្ដល់ចំលើយទូទៅផងដែរអំពីការទទួលយកនូវអំពើហិង្សាក្នុងគ្រួសារ ។ ដូច្នេះហើយ ពួកគេពុំបានផ្ដល់លទ្ធភាពផ្សេងទៀតចំពោះភាពលំអៀងខាងវប្បធម៌សង្គមដែលមានចំពោះស្ត្រីដែលត្រូវបានគេរំលោភបំពាននោះទេ ។ នៅក្នុងករណី ភាគច្រើននៃអំពើហិង្សា និងការរំលោភបំពានភាគីទាំងសងខាងត្រូវបានគេសម្រុះសម្រួលគ្នាឡើងវិញ ហើយមានអ្នកដែលស្វែងរកការលែងលះគ្នាជាច្រើន ពុំបានទទួលជោគជ័យឡើយ ។ មធ្យោបាយ សំខាន់ៗដទៃទៀត (ការផ្ដល់ការពិគ្រោះបញ្ហា មណ្ឌលសុខភាព ជំនួយផ្លូវច្បាប់) ជាធម្មតាពុំទាន់មាន នៅក្នុងតំបន់ភាគច្រើននៅឡើយទេ ។

ការសិក្សាស្រាវជ្រាវ ក៏បានរកឃើញថាអំពើហិង្សាក្នុងគ្រួសារ គួរតែត្រូវបានពិនិត្យមើលឡើងវិញក្នុងបរិបទនៃភាពក្រីក្រ ។ អំពើហិង្សាមានផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរទៅលើប្រជាពលរដ្ឋក្រីក្រទាំងការពាក់ពន្ធ័ទៅនឹងការទទួលយកនូវអំពើហិង្សា និងភាពទទួលរងគ្រោះរបស់ប្រជាពលរដ្ឋក្រីក្រដោយសារអំពើហិង្សា ។ អ្នកដែលមានប្រាក់ចំណូលទាបបំផុត បានលើកឡើងជាប្រចាំអំពីការទទួលរងគ្រោះដោយសារអំពើហិង្សា និងការរំលោភសេពសន្ថវៈ ព្រមទាំងការទទួលយកនូវឥរិយាបថហិង្សា និងកង្វះមធ្យោបាយជួយសង្គ្រោះ ។

១២៣ ច្បាប់ដែលមានស្រាប់ ដែលចាត់ទុកការរំលោភបំពានផ្លូវកាយ ជាបទឧក្រិដ្ឋ គឺមាននៅក្នុងក្រមព្រហ្មទណ្ឌ ឬច្បាប់ អាពាហ៍ពិពាហ៍ និងគ្រួសារ ដែលផ្ដល់នូវកិច្ចការពារបណ្ដោះអាសន្ន ក្នុងករណីលែងលះគ្នា

អំពើហិង្សាក្នុងគ្រួសារនៅប្រទេសកម្ពុជា កើតមានឡើងនៅក្នុងសំណាញ់ចាក់ស្រេះនៃឥរិយាបថ និងតំលៃនៃតួនាទីយេនឌ័រ ទំនាក់ទំនងក្នុងសង្គម និងអំពើហិង្សាជាទូទៅ។ ប្រេវ៉ាឡង់នៃអំពើហិង្សាក្នុងគ្រួសារពុំសូវមានការផ្លាស់ប្តូរប៉ុន្មានឡើយ បើប្រៀបធៀបរវាងការសិក្សាស្រាវជ្រាវនេះ ជាមួយនឹងលទ្ធផលរកឃើញនៅក្នុងការសិក្សាស្រាវជ្រាវរបស់អង្គការប្រឆាំងនឹងអំពើហិង្សាក្នុងគ្រួសារ (PADV) ដែលបានផ្សព្វផ្សាយក្នុងឆ្នាំ១៩៩៦។ ចំនួនភាគរយនៃប្រជាពលរដ្ឋ ដែលដឹង/ស្គាល់ស្ត្រីដែលទទួលរងនូវអំពើហិង្សាក្នុងគ្រួសារក្នុងប្រទេសកម្ពុជា (៦៤%) គឺទាបជាងលទ្ធផលនៃការស្រាវជ្រាវនៅក្នុងឆ្នាំ ១៩៩៦ (៧៤%) ប៉ុន្តែ PADV ពុំបានសាកសួរអំពីអំពើហិង្សាដែលប្រព្រឹត្តិដោយសមាជិកគ្រួសារឡើយ។ ការសិក្សាស្រាវជ្រាវនេះបានបង្ហាញភស្តុតាងថា រូបភាពខ្លះនៃអំពើហិង្សាពិតជាអាចមានការកើនឡើង។ តាមរបាយការណ៍បានឱ្យដឹងថាប្រេវ៉ាឡង់នៃប្រពន្ធដែលប្រើអំពើហិង្សាទៅលើប្តីរបស់ខ្លួនបានកើនឡើងពី ៣%ក្នុងឆ្នាំ ១៩៩៦ ដល់ ១២%នៅក្នុងការសិក្សាស្រាវជ្រាវនេះ។

បើទោះបីជាយ៉ាងណាក្តី មានអ្នកផ្តល់ជំនួយ រដ្ឋាភិបាល និងអង្គការក្រៅរដ្ឋាភិបាលមួយចំនួនធំបានខិតខំយ៉ាងខ្លាំងក្លាក្នុងការកាត់បន្ថយអំពើហិង្សាក្នុងគ្រួសារ ក្នុងរយៈពេលប្រាំបួនឆ្នាំ ចុងក្រោយនេះ។ ប៉ុន្តែ ដោយសារការសិក្សាស្រាវជ្រាវនេះ បង្ហាញថាកិច្ចខិតខំប្រឹងប្រែងទាំងនេះពុំបាននាំឱ្យមានការផ្លាស់ប្តូរនៅក្នុងឥរិយាបថ ឬអាកប្បកិរិយាទេនោះដូច្នេះហើយគួរតែមានសំណួរលើកឡើងថា ហេតុអ្វីបានជាការធ្វើអន្តរាគមន៍កន្លងមកទទួលបរាជ័យ។

**អ្នកសរសេររបាយការណ៍នេះ និងអង្គការផ្តល់មូលនិធិដែលសកម្មនៅក្នុងវិស័យនេះ បានធ្វើសេចក្តីសន្និដ្ឋានដូចខាងក្រោម:**

**១.** ចំណុចសំខាន់នោះ គឺថាយុទ្ធវិធីកន្លងមកទាំងអស់ ពុំបានផ្សារភ្ជាប់ទៅនឹងតំលៃ និងឥរិយាបថរបស់ប្រទេសកម្ពុជាទេ។ ការសិក្សាស្រាវជ្រាវនេះបង្ហាញថា អំពើហិង្សាបណ្តាលមកពីបញ្ហាជុំវិញអំណាច និងការត្រួតត្រា។ អំពើហិង្សាត្រូវបានគេប្រើដើម្បីពង្រឹងការអនុវត្តន៏តួនាទីយេនឌ័រ និងដើម្បីដាក់ទោសលើស្ត្រី ដែលជជែកតវ៉ាអំពីតួនាទីត្រួតត្រារបស់ប្តីនៅក្នុងគ្រួសារ។ បុរសប្រើប្រាស់រូបភាពនៃអំពើហិង្សាធ្ងន់ធ្ងរ ដើម្បីអនុវត្តសិទ្ធិរបស់ខ្លួននៅក្នុងការត្រួតត្រា និងរូបភាពពុំសូវធ្ងន់ធ្ងរដើម្បីត្រួតត្រា និងកំណត់ការប្រព្រឹត្តិរបស់ស្ត្រីក្នុងនាមជាប្រពន្ធ និងជាម្តាយ។ ការជំរុញឱ្យមានការអាណិតអាសូរដល់ជនរងគ្រោះដូចដែលកម្មវិធីនានាបានអនុវត្តកន្លងមក ដើម្បីបង្ហាញនូវ "ករណីពិតប្រាកដ" បានបរាជ័យនៅក្នុងការដោះស្រាយនូវបញ្ហាគ្រឹះនៃអំណាច និងការត្រួតត្រានេះ ហើយការបង្ហាញរូបភាពរបស់ស្ត្រីជាជនរងគ្រោះបានធ្វើឱ្យស្ថានភាព/តួនាទីរបស់ស្ត្រីកាន់តែចុះខ្សោយ។

**២.** ចំណុចសំខាន់មួយទៀតនៃការធ្វើអន្តរាគមន៏កន្លងមក គឺការអប់រំសិទ្ធិស្ត្រី។ ប៉ុន្តែកិច្ចខិតខំប្រឹងប្រែងទាំងនេះ ផ្តោតតែទៅលើស្ត្រី និងពុំបានផ្តោតទៅលើបុរសនៅពេលជាមួយគ្នានោះទេ។ ការលើកទឹកចិត្តឱ្យស្ត្រីប្រឈមមុខដោះស្រាយនឹងតួនាទីត្រួតត្រារបស់ប្តីនៅក្នុង

គ្រួសារ ដោយពុំបានអប់រំបុរសអំពីទំនាក់ទំនងស្មើភាពគ្នា អាចមានផលវិបាកយ៉ាងធ្ងន់ធ្ងរសំរាប់ស្ត្រីដែលរស់នៅក្នុងទំនាក់ទំនងគ្នាមួយ ដែលមានការរំលោភបំពាន។ ដោយការសិក្សាស្រាវជ្រាវនេះបានបង្ហាញថា អ្នកផ្ដល់ចំលើយបានយល់ថាអំពើហិង្សាអាចទទួលយកបាន
នៅ ក ្ ុ ង ្ ស្ដូ ្ វ ច ន ណ្ដ ធ ិះ ី ចំ ៍ ដាក
ឡើងវិញលើយុទ្ធវិធីទាំងនេះ។

៣. កម្មវិធី និងសកម្មភាពកន្លងមក បានផ្ដោតទៅលើសារដែលថាអំពើហិង្សាក្នុងគ្រួសារ គឺជាឧក្រិដ្ឋកម្ម។ ការផ្ដោតទៅលើអំពើហិង្សាក្នុងគ្រួសារថាជាបទឧក្រិដ្ឋ គឺពុំបានចាប់អារម្មណ៍អំពីភាពពិតជាក់ស្ដែងនៃប្រទេសកម្ពុជា ក្នុងសម័យអន្តរកាលនេះទេ។ ការអនុវត្តន៍ច្បាប់នៅទន់ខ្សោយ ដូច្នេះច្បាប់ពុំបានធ្វើឱ្យអ្នកប្រព្រឹត្តអំពើហិង្សាមានការរាងចាល ឬពុំបានជួយលើកកំពស់តំលៃនៃអាកប្បកិរិយាត្រឹមត្រូវនោះទេ។ តាមពិតអ្នកផ្ដល់ចំលើយមានចំនួនស្មើរតែ ២ ភាគ ៣ បាននិយាយថា កង្វះការអនុវត្តន៍ច្បាប់ គឺជាឥទ្ធិពលធំបំផុតទៅលើឥរិយាបថរបស់បុរសចំពោះស្ត្រី។ ដូចគ្នានេះដែរ ការសិក្សាស្រាវជ្រាវនេះ បានបង្ហាញថា នៅក្នុងប្រទេសកម្ពុជា ពុំមានការយល់ដឹងច្បាស់លាស់អំពីសិទ្ធិនៅឡើយទេ។ អ្នកផ្ដល់ចំលើយភាគច្រើន ពុំបានយល់ដឹងអំពីសិទ្ធិជាទូទៅឡើយ ហើយមានចំនួនសមាមាត្រដ៏គួរឱ្យកត់សំគាល់នៃក្រុមអ្នកផ្ដល់ចំលើយបានជឿថា អ្នកខ្លះមានសិទ្ធិច្រើនជាងអ្នកខ្លះទៀត។ លទ្ធផលរកឃើញដ៏សំខាន់មួយ គឺថាចំនួនស្ត្រីដែលទទួលយកនូវអំពើហិង្សា និងការរំលោភបំពាន ព្រមទាំងការផ្ដល់សិទ្ធិជាច្រើនដល់បុរស គឺច្រើនជាងបុរសទៅទៀត។

៤. យុទ្ធនាការកន្លងមកជាញឹកញាប់ ពុំបានចាប់អារម្មណ៍ទៅលើកំរិតដ៏ខ្ពស់នៃការទទួលយកនូវអំពើហិង្សានៅក្នុងប្រទេសកម្ពុជា និងការឱ្យតំលៃទៅលើសារៈសំខាន់នៃការថែរក្សាគ្រួសារឱ្យបានជួបជុំគ្នាក្នុងគ្រប់កាលៈទេសៈ ដែលចំណុចទាំងពីរនេះត្រូវបានផ្ដោតជាសំខាន់នៅក្នុងការសិក្សាស្រាវជ្រាវនេះ។ អង្គការខ្លះផ្ដោតទៅលើការលែងលះគ្នា ឬការផ្ដល់ទីជំរកជាដំណោះស្រាយចំពោះអំពើហិង្សាក្នុងគ្រួសារ។ ស្ត្រីជាច្រើនពុំចង់ចាកចេញ ពីប្ដីរបស់ខ្លួនទេ ដូច្នេះមធ្យោបាយទាំងនេះ ពុំអាចដោះស្រាយតំរូវការរបស់ពួកគេបានឡើយ។ ទីជំរក និងការលែងលះ គឺជាវិធានការចុងក្រោយក្នុងចំណោមលទ្ធភាពផ្សេងៗទៀត។ មានការយកចិត្តទុកដាក់តិចតួច ទៅលើដំណោះស្រាយជំលោះ និងការលើកកំពស់ទំនាក់ទំនងក្នុងគ្រួសារ រចនាសម្ព័ន្ធជួយសង្គ្រោះតាមសហគមន៍ ប្រព័ន្ធបញ្ជូន ការផ្ដល់ការពិគ្រោះបញ្ហា ឬការធ្វើការជាមួយបុរសដែលប្រើអំពើហិង្សា។

តាមរយៈទិន្នន័យដែលបានប្រមូល និងការវិភាគទិន្នន័យ អ្នកសរសេររបាយការណ៍នេះ និងអង្គការផ្ដល់មូលនិធិ បានយល់ឃើញថាអនុសាសន៍ដែលបានផ្ដល់ជូនទាំងនេះ គឺមានភាពសមស្របបំផុតក្នុងការដោះស្រាយបញ្ហាអំពើហិង្សាប្រឆាំងនឹងស្ត្រី នៅក្នុងបរិបទប្រទេសកម្ពុជា។



# ឧបសម្ព័ន្ធ

## តារាងទី ៣៨
### សំណួរទី ៩ a

*ភាគរយនៃអ្នកផ្ដល់ចំលើយ ដែលបានឆ្លើយថា "ទេ មិនអាចទទួលបានទាល់តែសោះ" ចំពោះសំណួរៈ តើអាចទទួលយកបានទេ ដែលប្រពន្ធប្រព្រឹត្តិអំពើនេះទៅលើប្ដី?*

*(N=3030)*



**តារាងទី ៣៩**

**សំណួរទី ១១**

*តើអំពើទាំងនេះ ណាមួយដែលជាអំពើឧក្រិដ្ឋ?*

*(N=3030)*



| **មិនដែលស្គាល់** | បុរស (N=1450) | នារី (N=1580) | Δ |
|---|---|---|---|
| ស្រែកគំហ៊ក | ២% | ៣% | ១% |
| ជេរបញ្ចោរ ឬប្រមាថមើលងាយ ។ល។ | ៤% | ៥% | ១% |
| គុប ឬចោលអ្វីមួយ ។ល។ | ២៣% | ២០% | -៣% |
| ខោកក្បាល ។ល។ | ២៧% | ២៨% | ១% |
| ចងដៃហើយវាយ ។ល។ | ៦០% | ៥៣% | -៧% |
| គំរាមកំហែងដោយកាំបិត ។ល។ | ៦៧% | ៦៦% | -១% |
| ដុត/ច្របាច់ក ។ល។ | ៧៧% | ៨០% | ៣% |
| ជះទឹកអាស៊ីដ ។ល។ | ៧៦% | ៨២% | ៦% |

## តារាងទី ៤០

### សំណួរទី ១២ a

*តើខ្លួនអ្នកផ្ទាល់ដឹង/ស្គាល់ប្តីដែលបានប្រព្រឹត្តអំពើដូចខាងក្រោមនេះ ទៅលើប្រពន្ធរបស់គាត់ដែររឺទេ?*

*(N=3030)*



## តារាងទី ៤១

### សំណួរទី ១២ a

*ភាគរយនៃអ្នកផ្តល់ចំលើយ ដែលបានឆ្លើយថា "បាទ/ចាស៎, ជាធម្មតា" "បាទបាទ/ចាស៎, ម្តងម្កាល" ឬ "កំរណាស់" នៅក្នុងសំណួរ : តើខ្លួនអ្នកផ្ទាល់ដឹង/ស្គាល់ ប្តីដែលបានប្រព្រឹត្តិអំពើដូចខាងក្រោមនេះទៅលើប្រពន្ធរបស់គាត់ដែររឺទេ? (N=3030)*



**តារាងទី ៩២**
**សំណួរទី ១៤ c**
*តើមនុស្សដែលប្រព្រឹត្តអំពើទាំងនោះ បានធ្វើអ្វីទេ ដើម្បីបញ្ឈប់ការប្រព្រឹត្តអំពើរបស់ខ្លួន?*
*(N=2935)*



**តារាងទី ៤៣**
**សំណួរទី ១៥ b**
*តើរយៈពេល ១២ ខែចុងក្រោយមកនេះ ការប្រព្រឹត្តអំពើទាំងនេះ បានកើតឡើងចំនួនប៉ុន្មានដង?*



## តារាងទី ៤៤

### សំណួរទី ១៥ c

*តើមានអ្វីដែលអាចបញ្ឈប់អ្នកបាន ពីការប្រព្រឹត្តនូវអំពើទាំងនេះ?*

*(N=1647)*



## តារាងទី ៩៥

### សំណួរទី ១៦ a

*ប្ដី ឬប្រពន្ធរបស់អ្នក ធ្លាប់បានប្រព្រឹត្តអំពើទាំងនេះទៅលើខ្លួនអ្នកដែរឬទេ?*

*(N=1984)*

| **ទេ មិនដែលទាល់តែសោះ** | បុរស (N=890) | នារី (N=1094) | Δ |
|---|---|---|---|
| ស្រែកគំហក | ២៣% | ២៤% | ១% |
| ជេរបញ្ឆោរ ។ល។ | ៥៦% | ៤៩% | -៧% |
| គប់ ឬចោលអ្វីមួយ ។ល។ | ៨៦% | ៧៥% | -១១% |
| ខោកក្បាល ។ល។ | ៨៩% | ៨៣% | -៦% |
| ចងដៃហើយវាយ ។ល។ | ៩៦% | ៩៣% | -៣% |
| គំរាមកំហែងដោយកាំបិត ។ល។ | ៩៦% | ៩២% | -៤% |
| ដុត/ច្របាច់ក | ៩៨% | ៩៩% | ១% |
| ជះទឹកអាស៊ីដ ។ល។ | ៩៨% | ៩៩% | ១% |



**តារាងទី ៤៦**

**សំណួរទី ១៦ b**

*តើរយៈពេល ១២ ខែចុងក្រោយមកនេះ ការប្រព្រឹត្តអំពើទាំងនេះបានកើតឡើងចំនួនប៉ុន្មានដង?*



**តារាងទី ៤៧**
**សំណួរទី ១៨ a**
*តើអ្នកបានធ្វើអ្វីខ្លះដើម្បីបញ្ឈប់អំពើខាងលើ?*
*(N=2628)*



## តារាងទី ៤៨

### សំណួរទី ២២ a

*តើប្រពន្ធអាចធ្វើអ្វីប្រសិនបើប្ដីរបស់គាត់ប្រព្រឹត្តដូចនេះ?*

*(N= 3030)*



## តារាងទី ៤៩

### សំណួរទី ២៣ b

*ភាគរយនៃអ្នកផ្តល់ចំលើយ ដែលបានឆ្លើយ "ទេ មិនដែលទាល់តែសោះ" ក្នុងសំណួរ:*

*តើខ្លួនអ្នកផ្ទាល់ដឹង /ជួបប្រទះនឹងករណីដែលប្តីបានប្រព្រឹត្តដូចខាងក្រោមទៅកាន់ប្រពន្ធដែរឬទេ?*
*(N= 3025)*

| ទេ មិនដែលទាល់តែសោះ | បុរស | នារី | |
|---|---|---|---|
| ហាមឃាត់នាងក្នុងការស្លៀកពាក់សំលៀកបំពាក់មួយចំនួនដែលប្តីមិនពេញចិត្ត | ៣១% | ២៩% | -២% |
| ទទូចចង់ដឹងពីទីកន្លែងដែលប្រពន្ធរបស់គាត់នៅគ្រប់ពេលវេលា | ៤០% | ៣៧% | -៣% |
| ចោទប្រកាន់ប្រពន្ធរបស់គាត់ថាមិនស្មោះត្រង់ | ៤២% | ៣១% | -១១% |
| មិនអោយលុយទៅប្រពន្ធដើម្បីចាយវាយ | ៤៦% | ៣៩% | -៧% |
| មិនអនុញ្ញាតិអោយប្រពន្ធរបស់គាត់ចេញក្រៅផ្ទះ | ៤៩% | ៥៦% | ៧% |
| មិនអនុញ្ញាតិអោយប្រពន្ធរបស់គាត់ជួបមិត្តស្រីរបស់នាង | ៦២% | ៥៨% | -៤% |
| មិនអនុញ្ញាតិអោយប្រពន្ធរបស់គាត់ទៅសួរសុខទុក្ខគ្រួសាររបស់នាង | ៦៥% | ៦៦% | ១% |





**តារាងទី ៥០**

**សំណួរទី ២៥ a**

*ភាគរយនៃអ្នកផ្ដល់ចំលើយ ដែលបានឆ្លើយ "ទេ មិនដែលទាល់តែសោះ" ក្នុងសំណួរ :*

*តើខ្លួនអ្នកផ្ទាល់ ដែលធ្លាប់មិនសប្បាយចិត្ត ឬខឹងខ្លាំងជាមួយប្រពន្ធរបស់អ្នកនៅកាលៈទេសៈ ខាងក្រោមនេះណាខ្លះដែរឬទេ?*

*(N= 902)*





## តារាងទី ៥១
### សំណួរទី ២៥ b

*ភាគរយនៃអ្នកផ្តល់ចំលើយ ដែលបានឆ្លើយ "ទេ មិនដែលទាល់តែសោះ" ក្នុងសំណួរ :*

*តើអ្នកធ្លាប់ធ្វើអ្វីខ្លះខាងក្រោមនេះដែរឬទេ?*
*(N= 902)*





**តារាងទី ៥២**

**សំណួរទី ២៥ c**

*ភាគរយនៃអ្នកផ្តល់ចំលើយ ដែលបានឆ្លើយ*
*"ទេ មិនដែលទាល់តែសោះ" ក្នុងសំណួរៈ*
*តាមគំនិតរបស់អ្នក តើមានអ្វីអាចបញ្ឈប់អ្នកពីការធ្វើដូច្នេះ?*
*(N= 501)*





**តារាងទី ៥៣**
**សំណួរទី ២៦ a**

*ភាគរយនៃការផ្ដល់ចំលើយ ដែលបានឆ្លើយ "**ទេ មិនដែលទាល់តែសោះ**" ក្នុងសំណួរ: តើប្ដីរបស់អ្នកដែលធ្លាប់មិនសប្បាយចិត្ត ឬខឹងខ្លាំងជាមួយអ្នក នៅកាលៈទេសៈខាងក្រោមនេះណាខ្លះដែលឬទេ? (N= 1111)*





## តារាងទី ៥៤

### សំណួរទី ២៦ b

*ភាគរយនៃអ្នកផ្តល់ចំលើយដែលបានឆ្លើយ "ទេ មិនដែលទាល់តែសោះ" ក្នុងសំណួរៈ តើប្តីរបស់អ្នកធ្លាប់ធ្វើអ្វីខ្លះខាងក្រោមនេះដែរឬទេ?*

*(N= 1115)*





**តារាងទី ៥៥**

**សំណួរទី ២៦ c**

*ប្រសិនបើប្តីរបស់អ្នកប្រព្រឹត្តដូចនេះ តើអ្នកធ្វើអ្វីខ្លះដែរ ?*
*(N= 649)*



## តារាងទី ៥៦

### សំណួរទី ២៧ d

*តើស្ត្រីម្នាក់អាចធ្វើអ្វីបាន ប្រសិនបើនាងត្រូវបានប្តីបង្ខំអោយរួមភេទ ដែលផ្ទុយនឹងឆន្ទៈរបស់នាង?*

*(N= 3030)*



**តារាងទី ៥៧**

**សំណួរទី ២៩ b**

*នាងបានធ្វើអ្វីខ្លះដែរទេ?*

*(N= 420)*



**តារាងទី ៥៤**

**សំណួរទី ៣២ b**

*តើអ្នកចាប់រំលោភសេពសន្ថវៈនោះជានរណាដែរ?*

*(N= 820)*



**តារាងទី ៥៩**

**សំណួរទី ៣២ d**

*តើបានជាលទ្ធផលអ្វីខ្លះ?*

*(N= 797)*



**តារាងទី ៦០**

**សំណួរទី ៣៦ a, d**

*ស្ត្រីនៅក្នុងភូមិឃុំរបស់អ្នកធ្លាប់ទទួលរងគ្រោះថ្នាក់ដោយសារបញ្ហាទាំងនេះ តើនាងទំនងជាមកជួបភ្នាក់ងារ ដើម្បីស្វែងរកជំនួយដែរឬទេ?*

*(N= 3030)*



### តារាងទី ៦១
### សំណួរទី ៣៧ b
*តើជាធម្មតាស្ត្រីស្វែងរកការលែងលះគ្នានៅឯណា?*
*(N= 3030)*



**តារាងទី ៦២**

**សំណួរទី ៣៩ a**

*ក្នុងករណីមានរឿងទាំងនេះកើតឡើង តើអ្នកបានស្វែងរកការលែងលះគ្នាដែរឬទេ?*

*(N= 330)*



# A ឧបសម្ព័ន្ធ - សិទ្ធិ

**ទស្សនៈ - តើមានមនុស្សខ្លះ មានសិទ្ធិច្រើនជាងមនុស្សដទៃទៀតដែរឬទេ?**




**តារាងទី ៦៣**

សំណួរទី ៤០ c

*ភាគរយនៃអ្នកផ្តល់ចំលើយ ដែលបានឆ្លើយ "ចាស/បាទ" នៅក្នុងសំណួរ : តើមានមនុស្សខ្លះ មានសិទ្ធិច្រើនជាងមនុស្សដទៃទៀតដែរឬទេ?*

*(N= 3030)*




**តារាងទី ៦៤**

សំណួរទី ៤០ d

*អ្នកទាំងនោះ ជានរណា?*

*(N= 774)*

## តារាងទី ៦៥

### សំណួរទី ៨ a

*ភាគរយនៃអ្នកផ្តល់ចំលើយដែលបានឆ្លើយ "ទេ មិនដែលទាល់តែសោះ" នៅក្នុងសំណួរៈ តើអាចទទួលយកបានដែរឬទេ ចំពោះប្តីប្រព្រឹត្តិអំពើនេះទៅលើប្រពន្ធ?* (N= 301)



## តារាងទី ៦៦
### សំណួរទី ៩ a
*តើអាចទទួលយកបានទេដែលប្រពន្ធ ប្រព្រឹត្តិអំពើទាំងនេះ ទៅលើប្ដី?*

*(N= 301)*



## តារាងទី ៦៧

### សំណួរទី ១០ a

*តើមនុស្សម្នាក់អាចធ្វើអ្វីបានខ្លះ ប្រសិនបើប្ដី ឬប្រពន្ធរបស់ពួកគេប្រព្រឹត្តអំពើដូច្នេះ?*
*(N= 301)*

| | អាជ្ញាធរស្រុក | អាជ្ញាធរឃុំ-សង្កាត់ | ប៉ូលីស (ថ្នាក់ខ្ពស់) | ប៉ូលីស (ថ្នាក់ទាប) |
|---|---|---|---|---|
| ទៅរកមេភូមិ ឬ មេឃុំ/ចាស់ទុំក្នុងភូមិ | ៩០% | ៨៧% | ៧៥% | ៨០% |
| ប្រាប់សាច់ញាតិ ឬមិត្តភ័ក្រ | ៧០% | ៨០% | ៨១% | ៨៨% |
| ទៅរកប៉ូលីស/ទៅរកតុលាការ | ៧៥% | ៥៤% | ៦០% | ៧៧% |
| មិនធ្វើអ្វីទាំងអស់/ចេះតែទ្រាំទៅ | ២៨% | ៣១% | ២៧% | ២៧% |
| ទៅមន្ទីរពេទ្យ ។ល។ | ២០% | ១៨% | ១៣% | ១៨% |
| ស្វែងរកការណែនាំពីមេធាវី | ២០% | ១៣% | ៥% | ១៦% |
| ស្វែងរកជំនួយ ឬការពិគ្រោះយោបល់ | ១៣% | ៧% | ៨% | ៤% |
| ទៅជួបថៅកែ | ១០% | ២% | ២% | ៤% |

## តារាងទី ៦៨
## សំណួរទី ១១

*តាមគំនិតរបស់អ្នក តើអំពើទាំងនេះណាមួយ ដែលជាអំពើឧក្រិដ្ឋ (ជាអំពើដែលអ្នកប្រព្រឹត្តិ អាចនឹងត្រូវទទួលពិន័យ ឬជាប់ពន្ធនាគារ)?*

*(N= 301)*

- អាជ្ញាធរស្រុក
- អាជ្ញាធរឃុំ-សង្កាត់
- ប៉ូលីស (ថ្នាក់ខ្ពស់)
- ប៉ូលីស (ថ្នាក់ទាប)



**តារាងទី ៦៩**
**សំណួរទី ៣០ a**
*តាមគំនិតរបស់អ្នក តើអ្វីខ្លះជាសិទ្ធិដ៏សំខាន់បំផុត ដែលពលរដ្ឋមាន?*
*(N= 301)*



## វិធីសាស្ត្រ

គោលបំណងនៃការអង្កេតនេះ គឺដើម្បីបង្កើនការយល់ដឹងលំអិតអំពីអំពើហិង្សាក្នុងគ្រួសារ នៅក្នុងប្រទេសកម្ពុជា តាមរយៈទិន្នន័យជាបរិមាណ និងទិដ្ឋភាពទូលំទូលាយពីកត្តាដទៃទៀត។ ការអង្កេតនេះមានបំណងបង្កើតជាទិន្នន័យជាមូលដ្ឋាន ដែលនឹងត្រូវយកទៅប្រើប្រាស់សំរាប់វាស់វែងទៅលើការអង្កេតត្រួតពិនិត្យទៅអនាគត និងផ្តល់នូវអនុសាសន៍នានាសំរាប់ជាយុទ្ធវិធី និងយុទ្ធសាស្ត្រដើម្បីធ្វើឱ្យការអនុវត្តន៍របស់រដ្ឋាភិបាលនិងអាជ្ញាធរមូលដ្ឋាននៅក្នុងបញ្ហានេះកាន់តែល្អប្រសើរឡើង។

ការអង្កេតនេះ បានប្រើប្រាស់ក្រុមអ្នកផ្តល់ចំលើយ ចំនួនពីរក្រុម ដូចបានបញ្ជាក់ខាងក្រោម៖

- មនុស្សចំនួន ៣០០០ នាក់ មកពីប្រជាពលរដ្ឋទូទៅ
- មនុស្សចំនួន ៣០០ នាក់ ជាអាជ្ញាធរមូលដ្ឋាន (១៥០ នាក់) និងប៉ូលីស (១៥០ នាក់) ត្រូវបានបែងចែកស្មើគ្នានៅក្នុងខេត្តនីមួយៗ សំរាប់ជាក្រុមអ្នកផ្តល់ចំលើយ ហើយត្រូវបានជ្រើសរើសដោយចៃដន្យ។[១២៥]

ក្រុមអ្នកផ្តល់ចំលើយទូទៅ ត្រូវបានជ្រើសរើសពីចំណោមប្រជាពលរដ្ឋខ្មែរ ដែលមានអាយុពី ១៥ ឆ្នាំឡើងទៅ ហើយនឹងអាចប្រើប្រាស់ម្តងទៀតនៅក្នុងការអង្កេតទៅអនាគត។ បច្ចេកទេសនៃការរៀបចំក្រុមអ្នកផ្តល់ចំលើយ គឺសំរាប់ពហុដំណាក់កាល ដែលបានរៀបចំក្រុមអ្នកផ្តល់ចំលើយជាក្រុមៗទៅតាមចំនួនសមាមាត្រ។ ក្រុមអ្នកផ្តល់ចំលើយ ត្រូវបានបង្កើតឡើងក្នុងដំណាក់កាលជាច្រើន ដូចបានបញ្ជាក់ដូចខាងក្រោម៖

- ក្នុងដំណាក់កាលទីមួយ៖ ១៣ ខេត្តដែលមានចំនួន ៣ ភាគ ៤ នៃប្រជាពលរដ្ឋខ្មែរត្រូវបានជ្រើសរើសដោយចៃដន្យ។
- ក្នុងដំណាក់កាលទីពីរ៖ ខេត្តទាំងនេះ ត្រូវបានបែងចែកជាតំបន់ទីប្រជុំជន តំបន់ជនបទ និងស្រុកដាច់ស្រយាល ហើយស្រុកសរុបចំនួន ៥៩ ត្រូវបានជ្រើសរើសដោយចៃដន្យទៅតាមសមាមាត្រនៃទំហំប្រជាពលរដ្ឋ។
- ក្នុងដំណាក់កាលទីបី៖ ស្រុកទាំងនេះត្រូវបានបែងចែកទៅតាមភេទ និងក្រុមអាយុទៅតាមសមាមាត្រនៃទំហំប្រជាពលរដ្ឋ។
- ដំណាក់កាលចុងបញ្ចប់៖ អ្នកដែលត្រូវធ្វើសម្ភាស ត្រូវបានជ្រើសរើសចៃដន្យ ដោយយោងទៅតាមកត្តាដូចខាងលើ។

[១២៥] ទំហំដំបូងនៃក្រុមអ្នកផ្តល់ចំលើយ គឺមានមនុស្សចំនួន៣០០០នាក់ និង៣០០នាក់ក្នុងចំណោមអាជ្ញាធរមូលដ្ឋាន និង ប៉ូលីស។ ប៉ុន្តែក្រុមអ្នកស្រាវជ្រាវបានធ្វើការការសម្ភាសន៍ពិតប្រាកដចំនួន៣០៣០ សំរាប់ក្រុមអ្នកផ្តល់ចំលើយទូទៅ និងចំនួន ៣០១ សំរាប់ក្រុមអាជ្ញាធរមូលដ្ឋាន និងប៉ូលីស ដើម្បីធ្វើអោយប្រាកដថាពួកគេពិតជាបានបំពេញទៅតាមចំនួនកិច្ចសម្ភាសន៍ ដែលជាគោលដៅ។ ចំនួនកិច្ចសម្ភាសន៍ដែលធ្វើឡើងសំរាប់សំណួរនិមួយៗ ត្រូវបានបញ្ចូលនៅក្នុងតារាងចំលើយ។

ការសម្ភាសន៍ជាច្រើន ដែលបានធ្វើឡើងនៅក្នុងការអង្កេតនេះ គឺក្នុងបំណងបង្កើនភាពច្បាស់លាស់សំរាប់ការអង្កេតនេះ។ កត្តាទាំងនេះ ដោយរួមទាំងប្រជាពលរដ្ឋដែលមានលក្ខណៈដូចគ្នានៅក្នុងប្រទេសកម្ពុជា គឺបាននាំមកនូវជំនឿទុកចិត្តយ៉ាងខ្ពស់សំរាប់ការអង្កេតនេះ។ ឧទាហរណ៍ នៅក្នុងករណីដែលមានអ្នកផ្តល់ចំលើយចំនួន ៣៥% បានឆ្លើយទៅនឹងសំណួរដោយនិយាយថា "បាទ/ចាស" (អក្សរ P តំណាងឱ្យប្រេកង់សីអ្នកផ្តល់ចំលើយ = ៣៥%) ភាពជឿទុកចិត្តបាន ត្រូវបានផ្តល់ឱ្យតាមរូបមន្តP (ប្រេកង់សីក្នុងចំនួនប្រជាពលរដ្ឋខ្មែរ) = ៣៥ ± ២,៥%។ រូបមន្តនេះ អាចមានលក្ខណៈត្រឹមត្រូវចំនួន ៩៥%។ម្យ៉ាងទៀតរូបមន្តនេះពិតជាទទួលបានចំនួន ៩៥% នៃចំនួនប្រជាពលរដ្ឋខ្មែរទាំងអស់ក្នុងចន្លោះពី ៣២.៥% និង ៣៧.៥% នឹងឆ្លើយថា "បាទ/ចាស"។ ដើម្បីសំរេចបាននូវភាពត្រឹមត្រូវចំនួន ៩៩% គឺត្រូវធ្វើទៅតាមរូបមន្ត P = ៣៥ ± ៣.៥%។ ភាពអាចជឿទុកចិត្តបាន គឺជាមុខងារមួយនៃរូបមន្ត P ដូច្នេះ ភាពអាចជឿទុកចិត្តបាន មានភាពខុសគ្នាបន្តិចបន្តួច គឺនៅក្នុងចន្លោះពីប្រមាណ ១% និង ៤%។

ទិន្នន័យត្រូវបានប្រមូល តាមរយៈការធ្វើសម្ភាសន៍ផ្ទាល់ ដោយប្រើប្រាស់បញ្ជីសំណួរដែលបានរៀបចំ។[១២៦] រាល់អ្នកសម្ភាសទាំងអស់ សុទ្ធសឹងតែមានបទពិសោធន៍ ហើយអ្នកសម្ភាសទាំងនេះទទួលបានការពន្យល់ណែនាំ និងបណ្តុះបណ្តាលស្តីពីការអង្កេតជាក់លាក់នេះ ព្រមទាំងអំពីអំពើហិង្សាក្នុងគ្រួសារ និងសមភាពយេនឌ័រ។ រាល់ការសម្ភាសន៍ទាំងអស់ជាមួយស្ត្រី ត្រូវបានធ្វើឡើងដោយអ្នកសម្ភាសជាស្ត្រី។ ការសិក្សាស្រាវជ្រាវនេះ ត្រូវបានធ្វើឡើងរវាងពីខែធ្នូ ឆ្នាំ ២០០៤ និងដើមខែកុម្ភៈ ឆ្នាំ ២០០៥។ បន្ទាប់មក ការធ្វើសម្ភាសន៍ចំនួន ៣០% ក្នុងចំណោមកិច្ចសម្ភាសន៍ទាំងអស់ ត្រូវបានជ្រើសរើសដោយចៃដន្យ និងធ្វើឡើងម្តងទៀត។

ការសិក្សាស្រាវជ្រាវនេះ បានប្រើប្រាស់បញ្ជីសំណួរមួយសំរាប់ក្រុមអ្នកផ្តល់ចំលើយទូទៅ និងបញ្ជីសំណួរមួយទៀតដែលខុសគ្នាបន្តិចបន្តួចសំរាប់អាជ្ញាធរមូលដ្ឋាននិងប៉ូលីស ។បញ្ជីសំណួរដែលប្រើជាមួយមន្ត្រីទាំងនេះ ក៏មានបំណងចង់បាននូវព័ត៌មានជាក់លាក់ស្តីពីឥរិយាបថ និងអាកប្បកិរិយារបស់ស្ថាប័នអនុវត្តច្បាប់ និងចំណេះដឹងផ្នែកច្បាប់របស់ពួកគេ។ តំរូវការជាក់លាក់របស់ក្រុមនីមួយៗនៃអាជ្ញាធរមូលដ្ឋាន និងប៉ូលីសទាំងនេះ បានតំរូវឱ្យមានយុទ្ធវិធីខុសគ្នាបន្តិចបន្តួច និងភាពខុសគ្នាខ្លះនៅក្នុងបញ្ជីសំណួរជាក់លាក់ទាំងនេះ។ ប៉ុន្តែកិច្ចសម្ភាសន៍ភាគច្រើនដែលបានធ្វើឡើងជាមួយក្រុមនីមួយៗមាន "ចំណុចស្នូល" រួមមួយ ដើម្បីទទួលបានការវិភាគ ការប្រៀបធៀប និងការបកស្រាយទិន្នន័យឱ្យកាន់តែទូលំទូលាយថែមទៀត។ សំណួរសំខាន់ៗ គឺមានដូចគ្នាសំរាប់ក្រុមគោលដៅទាំងពីរ ប៉ុន្តែអាជ្ញាធរមូលដ្ឋាន និងប៉ូលីសត្រូវបានគេសាកសួរនូវសំណួរបន្ថែមទៅលើប្រធានបទដូចខាងក្រោមៈ

- ចំណេះដឹងអំពីបញ្ហាអំពើហិង្សាក្នុងគ្រួសារ និងភាពសមស្របនៃការយល់ដឹងនេះនៅក្នុងសង្គមខ្មែរ។
- ចំណេះដឹងជាក់លាក់ចំពោះច្បាប់ ដែលពាក់ព័ន្ធ។
- សកម្មភាពដែលពួកគេ ជាធម្មតា អនុវត្តទៅតាមស្តង់ដានៃករណីនានា។

១២៣ ចំពោះបញ្ជីសំណួរពេញលេញសំរាប់ការធ្វើអង្កេតនេះ សូមពិនិត្យមើលឧបសម្ព័ន្ធ C ។

- ការប៉ាន់ប្រមាណ និងការវាយតំលៃលើប្រព័ន្ធតុលាការ និងប៉ូលិស ពាក់ព័ន្ធទៅនឹងអំពើហិង្សាប្រឆាំងនឹងស្ត្រី ។
- សំណូមពរសំរាប់ការកែលំអ ដែលចាំបាច់ ។

## ប្រវត្តិសង្ខេបនៃអ្នកផ្តល់ចំលើយៈ ក្រុមតំណាងប្រជាជនទូទៅ

ការអង្កេតនេះ ត្រូវបានធ្វើឡើងជាមួយក្រុមអ្នកផ្តល់ចំលើយពីរខុសគ្នាៈ ក្រុមអ្នកផ្តល់ចំលើយដែលត្រូវបានជ្រើសរើសដោយចៃដន្យ តំណាងឱ្យប្រជាពលរដ្ឋខ្មែរទាំងមូល (ចំនួន = ៣០៣០) និងក្រុមមន្ត្រីមូលដ្ឋាន និងប៉ូលិស (ចំនួន = ៣០១) ។ ផ្នែកនេះផ្តោតទៅលើលទ្ធផលដែលបានមកពីក្រុមអ្នកផ្តល់ចំលើយទូទៅ ។

អ្នកផ្តល់ចំលើយភាគច្រើន បានរៀបការ និងមានកូនរួចហើយ ។ ជាពិសេសរូបភាពនៃអ្នកផ្តល់ចំលើយមានដូចខាងក្រោមៈ

- ក្រុមអ្នកផ្តល់ចំលើយ មានចំនួនស្ត្រី (៥២%) ច្រើនជាបុរស ៤៨%) បន្តិចបន្តួច ។
- ភាគច្រើននៃអ្នកដែលនៅក្នុងក្រុមអ្នកផ្តល់ចំលើយ (៦០%) បានរៀបការរួចហើយ ។ មានមនុស្សចំនួនតិចតួចដែលមានអាយុ៣០ឆ្នាំ ឬនៅលីវ ។
- អ្នកផ្តល់ចំលើយជាច្រើន បានរៀបការមុនអាយុ ២៥ ឆ្នាំ ហើយស្ត្រីមានចំនួនស្ទើរតែពាក់កណ្តាលបានរៀបការមុនអាយុ ២០ ឆ្នាំ ។ ប៉ុន្តែបុរសមានចំនួន ៣១% បានរៀបការមុនអាយុ ២០ឆ្នាំ ។
- ចំនួនភាគច្រើនបំផុតនៃអ្នកដែលបានរៀបការ មានកូនរួចហើយ ។
- អ្នកផ្តល់ចំលើយភាគច្រើន (៨២%) រស់នៅក្នុងតំបន់ជនបទ ។ រីឯចំនួន ១៥% រស់នៅក្នុងតំបន់ទីប្រជុំជននិង៣% រស់នៅក្នុងតំបន់ដាច់ស្រយាល (ត្រូវបានកំណត់ថាមានមនុស្សចំនួន ១០ នាក់នៅក្នុងមួយគីឡូម៉ែត្រការេ) ។
- អ្នកផ្តល់ចំលើយជាច្រើន (៤៤%) បានរាយការណ៍ថា យ៉ាងតិចណាស់ ក៏ពួកគេរស់ជាមួយឪពុក ឬម្តាយដែរ ។ ហើយចំនួនជាច្រើនបានរស់នៅជាមួយសាច់ញាតិដទៃទៀត ។ ការរស់នៅជាមួយឪពុកម្តាយ គឺជារឿងទូទៅនៅក្នុងតំបន់ជនបទ ។ មានអ្នករស់នៅក្នុងទីក្រុងភ្នំពេញចំនួនតិចតួចប៉ុណ្ណោះ (១៦%) បាននិយាយថាពួកគេរស់នៅជាមួយឪពុកម្តាយ ។

ការអង្កេតនេះ បានដាក់បញ្ចូលមនុស្សដែលមានអាយុពី ១៥ ឆ្នាំឡើងទៅដូចដែលបានបញ្ជាក់ខាងក្រោមក្នុងតារាងអាយុ ។ ក្រុមដែលមានមនុស្សច្រើនបំផុត គឺក្រុមអាយុចាប់ពី ៤០ ឆ្នាំឡើងទៅដែលតំណាងឱ្យចំនួន ១ ភាគ ៣ ក្នុងចំណោមចំនួនសរុប ។ ប៉ុន្តែការអង្កេតនេះបានដាក់បញ្ចូលមនុស្សក្នុងចំណោមគូឱ្យកត់សំគាល់ ដែលមានអាយុពី ១៥ ដល់ ១៩ ឆ្នាំ ។ ក្រុមអាយុនេះ រួមជាមួយនឹងអ្នកដែលមានអាយុពី (២០ ដល់ ២៤ ឆ្នាំ) មានចំនួនស្ទើរតែ ១ ភាគ ៣ នៃក្រុមអ្នកផ្តល់ចំលើយទាំងអស់ ដែលនាំឱ្យមានការស្រាវជ្រាវទៅលើនិន្នាការក្នុងចំណោមមនុស្សវ័យក្មេងនៅក្នុងប្រទេសកម្ពុជា ។

| អាយុ | (N=3026) |
|---|---|
| ១៥-១៩ | ១៧% |
| ២០-២៤ | ១៦% |
| ២៥-២៩ | ១៣% |
| ៣០-៣៩ | ២១% |
| ពី ៤០ និងច្រើនជាងនេះ | ៣៣% |

*តារាងអាយុរបស់អ្នកផ្តល់ចំលើយ*

| ប្រាក់ចំណូល | (N=2926) |
|---|---|
| $២០ ឬតិចជាង | ៦% |
| $២១ - $៥០ | ៣១% |
| $៥១ - $១០០ | ៣៤% |
| $១០១ - $២០០ | ២១% |
| ច្រើនជាង $២០០ | ៨% |

*តារាងប្រាក់ចំណូលរបស់អ្នកផ្តល់ចំលើយ*

ប្រាក់ចំណូលក្នុងគ្រួសារ ត្រូវបានគេវាស់ទៅតាមប្រាក់ចំណូលចំនួនប្រាំប្រភេទ ដែលមានចាប់ពី ២០ ដុល្លា ឬតិចជាងនេះ ក្នុងមួយខែ ទៅដល់ ២០០ ដុល្លាឡើងទៅក្នុងមួយខែ ។ អ្នកដែលមានប្រាក់ចំណូល ២១ ដុល្លា ដល់ ៥០ ដុល្លាក្នុងមួយខែ មានចំនួនស្ទើរតែ ១ ភាគ ៣ ក្នុងចំណោមក្រុមអ្នកផ្តល់ចំលើយ ដូចគ្នាទៅនឹងអ្នកដែលមានប្រាក់ចំណូល ៥១ ដុល្លា ដល់ ១០០ ដុល្លាក្នុងមួយខែដែរ ។

កំរិតអប់រំសិក្សារបស់អ្នកផ្តល់ចំលើយ មានចាប់ពីការសិក្សាក្រៅប្រព័ន្ធ ដល់អ្នកដែលបានសិក្សានៅសកលវិទ្យាល័យដូចដែលបានបញ្ជាក់ក្នុងតារាងស្តីពីការសិក្សាអប់រំខាងក្រោម ។ស្ទើរតែចំនួនពាក់កណ្តាលនៃក្រុមអ្នកផ្តល់ចំលើយបានចូលសិក្សានៅថ្នាក់បឋម ឬបានបញ្ចប់ការសិក្សាថ្នាក់បឋម ។ ចំនួនច្រើនជាង ១ ភាគ ៣ បានសិក្សានៅក្នុងថ្នាក់មួយចំនួននៅមធ្យមសិក្សា ឬបានបញ្ចប់មធ្យមសិក្សា ។

| តារាងអប់រំ | (N=2926) |
|---|---|
| ការសិក្សាក្រៅប្រព័ន្ធ | ១២% |
| មួយចំនួននៅថ្នាក់បឋម ឬបានបញ្ចប់ការសិក្សាថ្នាក់បឋម | ៤៨% |
| មួយចំនួននៅមធ្យមសិក្សា ឬបានបញ្ចប់មធ្យមសិក្សា | ៣៨% |
| សកលវិទ្យាល័យ | ២% |

*កំរិតអប់រំសិក្សារបស់អ្នកផ្តល់ចំលើយ*

មានការពាក់ព័ន្ធគ្នាទៅវិញទៅមកយ៉ាងខ្លាំងនៅក្នុងកត្តាជាច្រើនទាំងនេះ ។ ឧទាហរណ៍មនុស្សភាគច្រើនដែលមានប្រាក់ចំណូលទាបបំផុត និងភាគច្រើននៃអ្នកពុំមានការសិក្សាគឺជាស្ត្រី:

- មានចំនួនសរុប ៧០% ក្នុងចំណោមអ្នកដែលមានប្រាក់ចំណូលតិចជាង ២០ ដុល្លាក្នុងមួយខែ (កំរិតប្រាក់ចំណូលទាបបំផុតនៅក្នុងការអង្កេតនេះ) គឺជាស្ត្រី ។
- ចំនួន ៧៤% ក្នុងចំណោមអ្នកដែលពុំមានការសិក្សា គឺជាស្ត្រី ។

កំរិតអប់រំសិក្សា ក៏បានបង្ហាញនូវការពាក់ព័ន្ធយ៉ាងខ្លាំងទៅនឹងប្រាក់ចំណូល អាយុ និងទីកន្លែងរស់នៅ (ទីប្រជុំជន តំបន់ជនបទ ឬតំបន់ដាច់ស្រយាល) ។

- កំរិតអប់រំសិក្សាទាបបំផុត មានការពាក់ព័ន្ធទៅនឹងកំរិតប្រាក់ចំណូលទាបបំផុត: ចំនួន ៨១% ក្នុងចំណោមអ្នកដែលមានប្រាក់ចំណូល ២០ ដុល្លា ឬក្រោម ២០ ដុល្លាក្នុងមួយខែ ពុំមានការសិក្សាទាល់តែសោះ ឬមានការសិក្សាខ្លះនៅកំរិតបឋម។ ចំនួន ៣៥% នៃអ្នកដែលមានប្រាក់ចំណូលច្រើនជាង ២០០ ដុល្លាក្នុងមួយខែ គឺស្ថិតក្នុងប្រភេទអ្នកដែលមានកំរិតអប់រំសិក្សាទាបបំផុត។
- ផ្ទុយទៅវិញអ្នកដែលមានការសិក្សានៅសកលវិទ្យាល័យ ត្រូវបានគេចាត់ទុកនៅក្នុងក្រុមអ្នកដែលមានប្រាក់ចំណូលខ្ពស់បំផុត (៩%) និងនៅក្នុងក្រុមទាំងបីនៃអ្នកមានប្រាក់ចំណូលទាបបំផុត (១%)។
- កង្វះការសិក្សាក្នុងប្រព័ន្ធ ក៏មានការពាក់ព័ន្ធទៅនឹងអាយុផងដែរ។ ចំនួនតិចជាង ២%នៃអ្នកដែលមានអាយុក្រោម ២០ ឆ្នាំ ពុំមានការសិក្សានោះទេ បើធៀបនឹងអ្នកដែលមានអាយុចាប់ ពី ៤០ ឆ្នាំឡើងទៅមានចំនួន ៦៦%។
- អ្នកផ្តល់ចំលើយដែលរស់នៅទីប្រជុំជន មានការសិក្សា និងប្រាក់ចំណូលច្រើនជាងគេ។ មានតែចំនួន ៣៩%ប៉ុណ្ណោះ មានការសិក្សាកំរិតបឋម ឬក្រោមបឋម ហើយចំនួន ១៨% មានប្រាក់ចំណូល ៥០ ដុល្លា ឬក្រោម ៥០ ដុល្លា ក្នុងមួយខែ។

## ប្រវត្តិសង្ខេបនៃអ្នកផ្តល់ចំលើយ: ក្រុមអាជ្ញាធរមូលដ្ឋាន និងប៉ូលីស

រាជរដ្ឋាភិបាលកម្ពុជា ត្រូវបានរៀបចំទៅជា ២០ ខេត្ត និងក្រុងបួន។ ខេត្ត-ក្រុងទាំងនេះត្រូវបានបែងចែកជា ១៨៥ ស្រុក និង ១.៦២១ ឃុំ-សង្កាត់។

ក្រុមនេះ ចំនួន (៣០១ នាក់) ត្រូវបានបែងចែកទៅតាមប្រភេទការងារបួនខុសៗគ្នា និងស្របទៅតាមកំរិតអប់រំសិក្សា និងប្រាក់ចំណូល។ ក្រុមនេះ ពុំមែនជាក្រុមតំណាងឱ្យអាជ្ញាធរមូលដ្ឋាន និងប៉ូលីសទាំងអស់នៅក្នុងប្រទេសកម្ពុជាទេ។ ដូចបានបង្ហាញនៅក្នុងតារាងខាងក្រោមដែលស្តីពីប្រវត្តិសង្ខេបរបស់អាជ្ញាធរមូលដ្ឋាន និងប៉ូលីស មានចំនួនស្ទើរតែពាក់កណ្តាលនៃអ្នកផ្តល់ចំលើយនៅក្នុងក្រុមនេះ គឺជាអាជ្ញាធរឃុំ-សង្កាត់។ អ្នកផ្តល់ចំលើយដទៃទៀត គឺជាមន្ត្រីប៉ូលីសថ្នាក់ទាប។ ប៉ូលីសខ្លះធ្វើការនៅឃុំ-សង្កាត់ ដូច្នេះអ្នកធ្វើការនៅឃុំ-សង្កាត់ មានចំនួនសរុប ៧៦%។

| ប្រភេទនៃអ្នកផ្តល់ចំលើយ | (N=301) |
|---|---|
| អាជ្ញាធរស្រុក | ១៣% |
| អាជ្ញាធរឃុំ-សង្កាត់ | ៤៦% |
| ប៉ូលីស (ថ្នាក់ខ្ពស់) | ២២% |
| ប៉ូលីស (ថ្នាក់ទាប) | ១៩% |

| អាយុ | (N=301) |
|---|---|
| ២០-២៤ | ១% |
| ២៥-២៩ | ១% |
| ៣០-៣៩ | ១៧% |
| ៤០ និងច្រើនជាងនេះ | ៨១% |

| តំបន់ | (N=301) |
|---|---|
| ទីប្រជុំជន | ២៤% |
| ជនបទ | ៦៨% |
| តំបន់ដាច់ស្រយាល | ៨% |

អ្នកផ្តល់ចំលើយទាំងនេះ ភាគច្រើនមកពីតំបន់ជនបទ និងនៅក្នុងក្រុមដែលមានអាយុច្រើន។ ចំនួនច្រើនជាង ៣ ភាគ ៤ មានអាយុចាប់ពី ៤០ ឆ្នាំឡើងទៅ។ អ្នកផ្តល់ចំលើយដែលមានអាយុតិចជាងនេះ ច្រើនតែជាមន្ត្រីប៉ូលីសថ្នាក់ទាប។ អ្នកផ្តល់ចំលើយភាគច្រើន គឺជាបុរស ទោះបីក្រុមនេះមានស្ត្រី ១២នាក់ក៏ដោយ។ ចំនួន ៨នាក់ក្នុងចំណោមស្ត្រីទាំង ១២ នាក់នេះ គឺជាអាជ្ញាធរឃុំ-សង្កាត់។

ទាក់ទងទៅនឹងកំរិតអប់រំសិក្សា អាជ្ញាធរមូលដ្ឋាន និងប៉ូលីស មានការសិក្សាតិចតួចបំផុត។ នៅក្នុងក្រុមនេះចំនួន ២៩% ពុំមានការសិក្សា ឬកំរិតសិក្សាថ្នាក់បឋមទេ។ ប៉ុន្តែ អាជ្ញាធរថ្នាក់ស្រុក មានការសិក្សាច្រើនបំផុត។ ចំនួន ៦៥%នៃអាជ្ញាធរទាំងនេះ មានកំរិតអប់រំនៅមធ្យមសិក្សា និង ២៨% បានសិក្សានៅសកលវិទ្យាល័យ។

| **តារាងអប់រំ** | (N=301) |
|---|---|
| ការសិក្សាក្រៅប្រព័ន្ធ | ១% |
| មួយចំនួននៅថ្នាក់បឋម ឬបានបញ្ចប់ការសិក្សាថ្នាក់បឋម | ២១% |
| មួយចំនួននៅមធ្យមសិក្សា ឬបានបញ្ចប់មធ្យមសិក្សា | ៧០% |
| សកលវិទ្យាល័យ | ៧% |

*កំរិតអប់រំសិក្សារបស់អជ្ញាធរមូលដ្ឋាន និងប៉ូលីស ដែលធ្វើការអង្កេត*

| **ប្រាក់ចំណូល** | (N=301) |
|---|---|
| $២០ ឬតិចជាង | ១% |
| $២១ - $៥០ | ១៧% |
| $៥១ - $១០០ | ៣០% |
| $១០១ - $២០០ | ៣៤% |
| ច្រើនជាង $២០០ | ១៨% |

*ប្រាក់ចំណូលរបស់អ្នកផ្តល់ចំលើយ*

ប្រាក់ចំណូលមានចាប់ពិចំនួនតិចជាង ២០ ដុល្លាក្នុងមួយខែ ទៅដល់ ជាង ២០០ ដុល្លាក្នុងមួយខែ។ អាជ្ញាធរថ្នាក់ស្រុក ហាក់ដូចជាមានចំនួនច្រើនជាងអ្នកប្រកបវិជ្ជាជីវៈដទៃទៀត ដែលរកបានប្រាក់ចំណូលច្រើនជាង ១០០ ដុល្លាក្នុងមួយខែ។

# ទិន្នន័យប្រជាសាស្ត្រ

ឥឡូវ សំណួរ ២ ៣ ចុងក្រោយអំពីខ្លួនអ្នក និងក្រុមគ្រួសារអ្នក ដើម្បីជួយយើងនៅក្នុងការវិភាគ

**D 1**

ស្ថានភាពគ្រួសារ?

| | |
|---|---|
| នៅលីវ | ១ |
| មានគូរស្រករហើយមានកូន | ២ |
| មានគូរស្រករហើយមិនទាន់មានកូន | ៣ |
| លែងគ្នា ឬ បែកគ្នា | ៤ |
| មេម៉ាយ ឬពោះម៉ាយ | ៥ |
| មិនព្រមឆ្លើយ (សូមកុំអាន) | ៩៨ |

**D 2**

តើអ្នកអាយុប៉ុន្មានហើយ?

**D 2a**

កត់ត្រាភេទ

| | |
|---|---|
| ប្រុស | ១ |
| ស្រី | ២ |

**D 3**

តើអ្នកមានកំរិតវប្បធម៌ខ្ពស់បំផុតដល់ថ្នាក់ណាដែរ ?

| | |
|---|---|
| មិនបានចូលរៀន | ១ |
| បានរៀនបឋមសិក្សា | ២ |
| បញ្ចប់បឋមសិក្សា | ៣ |
| បានរៀនមធ្យមសិក្សាកំរិត២ | ៤ |
| មេម៉ាយ ឬពោះម៉ាយ | ៥ |
| មិនព្រមឆ្លើយ (សូមកុំអាន) | ៩៨ |

**D 4**

តើអ្នកប្រកបមុខរបរអ្វី?
មុខរបរ: ____________
ប្រភេទទីកន្លែងធ្វើការ : ____________
មុខជំនាញ: ____________
ប្រសិនបើចូលនិវត្តន៍ មុខរបរកាលពីមុន: ____________
ប្រសិនបើកាន់កាប់ការងារផ្ទាល់ខ្លួន ឬអ្នកចាត់ចែងការងារ, តើអ្នកទទួលខុសត្រូវលើនិយោជិកប៉ុន្មាននាក់ ____________
ប្រសិនបើធ្វើការនៅក្រសួងស៊ីវិល ឬកងកំលាំងប្រដាប់អាវុធ តើអ្នកកាន់តំណែងអ្វី ឋានៈអ្វី ? ____________

**D 4a**

